ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

PHNOM PENH AUTONOMOUS PORT

កំពង់ផែស្វយ័តភ្នំពេញ

# របាយការណ៍ប្រចាំឆ្នាំ ២០១៨







# ANNUAL REPORT 2018

ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ
**Listed Company**







**Your Convenience and Efficiency Are Our Primary Concerns**

# របាយការណ៍
# ប្រចាំ ឆ្នាំ២០១៨
# របស់កំពង់ផែស្វយ័តភ្នំពេញ

# ទស្សនវិស័យ
# និងបេសកកម្ម

## ទស្សនវិស័យ

- ទស្សនវិស័យរបស់ ក.ស.ភ. គឺរក្សាភាពជាអ្នកគ្រប់គ្រងក្នុងអាជីវកម្មដឹកជញ្ជូនតាមដងទន្លេមេគង្គ និងដើរតួនាទីជាបណ្ដាញដឹកជញ្ជូនតាមផ្លូវទឹកប្រកបដោយប្រសិទ្ធភាព សមត្ថភាព និងតម្លាភាព ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយដៃគូពាណិជ្ជកម្មក្រៅប្រទេស។

## បេសកកម្ម

- បេសកកម្មរបស់ ក.ស.ភ. គឺគ្រប់គ្រង អភិវឌ្ឍ ធ្វើប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធផែ និងបម្រើ សេវាកម្មចម្បង និងសេវាកម្មពាក់ព័ន្ធដទៃទៀត ដើម្បីធានាឱ្យមាននិរន្តរភាពនៃការលូតលាស់ផ្នែកសេដ្ឋកិច្ច និងការរីកចម្រើនក្នុងសង្គមជាតិទាំងមូល។

## ១. ព័ត៌មានហិរញ្ញវត្ថុសង្ខេប ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប និងកម្មសិទ្ធិភាគហ៊ុនិកធម្មតា

### ១.១. ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | | ៣១ ធ្នូ ឆ្នាំ២០១៨ | ៣១ ធ្នូ ឆ្នាំ២០១៧ |
|---|---|---|---|
| **ស្ថានភាពហិរញ្ញវត្ថុ (ពាន់រៀល)** | | | |
| ទ្រព្យសកម្មសរុប | | ៧៥១.៨៨៦.៧០៥ | ៦៨០.៤៦០.៤៥៩ |
| បំណុលសរុប | | ១៨៥.៥០០.៥៧៧ | ១៤០.១៥៩.១៥០ |
| មូលធនសរុប | | ៥៦៦.៣៨៦.១២៨ | ៥៤០.៣០១.៣០៩ |
| **លទ្ធផលហិរញ្ញវត្ថុ (ពាន់រៀល)** | | | |
| ចំណូលសរុប | | ៨៣.៨២៤.២៤៤ | ៧៦.២៧៣.៧១៧ |
| ចំណេញមុនបង់ពន្ធ | | ៣១.០៧៤.៩២៥ | ២៥.០១២.១៩២ |
| ចំណេញសុទ្ធក្រោយបង់ពន្ធ | | ៣២.៧៦៧.៤៨៦ | ២១.៦៨៨.៦១៤ |
| **អនុបាតហិរញ្ញវត្ថុ** | | | |
| អនុបាតសាធនភាព (ភាគរយ) | | ២៤,២០ | ២៣,៧៥ |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត (ចំនួនដង) | ៤,៨៤ | ២,៨៦ |
| | អនុបាតចរន្តលឿន (ចំនួនដង) | ៤,៨៤ | ២,៨៦ |
| អនុបាតចំណេញភាព | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម (ភាគរយ) | ៤,៣៨ | ៣,១៧ |
| | ផលចំណេញក្នុងមួយឯកតាមូលធន (ភាគរយ) | ៥,៨១ | ៣,៩៩ |
| | គំលាតចំណេញដុល (ភាគរយ) | ៦៥,០៩ | ៦៥,៧៤ |
| | គំលាតចំណេញភាព (ភាគរយ) | ៣៩,២៧ | ២៨,២៩ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១.៥៩១,២៤ | ១.០៤៣,២១ |

## ១.២. ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨)






## ការបែងចែកប្រភេទចំណូលធៀបនឹងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្ម




## ប្រាក់ចំណេញសម្រាប់ឆ្នាំ ២០១៨ (ពាន់រៀល)



### ប្រាក់ចំណេញសម្រាប់ ឆ្នាំ២០១៨ ធៀបនឹងផែនការ ឆ្នាំ២០១៨ ( ពាន់រៀល )




### ប្រាក់ចំណេញតាមបណ្ដាឆ្នាំនីមួយៗ ចាប់ពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៨ និងផែនការឆ្នាំ២០១៨ (ពាន់រៀល)



## ១.៣. កម្មសិទ្ធិភាព ភាគហ៊ុនិកធម្មតា (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨)

| ភាគហ៊ុន | ចំនួនភាគហ៊ុន | កម្មសិទ្ធិភាព |
|---|---|---|
| ភាគហ៊ុនប្រភេទ("គ") | | |
| ១.រដ្ឋ តំណាងដោយ (ស.ហ.វ.) | ៩៣.៧៦៩.១២០ | ១០០% |
| ភាគហ៊ុនធម្មតា (ប្រភេទ "ខ") | | |
| ១. រដ្ឋ តំណាងដោយ (ស.ហ.វ.) | ១៦.៥៤៧.៤៩២ | ៨០% |
| ភាគហ៊ុនធម្មតា (ប្រភេទ "ក") | | |
| ១. ESOP | ២៧៣.០២៧ | ១,៣២% |
| ២. ភាគហ៊ុនិកឯកជន | ៣.៨៦៣.៨៤៦ | ១៨,៦៨% |
| សរុបភាគហ៊ុនធម្មតា(ប្រភេទ "ក") | ៤.១៣៦.៨៧៣ | ២០% |

** ភាគហ៊ុនធម្មតា សរុប (២០.៦៨៤.៣៦៥ភាគហ៊ុន)។*




តម្លៃជួញដូរភាគហ៊ុនជាមធ្យម (គិតជារៀល) និងបរិមាណជួញដូរជាមធ្យម (ភាគហ៊ុន) នៃភាគហ៊ុនប្រភេទ ក
៦០០០
៥៥០០
៥០០០
៤៥០០
៤០០០
៣៥០០
៣០០០
២៥០០
២០០០
១៥០០
១០០០
៥០០
០
៨០០០
៧០០០
៦០០០
៥០០០
៤០០០
៣០០០
២០០០
១០០០
០
៥១៣៤
៩៥២
៤១០២
៥៣៤០
៥២៩០
១៧៥៨
៥១៥៩
៥២៨៥
៥៤២៥
៤១៣
៥៥២៤
៥៤៦០
៥៣៩០
២៣៦
៥៤៧៨
៨០៣
៦០១៨
៤២៤
៦៣៨២
២៤៦
៦៤៣១
៧៤៦
៧៤៦៤
២៧៨៤
មករា
កុម្ភៈ
មីនា
មេសា
ឧសភា
មិថុនា
កក្កដា
សីហា
កញ្ញា
តុលា
វិច្ឆិកា
ធ្នូ
បរិមាណជួញដូរជាមធ្យម (ភាគហ៊ុន)
តម្លៃជួញដូរជាមធ្យម

## ២. សមាសភាពក្រុមប្រឹក្សាភិបាល



ឯកឧត្តម ហ៊ី បាវី
ប្រធានក្រុមប្រឹក្សាភិបាល
និងជាអគ្គនាយក គ.ស.ភ.



ឯកឧត្តម សួន រចនា
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន



ឯកឧត្តម កែន សម្បត្តិ
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ឯកឧត្តម ប៉ែន សុវិជាតិ
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងពាណិជ្ជកម្ម



លោក ហ្គី អានវ៉ានិច
សមាជិកក្រុមប្រឹក្សាភិបាល
អភិបាលឯករាជ្យ



លោក ឱត សុចល
សមាជិកក្រុមប្រឹក្សាភិបាល
អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន



លោកស្រី ជួន សុខេម
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងនិយោជិត គ.ស.ភ.

## ៣. សេចក្តីថ្លែងរបស់អគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល

សម្រាប់ការអនុវត្ត ឆ្នាំ២០១៨ ចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មមានចំនួន ៨៣.៨២៨.២៨៨ ពាន់រៀល (២០.៧២២.៩២៨ដុល្លារអាមេរិក) សម្រេចបាន ៩៩,៧៧% នៃការគ្រោងផែនការឆ្នាំ២០១៨ បើធៀបនឹងការអនុវត្តឆ្នាំ២០១៧ កើនឡើងចំនួន ៧.៥៥០.៥២៧ពាន់រៀល (១.៨៦៦.៦៣២ដុល្លារអាមេរិក) ឬស្មើនឹង ៩,៩០%។ ចំណែកប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទមានសរុបចំនួន ៣២.៧៦៧.៨៨៦ពាន់រៀល (៨.១០០.៧៣៨ដុល្លារអាមេរិក) សម្រេចបាន ១៣៧,៩១% នៃការគ្រោងផែនការឆ្នាំ២០១៨ និងធៀបនឹងឆ្នាំ២០១៧ កើនឡើងចំនួន ១១.០៧៨.៨៧២ពាន់រៀល (២.៧៣៨.៩០៥ដុល្លារអាមេរិក) ឬស្មើនឹង ៥១,០៨%។ ដោយឡែក ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិក្នុងឆ្នាំ២០១៨ (basic earnings per share) គឺចំនួន ១.៥៩១,២៨រៀល (០,៣៩ ដុល្លារអាមេរិក) ។

សមិទ្ធិផលខាងលើអាស្រ័យដោយ ក. ស. ភ. តែងប្រកាន់ភ្ជាប់នូវការយកចិត្តទុកដាក់ក្នុងការបម្រើសេវាកម្មប្រតិបត្តិការផែជូនអតិថិជនប្រកបដោយតម្លាភាព និងភាពឆាប់រហ័ស ដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាព និងទំនុកចិត្តខ្ពស់ចំពោះតម្រូវការរបស់អតិថិជន។ ជាក់ស្តែង ក.ស.ភ. បានប្រើប្រាស់គ្រប់យន្តការតាមរយៈការពង្រឹងគុណភាពសេវាកម្ម ការពង្រីកសមត្ថភាពលើកដាក់ និងផ្ទេរផ្ទុក ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការជួសជុលថែទាំ ការងារជលធារសាស្ត្រ និងការងារបំពាក់គ្រឿងចក្រ និងឧបករណ៍ថ្មីៗជាដើម។

### ៣.១. ទិសដៅការងារអនុវត្តចម្បងរបស់ ក.ស.ភ.

- បន្តអនុវត្តផែនការសកម្មភាពការងារតាមផែនការដែលបានគ្រោងទុកសម្រាប់ ឆ្នាំ២០១៩
- ធានាគុណភាព តម្លៃ តម្លាភាព ប្រសិទ្ធភាព និងភាពឆាប់រហ័ស នៃការផ្តល់សេវាកម្មជូនអតិថិជន
- ពង្រីកសេវាកម្ម និងអាជីវកម្មដែលមានស្រាប់ ឱ្យមានលក្ខណៈកាន់តែទូលំទូលាយ និងបង្កើតឱ្យមានសេវាកម្មថ្មីបន្ថែមទៀតដែលពាក់ព័ន្ធនឹងវិស័យកំពង់ផែ និងភ័ស្តុភារកម្ម
- ពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គលិក ដើម្បីឆ្លើយតបនឹងការវិវឌ្ឍរបស់អង្គភាពស្របទៅនឹងការផ្លាស់ប្តូរចរន្តភាវូបនីយកម្ម និងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព
- ពង្រឹងកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រ ជាមួយបណ្តាកំពង់ផែក្នុងតំបន់ និងបណ្តាកំពង់ផែដទៃទៀតនៅលើពិភពលោក
- បង្កើនឧត្តមភាពប្រកួតប្រជែងដោយស្មោះត្រង់ ជាមួយកំពង់ផែក្នុង និងក្រៅប្រទេស
- ខិតខំ និងបន្តផ្តោតការយកចិត្តទុកដាក់លើការធ្វើទំនើបកម្មប្រតិបត្តិការផែ ឱ្យស្របតាមស្តង់ដារ និងប្រព័ន្ធបច្ចេកវិទ្យា
- ចូលរួមក្នុងសកម្មភាពសង្គម និងសហគមន៍មូលដ្ឋាន។

### ៣.២. ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល

សម្រាប់ឆ្នាំ២០១៨ ក. ស. ភ. បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលចំនួន ៥លើក ដូចខាងក្រោម៖

*១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី៩ អាណត្តិទី៦ ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨*

- បានពិនិត្យ និងទទួលស្គាល់នូវរបាយការណ៍ស្តីពីលទ្ធផលបឋមផ្នែកអាជីវកម្ម និងហិរញ្ញវត្ថុ ឆ្នាំ២០១៧ របស់ ក. ស. ក.
- បានពិនិត្យ និងសម្រេចឱ្យ ក. ស. ក. ធ្វើកិច្ចសហការជាមួយក្រុមហ៊ុន KTC International Co., Ltd. ក្រោមទម្រង់ជាការផ្តល់អចលនទ្រព្យ និងគ្រឿងចក្រវិញ ជំនួសឱ្យការចូលទុនធ្វើអាជីវកម្មរួមគ្នា
- បានពិនិត្យ និងសម្រេចឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន ខ្ចីថវិការបស់ ក. ស. ក. ដើម្បីទិញកាណូតដឹកអ្នកដំណើរតាមផ្លូវទឹក Taxi Boat ចំនួន ២ គ្រឿង ហើយក្រសួងនឹងប្រគល់កាណូតទាំង ២ គ្រឿងនេះ ឱ្យនាយកដ្ឋានណាមួយ ឬអង្គភាពណាមួយក្រោមចំណុះក្រសួង ជាអ្នកធ្វើប្រតិបត្តិការសេវាដឹកអ្នកដំណើរតាមផ្លូវទឹកនេះ។ ក្រសួងនឹងសងត្រឡប់មកឱ្យ ក. ស. ក. នូវកម្ចីខាងលើជាក្រោយវិញ។
- បានពិនិត្យ និងសម្រេចឱ្យ ក. ស. ក. បន្តធ្វើការសហការជាមួយក្រុមហ៊ុន ហ្គ្រីន ត្រេដ (Green Trade) លើការបង្កើតរោងចក្រកែច្នៃស្រូវ-អង្ករ នៅចំណតផែកុងតឺន័រ LM១៧
- បានពិនិត្យ និងអនុញ្ញាតជាគោលការណ៍ឱ្យ ក. ស. ក. ស្នើសុំអាជ្ញាបណ្ណពីក្រសួងរ៉ែ និងថាមពល មុននឹងចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU) ជាមួយក្រុមហ៊ុន Infunde Development Pte. Ltd. លើគម្រោងផ្គត់ផ្គង់ថាមពលអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ (Solar Power) នៅចំណតផែកុងតឺន័រ LM១៧។

### ២. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១០ អាណត្តិទី៦ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨

- បានសម្រេចអនុម័តរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទ២០១៧ ដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ KPMG
- បានពិភាក្សា និងសម្រេចលើការកំណត់ប្រាក់ថ្លែងសរសើរជូនថ្នាក់ដឹកនាំ និងនិយោជិត ក. ស. ក. ប្រចាំឆ្នាំ២០១៧ ចំនួន ៣ខែ នៃប្រាក់បៀវត្សសរុបជាមធ្យមប្រចាំឆ្នាំ និងការបែងចែកប្រាក់ចំណេញចូលមូលនិធិនានាសម្រាប់ឆ្នាំ២០១៧
- បានពិភាក្សា និងសម្រេចលើការបែងចែកភាគលាភជូនភាគហ៊ុនិករបស់ ក. ស. ក. ប្រចាំឆ្នាំ២០១៧ និងការផ្ទេរចូលមូលនិធិអភិវឌ្ឍន៍សហគ្រាស ដូចខាងក្រោម៖

ក).បែងចែកភាគលាភជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" ចំនួន ៦% នៃថ្លៃ IPO ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

- ប្រភេទភាគលាភដែលត្រូវបែងចែក (Type of Dividend): ជាសាច់ប្រាក់
- រយៈពេលភាគលាភ (Period of dividend): ប្រចាំឆ្នាំ២០១៧
- អនុបាត នៃការបែងចែកភាគលាភ (Dividend Payout Ratio ): ៥.៨៦%
- ភាគលាភសរុបដែលត្រូវបែងចែក (Total Dividend): ៦.២៧០.៨៤៧.៣៨៦ រៀល
- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (Dividend per Share): ៣០៧ រៀល

- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគលាភដែលត្រូវទទួលបានភាគលាភ (Record Date): ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨
- កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date): ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨។

ខ).បែងចែកភាគលាភជូនភាគហ៊ុនិកប្រភេទ "ខ" (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ទឹកប្រាក់ចំនួន ២.២៥២.៧០៨ ពាន់រៀល (ពីរប៊ីលាន ពីររយសែសិបពីរលាន ប្រាំពីររយប្រាំបីពាន់រៀលគត់)។

គ).ផ្ទេរចូលក្នុងមូលនិធិអភិវឌ្ឍន៍សហគ្រាសចំនួន ៨២% ដែលមានទឹកប្រាក់ចំនួន ១៦.០០៦.១៩៧ ពាន់រៀល (ស្មើនឹង ៣.៩៥៧.០៣២ ដុល្លារអាមេរិក)។

- បានពិភាក្សា និងសម្រេចលើការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៣ ឆ្នាំ២០១៨ របស់ ក. ស. ភ. ដូចខាងក្រោម៖
  - កាលបរិច្ឆេទប្រារព្ធមហាសន្និបាតភាគហ៊ុនិកលើកទី៣: ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៨
  - កាលបរិច្ឆេទកំណត់ទុក (Record Date): ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨
  - ទីកន្លែងនៃមហាសន្និបាតភាគហ៊ុនិកលើកទី៣: សាលប្រជុំជាន់ទី៣ នៃអគាររដ្ឋបាលទីស្នាក់ការកណ្តាល (ចំណតផែថ្មTS៣) ដែលមានអាសយដ្ឋាន ស្ថិតនៅអគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
  - របៀបវារៈ នៃមហាសន្និបាតភាគហ៊ុនិកលើកទី៣ គឺរបាយការណ៍ស្តីពីលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងទិសដៅការងារអនុវត្តបន្តឆ្នាំ២០១៨។
- បានសម្រេចអនុម័តកិច្ចសន្យារវាង ក. ស. ភ. និងក្រុមហ៊ុន SYC CO., LTD. ស្តីពីការផ្តល់សេវាកម្មដឹកជញ្ជូន
- បានសម្រេចយល់ព្រមផ្ទេរសិទ្ធិឱ្យទៅអគ្គនាយក រួមនឹងប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ ចុះហត្ថលេខាបញ្ជាក់លើរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆ្នាំ ដោយអនុវត្តចាប់ពីឆ្នាំ២០១៨ នេះតទៅ
- បានសម្រេចអនុញ្ញាតឱ្យ ក. ស. ភ. ធ្វើលិខិតស្នើសុំការលើកលែងការពិន័យ និងការពន្យាកិច្ចផ្សេងៗទៅក្រសួងរ៉ែ និងថាមពល
- បានយល់ព្រមឱ្យ ក. ស. ភ. លើកគម្រោងបន្ថែមសម្រាប់សាងសង់ទីលានផ្ទុកកុងតឺន័រត្រជាក់បន្ថែមលើគម្រោងសាងសង់ទីលានដំហានទី២ នៅចំណតផែកុងតឺន័រ LM១៧ ដែលនឹងកំពុងដំណើរការសាងសង់ ដោយត្រូវអនុវត្តការងារតាមនីតិវិធីច្បាប់ជាធរមាន។

### *៣. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១១ អាណត្តិទី៦ កាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៨*

- បានពិនិត្យ និងសម្រេចអនុម័តរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្មរយៈពេល ៥ខែ ដើមឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុរយៈពេល ៤ខែ ដើមឆ្នាំ២០១៨ របស់ ក. ស. ភ.

- បានពិនិត្យ និងសម្រេចឱ្យ ក.ស.ក. ធ្វើការកែសម្រួលខ្លឹមសារនៃសេចក្តីព្រាងកិច្ចសន្យាស្តីពីការជួលដីរបស់កំពង់ផែស្វយ័តភ្នំពេញ ពីគល់ស្ពានជ្រោយចង្វារ មកដល់ផ្សាររាត្រីឱ្យទៅក្រុមហ៊ុន ធៀន ឈើង ថៃ គ្រុប រួចស្នើសុំការពិនិត្យ និងសម្រេចពីក្រសួងអាណាព្យាបាលទាំងពីរ
- បានពិនិត្យ និងសម្រេចទទួលស្គាល់ខ្ទង់ចំណាយរបស់ ក. ស. ក. លើការផ្គត់ផ្គង់ប្រេង និងការថែទាំកាណូតដឹកអ្នកដំណើរតាមផ្លូវទឹក (Taxi Boat) និងសម្រេចឱ្យ ក. ស. ក. ធ្វើរបាយការណ៍បូកសរុបចំណាយជូនទៅក្រសួងសាធារណការ និងដឹកជញ្ជូន នៅពេលមានការប្រគល់ទទួលពីក្រសួងសាធារណការ និងដឹកជញ្ជូន ឱ្យទៅរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីមានមូលដ្ឋានក្នុងការស្នើសុំការទូទាត់ត្រឡប់មក ក. ស. ក. វិញ
- បានពិនិត្យ និងសម្រេចឱ្យ ក. ស. ក. ឧបត្ថម្ភថវិកាចំនួន ១០០ លានរៀល ដល់ "មូលនិធិគន្ធៈបុប្ផាកម្ពុជា" សម្រាប់ឆ្នាំ២០១៨ និងបានអនុញ្ញាតជាគោលការណ៍ឱ្យ ក. ស. ក. បន្តផ្តល់ការឧបត្ថម្ភគាំទ្រដល់មូលនិធិគន្ធៈបុប្ផាកម្ពុជា និងកាកបាទក្រហមកម្ពុជា នៅឆ្នាំបន្តបន្ទាប់ខាងមុខទៀត
- បានពិនិត្យ និងសម្រេចតែងតាំងលោកស្រី ជួន សុខេម ជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ ជំនួសលោក តោ នី ដែលបានចូលនិវត្តន៍
- បានពិនិត្យ និងសម្រេចឯកភាពឱ្យ ក. ស. ក. ទិញដីបន្ថែម ចំនួន ២ ហិកតា សម្រាប់ត្រៀមបម្រុងក្នុងការពង្រីកហេដ្ឋារចនាសម្ព័ន្ធ នៃចំណតផែកុងតឺន័រ LM១៧ នៅថ្ងៃខាងមុខ ដោយត្រូវអនុវត្តតាមនីតិវិធីនៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- បានពិនិត្យ និងសម្រេចអនុញ្ញាតជាគោលការណ៍ឱ្យ ក. ស. ក. ធ្វើការសិក្សាពីផលសេដ្ឋកិច្ច និងតម្លៃជួលដីឃ្លាំងក្រុមហ៊ុន ហ្វ្រ៊ីន ត្រេដ ទំហំ ៧.៥៤៣,៦៨ ម៉ែត្រក្រឡា ជាមុនសិន រួចដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចលើលទ្ធផលនៃការសិក្សានាពេលក្រោយ។

*៧.កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១២ អាណត្តិទី៦ នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨*

- បានពិនិត្យ និងសម្រេចអនុម័តរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម សម្រាប់រយៈពេល ៨ខែ ដើមឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុប៉ាន់ស្មាន (មិនទាន់ធ្វើសវនកម្ម) សម្រាប់រយៈពេល ៧ខែ ដើមឆ្នាំ២០១៨ របស់ ក. ស. ក.
- បានពិនិត្យ និងសម្រេចឱ្យ ក. ស. ក. ស្នើសុំការអនុញ្ញាតពីក្រសួងអាណាព្យាបាលទាំងពីរ (ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ដើម្បីលុបបំណុលសេវាវាស់ស្ទង់ដែលក្រសួងរ៉ែ និងថាមពល នៅជំពាក់ ក. ស. ក. ចំនួន USD ៥៣.៥៨៨,១០ (ហាសិបបីពាន់ប្រាំរយប៉ែតសិបប្រាំបីដុល្លារអាមេរិក និងដប់សេន)
- បានពិនិត្យ និងទទួលជ្រាបអំពីការធ្វើវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឱ្យទៅក្រុមហ៊ុន យុនណាន សេងមៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក លើទីតាំងដីទីលានស្តុកសំបកកុងតឺន័រ (ICD) ដែលបានជួលឱ្យក្រុមហ៊ុន ដើម្បីអភិវឌ្ឍជា "មជ្ឈមណ្ឌលពាណិជ្ជកម្ម Triumph កម្ពុជា" សម្រាប់ឱ្យក្រុមហ៊ុនប្រើប្រាស់ក្នុងគោលបំណងស្របតាមផ្លូវច្បាប់

- បានពិនិត្យ និងសម្រេចឱ្យ ក. ស. ភ. ៖
  - សម្របសម្រួលជាមួយជាមួយភាគីក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប ដោះស្រាយបញ្ហានានា ដែលនៅសេសសល់
  - លើកសំណើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលយកសំណូមពរលើការស្នើសុំពន្យារពេលក្នុងការបង់ប្រាក់ឈ្នួលរបស់ក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប
  - ធ្វើរបាយការណ៍មួយជូនទៅក្រសួងអាណាព្យាបាលទាំងពីរ អំពីការដោះស្រាយផលប៉ះពាល់ ពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍ "មជ្ឈមណ្ឌលពាណិជ្ជកម្មធំរុះ THE CITY GATE"
- បានពិនិត្យ និងសម្រេចឱ្យ ក. ស. ភ. លើកសំណើសុំធ្វើការរុះរើ ឬផ្លាស់ប្តូរទៅទីតាំងថ្មីនូវអគារ ឬឃ្លាំង នៅលើទីតាំងទាំង ៣ កន្លែង របស់ ក. ស. ភ. ដូចជានៅទីតាំងដី ICD, ចំណតផែកុងតឺន័រ LM១៧, នៅទីតាំងដី ក. ស. ភ. ពីតស់ស្ពានប្រោយចង្វារ ដល់ផ្សាររាត្រី ជាកញ្ចប់ទៅក្រសួងអាណាព្យាបាលទាំងពីរ ដើម្បីស្នើសុំបង្កើតគណៈកម្មការចុះពិនិត្យ និងវាយតម្លៃសំណង់អគារ ឬឃ្លាំង ដែលមានក្នុងបញ្ជីសារពើភ័ណ្ឌរបស់ ក. ស. ភ. មុននឹងធ្វើការរុះរើ ឬវាយកំទេចចោល
- បានពិនិត្យ និងសម្រេចឱ្យ ក. ស. ភ. ស្នើសុំការបំភ្លឺពីមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ លើការគិតពន្ធប្រភេទផ្សេងៗ នៃកញ្ចប់ថវិកាដែលទទួលបានពីការជួលដីឱ្យទៅក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប មុននឹងមានវិធានការជាក្រោយ
- បានពិនិត្យ និងសម្រេចទុកការស្នើនូវភាគលាភពិសេសពីសំណាក់ភាគហ៊ុនិកឯកជន ស្ថិតនៅក្នុងការពិចារណាជាក្រោយទៀត ដោយរង់ចាំពិនិត្យមើលលទ្ធផលអាជីវកម្មនាបំណាច់ឆ្នាំ២០១៨ របស់ ក. ស. ភ. ក្រោយពីការបិទបញ្ជី និងធ្វើសវនកម្មរួចដោយសវនករឯករាជ្យ
- បានពិនិត្យ និងអនុញ្ញាតឱ្យ ក. ស. ភ. ពិនិត្យ និងចរចាអំពីតម្លៃជួលដីជាមួយក្រុមហ៊ុន ហ្វ្រើន គ្រេដ ឱ្យបានសមស្របដោយគោរពទៅតាមនីតិវិធី នៃបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន រួចលើកសំណើសុំការអនុញ្ញាតជួលទីតាំងដីខាងលើនេះ ពីក្រសួងអាណាព្យាបាលបច្ចេកទេស (ក្រសួងសាធារណការ និងដឹកជញ្ជូន) និងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

### ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៣ អាណត្តិទី៦ នាថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨

- បានពិនិត្យ និងអនុម័តលើរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម សម្រាប់រយៈពេល ១១ខែ ដើមឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុ សម្រាប់រយៈពេល ១០ខែ ដើមឆ្នាំ២០១៨ របស់ ក. ស. ភ.
- បានពិនិត្យ និងអនុម័តផែនការអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ឆ្នាំ២០១៩ របស់ ក. ស. ភ.
- បានពិភាក្សា និងសម្រេចស្នើឱ្យ ក. ស. ភ. សហការជាមួយភាគីគូរ៉េ ធ្វើការសិក្សាលម្អិតបន្ថែមអំពីផលសេដ្ឋកិច្ច, Return on Investment សម្រាប់ ក. ស. ភ. ផ្ទាល់ និងអំពីរយៈពេលដែល ក. ស. ភ. អាចមានលទ្ធភាពទទួលបានផលចំណេញពីគម្រោងនេះត្រលប់មកវិញជាមុន មុននឹងធ្វើការ

ពិចារណាលើការស្នើសុំគណទានសម្បទានពិសាធារណរដ្ឋកូរ៉េ ជាក្រោយ ហើយស្នើឱ្យ ក. ស. ភ. ធ្វើលិខិតផ្លូវការមួយទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនដំណឹងទៅភាគីកូរ៉េអំពីការសម្រេចនេះ

- បានពិនិត្យ ពិភាក្សា និងឯកភាពលើតម្លៃជួលដីជាមួយក្រុមហ៊ុនប្រ៊្វីន គ្រេដ ដើម្បីបង្កើតជាចំណតផែស្ងួត និងសម្រាប់ផ្តល់សេវាកម្មពាក់ព័ន្ធនឹងឡូជីស្ទីក ពាណិជ្ជកម្ម ឧស្សាហកម្ម និងទេសចរណ៍ និងស្នើឱ្យ ក. ស. ភ. លើកសំណើទាំងអស់នេះ ជូនក្រសួងអាណាព្យាបាលទាំងពីរ ដើម្បីសុំការសម្រេចយល់ព្រម
- បានពិនិត្យ ពិភាក្សា និងឯកភាពសម្រេចលើការបោះឆ្នោតជ្រើសតាំង និងជ្រើសរើសសមាសភាពនៃក្រុមប្រឹក្សាភិបាល អាណត្តិទី៧ ដូចខាងក្រោម÷
  - សម្រាប់អភិបាលជាតំណាងនិយោជិត, អភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ក. ស. ភ. នឹងរៀបចំការបោះឆ្នោតជ្រើសតាំងផ្អែកតាមបែបបទ និងនីតិវិធី ដែលបានកំណត់
  - សម្រាប់អភិបាលផ្សេងទៀត តំណាងមកពីក្រសួងពាក់ព័ន្ធដូចជា ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និងក្រសួងពាណិជ្ជកម្ម ក. ស. ភ. នឹងស្នើទៅក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីគោរពស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល លើការរក្សាទុកសមាសភាពដដែល ក្នុងអាណត្តិទី៧ នៃក្រុមប្រឹក្សាភិបាលរបស់ ក. ស. ភ.។
  - ចំពោះការចូលកាន់ដំណែងរបស់សមាជិកនៃក្រុមប្រឹក្សាភិបាលអាណត្តិទី៧, កំណត់យកកាលបរិច្ឆេទនៃការតែងតាំងក្រុមប្រឹក្សាភិបាលអាណត្តិទី៧ ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល គឺជាពេលវេលានៃការចូលកាន់តំណែងរបស់សមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី៧ ដើម្បីបង្កលក្ខណៈងាយស្រួល ក្នុងដំណើការរៀបចំការបោះឆ្នោតជ្រើសតាំង និងការរៀបចំស្នើតែងតាំងក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិបន្តបន្ទាប់ទៀត។
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យក្រុមហ៊ុន យុនណាន សេងម៉ៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក ប្តូរឈ្មោះគម្រោងពី "មជ្ឈមណ្ឌលផ្គត់ផ្គង់គ្រឿងសំណង់ CMSC" ទៅជា "មជ្ឈមណ្ឌលពាណិជ្ជកម្ម Triumph កម្ពុជា" វិញ ដោយ ក. ស. ភ. ត្រូវស្នើសុំការសម្រេចពីក្រសួងអាណាព្យាបាលទាំងពីរជាបន្តទៀត។

## ៣.៣. ការកំណត់ទិសដៅសម្រាប់ ឆ្នាំ២០១៩

ទស្សនវិស័យទៅអនាគត ក.ស.ភ. នឹងកំណត់ទិសដៅសម្រាប់អនុវត្តរួមមាន៖

- បន្តពង្រឹងការអភិវឌ្ឍធនធានមនុស្ស
- បន្តជំរុញការបង្កើតមជ្ឈមណ្ឌលភស្តុភារកម្ម ឃ្លាំងទំនើប និងឃ្លាំងត្រជាក់
- បន្តជំរុញការបង្កើតតំបន់គាំទ្រកំពង់ផែ
- បន្តជំរុញការបង្កើតសេវាកម្ម Line ទៅកាន់ផែមេដទៃ ក្រៅពីផៃកៃម៉េប
- បន្តជំរុញការនាំចូលទំនិញដែលប្រើប្រាស់រួចមួយទឹក (ទំនិញជជុះ) តាមរយៈ ក.ស.ភ.
- បន្តយកចិត្តទុកដាក់លើការបំពាក់គ្រឿងចក្រលើកដាក់ទំនើបៗ នៅចំណតផែកុងតឺន័រLM១៧
- បន្តពង្រឹងសមត្ថភាពលើកដាក់ទំនិញចាក់ធារ និងបង្កើតចំណតផែសម្រាប់ទំនិញចាក់ធារ

- ធ្វើទំនើបកម្ម និងពង្រីកចំណតផែអ្នកដំណើរ និងទេសចរ (TS១)
- បន្តជម្រុញបង្កើតចំណតផែពហុបំណងតាមដងទន្លេបន្ថែមទៀត
- បន្តពង្រឹងសមត្ថភាពលើកដាក់ទំនិញកសិកម្ម តាមចំណតផែនៃបណ្តាខេត្តផ្នែកខាងលើនៃទន្លេមេគង្គ
- ថែទាំផ្លូវនាវាចរណ៍ និងធ្វើការបូមស្តារទីតាំងប្រឡាយស្តៅ សម្រួលការដឹកជញ្ជូនទំនិញ រវាងខេត្តនានានៅតាមភូមិភាគឦសាន មកភ្នំពេញតាមទន្លេមេគង្គ និងតាមព្រំប្រទល់កម្ពុជា-វៀតណាម។

ក.ស.ភ. មានជំនឿចិត្ត និងគោលជំហរយ៉ាងមុតមាំក្នុងការអនុវត្តការងារប្រចាំថ្ងៃ និងប្រតិបត្តិការនៅតាមបណ្តាចំណតផែនានា ឱ្យមានតម្លាភាព ឱ្យមានភាពឆាប់រហ័ស ដើម្បីបង្កើននូវទំនុកចិត្ត និងការទាក់ទាញ នៃការផ្តល់សេវាកំពង់ផែប្រកបដោយស្តង់ដារជូនដល់អតិថិជន។

ក.ស.ភ. សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រសួងអាណាព្យាបាលទាំងពីរ គឺក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងភាគហ៊ុនិកទាំងអស់ ដែលជានិច្ចជាកាល តែងតែគាំទ្រ និងទុកចិត្តដល់សកម្មភាពការងាររបស់ ក.ស.ភ. រៀងរហូតមក។

ថ្ងៃសុក្រ ៨ រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០១៩

**ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក**

ហ៊ី_បាវី

# មាតិកា

ទស្សនវិស័យ និងបេសកកម្ម
១-ព័ត៌មានហិរញ្ញវត្ថុសង្ខេប ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប និងកម្មសិទ្ធិភាពភាគហ៊ុនិកធម្មតា iii
២-សមាសភាពក្រុមប្រឹក្សាភិបាល ix
៣-សេចក្តីថ្លែងរបស់អគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល x
**ផ្នែកទី១ : ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលបោះផ្សាយ ១**
១-ព័ត៌មានទូទៅអំពីកំពង់ផែស្វយ័តភ្នំពេញ ២
២-ដំណើរការធុរកិច្ចសង្ខេប ២
៣-ស្ថានភាពទីផ្សារ ៧
៤-ស្ថានភាពប្រកួតប្រជែង ១២
៥-ផែនការអនាគតសម្រាប់ ឆ្នាំ២០១៩ ១៤
**ផ្នែកទី ២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ១៦**
១-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែកសម្រាប់ ឆ្នាំ២០១៨ ១៧
២-ការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច ២២
៣-រចនាសម្ព័ន្ធចំណូល ២៤
**ផ្នែក ៣ : អភិបាលកិច្ចសាជីវកម្ម ២៥**
១-ភាគហ៊ុនិក ២៦
២-អង្គការលេខ ៣៣
៣-ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា ៣៤
៤-បុគ្គលិកជាន់ខ្ពស់ ៤៨
៥-ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់ ៧១
៦-លាភការ ឬប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ៧២
៧-ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ៧៥
៨-សិទ្ធិភាគីពាក់ព័ន្ធ ៨០
**ផ្នែកទី ៤ : បញ្ជីរាយនាមភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់ និង ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ៨១**
១-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ៨២
២-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតចំនួនច្រើន ៨២
**ផ្នែកទី ៥ : ព័ត៌មានអំពីការជួញដូរមូលបត្ររបស់ ក.ស.ភ. ៨៣**
១-ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ ៨៤
២-ថ្លៃ និងបរិមាណជួញដូរ ៨៤

**ផ្នែកទី ៦ : របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង** ៨៥
**ផ្នែកទី៧ : របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ** ១១៣
**ផ្នែកទី៨ : ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ** ១៧១
១-ប្រតិបត្តិការជាមួយភាគហ៊ុនិក ១៧២
២-ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់មានផលប្រយោជន៍ ១៧២
៣-ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ១៧២
៤-ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ ក.ស.ភ. ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ ក.ស.ភ. ដែលមានទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលធ្វើឡើងដោយ ក.ស.ភ. ១៧២
៥-ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលក្នុងរយៈពេល ២ឆ្នាំ ចុងក្រោយ ១៧៣
៦-ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈ សម្រាប់សេវាដែលខ្លួនបានផ្តល់តាមរយៈក្រុមហ៊ុនណាមួយដល់ ក.ស.ភ. ១៧៣
៧-ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធផ្សេងទៀត ១៧៣
**ផ្នែកទី ៩ : ការវិភាគរបស់ថ្នាក់ដឹកនាំ** ១៧៤
១-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ១៧៥
២-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ១៨៤
៣-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ១៨៧
៤-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ១៨៧
៥-ផលប៉ះពាល់ពីអតិផរណា ១៨៨
៦-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រដ្ឋាភិបាល ១៨៨
**ផ្នែកទី ១០ : ស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលអាជីវកម្ម របស់ ក.ស.ភ.** ១៩០
**ផ្នែកទី ១១ : ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន** ១៩២

# ផ្នែកទី១
# ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលបោះផ្សាយ

## ១. ព័ត៌មានទូទៅអំពីកំពង់ផែស្វយ័តភ្នំពេញ

ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ : **កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.)**

ជាអក្សរឡាតាំង : **PHNOM PENH AUTONOMOUS PORT (PPAP)**

- អក្សរកូដ : **KH1000040001**
- អាសយដ្ឋាន : **អគារលេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
- លេខទូរស័ព្ទ : **+៨៥៥ (0) ២៣ ៤២៧ ៨០២** លេខទូរសារ : **+៨៥៥ (0) ២៣ ៤២៧ ៨០២**
- គេហទំព័រ : **www.ppap.com.kh** អ៊ីម៉ែល : **ppapmpwt@online.com.kh**
- លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម : **CO.៧១៧៤ Et/២០០៤**
  កាលបរិច្ឆេទ : **២៣/វិច្ឆិកា/២០០៤**
- លេខអាជ្ញាបណ្ណអាជីវកម្ម : **០១២៧ ពណ.ចប**
  កាលបរិច្ឆេទ : **០៥/មករា/២០១៥**
- សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន លេខ : **០៧៤/១៥/គ.ម.ក./ស.ស.រ**
  ឈ្មោះបុគ្គលតំណាងបុគ្គលបោះផ្សាយ : **ឯកឧត្តម ហ៊ី បាវី**

## ២. ដំណើរការធុរកិច្ចសង្ខេប

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) គឺជាកំពង់ផែអន្តរជាតិមួយក្នុងចំណោមផែអន្តរជាតិទាំងពីររបស់ប្រទេសកម្ពុជា ដែលបម្រើសេវានាំចូល នាំចេញកុងតឺន័រ និងទំនិញទូទៅ។ ដូចនេះ ក្នុងនាមជាប្រតិបត្តិករផែ និងអាជ្ញាធរផែ ក.ស.ភ. កំពុងផ្តល់សេវាកម្មផែចម្បងៗ និងសេវាកម្មពាក់ព័ន្ធសំខាន់ដទៃទៀតដែលជាដំណើរការធុរកិច្ចរបស់ ក.ស.ភ.។

### *ក. ប្រតិបត្តិការក្នុងនាមជាប្រតិបត្តិករផែ*

ក្នុងនាមជាប្រតិបត្តិករផែ ក.ស.ភ. មានភារកិច្ចបម្រើសេវាសំខាន់ៗ រួមមាន ៖

- ផ្តល់សេវាលើកដាក់ទំនិញ ការស្តុកទំនិញ ការច្រកនិងរើទំនិញ ការផ្ទេរនិងផ្ទុក និងការដឹកជញ្ជូនទំនិញកុងតឺន័រ សម្រាប់ការនាំចេញ និងនាំចូលទំនិញឆ្លងប្រទេស
- ផ្តល់សេវាកណ្តាធារកិច្ច នាំនាវាចេញ-ចូល
- ផ្តល់សេវាចំណតផែអ្នកដំណើរ និងទេសចរ TS១
- សេវាកម្មនាវាសណ្តោង សេវាកម្មចង/ដោះពួរនាវា។

### *ខ. ប្រតិបត្តិការក្នុងនាមជាអាជ្ញាធរផែ*

ក្នុងនាមជាអាជ្ញាធរផែ ក.ស.ភ. មានតួនាទី៖

- ថែទាំផ្លូវនាវាចរណ៍ បំពាក់ឧបករណ៍ជំនួយដល់ការធ្វើនាវាចរណ៍ ដូចជាពោងសញ្ញា និងបង្គោលសញ្ញាសម្គាល់ទិសនាវាចរណ៍ រៀបចំការចូលចតនាវា និងថែរក្សាបរិស្ថានក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ
- ចាត់វិធានការធានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធវិស័យកំពង់ផែ និងការដឹកជញ្ជូននានាតាមផ្លូវទឹក។

### *គ. សេវាកម្ម/អាជីវកម្ម ផ្សេងទៀត*

ជាមួយនឹងការផ្តល់សេវាកម្មស្នូលលើការងារប្រតិបត្តិផែ និងអាជ្ញាធរផែ ក.ស.ភ. ក៏មានសេវាកម្ម/អាជីវកម្មបន្ទាប់បន្សំផ្សេងទៀត ដែលអាចបង្កើតឲ្យមានចំណូលបន្ថែមដូចជា៖

- សេវាកម្មបូមស្តារ៖ ក.ស.ភ. មានម៉ាស៊ីន និងគ្រឿងចក្របូមស្តារចំនួន ២គ្រឿង សម្រាប់ផ្តល់សេវាកម្មបូមស្តារដើម្បីចាក់បំពេញខ្សាច់ជូនដល់អតិថិជន
- សេវាកម្មគ្រប់គ្រងអាជីវកម្មខ្សាច់៖ ក.ស.ភ. ទទួលបានអាជ្ញាបណ្ណបូមស្តារប្រឡាយនាវាចរណ៍ និងធ្វើអាជីវកម្មខ្សាច់នៅទីតាំងចំនួន ២ ដោយអនុលោមតាមប្រកាសលេខ ០១ និង ០២ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល
- សេវាកម្មវាស់ស្ទង់ និងបំពាក់ពោង៖ ក.ស.ភ. មានទទួលផ្តល់សេវាកម្មវាស់ស្ទង់ និងបំពាក់ពោងតាមតម្រូវការរបស់អតិថិជន
- សេវាកម្មថែទាំ/ជួសជុលសំបកកុងតឺន័រ៖ ក.ស.ភ. មានទទួលផ្តល់សេវាកម្មថែទាំ/ជួសជុលសំបកកុងតឺន័រគ្រប់ប្រភេទទៅតាមតម្រូវការរបស់អតិថិជន
- ការជួលអចលនទ្រព្យ និងគ្រឿងចក្រផ្សេងៗ៖ ក្រៅពីការប្រើប្រាស់អចលនទ្រព្យ និងគ្រឿងចក្រសម្រាប់បម្រើឲ្យការងារអាជីវកម្ម និងប្រតិបត្តិការ អចលនទ្រព្យ និងគ្រឿងចក្រទាំងនោះក៏ត្រូវបានប្រើប្រាស់ និងចាត់ចែងសម្រាប់ការជួល ដើម្បីបង្កើនចំណូលបន្ថែមជូនដល់ ក.ស.ភ. ផងដែរ។

### *ឃ. មណ្ឌលអាជីវកម្មផែ*

យោងតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩ មណ្ឌលអាជីវកម្មរបស់ ក.ស.ភ. មានប្រវែង ១៦៦គីឡូម៉ែត្រ គិតចាប់ពីទន្លេបួនមុខ៖ ទន្លេមេគង្គលើ ១០០គីឡូម៉ែត្រ ទន្លេមេគង្គក្រោម ៦០គីឡូម៉ែត្រ និងទន្លេសាប ៦គីឡូម៉ែត្រ។ ក្នុងនាមអាជ្ញាធរ ក.ស.ភ. មានតួនាទីគ្រប់គ្រងចំណតផែឯកជននានា នៅក្នុងមណ្ឌលអាជីវកម្ម ដោយរាប់បញ្ចូលទាំងចំណតផែប្រេង និងចំណតផែទំនិញរាយដទៃទៀត។ ដោយឡែក ក.ស.ភ. គ្រប់គ្រង និងប្រតិបត្តិការដោយផ្ទាល់ទៅលើចំណតផែចម្បងចំនួន ៤ រួមមាន៖

### ឃ.១. ចំណតផែកុងតឺន័រ LM១៧

នៅចុងឆ្នាំ២០១៨ ក.ស.ភ. បានបញ្ចប់ការសាងសង់ចំណតផែកុងតឺន័រ LM១៧ ជំហានទី២ លើផ្ទៃដី ៤,៥ហិកតា បន្ថែមលើជំហានទី១ ដែលបានសាងសង់លើផ្ទៃដីទំហំ ១០ហិកតា ដូចនេះបច្ចុប្បន្ន ក.ស.ភ. បានសាងសង់ទីលានសម្រាប់ប្រតិបត្តិការកុងតឺន័រលើផ្ទៃដីសរុបចំនួន ១៤,៥ហិកតា នៃផ្ទៃដីសរុប ៣០ ហិកតា។ ក.ស.ភ. កំពុងប្រើប្រាស់ចំណតផែនេះ ធ្វើជាចំណតផែចម្បងសម្រាប់ទំនិញកុងតឺន័រ។ ចំណតផែនេះ មានសមត្ថភាពលើកដាក់កុងតឺន័របាន ៣០០.០០០ TEUs ក្នុងមួយឆ្នាំ។ ចំណតផែកុងតឺន័រLM១៧ មានស្ពានផែ ដែលមានបណ្តោយប្រវែង ៣០០ម៉ែត្រ ទទឹង ២២ម៉ែត្រ និងបំពាក់ដោយដងយោង TCC ចំនួន ៣គ្រឿង រថស្ទូច RTG ចំនួន ៨គ្រឿង និងគ្រឿងចក្រលើកដាក់លើទីលាន (Reach Stacker & Constacker) ចំនួន ៥គ្រឿង (Sky Stacker) ចំនួន ៣គ្រឿង និងរថយន្ត ៣០គ្រឿងបាននឹងកំពុងបំពេញការងារប្រតិបត្តិការ។

| | |
|---|---|
| **អាសយដ្ឋាន** | ភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល |
| **ទីតាំងចំណតផែ** | ស្ថិតនៅតាមដងទន្លេមេគង្គត្រើយខាងលិច ចម្ងាយ ២៥គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°២៨' ២៣.៦" និងរយៈបណ្តោយខាងកើត ១០៥°០៨'៤៩.៨" |
| **ទំហំផ្ទៃដីសរុប** | ៣៤៥.៧១៤ម៉ែត្រការ៉េ |
| **ទំហំផ្ទៃដី ចុះបញ្ជី** | ៣២៧.០៧៣ម៉ែត្រការ៉េ |
| **ទំហំផ្ទៃដីកំពុងធ្វើប្លង់កម្មសិទ្ធិ** | ១៨.២៥០ម៉ែត្រការ៉េ |
| **ចំណតនាវា** | មាន ៣ ចំណត សម្រាប់នាវាចំណុះ ៥.០០០ DWT |
| **ទីតាំងបោះយុថ្កា** | ទីតាំងបោះយុថ្កា របស់ចំណតផែកុងតឺន័រ LM១៧ ស្ថិតក្នុងរយៈទទឹងខាងជើង ១១°២៨'២៨.១៤" និងរយៈបណ្តោយខាងកើត ១០៥°៩'២.៣២" ចន្លោះជម្រៅទឹកពី ៨ម៉ែត្រ ទៅ ១៧ម៉ែត្រ។ បាតទន្លេមានដីភក់ និងខ្សាច់ ហើយចរន្តទឹកមានកម្លាំងខ្លាំងនៅរដូវវស្សា |
| **រលក** | ផលប៉ះពាល់មានចាប់ពីខែកុម្ភៈ ដល់ ខែមេសា ដោយកម្ពស់រលកមានចាប់ពី ០.២០ម៉ែត្រ ដល់ ០.៤៥ម៉ែត្រ គិតនៅខែធ្នូ ឆ្នាំ២០១៥ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវា ប្រែប្រួលពីកម្រិតអប្បបរមា ៤.៥ម៉ែត្រ ក្នុងខែមីនា ដល់កម្រិតអតិបរមា ៥.៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែកុងតឺន័រ LM១៧ អាស្រ័យជម្រៅទឹក នៅច្រកតូទីរ) |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោង (Traveling Cargo Crane) រថស្ទូច (Rubber Tyred Gantry) គ្រឿងចក្រលើកដាក់លើទីលាន (Reach Stacker Constacker & Sky Stacker) |

### ឃ.២. ចំណតផែពហុបំណង TS៣

ចំណតផែពហុបំណង TS៣ ជាចំណតផែចម្បងសម្រាប់ទំនិញរាយ និងទំនិញកុងតឺន័រឆ្លងកាត់។ ដោយសារសមត្ថភាពពង្រីកទីលានចំណតផែពហុបំណង TS៣ នៅមានកម្រិត ដើម្បីទទួលកំណើនចរាចរកុងតឺន័រប្រចាំឆ្នាំ ក.ស.ភ. បានវិនិយោគលើការអភិវឌ្ឍចំណតផែកុងតឺន័រ LM១៧។ ចាប់តាំងពីចំណតផែកុងតឺន័រ LM១៧ ត្រូវបានស្ថាបនារួចរាល់ ចំណតផែ TS៣ ត្រូវបានក្លាយទៅជាចំណតផែពហុបំណង សម្រាប់បម្រើការលើកដាក់ទំនិញរាយ កុងតឺន័រ និងប្រើជាចំណតផែអ្នកដំណើរ និងទេសចរ។

| | |
|---|---|
| **អាសយដ្ឋាន** | អគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| **ទីតាំងចំណតផែ** | ស្ថិតនៅតាមដងទន្លេសាប ត្រើយខាងលិច ចម្ងាយ ៣,២គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°៣៤' ៥៩,៦៨" និងរយៈបណ្ដោយខាងកើត ១០៤°៥៥' ១៧,៤១" |
| **ទំហំផ្ទៃដីសរុប** | ៤៨.៤៣៨,៧៦ ម៉ែត្រការ៉េ |
| **ទំហំផ្ទៃដីចុះបញ្ជី*** | ៣២.៨៥៤ ម៉ែត្រការ៉េ |
| **ចំណតនាវា** | មាន ៣ ចំណត សម្រាប់នាវាចំណុះ ៥.០០០ DWT |
| **ទីតាំងបោះយុថ្កា** | ទីតាំងអាចបោះយុថ្កាបាន គឺនៅទន្លេសាបខាងមុខចំណតផែ និងមួយកន្លែងទៀតនៅទន្លេចតុមុខ ដែលស្ថិតក្នុងរយៈទទឹង ខាងជើង ១១°៣៣'៤៦,៩៨" និងរយៈបណ្ដោយខាងកើត ១០៤°៥៦'៣៤,៥៧" មានជម្រៅទឹកពី ៥ម៉ែត្រ ទៅ១៥ម៉ែត្រ។ បាតទន្លេមានដីភក់ និងខ្សាច់ ដែលអាចបោះយុថ្កាជាប់បានល្អ |
| **រលក** | ផលប៉ះពាល់ មានចាប់ពីខែកុម្ភៈ ដល់ខែមេសា ដោយកម្ពស់រលកមានចាប់ពី ០,១០ម៉ែត្រ ដល់ ០,៣៥ម៉ែត្រ គិតនៅខែធ្នូ ឆ្នាំ២០១៥ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវាប្រែប្រួលពីកម្រិតអប្បបរមា ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់កម្រិតអតិបរមា៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែពហុបំណង៣ អាស្រ័យលើជម្រៅទឹក នៅច្រកគូទីរ) |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោងចល័ត (Mobile crane និង Crawler crane) ដងយោងបណ្ដែត (Floating crane) |

*<u>សម្គាល់</u>៖ *ទំហំដីអាចខុសគ្នារវាងទំហំផ្ទៃដីសរុប និងទំហំផ្ទៃដីចុះបញ្ជី ដោយសារការកាត់ចេញនូវដីចំណីផ្លូវ និងចំណីទន្លេ។*

### ឃ.៣ ចំណតផែទន្លេបិទ UM២

ក.ស.ភ. បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ជាមួយក្រុមហ៊ុន *មៀង លីហេង អ៊ិនវេសមិន* ដើម្បីធ្វើកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍចំណតផែទន្លេបិទ។ កិច្ចព្រមព្រៀងនេះ មានសុពលភាពរយៈពេល ២០ឆ្នាំ គិតចាប់ពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ រហូតដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០៣២។ យោងតាមកិច្ចព្រមព្រៀងនេះ ក.ស.ភ. ទទួលខុសត្រូវលើសេវាកម្មលើកដាក់ក្រោមដង

យោង រឺងដែគូងកជនទទួលខុសត្រូវលើការផ្តល់សេវាកម្មស្តុកទំនិញ។ ចំណូលពីថ្លៃឈ្នួលទាំងនេះ ត្រូវគិតដាច់ដោយឡែកពីគ្នា ផ្អែកលើប្រភេទសេវាកម្ម ដែលផ្តល់ដោយភាគីនីមួយៗ។ ក.ស.ភ. មិនទាន់ទទួលបានសិទ្ធិជាម្ចាស់គ្រប់គ្រងទីតាំងដីនោះនៅឡើយទេ ប៉ុន្តែ ក.ស.ភ. បានសាងសង់ផែបណ្តែត និងបំពាក់ដងយោងចល័ត និងរថចូក។ គោលបំណងសំខាន់ក្នុងការបង្កើតចំណតផែនេះ គឺដើម្បីធ្វើជាកន្លែងប្រមូលផ្តុំកសិផល និងលើកកម្ពស់ការដឹកជញ្ជូនតាមផ្លូវទឹក។ បច្ចុប្បន្ន ដំឡូងមី ជាប្រភេទផលិតផលសំខាន់ ដែលត្រូវបាននាំចេញតាមចំណតផែនេះ។

| | |
|---|---|
| **អាសយដ្ឋាន** | ភូមិដូនមៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ |
| **ទីតាំងចំណតផែ** | ចំណតផែទន្លេបិទUM២ ស្ថិតនៅតាមដងទន្លេមេគង្គត្រើយខាងកើត ចម្ងាយ ១០៣ គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°៥៧'៤៧,៧៣" និងរយៈបណ្តោយខាងកើត ១០៥°២៨' ៣៣,១៣" |
| **ទំហំផ្ទៃដី** | ទំហំតូច ចំណតនៅតាមច្រាំងទន្លេប្រវែង ១០០ម៉ែត្រ (ដោយមានបំពាក់ប៉ង់តុងដងយោងចល័ត និងកុងវ៉ូយ័រ) |
| **ចំណតនាវា** | ចំនួន ១ (ប៉ង់តុងបណ្តែតទំហំ ៦ម៉ែត្រ x ២៨ម៉ែត្រ) |
| **ទីតាំងបោះយុថ្កា** | ទីតាំង ដែលអាចបោះយុថ្កានៅចំណតផែទន្លេបិទ UM២ ស្ថិតនៅក្នុងរយៈទទឹងខាងជើង ១១°៥៨'៤៣,៤១" និងរយៈបណ្តោយខាងកើត ១០៥°២៨' ៩,៥៨" ក្នុងចន្លោះជម្រៅទឹកពី ៦ម៉ែត្រ ទៅ ២០ម៉ែត្រ។ នារដូវវស្សា នៅបាតទន្លេមានដីភក់ និងខ្សាច់ ហើយមានចរន្តទឹកមានកម្លាំងខ្លាំង។ |
| **រលក** | មិនមានផលប៉ះពាល់ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវា ប្រែប្រួលពីកម្រិតអប្បបរមា ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់កម្រិតអតិបរមា ៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែទន្លេបិទ គឺអាស្រ័យទៅលើជម្រៅទឹក នៅច្រកគូទីវ) |
| **ជម្រៅទឹកផ្លូវនាវាចរ** | ចាប់ពីទន្លេចតុមុខទៅដល់ខេត្តត្បូងឃ្មុំ តាមប្រឡាយស្តៅមានទទឹង៦០ម៉ែត្រ និងបណ្តោយ ៣៥០០ម៉ែត្រ។ ជម្រៅទឹក មានជម្រៅ ៥ម៉ែត្រ ក្នុងរដូវប្រាំង (ដោយមានការថែទាំទៀងទាត់) |
| **ម៉ោងប្រតិបត្តិការ** | ៧ថ្ងៃ/២៤ ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោងចល័ត (Mobile crane) ដងយោងបណ្តែត (Floating crane) និង កុងវ៉ូយ័រ (Conveyer) |

### *យ.៩. ចំណតអ្នកដំណើរ និងទេសចរ TS១*

ចំណតផែអ្នកដំណើរ និងទេសចរ TS១ ជាចំណតផែអ្នកដំណើរចម្បងរបស់ ក.ស.ភ.។ ចំណតផែនេះត្រូវបានប្រើប្រាស់ ដើម្បីធ្វើជាចំណតផែអ្នកដំណើរក្នុងស្រុក ក៏ដូចជាទៅកំពង់ផែនៃប្រទេសវៀតណាម។ ក្នុងឆ្នាំ២០១៨ ចំនួនអ្នកដំណើរឆ្លងកាត់ចំណតផែអ្នកដំណើរ និងទេសចរ TS១ មានចំនួន ៥៥,៧៨៦នាក់។ តួលេខនេះ រាប់បញ្ចូលទាំងអ្នកដំណើរ ពីភ្នំពេញទៅចំណតផែក្នុងស្រុកនានា ពីភ្នំពេញទៅប្រទេសវៀតណាម ព្រមទាំងអ្នកទេសចរ ដែលធ្វើដំណើរឆ្លងកាត់តាមដងទន្លេមេគង្គ ក្បែររាជធានីភ្នំពេញ។

| | |
|---|---|
| **អាសយដ្ឋាន** | វិថីព្រះស៊ីសុវត្ថិ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| **ទីតាំងចំណតផែ** | ចំណតអ្នកដំណើរ និងទេសចរ TS១ ស្ថិតនៅតាមដងទន្លេសាបត្រើយខាងលិចចម្ងាយ ២គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងរយៈទទឹងខាងជើង ១១°៣៤'៣២,៤៥" និងរយៈបណ្ដោយខាងកើត ១០៤° ៥៥'៣៦,៨៨។ |
| **ទំហំផ្ទៃដីសរុប**<br>**ទំហំផ្ទៃដីចុះបញ្ជី*** | ៦.៦៧៦ ម៉ែត្រការ៉េ<br>១.៦៩៩ ម៉ែត្រការ៉េ |
| **ចំណតនាវា** | មានប៉ង់តុងចំនួន ២គ្រឿង |
| **ទីតាំងបោះយុថ្កា** | ទីតាំងអាចបោះយុថ្កាបាន នៅខាងមុខចំណតផែ តំបន់ទន្លេសាប និងមួយទីតាំងទៀតនៅតំបន់ទន្លេចតុមុខ ស្ថិតក្នុងរយៈទទឹងខាងជើង ១១°៣៣'៤៦,៩៨" និងរយៈបណ្ដោយខាងកើត ១០៤°៥៦'២៤,៥៧" ចន្លោះជម្រៅទឹកពី ៥ម៉ែត្រ ទៅ ១៥ម៉ែត្រ។ នារដូវវស្សា បាតទន្លេមានដីភក់ និងខ្សាច់ ដែលជាផ្ទៃមានកម្លាំងទប់ជាប់ល្អ ហើយជម្រើសទីតាំងទី២ ដើម្បីបោះយុថ្កាមានចរន្តទឹកខ្លាំង។ |
| **រលក** | ផលប៉ះពាល់មានចាប់ពីខែកុម្ភៈ ដល់ខែមេសា ដោយកម្ពស់រលកមានចាប់ពី ០,១ម៉ែត្រ ដល់ ០,៣៥ម៉ែត្រ គិតនៅខែធ្នូ ឆ្នាំ២០១៥ |
| **ជម្រៅស៊ីទឹក** | ជម្រៅស៊ីទឹកប្រែប្រួលពី ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់ ៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅស៊ីទឹកសម្រាប់នាវាចរាចរមកចំណតផែពហុបំណង TS៣ គឺអាស្រ័យទៅលើជម្រៅស៊ីទឹក នៅច្រកគូទីវ) |
| **ប្រតិបត្តិការ** | ៧ថ្ងៃ/២៤ម៉ោង |
| **គ្រឿងចក្រលើកដាក់** | មានប៉ង់តុងចំនួន ២គ្រឿង ដោយមានស្ពានតភ្ជាប់ទៅច្រាំងទន្លេ |

*សម្គាល់៖ *ទំហំដីអាចខុសគ្នារវាងទំហំផ្ទៃដីសរុប និងទំហំផ្ទៃដីចុះបញ្ជី ដោយសារការកាត់ចេញនូវដីចំណីផ្លូវ និងចំណីទន្លេ។*

## ៣- ស្ថានភាពទីផ្សារ

ទីផ្សាររបស់ ក.ស.ភ. ពឹងផ្អែកទៅលើតម្រូវការប្រើប្រាស់ទំនិញក្នុងប្រទេស និងក្រៅប្រទេស។ ជាក់ស្ដែង តម្រូវការក្នុងប្រទេស គឺពឹងផ្អែកទៅលើតម្រូវការរបស់ប្រជាជន សហគ្រាស រោងចក្រឧស្សាហកម្ម និងសំណង់អាគារផ្សេងៗជាដើម ប៉ុន្តែ ដោយប្រទេសកម្ពុជាពុំទាន់មានផលិតភាពគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុកបាន ដូចនេះ ការនាំចូលពីក្រៅប្រទេស គឺមានភាពចាំបាច់ខ្លាំង ដើម្បីបំពេញសេចក្ដីត្រូវការនៅក្នុងស្រុក។ តួយ៉ាងដូចវិស័យកាត់ដេរ និងសំណង់អាគារផ្សេងៗគឺ មានតម្រូវការនាំចូលវត្ថុធាតុដើមពីក្រៅប្រទេសដើម្បីផ្គត់ផ្គង់ចង្វាក់ផលិតកម្ម និងសំណង់ក្នុងស្រុក។ ដោយឡែកចំពោះទីផ្សារក្រៅប្រទេសវិញ គឺពឹងផ្អែកទៅលើចរន្តសេដ្ឋកិច្ចសកល ទំហំកូតាដែលបានផ្ដល់ឲ្យប្រទេសកម្ពុជា និងការបញ្ជាទិញផ្សេងៗ ដោយក្នុងនោះមាន សហរដ្ឋអាមេរិក ប្រទេសចិន សហគមន៍អឺរ៉ុប និងប្រទេជប៉ុន ដែលជាទីផ្សារធំសម្រាប់ការបញ្ជាទិញ និងធ្វើការដឹកជញ្ជូនតាមចំណតផែកុងតឺន័ររបស់ ក.ស.ភ.។

ជាមួយគ្នានេះដែរ ផ្អែកតាមរបាយការណ៍របស់ នាយកដ្ឋានផែនការ/ទីផ្សារ បរិមាណកុងតឺន័រឆ្លងកាត់ ក.ស.ភ. នៅក្នុងឆ្នាំ២០១៨ បានកើនឡើង ១៦% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៧។ កំណើននៅក្នុងឆ្នាំ២០១៨ នេះ អាស្រ័យលើការនាំចូលទំនិញជាគ្រឿងសំណង់មានរហូតដល់ ៤៨% និងវត្ថុធាតុដើមវាយនភណ្ឌ ១២% ប៉ុន្តែ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៧ ការនាំចូលទំនិញជាគ្រឿងសំណង់មានការថយចុះ ២% និង ការនាំចូលវត្ថុធាតុដើមវាយនភណ្ឌមានការធ្លាក់ចុះ ៣៧%។ ដោយឡែក ចំពោះការនាំចេញវិញទំនិញជា វាយនភណ្ឌនៅតែបន្តកើនឡើង ២២% បើប្រៀបធៀបនឹងឆ្នាំ២០១៧ ប៉ុន្តែអង្ករបានធ្លាក់ចុះ ២៥%។ (យោងតាមក្រាហ្វិកលេខ១ លេខ២ លេខ៣ និងលេខ៤ របស់ នាយកដ្ឋានផែនការ/ទីផ្សារ)។

ក្រាហ្វិកលេខ១




*(ប្រភព៖ ទិន្នន័យប្រចាំឆ្នាំ ២០១៧ និងប្រចាំឆ្នាំ២០១៨ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ភ.)*

## ក្រាហ្វិកលេខ២២

## ស្ថិតិកុងតឺន័រនាំចូល-នាំចេញតាមច្រក ក.ស.ត. ប្រចាំឆ្នាំ២០១៨ គិតជា (ធីអ៊ីយូ)







*(ប្រភព៖ ទិន្នន័យប្រចាំឆ្នាំ ២០១៧ និងប្រចាំឆ្នាំ២០១៨ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ភ.)*

## ក្រាហ្វិកលេខ២៣




| | គ្រឿងសំណង់ | ម្ហូបអាហារ និងភេសជ្ជៈ | វត្ថុធាតុដើមវាយនភណ្ឌ | សម្ភារប្រើប្រាស់ក្នុងផ្ទះ | គ្រឿងបន្លាស់ | គ្រឿងម៉ាស៊ីន | ថ្នាំពេទ្យ |
|---|---|---|---|---|---|---|---|
| ប្រចាំឆ្នាំ ២០១៧ | ២៩៦២៨ | ៤២៣៩ | ១១០៩៩ | ៣៤២៤ | ១១៥៦ | ១២០៤ | ១៥៧០ |
| ប្រចាំឆ្នាំ ២០១៨ | ២៩១០២ | ៥៧៣៩ | ៧០៤០ | ៥៨០៨ | ២០៦២ | ២០៦៤ | ៨៨៦ |
| អត្រាប្រែប្រួលជាភាគរយ ប្រចាំឆ្នាំ២០១៧ និងប្រចាំឆ្នាំ២០១៨ | -២% | ៣៥% | -៣៧% | ៧០% | ៧៨% | ៧១% | -៤៤% |

*(ប្រភព៖ ទិន្នន័យប្រចាំឆ្នាំ ២០១៧ និងប្រចាំឆ្នាំ២០១៨ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ភ.)*

## ក្រាហ្វិកលេខ៤

**ស្ថិតិទំនិញនាំចេញតាមច្រក ក.ស.ភ. ប្រចាំឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៧ គិតជា (ធីអ៊ីយូ)**




| | វាយនភណ្ឌ | អង្ករ |
|---|---|---|
| ប្រចាំឆ្នាំ ២០១៧ | ៦៦៤៧៥ | ៨៤៥០ |
| ប្រចាំឆ្នាំ ២០១៨ | ៨១២៦២ | ៦៣៨៦ |

*(ប្រភព៖ ទិន្នន័យប្រចាំឆ្នាំ ២០១៧ និងប្រចាំឆ្នាំ២០១៨ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ភ.)*

## ក្រាហ្វិកលេខ៥

**ចំណែកទីផ្សារនាំចូលទំនិញតាមច្រក ក.ស. ភ. ប្រចាំឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៧ គិតជា (ធីអ៊ីយូ)**




| | ប្រទេសចិន | ប្រទេសវៀតណាម | ប្រទេសម៉ាឡេស៊ី | ប្រទេសជប៉ុន | សហគមន៍អឺរ៉ុប | សហរដ្ឋអាមេរិក |
|---|---|---|---|---|---|---|
| ប្រចាំឆ្នាំ ២០១៧ | ៣៩៦៦៣ | ៥២៤៦ | ១៨៣២ | ៩៤៥ | ២៧៥៦ | ១៥៦០ |
| ប្រចាំឆ្នាំ ២០១៨ | ៤០៤១៥ | ៦៣៦១ | ៣៣៧០ | ៨៤៩ | ៣៣៧៤ | ៣៥៣ |
| អត្រាប្រែប្រួលជាភាគរយ ប្រចាំឆ្នាំ២០១៧ និងប្រចាំឆ្នាំ២០១៨ | ២% | ២១% | ៨៤% | -១០% | ២២% | -៧៧% |

*(ប្រភព៖ ទិន្នន័យប្រចាំឆ្នាំ ២០១៧ និងប្រចាំឆ្នាំ២០១៨ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ភ.)*

<u>ក្រាហ្វិកលេខ២៦</u>

**ចំណែកទីផ្សារនាំចេញទំនិញតាមប្រភព ក.ស.ភ. ប្រចាំឆ្នាំ២០១៨**
**ធៀបនឹងឆ្នាំ២០១៧ គិតជា (ធីអ៊ីយូ)**




| | ប្រទេសចិន | ប្រទេសវៀតណាម | ប្រទេសជប៉ុន | សហគមន៍អឺរ៉ុប | សហរដ្ឋអាមេរិក |
|---|---|---|---|---|---|
| ប្រចាំឆ្នាំ ២០១៧ | ១៤១០៩ | ៤១៥៨ | ១១៩១១ | ៤០៣៤ | ២៩០២៦ |
| ប្រចាំឆ្នាំ២០១៨ | ១៣០៨៩ | ១៦០៦ | ១១២៦៦ | ៦៤៤៣ | ៤៣៣២១ |
| អត្រាប្រែប្រួលជាភាគរយ ប្រចាំឆ្នាំ២០១៧ និងប្រចាំឆ្នាំ២០១៨ | -៧% | -៦១% | -៥% | ៦០% | ៤៩% |

*<u>(ប្រភព៖ ទិន្នន័យប្រចាំឆ្នាំ ២០១៧ និងប្រចាំឆ្នាំ២០១៨ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ភ.)</u>*

យោងតាមក្រាហ្វិកលេខ២៥ និងលេខ២៦ ប្រទេសដែលធ្វើការផ្គត់ផ្គង់ទំនិញ និងវត្ថុធាតុដើមសម្រាប់ឆ្លើយតបទៅនឹងតម្រូវការប្រជាជន និងចង្វាក់ផលិតកម្មក្នុងប្រទេសតាមរយៈការនាំចូលតាមចំណតផែកុងតឺន័ររបស់ ក.ស.ភ. នោះ គឺប្រទេសចិនមានចំនួន ៦៧% និងប្រទេសវៀតណាមមានចំនួន ១១% នេះបើធៀបទៅនឹងការនាំចូលពីបណ្តាលប្រទេសផ្សេងៗនៅក្នុងឆ្នាំ២០១៨ ប៉ុន្តែ បើធៀបទៅនឹងឆ្នាំ២០១៧ ការនាំចូលពីប្រទេសចិនកើនឡើង ២% និងប្រទេសវៀតណាមមានការកើនឡើង ២១%។ ចំណែកទីផ្សារនៃការនាំចេញវិញ គឺការនាំចេញទៅកាន់សហរដ្ឋអាមេរិកមានចំនួន ៤៧% និងសហគមន៍អឺរ៉ុបមានចំនួន ៧% បើប្រៀបធៀបទៅនឹងការនាំចេញទៅកាន់បណ្តាលប្រទេសផ្សេងៗនៅក្នុងឆ្នាំ២០១៨ ប៉ុន្តែ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៧ ការនាំចេញទៅកាន់សហរដ្ឋអាមេរិកកើនឡើង ៤៩% និងសហគមន៍អឺរ៉ុបមានការកើនឡើង ៦០%។

ជារួមអត្រាកំណើនកុងតឺន័រឆ្លងកាត់ ក.ស.ភ. នៅក្នុងឆ្នាំ២០១៨នេះ គឺផ្អែកទៅលើហេតុផលដូចខាងក្រោម៖

- អត្រាកំណើនរបស់ប្រជាជនរបស់ប្រទេសក្នុងរង្វង់ ១,៦% ក្នុងមួយឆ្នាំ និងស្របជាមួយអត្រាកំណើនសេដ្ឋកិច្ច GDP នៅតែរក្សាបន្តកំណើន ៧,២% និងអត្រាអតិផរណាស្ថិតក្នុងរង្វង់ ៣,០៤ ក្នុងមួយឆ្នាំ ដូចនេះ អត្រាកំណើនទាំងនេះគឺជាប្រភពនៃកំណើនតម្រូវការ និងលទ្ធភាពក្នុងការទិញទំនិញនៅលើទីផ្សារ។ ប៉ុន្តែ ដោយសារប្រទេសកម្ពុជានៅពុំទាន់មានផលិតភាពគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក ដូចនេះ ប្រទេសកម្ពុជាត្រូវធ្វើការបញ្ជារទិញទំនិញពីក្រៅប្រទេសដើម្បីបំពេញសេចក្តីត្រូវការក្នុងស្រុក។ តួយ៉ាងនៅក្នុង

ឆ្នាំ២០១៨នេះ យើងសង្កេតឃើញថា សម្រាប់ការនាំចូលម្ហូបអាហារ និងភេសជ្ជមានការកើនឡើង ៣៥% សម្ភារប្រើប្រាស់ក្នុងផ្ទះមានការកើនឡើង ៧០% និងគ្រឿងម៉ាស៊ីន ៧១% បើប្រៀបធៀបនឹងឆ្នាំ២០១៧

- អត្រាកំណើននៃវិស័យអចលនទ្រព្យ គេហដ្ឋាន និងសំណង់អាគារផ្សេងៗនៅក្នុងប្រទេសកម្ពុជា បានជម្រុញឲ្យប្រទេសកម្ពុជាត្រូវធ្វើការនាំចូលនូវគ្រឿងសំណង់ជាច្រើនដើម្បីផ្គត់ផ្គង់នូវកំណើនអចលនទ្រព្យខាងលើ ដោយក្នុងនោះការនាំចូលគ្រឿងសំណង់តាមចំណតផែកុងតឺន័ររបស់ ក.ស.ភ. មានចំនួន ៤៨% នៃការនាំចូលសរុបក្នុងឆ្នាំ២០១៨ ប៉ុន្តែ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៧ មានការថយចុះ ២%
- ស្ថានភាពសេដ្ឋកិច្ចសកលលោកនៅតែមានភាពល្អប្រសើរ ជាពិសេស សហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប ប្រទេសជប៉ុន និងប្រទេសចិន ដែលជាដៃគូពាណិជ្ជកម្មដ៏សំខាន់សម្រាប់ប្រទេសកម្ពុជាតាមរយៈការនាំចេញ និងនាំចូល។ ជាក់ស្តែង នៅក្នុងឆ្នាំ២០១៨ ការនាំចេញទៅកាន់សហរដ្ឋអាមេរិកមានចំនួន ៤៧% នៃប្រទេសនាំចេញសរុបក្នុងឆ្នាំ២០១៨ ប៉ុន្តែបើប្រៀបធៀបទៅនឹងឆ្នាំ២០១៧ មានការកើនឡើងចំនួន ៤៩%។ ចំណែកឯ ការនាំចេញទៅកាន់សហគមន៍អឺរ៉ុបមានចំនួន ៧% នៃប្រទេសនាំចេញសរុបក្នុងឆ្នាំ២០១៨ ប៉ុន្តែបើប្រៀបធៀបទៅនឹងឆ្នាំ២០១៧ មានការកើនឡើង ៦០%។

ជារួមមកសម្រាប់ស្ថានភាពទីផ្សាររបស់ ក.ស.ភ. នៅក្នុងឆ្នាំ២០១៨នេះ ក.ស.ភ. នៅតែជាច្រកទ្វារសំខាន់សម្រាប់ទំនិញឆ្លងកាត់ ដោយផ្អែកលើអត្រាកំណើននៃទំនិញឆ្លងកាត់ដូចបានបង្ហាញនៅក្នុងក្រាហ្វិកខាងលើ។ ប៉ុន្តែ បើពិនិត្យទៅលើចំណែកទីផ្សារនៃការនាំចេញ និងនាំចូល ប្រទេសជប៉ុន ប្រទេសចិន សហគមន៍អឺរ៉ុប សហរដ្ឋអាមេរិក នៅតែជាច្រកដ៏សំខាន់ និងរឹងមាំបំផុតសម្រាប់ការដឹកជញ្ជូនទំនិញឆ្លងកាត់តាមចំណតផែកុងតឺន័ររបស់ ក.ស.ភ. ទៅមកប្រទេសកម្ពុជា។

## ៤- ស្ថានភាពប្រកួតប្រជែង

ក.ស.ភ. គឺជាចំណតផែអន្តរជាតិតាមដងទន្លេតែមួយគត់ក្នុងការផ្តល់សេវាកម្មចំណតនាវា និងសេវាកម្មលើកដាក់ទំនិញជាកុងតឺន័រ និងទំនិញទូទៅជូនអតិថិជន។ បរិមាណកុងតឺន័រឆ្លងកាត់ ក.ស.ភ. ក្នុងឆ្នាំ២០១៨នេះ មានអត្រាកំណើន ១៦% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៧។ ប្រសិនបើពិនិត្យទៅលើស្ថានភាពដៃគូប្រកួតប្រជែងវិញ កំពង់ផែស្វយ័តភ្នំពេញ នៅតែដើរតួនាទីសំខាន់ និងរឹងមាំបំផុតក្នុងវិស័យកំពង់ផែដែលជាច្រកសំខាន់សម្រាប់ការដឹកជញ្ជូនទំនិញឆ្លងកាត់នៅតាមដងទន្លេ។ ខាងក្រោមនេះគឺជាកត្តាបង្ហាញឲ្យឃើញពីឧត្តមភាពប្រកួតប្រជែងរបស់ ក.ស.ភ. លើការផ្តល់សេវាកម្មកំពង់ផែ៖

### ៤.១. ទីតាំងភូមិសាស្ត្រ

ក.ស.ភ. ស្ថិតនៅទីតាំងភូមិសាស្ត្រប្រកបដោយសក្តានុពល និងយុទ្ធសាស្ត្រ ដោយនៅចំបេះដូងនៃរាជធានីភ្នំពេញដែលជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ឧស្សាហកម្ម រោងចក្រ អ្នកប្រើប្រាស់ និងជាកន្លែងប្រមូលផ្តុំ

ទៅដោយកម្លាំងពលកម្ម។ ការដឹកជញ្ជូនតាម ក.ស.ភ. ផ្តល់ភាពងាយស្រួល រហ័ស និងចំណាយតិច ក្នុងការចែកចាយ និងផ្គត់ផ្គង់ទំនិញដល់អ្នកប្រើប្រាស់។ ជាមួយគ្នានេះដែរ ទីតាំងរបស់ ក.ស.ភ. គឺនៅជិត និងមានរយៈចំងាយនៃការដឹកជញ្ជូនជិតជាងចំណតផែដទៃទៀត នៅក្នុងប្រទេសកម្ពុជា ដូចជាការដឹកជញ្ជូនទំនិញឆ្លងកាត់ទៅកាន់ប្រទេសវៀតណាម ប្រទេសចិន និងសហរដ្ឋអាមេរិកជាដើម។ ដែលប្រទេសទាំងនេះ គឺមានទំហំពាណិជ្ជកម្មធំជាមួយប្រទេសកម្ពុជាបើធៀបទៅនឹងប្រទេសដទៃទៀត។

### ៤.២. សេវាកម្ម

ក.ស.ភ. នៅតែរក្សាបាននូវគោលការណ៍របស់ ក.ស.ភ. ដោយផ្តោតទៅលើ គុណភាពល្អ សុវត្ថិភាព សេវាកម្មរហ័ស២៤ម៉ោង និងតម្លៃមានភាពប្រកួតប្រជែងជូនដល់អតិថិជន។

### ៤.៣. តម្លៃសេវាកម្ម

ក.ស.ភ. នឹងផ្តល់នូវតម្លៃដែលមានលក្ខណៈប្រកួតប្រជែង និងបន្តរក្សាផ្តល់ជូនតម្លៃអនុគ្រោះដល់អតិថិជនទៅលើសេវាកម្មលើកដាក់កុងតឺន័រ និងសេវាកម្មចំណតនាវា។ បើក្រុមហ៊ុនដឹកជញ្ជូនកុងតឺន័រ បានកាន់តែច្រើន នោះការគិតថ្លៃលើកដាក់នឹងទទួលបានការលើកទឹកចិត្តក្នុងការបញ្ចុះតម្លៃ។

ជាមួយគ្នានេះដែល ក.ស.ភ. នៅតែរក្សាផ្តល់តម្លៃដែលមានភាពបទបែនដល់អតិថិជនដែលបានទទួលសេវាកម្មពី ក.ស.ភ.។ យុទ្ធសាស្រ្តតម្លៃដែលមានភាពបទបែងនេះហើយជាចំនុចខ្លាំងរបស់ ក.ស.ភ. ក្នុងការទាក់ទាញអតិថិជន។

ក.ស.ភ. បានផ្តល់តម្លៃអនុគ្រោះដល់សេវាកម្មលើកដាក់ និងការរក្សាទុកកុងតឺន័រដែលផ្ទុកទំនិញប្រភេទជាផលិផលកសិកម្ម។ ជាពិសេស ក.ស.ភ. បានផ្តល់តម្លៃអនុគ្រោះមិនគិតថ្លៃចំពោះថ្លៃច្រកទ្វារថយន្តដែលដឹកជញ្ជូនកុងតឺន័រផ្ទុកទំនិញជាអង្ករឆ្លងកាត់ ក.ស.ភ.។

លើសពីនេះ ក.ស.ភ. នៅតែបន្តផ្តល់សេវាកម្មប្រតិបត្តិការផែ ២៤ម៉ោង/៧ថ្ងៃ ដោយពុំគិតកម្រៃសេវាបន្ថែមម៉ោងនោះទេ។

### ៤.៥. ការផ្សព្វផ្សាយរបស់ ក.ស.ភ.

ក.ស.ភ. នៅតែរក្សាបន្តការផ្សព្វផ្សាយ និងប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីផ្តល់ព័ត៌មានដល់អតិថិជនឱ្យបានគ្រប់គ្រាន់ និងស្គាល់កាត់តែច្បាស់អំពី ក.ស.ភ. ដើម្បីងាយស្រួលដល់ការសម្រេចចិត្តក្នុងការប្រើប្រាស់សេវាកម្មរបស់ ក.ស.ភ.។ ជាក់ស្តែង អតិថិជន អាចទទួលនូវព័ត៌មានសេវាកម្មរបស់ ក.ស.ភ. តាមរយៈមធ្យោបាយផ្តល់ព័ត៌មានជាច្រើនរួមមាន៖

ទី១. ការចុះផ្សាយព័ត៌មាន តាមគេហទំព័រ ប្រតិទិន នាមប័ណ្ណ ខិតប័ណ្ណ វត្ថុអនុស្សាវរីយ៍ និងសៀវភៅព័ត៌មានពាណិជ្ជកម្ម (របស់សភាពាណិជ្ជកម្មកម្ពុជា)

ទី២. ការផ្សព្វផ្សាយព័ត៌មាន នៅតាមសិក្ខាសាលា ក្នុងវគ្គបណ្តុះបណ្តាល និងការប្រជុំផ្សេងៗ

ទី៣. តាមរយៈការផ្សព្វផ្សាយព័ត៌មានសាជីវកម្មរបស់ ក.ស.ភ. តាមរយៈផ្សារមូលបត្រកម្ពុជា

ទី៤. យុទ្ធសាស្រ្តចុះផ្សព្វផ្សាយដោយផ្ទាល់ជាមួយអតិថិជនជាក្រុមហ៊ុនដឹកជញ្ជូននានា

ទី៥. ការផ្លាស់ប្តូរបច្ចុប្បន្នភាពនូវព័ត៌មានសេវាកម្ម និងគម្រោងអភិវឌ្ឍន៍ផែ នៅក្នុងក្របខណ្ឌនៃការប្រជុំរបស់សមាគមកំពង់ផែអាស៊ាន (APA) រវាងសមាជិកកំពង់ផែអាស៊ាន។

មធ្យោបាយផ្សព្វផ្សាយទាំងនេះ ជាប្រភពព័ត៌មានគ្រប់ជ្រុងជ្រោយ ដែលជួយឱ្យអតិថិជនបានស្គាល់ និងទាក់ទាញការប្រើប្រាស់សេវាកម្មរបស់ ក.ស.ភ. នៅលើទីផ្សារ។

៤.៦. ការដាក់ចេញនូវវិធានការរបស់រាជរដ្ឋាភិបាលដើម្បីពង្រឹងលើការត្រួតពិនិត្យលើមធ្យោបាយដឹកជញ្ជូនលើសទម្ងន់នៅតាមផ្លូវគោក។ ការចាត់វិធានការនេះ ជាឱកាសមួយដែលបានជម្រុញឲ្យមានកំណើននៃការដឹកជញ្ជូនតាមផ្លូវទឹកព្រោះថា ការដឹកជញ្ជូនតាមផ្លូវគោក អតិថិជនត្រូវចំណាយច្រើន និងដឹកជញ្ជូនបានចំនួនតិច ជាពិសេស គ្រោះថ្នាក់ចរាចរតាមដងផ្លូវដែលអាចជម្រុញឲ្យអតិថិជនចំណាយថ្លៃដឹកជញ្ជូនកាន់តែច្រើន ខណៈពេលដែលការដឹកជញ្ជូនតាមផ្លូវទឹក នឹងផ្តល់ផលចំណេញច្រើនដល់អតិថិជនដូចជាការ ដឹកជញ្ជូនបានបរិមាណច្រើន ចំណាយថ្លៃដើមតិច និងពុំប៉ះពាល់ខ្លាំងដល់បរិដ្ឋានដូចការដឹកជញ្ជូនតាមផ្លូវគោកឡើយ។

ដូចនេះ ស្ថានភាពប្រកួតប្រជែងរបស់ ក.ស.ភ. សម្រាប់ ឆ្នាំ២០១៨នេះ នៅតែមានភាពរឹងមាំ ទាក់ទាញ និងឈានទៅមុខជានិច្ច ដើម្បីទាក់ទាញអតិថិជនឲ្យនៅតែបន្តប្រើប្រាស់សេវាកម្មរបស់ ក. ស. ភ.។

## ៥-ផែនការអនាគតសម្រាប់ឆ្នាំ ២០១៩

ខាងក្រោម គឺជាគម្រោងអនាគតដែលមានតម្លៃវិនិយោគលើសពី ១០០.០០០ ដុល្លារអាមេរិក ដែលនឹងត្រូវវិនិយោគក្នុងរយៈពេល ១ឆ្នាំ ទៅ ៥ឆ្នាំខាងមុខ។

### *ក. គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី៣ របស់ចំណតផែកុងតឺន័រ LM១៧*

| ឈ្មោះ | គម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី៣ (ជំហានទី១) |
|---|---|
| **បរិយាយ** | ចន្លោះពី ឆ្នាំ២០១៣ ដល់ ឆ្នាំ២០១៨ ចំនួនកុងតឺន័រដែលឆ្លងកាត់ជាមធ្យមកើនឡើងប្រហែល ១៤,០៩% រៀងរាល់ឆ្នាំ។ ដោយសារតែ កុងតឺន័រដែលឆ្លងកាត់បច្ចុប្បន្ននៅ LM១៧ មានចំនួន ២១៣.៥៧១ធីអ៊ីយូ ក្នុងឆ្នាំ២០១៨ ក.ស.ភ. ព្យាករណ៍ថាចំនួនកុងតឺន័រនឹងបន្តកើនឡើងដល់ ២៣៤.០០០ធីអ៊ីយូ ក្នុងឆ្នាំ២០១៩។ ដើម្បីទទួលបានកំណើននេះ ក.ស.ភ. ត្រូវធ្វើការពង្រីកបបនីយភណ្ឌ-ផែ និងបរិក្ខារបន្ថែមទៀត |
| **ជំហានទី១ នៃដំណាក់កាលទី៣ ពីឆ្នាំ២០១៩** | |
| **គោលបំណង** | ធានាសមត្ថភាពលើកដាក់របស់ផែក្នុងការទទួលកំណើនកុងតឺន័រឆ្លងកាត់ជារៀងរាល់ឆ្នាំ |
| **លទ្ធផលរំពឹងទុក** | បង្កើនសមត្ថភាពលើកដាក់របស់ចំណតផែកុងតឺន័រLM១៧ ដល់កម្រិត ៥០០.០០០ធីអ៊ីយូ ក្នុងមួយឆ្នាំ |
| **ទីតាំងគម្រោង** | ភាគខាងកើតចំណតផែកុងតឺន័រ LM១៧ |
| **ទំហំនៃគម្រោង** | ៣,៥ ហិកតា |
| **ភ្នាក់ងារអនុវត្តគម្រោង** | កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) |

| ឈ្មោះ | គម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី៣ (ជំហានទី១) |
|---|---|
| ថវិកាត្រូវចំណាយ | - សាងសង់ទីលានការ៉ុឡាទំហំ ១៨.៦៥០ម៉ែត្រក្រឡា និងផ្លូវ RTG ទំហំ ១,៥ម X ២៧២ម ចំនួន ៣ខ្សែ គ្រោងចំណាយទឹកប្រាក់ចំនួន ៥.៩៩៥.០០០.០០០រៀល<br>- សាងសង់សួនច្បារទំហំ ៨មx៥៦០ម, ដាក់បង្គោលភ្លើងបំភ្លឺកម្ពស់៣៥ម៉ែត្រ ចំនួន ៤បង្គោល, ប្រព័ន្ធកាមេរ៉ាសុវត្ថិភាពនៅលើទីលានចំនួន ៤បង្គោល និងប្រព័ន្ធទឹកពន្លត់អគ្គីភ័យ ៨កន្លែង តាមបណ្តោយមាត់ទន្លេ នៅលើផ្ទៃដី ៤.៤៨០ម៉ែត្រក្រឡា គ្រោងចំណាយចំនួន ២.០០០.០០០.០០០រៀល<br>- សាងសង់ផ្លូវ Asphalt-Concrete ពីប្លង់ A ដល់ប្លង់B តាមបណ្តោយមាត់ទន្លេទំហំ ១៥ម X ៧៨០ម លើទំហំផ្ទៃដី ១១.៧០០ម៉ែត្រក្រឡា គ្រោងចំណាយទឹកប្រាក់ចំនួន ២.៧៤០.០០០.០០០រៀល<br>- បំពាក់ប្រព័ន្ធកាមេរ៉ានៅច្រកចេញចូលថ្មី គ្រោងចំណាយទឹកប្រាក់ចំនួន ៦១៥.០០០.០០០រៀល<br>- បំពាក់ជញ្ជីងថ្លឹងរថយន្ត ចំនួន ៤គ្រឿង គ្រោងចំណាយទឹកប្រាក់ចំនួន ៦៤០.០០០.០០០រៀល |
| ប្រភពហិរញ្ញវត្ថុ | - មូលធនទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង<br>- មូលនិធិបម្រុងរបស់ ក.ស.ភ. |
| រយៈពេលអនុវត្តគម្រោង | ២០១៩-២០២១ |
| កម្មសិទ្ធិដី | កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) |
| បញ្ហាសង្គម | ការអនុវត្តគម្រោងដំណាក់កាលទី២នៃចំណតផែកុងតឺន័រLM១៧ នឹងបង្កើតការងារបន្ថែម តាមរយៈការជ្រើសរើសបុគ្គលិកបន្ថែម |
| បញ្ហាបរិស្ថាន | គ្មានការបង្ហាញណាមួយដែលបញ្ជាក់ថាអាចមានផលប៉ះពាល់ដល់ផ្នែកបរិស្ថានឡើយ |
| សកម្មភាពតាមដាន | បង្កើតក្រុមការងារដើម្បីតាមដានការអនុវត្តគម្រោង |

# ផ្នែកទី២
# ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ១. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែកសម្រាប់ ឆ្នាំ២០១៨

### ១.១. តារាងស្ថិតិបរិមាណទំនិញ និងនាវាឆ្លងកាត់ ក.ស.ភ.

| ល.រ | បរិយាយ | ឯកតា | ផែនការ ឆ្នាំ២០១៨ | អនុវត្ត ឆ្នាំ២០១៨ | អនុវត្ត ឆ្នាំ២០១៧ | អនុវត្ត ឆ្នាំ ២០១៦ | ប្រៀបធៀប (%) | កើន/ថយ (%) | |
|---|---|---|---|---|---|---|---|---|---|
| ក | ខ | គ | ១ | ២ | ៣ | ៤ | ៥=(២/១) | ៦=(២/៣)-១០០% | ៧=(៣/៤)-១០០% |
| I | **បរិមាណទំនិញ និង ប្រេងឥន្ធនៈឆ្លងកាត់** | តោន | ២.៨០០.០០០ | ៣.១៣៤.៩៩៦ | ២.៧៥៧.៦៦១ | ២.៤០៩.៦៣២ | ១០៨% | +១៤% | +១៤% |
| | ក. បរិមាណទំនិញឆ្លងកាត់ | - | ១.៦៨០.០០០ | ១.៦៣៣.៧០៤ | ១.៥៤១.៥២៥ | ១.២៧០.៤១៦ | ៩៧% | +៦% | +២១% |
| | - ទំនិញនាំចូល | - | ១.១០០.០០០ | ១.០៦១.២៥០ | ៩៨៦.៧៨៧ | ៨៣៣.៨២៧ | | | |
| | - ទំនិញនាំចេញ | - | ៥៨០.០០០ | ៥៧២.៤៥៣ | ៥៥៤.៧៣៨ | ៤៣៦.៥៨៩ | | | |
| | ខ. បរិមាណទំនិញលើកដាក់ចល័ត | - | ៥១០.០០០ | ៧៣០.៥៤៦ | ៥០២.១៩៥ | ៤៤៨.៣៨៩ | ១៤៣% | +៤៥% | +១២% |
| | - ទំនិញលើកដាក់ក្នុងផៃ | - | ៦០.០០០ | ៥១.១៧៨ | ២១.១៩០ | ៦៥.១២៣ | | | |
| | - ទំនិញលើកដាក់ក្រៅផៃ | - | ៤៥០.០០០ | ៦៧៩.៣៦៨ | ៤៨១.០០៥ | ៣៨៣.២៦៦ | | | |
| | គ.បរិមាណប្រេងឥន្ធនៈ និងហ្គាសឆ្លងកាត់ | - | ៧១០.០០០ | ៧៧០.៧៤៦ | ៧១៣.៩៤១ | ៦៩០.៨២៧ | ១០៩% | +៨% | +៣% |
| | **បរិមាណកុងតឺន័រឆ្លងកាត់** | TEU | ២០០.០០០ | ២១៣.៥៧១ | ១៨៤.៨០៥ | ១៥១.៧៨១ | ១០៧% | +១៦% | +២២% |
| | -មានទំនិញ | - | ១៤០.០០០ | ១៥១.៧៤៩ | ១៣៦.៩៨៤ | ១១៥.២៧៩ | | | |
| | -គ្មានទំនិញ | - | ៦០.០០០ | ៦១.៨២២ | ៤៧.៨២១ | ៣៦.៥០២ | | | |
| II | **បរិមាណទំនិញលើកដាក់** | តោន | ២.១៩០.០០០ | ២.៣៦៤.២៥១ | ២.០៤៣.៧២០ | ១.៧១៨.៨០៥ | ១០៨% | +១៦% | +១៩% |
| | -ប្រគល់ផ្ទាល់ | - | ៥១០.០០០ | ៧៣០.៥៤៦ | ៥០២.១៩៥ | ៤៤៨.៣៨៩ | | | |
| | -ឆ្លងកាត់ឃ្លាំង - ទីលាន | - | ១.៦៨០.០០០ | ១.៦៣៣.៧០៤ | ១.៥៤១.៥២៥ | ១.២៧០.៤១៦ | | | |
| III | **បរិមាណនាវាសរុប** | គ្រឿង | ១.៨៣០ | ២.០២៣ | ១.៦៧៦ | ១.៦៧៩ | ១១១% | +២១% | -0,១៨% |
| | -នាវា-សាឡង់បណ្ដាប្រទេសផ្សេងៗ | - | ១.២៥០ | ១.៣៩៨ | ១.០៨៣ | ១.០៧៥ | | | |

| ល.រ | បរិយាយ | ឯកតា | ផែនការ ឆ្នាំ២០១៨ | អនុវត្ត ឆ្នាំ២០១៨ | អនុវត្ត ឆ្នាំ២០១៧ | អនុវត្ត ឆ្នាំ ២០១៦ | ប្រៀបធៀប (%) | កើន/ថយ (%) | |
|---|---|---|---|---|---|---|---|---|---|
| ក | ខ | គ | ១ | ២ | ៣ | ៤ | ៥=(២/១) | ៦=(២/៣)-១០០% | ៧ |
| | -នាវា-សាឡង់កម្ពុជា | - | ៩៥ | ៥៧ | ៧១ | ១០២ | | | |
| | -នាវា-សាឡង់ប្រេងឥន្ធនៈ | - | ៤៨៥ | ៥៦៨ | ៥២២ | ៥០២ | | | |
| IV | **បរិមាណនាវាអ្នកដំណើរទេសចរក្នុងស្រុក (ចេញ-ចូល)** | ជើង | **២.៦៥០** | **២.៥៦៩** | **២.៧០៦** | **២.០៩៦** | **៩៧%** | **- ៥%** | **+ ២៩%** |
| | - ភ្នំពេញ-សៀមរាប សៀមរាប-ភ្នំពេញ | - | ១៥០ | ១២៥ | ២៣៦ | ៧២ | | | |
| | - នាវាទេសចរណ៍ក្នុងក្រុង | - | ២.៥០០ | ២.៤៤៤ | ២.៤៧០ | ២.០២៤ | | | |
| V | **បរិមាណអ្នកដំណើរ និងទេសចរក្នុងស្រុក (ចេញ-ចូល)** | នាក់ | **១១.៦០០** | **១១.៤៩៦** | **១៣.៨៨០** | **៩.៩០៤** | **៩៩%** | **- ១៧%** | **+៨០%** |
| | - ភ្នំពេញ-សៀមរាប សៀមរាប-ភ្នំពេញ | - | ៤.៥០០ | ២.៧២៤ | ៥.៦៧៨ | ៣.៧០១ | | | |
| | - ទេសចរណ៍ក្នុងក្រុង | - | ៧.១០០ | ៨.៧៧២ | ៨.២០២ | ៦.២០៣ | | | |
| VI | **បរិមាណនាវាអ្នកដំណើរបរទេស និងទេសចរឆ្លងកាត់ (វៀតណាម)** | ជើង | **១.៧៦០** | **២.២៤៩** | **២.១២២** | **១.៥៩៤** | **១២៨%** | **+ ៦%** | **+៣៣%** |
| | - ចំនួននាវាភ្នំពេញ-ចូវដុក-ភ្នំពេញ | - | ១.២០០ | ១.៥០៤ | ១.៤៩៩ | ៩៩៧ | | | |
| | - ចំនួននាវាទេសចរណ៍ | - | ៥៦០ | ៧៤៥ | ៦២៣ | ៥៩៧ | ១៣៣% | +២០% | + ៤% |
| | **បរិមាណអ្នកដំណើរបរទេស និងទេសចរឆ្លងកាត់ (វៀតណាម)** | នាក់ | **២៧.២០០** | **៤៤.២៩០** | **៣៣.១៣៣** | **២៩.៤១៦** | **១៦៣%** | **+៣៤%** | **+ ១៣%** |
| | - ចំនួននាវាភ្នំពេញ-ចូវដុក-ភ្នំពេញ | - | ៥.២០០ | ១២.៤០០ | ៦.៤១៨ | ៤.១៧៤ | | | |
| | - ចំនួនភ្ញៀវទេសចរណ៍ | - | ២២.០០០ | ៣១.៨៩០ | ២៦.៧១៥ | ២៥.២៤២ | ១៤៥% | +១៩% | + ៦% |

*(ប្រភពៈនាយកដ្ឋានផែនការ/ទីផ្សារ)*

- បរិមាណទំនិញ-ប្រេងឥន្ធនៈឆ្លងកាត់ ក.ស.ភ. ក្នុងឆ្នាំ២០១៨ មានចំនួន ៣.១៣៤.៩៩៦តោន កើនឡើង ១៤% ធៀបនឹងការអនុវត្តក្នុងឆ្នាំ២០១៧ (២.៧៥៧.៦៦១ តោន) សម្រាប់រយៈពេល១ ឆ្នាំ២០១៨ នេះ ក.ស.ភ. សម្រេចបាន ១០៨% ធៀបនឹងផែនការឆ្នាំ ២០១៨ (២.៩០០.០០០ តោន)

- នាវាឆ្លងកាត់ ក.ស.ភ. ក្នុងឆ្នាំ២០១៨ មានចំនួន ២.០២៣គ្រឿង កើនឡើង ២១% ធៀបនឹងការអនុវត្តក្នុងឆ្នាំ២០១៧ (១.៦៧៦គ្រឿង) សម្រាប់រយៈពេល១ ឆ្នាំ២០១៨ ក.ស.ភ. សម្រេចបាន ១១១% ធៀបនឹងផែនការឆ្នាំ២០១៨ (១.៨៣០គ្រឿង)
- នាវាអ្នកដំណើរ និងទេសចរណ៍អន្តរជាតិក្នុងឆ្នាំ២០១៨ មានចំនួន ៧៤៥ជើង កើនឡើង ២០% ធៀបនឹងការអនុវត្តក្នុងឆ្នាំ២០១៧ (៦២៣ជើង) សម្រាប់រយៈពេល១ ឆ្នាំ២០១៨ នេះ ក.ស.ភ. សម្រេចបាន ១៣៣% ធៀបនឹងផែនការឆ្នាំ២០១៨ (៥៦០ជើង)
- បរិមាណកុងតឺន័រក្នុងឆ្នាំ២០១៨ មានចំនួន ២១៣.៥៧១TEUs កើនឡើង ១៦% ធៀបនឹងការអនុវត្តក្នុងឆ្នាំ២០១៧ (១៨៤.៨០៥ TEUs) សម្រាប់រយៈពេល១ ឆ្នាំ២០១៨នេះ ក.ស.ភ. សម្រេចបាន ១០៧% ធៀបនឹងផែនការឆ្នាំ២០១៨ (២០០.០០០TEUs)
- បរិមាណអ្នកដំណើរ និងទេសចរឆ្លងកាត់ ក.ស.ភ. ក្នុងឆ្នាំ២០១៨ មានចំនួន ៣១.៨៩០នាក់ កើនឡើង ១៩% ធៀបនឹងការអនុវត្តក្នុងឆ្នាំ២០១៧ (២៦.៧១៥នាក់) សម្រាប់រយៈពេល១ ឆ្នាំ២០១៨ ក.ស.ភ. សម្រេចបាន ១៤៥% ធៀបនឹងផែនការឆ្នាំ២០១៨ (២២.០០០នាក់)។

## ក្រាហ្វិក ស្តីពីការប្រៀបធៀបការអនុវត្តឆ្នាំ ២០១៨ - ឆ្នាំ២០១៧ - ២០១៦ និងផែនការឆ្នាំ២០១៨



## ១.២. ការអនុវត្តការងារជលធារាសាស្ត្រ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់គ្រឿងចក្រ

- <u>*ការងារជលធារាសាស្ត្រ*</u>

- សម្រាប់ឆ្នាំ២០១៨ ការងារគ្រប់គ្រងលើដំណើរការបូមស្តារ ដើម្បីយកខ្សាច់ផ្គត់ផ្គង់តម្រូវការប្រើប្រាស់ក្នុងស្រុក ដែលបូមចេញពីទីតាំងប្រឡាយស្តៅតាឯក និងទីតាំងប្រឡាយខ្សុំកោះកែវ មានបរិមាណសរុបចំនួន ៧៩៨.០០៦ម៉ែត្រគ្រីគុណ

- <u>*ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធ*</u>

- បានចាក់បេតុងអាម៉េចន្លោះផ្លូវRTG លេខ៤ និងលេខ៥ ទំហំ ២៥២មx២,៥មx២០សម នៅចំណតផែកុងតឺន័រ LM១៧
- បានសាងសង់ទីលានស្តុកកុងតឺន័រត្រជាក់ ស្ថិតនៅប្លង់ B នៃចំណតផែកុងតឺន័រLM១៧
- បានសាងសង់របងជុំវិញរោងស៊ីទែនប្រេង ប្រវែង ១៩០ម ស្ថិតនៅប្លង់Bនៃចំណតផែកុងតឺន័រLM១៧
- បានសាងសង់ច្រាំងទន្លេប្រវែង ៥៦០ម៉ែត្រនៅប្លង់ B នៅចំណតផែកុងតឺន័រLM១៧
- បានសាងសង់ទីលានស្តុកកុងតឺន័រជំហានទី២ (ប្លង់ B) នៅចំណតផែកុងតឺន័រLM១៧ ដែលអនុវត្ត ដោយក្រុមហ៊ុន សៀង ហៃ គ្រុប ជាអ្នកទទួលការសាងសង់
- បានពង្រឹងឆ្អឹងប៉ុងតុងផ្ទះទឹកគង្គា

- <u>*ការទិញ/បំពាក់គ្រឿងចក្រ ឬឧបករណ៍ថ្មី*</u>

- បានដាក់បង្គោលភ្លើងហ្វាចំនួន ១បង្គោល ស្ថិតក្នុងទីលានស្តុកសំបកកុងតឺន័រ (ប្លង់B) នៅចំណតផែកុងតឺន័រ LM១៧
- ទិញរថយន្ត Toyata Alphard (ពណ៌ស ឆ្នាំ២០១៨) ចំនួន ១គ្រឿង
- ទិញរថយន្ត Toyata Hilux Revo (ពណ៌ស ឆ្នាំ២០១៨) ចំនួន ៣គ្រឿង
- ទិញឧបករណ៍ Radio Data Terminal (Tally Board) FZ-G1 ចំនួន ១គ្រឿង
- ទិញឧបករណ៍ Radio Data Terminal (Honeywell) CK3X ចំនួន ១គ្រឿង
- ទិញចង្កៀងផ្តល់សញ្ញាសម្រាប់ផ្លូវនាវាចរណ៍ ចំនួន ៤គ្រឿង
- វិនិយោគលើការទិញដីនៅចំណតផែកុងតឺន័រLM១៧ ក្នុងទំហំ ២០.៣២៥,១៣ម៉ែត្រក្រឡា

## ២. ការប្រែប្រួលសំខាន់ៗ ពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

### ក. ការចុះកិច្ចសន្យាជួលដីជាមួយក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប

កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ ក.ស.ភ. បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប (ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់មេ YUE TAI GROUP) ស្តីពីការជួលដីរបស់កំពង់ផែស្វយ័តភ្នំពេញ ពីគល់ស្ពានជ្រោយចង្វាររហូតដល់ផ្សាររាត្រី ដើម្បីអភិវឌ្ឍជា "**មជ្ឈមណ្ឌលពាណិជ្ជកម្មធំៈ The City Gate**" រួមមាន អគារបណ្តុំការិយាល័យពាណិជ្ជកម្ម មជ្ឈមណ្ឌលសិល្បៈ ទីធ្លាសម្តែងវប្បធម៌សិល្បៈ ទីធ្លាសួនបាញ់ទឹក របាំលើទឹក និងផ្សារអណ្តែតទឹក ទីធ្លាសួនកម្សាន្តកំពង់ផែ និងសួនច្បារសាធារណៈ មជ្ឈមណ្ឌលទេសចរណ៍រាជធានីភ្នំពេញដ៏ឆ្លាតវៃ ការិយាល័យបច្ចេកវិទ្យា អគារស្នាក់នៅរួមបែបវប្បធម៌ អគារស្នាក់នៅរួមបែបថ្មៃប្រឌិតទំនើប និងសណ្ឋាគារលំដាប់ផ្កាយប្រាំ សាលតាំងពិព័រណ៍ មជ្ឈមណ្ឌលបេតិកភណ្ឌអរូបី និងសិប្បកម្ម និងវិចិត្រសាលបែបវប្បធម៌ ព្រះពុទ្ធសាសនា និងសកម្មភាពផ្សេងៗទៀត ដូចមានកំណត់ក្នុងលិខិតជូនដំណឹងលេខ ១៨៧ សជណ. ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៧ របស់ទីស្តីការ គណៈរដ្ឋមន្ត្រី។

កិច្ចសន្យាជួលនេះមានរយៈពេល ៥០ ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ២០៦៨។ ប្រាក់ឈ្នួលលើការជួលដីនេះ គឺជាការបង់ប្រាក់ឈ្នួលផ្តាច់តែម្តង ចំនួន ១៦.៥០០.០០០ (ដប់ប្រាំមួយលាន ប្រាំរយពាន់) ដុល្លារអាមេរិក សម្រាប់រយៈពេល ៥០ ឆ្នាំ រួមបញ្ចូលទាំងអាករលើតម្លៃបន្ថែម (VAT) ចំនួន ១០%។

ជាមួយនឹងគម្រោងអភិវឌ្ឍន៍ "**មជ្ឈមណ្ឌលពាណិជ្ជកម្មធំៈ The City Gate**" នេះ កំពង់ផែស្វយ័តភ្នំពេញ នៅតែបន្តរក្សាមុខងារប្រតិបត្តិការរបស់ទីតាំងជួលខាងលើ ជាចំណតផែលើកដាក់ទំនិញ និងចំណតផែទេសចរណ៍ជាតិ និងអន្តរជាតិ។

លើសពីនេះ ក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប យល់ព្រមចេញចំណាយផ្ទាល់ខ្លួនសាងសង់ហេដ្ឋារចនាសម្ព័ន្ធដើម្បី÷

- បម្រើឱ្យផលប្រយោជន៍សាធារណៈ ព្រមទាំងចូលរួមលើកកម្ពស់សោភ័ណភាពរាជធានីភ្នំពេញ រួមមាន÷
  - សាងសង់ច្រាំងទន្លេពីគល់ស្ពានជ្រោយចង្វារ មកដល់ផ្សាររាត្រី ដែលមានទឹកប្រាក់ចំនួន ១៩.០០០.០០០ (ដប់ប្រាំបួនលាន) ដុល្លារអាមេរិក
  - សាងសង់ផ្លូវថ្មើរជើង និងផ្លូវសម្រាប់រថយន្តធុនតូច ស្របមាត់ទន្លេពីគល់ស្ពានជ្រោយចង្វារ មកដល់ផ្សាររាត្រី ដែលមានទឹកប្រាក់ចំនួន ១១.០០០.០០០ (ដប់មួយលាន) ដុល្លារអាមេរិក
- និងដើម្បីប៉ះប៉ូវផលប៉ះពាល់ដល់អាជីវកម្មរបស់កំពង់ផែស្វយ័តភ្នំពេញដោយសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មី ឱ្យមកកំពង់ផែស្វយ័តភ្នំពេញ រួមមានៈ
  - សាងសង់អគាររដ្ឋបាលថ្មីរបស់ កំពង់ផែស្វយ័តភ្នំពេញ ដែលមានទឹកប្រាក់ចំនួន ១១.០០០.០០០ (ដប់មួយលាន) ដុល្លារអាមេរិក
  - សាងសង់ចំណតផែពហុបំណងថ្មី ចំនួន ២ ដែលមានទឹកប្រាក់ចំនួន ៣០.០០០.០០០ (សាមសិបលាន) ដុល្លារអាមេរិក។

### ខ. ការចុះកិច្ចព្រមព្រៀងជាមួយធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB)

នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៨ ក.ស.ភ. បានចុះកិច្ចព្រមព្រៀងជាមួយធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) ដើម្បីដាក់ប្រាក់ឈ្នួលដែលបានពីការជួលដីឱ្យទៅក្រុមហ៊ុន ចៀន ឈីង ថៃ គ្រុប ជាប្រាក់បញ្ញើមានកាលកំណត់ សម្រាប់រយៈពេល ២០(ម្ភៃ) ឆ្នាំ ដោយទទួលបានការប្រាក់ក្នុងការវិនិយោគនាថ្ងៃអនាគត ក្នុងអត្រាការប្រាក់ ៧.៧៥% ក្នុងមួយឆ្នាំ។

### គ. ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ "ចំណតផែកុងតឺន័រ LM១៧ ជំហានទី២ នៃគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរបស់កំពង់ផែស្វយ័តភ្នំពេញ"

នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ កំពង់ផែស្វយ័តភ្នំពេញ បានរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ **"ចំណតផែកុងតឺន័រ LM១៧ ជំហានទី២ នៃគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរបស់កំពង់ផែស្វយ័តភ្នំពេញ"** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួងសាធារណការ និងដឹកជញ្ជូន** និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំនៃក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិកក្រុមប្រឹក្សាភិបាល ក.ស.ភ. អាជ្ញាធរពាក់ព័ន្ធ កម្មករ-និយោជិត ក.ស.ភ. និងបងប្អូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។

ការពង្រីកហេដ្ឋារចនាសម្ព័ន្ធនៃចំណតផែកុងតឺន័រ LM១៧ ជំហានទី២នេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីឆ្លើយតបនឹងកំណើនកុងតឺន័រឆ្លងកាត់ជាបន្តបន្ទាប់ ដែលលើសពីសមត្ថភាពនៃចំណតផែកុងតឺន័រ ជំហានទី១ ដែលមានសមត្ថភាព ១៥០.០០០ ធីអ៊ីយូ ។ កំណើនកុងតឺន័រឆ្លងកាត់ ក.ស.ភ. ប្រចាំឆ្នាំមានជាមធ្យមចំនួន ១៤,៩% ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយពីឆ្នាំ២០១៣-២០១៧ ។ ជាក់ស្ដែង នៅឆ្នាំ២០១៦ បរិមាណកុងតឺន័រឆ្លងកាត់ ក. ស.ភ. មានចំនួន ១៥១.៧៨១ ធីអ៊ីយូ ដែលបរិមាណនេះដល់សមត្ថភាពនៃចំណតផែកុងតឺន័រ ជំហានទី១ ។

ការពង្រីកហេដ្ឋារចនាសម្ព័ន្ធនៃចំណតផែកុងតឺន័រ LM១៧ ជំហានទី២ ធ្វើនៅលើផ្ទៃដីទំហំ ៤,៥ ហិកតា ស្ថិតនៅភាគខាងជើងនៃ ចំណតផែកុងតឺន័រ LM១៧ ជំហានទី១ ដោយប្រើប្រាស់ទុនវិនិយោគផ្ទាល់របស់ ក.ស.ភ. ប្រមាណ ៩ លានដុល្លារអាមេរិក ដែលបានមកពីមូលនិធិបម្រុងវិនិយោគរបស់ ក.ស.ភ. និងទុនបានមកពីការបោះផ្សាយលក់ភាគហ៊ុននៅលើផ្សារមូលបត្រកម្ពុជា។ ការពង្រីកហេដ្ឋារចនាសម្ព័ន្ធចំណតផែកុងតឺន័រ LM១៧ ជំហានទី២ រួមមាន ការសាងសង់ទីលានផ្ទុកកុងតឺន័រ ការបំពាក់រថស្ទូចលើទីលានប្រភេទ RTG ចំនួន ៤ គ្រឿង និងរថយន្តដឹកជញ្ជូនចំនួន ២៤ គ្រឿង ។ ចំណតផែកុងតឺន័រ LM១៧ ទាំងជំហានទី១ និងជំហានទី២ មានសមត្ថភាពអាចផ្ទុកកុងតឺន័របានចំនួន ៣០០.០០០ ធីអ៊ីយូ ក្នុងមួយឆ្នាំ។

ជាជំហានបន្ទាប់ ក្រោយពីចំណតផែកុងតឺន័រ LM១៧ ជំហានទី២ បានបញ្ចប់ ក. ស. ភ. នឹងបន្តអនុវត្តគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធនៃចំណតផែកុងតឺន័រ LM១៧ ជំហានទី៣ នៅចន្លោះពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ លើផ្ទៃដីទំហំ ៥,៥ ហិកតា នៅភាគខាងជើងនៃចំណតផែកុងតឺន័រ LM១៧ ជំហានទី១ ក្នុងគោលដៅបង្កើនសមត្ថភាពផ្ទុករបស់ចំណតផែកុងតឺន័រ LM១៧ ឱ្យដល់ ៥០០.០០០ ធីអ៊ីយូ ក្នុងមួយឆ្នាំ។

## ៣- វេចនាសម្ព័ន្ធចំណូល

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | |
|---|---|---|---|---|
| | ពាន់រៀល | ប្រៀបធៀបនឹងចំណូលសរុប | ពាន់រៀល | ប្រៀបធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ក្រោមដងយោង(Stevedoring) | ៣៥.៣៧៧.៩៩១ | ៤២,២២% | ៣១.២៩៨.០៦២ | ៤១,០៥% |
| ចំណូលលើកដាក់លើទីលាន(LOLO) | ២៩.៧៣៤.៧៤២ | ៣៥,៤៧% | ២៦.៦៨៩.៣៥១ | ៣៤,៩៩% |
| ចំណូលពីកិច្ចការផែ | ១៣.៨០៨.៨០៩ | ១៦,៤៧% | ១២.៨០៤.៩២៩ | ១៦,៧៩% |
| ចំណូលពីច្រកទ្វារ | ៣.១៨៥.០២១ | ៣,៨០% | ២.៧១១.៤៨១ | ៣,៥៥% |
| ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ | ១.៤៩៦.២១៧ | ១,៧៨% | ១.៧២៣.៤៦៥ | ២,២៦% |
| ចំណូលពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ | ១២៦.៧៩៥ | ០,១៥% | ១៥៥.៦៣១ | ០,២០% |
| ចំណូលពីការវាស់ស្ទង់ | - | ០,០០% | ៧៧៣.១៨៦ | ១,០១% |
| ចំណូលពីការដឹកជញ្ជូន | ៨.៦៦៨ | ០,០១% | ២.៩៤៥ | ០,០០% |
| ចំណូលពីថ្លៃឈ្នួលថ្លឹងកុងតឺន័រ | ២៧.២៤៣ | ០,០៣% | ១១៣.៧៨២ | ០,១៥% |
| ចំណូលពីសេវាកម្មជួសជុល និងថែទាំកុងតឺន័រ | ៩១៤ | ០,០០% | ៨៨៥ | ០,០០% |
| ចំណូលពីការរើរៀបទំនិញ | ៥៧.៨៤៤ | ០,០៧% | - | ០,០០% |
| សរុប: | ៨៣.៨២៤.២៤៤ | ១០០,០០% | ៧៦.២៧៣.៧១៧ | ១០០,០០% |

# ផ្នែកទី៣
# អភិបាលកិច្ចសាជីវកម្ម

## ១.ភាគហ៊ុនិក

### ក. ការការពារសិទ្ធិរបស់ភាគហ៊ុនិក

សិទ្ធិរបស់ភាគហ៊ុនិក ត្រូវបានធានាដោយមហាសន្និបាតភាគហ៊ុនិក ដោយក្រុមប្រឹក្សាភិបាល និងដោយអគ្គនាយកដែលមានកំណត់នៅក្នុងលក្ខន្តិកៈរបស់ ក.ស.ភ. ដូចខាងក្រោម៖

- ភាគហ៊ុនិកប្រភេទ "ក" និងប្រភេទ "ខ" មានសិទ្ធិបោះឆ្នោតពេញលេញ ដោយ ១ភាគហ៊ុន ស្មើនឹង ១សម្លេង ក្នុងមហាសន្និបាតភាគហ៊ុនិករបស់ ក.ស.ភ. ទៅលើបញ្ហាដែលបានលើកឡើងក្នុង ការប្រជុំ ដែលក្នុងនោះមានដូចជា លទ្ធផលសកម្មភាពការងារប្រចាំឆ្នាំ គម្រោងផែនការវិនិយោគប្រចាំឆ្នាំ ការបោះឆ្នោតជ្រើសរើសអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិ ព្រមទាំងទៅលើបញ្ហា ដែលពាក់ព័ន្ធផលប៉ះពាល់ដល់ប្រយោជន៍របស់ភាគហ៊ុនិក ដូចជាការកាត់បន្ថយការតម្លើង ឬការកែប្រែផ្សេងទៀតទៅលើដើមទុនរបស់ ក.ស.ភ. ឬការផ្លាស់ប្តូរសិទ្ធិដែលពាក់ព័ន្ធនឹង ប្រភេទមូលបត្រដែលមានក្នុងដើមទុនរបស់ក្រុមហ៊ុន ឬការទិញមកវិញ ការទទួលយកដោយ ក.ស.ភ. នូវមូលបត្រណាមួយ ឬមូលបត្រដទៃទៀតរបស់ ក.ស.ភ. ការរំលាយបញ្ចូលគ្នារវាង ក.ស.ភ. និងក្រុមហ៊ុនដទៃទៀត ការរំលាយ ឬការជម្រះបញ្ជី ក.ស.ភ. ការធ្វើវិសោធនកម្មលក្ខន្តិកៈ។ ដោយឡែក ភាគហ៊ុនិកប្រភេទ "គ" មិនមានសិទ្ធិបោះឆ្នោតនោះទេ លើកលែងតែពាក់ព័ន្ធនឹងបញ្ហាមួយចំនួនដូចជា ការរំលាយបញ្ចូលគ្នារវាង ក.ស.ភ. និង ក្រុមហ៊ុនដទៃទៀត ការរំលាយ ឬការជម្រះបញ្ជី ក.ស.ភ. ការធ្វើវិសោធនកម្មលក្ខន្តិកៈ។
- ភាគហ៊ុនិកប្រភេទ "ក" និងប្រភេទ "ខ" មានសិទ្ធិទទួលភាគលាភដែលប្រកាសដោយក្រុមប្រឹក្សាភិបាលរបស់ ក.ស.ភ.។ លើសពីនេះទៀត ភាគហ៊ុនិកប្រភេទ "ក" ត្រូវបានធានានូវទិន្នផលភាគលាភប្រចាំឆ្នាំអប្បបរមាក្នុងអត្រា ៥% ក្នុងរយៈពេល ៥ឆ្នាំ។ រីឯភាគហ៊ុនិកប្រភេទ "គ" មិនមានសិទ្ធិទទួលបានភាគលាភនោះទេ។
- ភាគហ៊ុនិករបស់ ក.ស.ភ. មានសិទ្ធិទទួលបាននូវព័ត៌មានដែលទាក់ទងនឹង ក.ស.ភ. តាមរយៈការផ្តល់ព័ត៌មានទាន់ពេល ព័ត៌មានដែលផ្សព្វផ្សាយនៅលើគេហទំព័ររបស់ ក.ស.ភ. របាយការណ៍សមាយិក រួមមានរបាយការណ៍ប្រចាំត្រីមាស និងរបាយការណ៍ប្រចាំឆ្នាំ ព្រមទាំងព័ត៌មានដទៃទៀត តាមការស្នើសុំរបស់ភាគហ៊ុនិក។
- ភាគហ៊ុនិករបស់ ក.ស.ភ. មានសិទ្ធិបុព្វក្រ័យក្នុងការជាវបានមុននូវភាគហ៊ុនថ្មីដែលក្នុងប្រភេទតែមួយជាមួយនឹងភាគហ៊ុនដែលខ្លួនកំពុងកាន់កាប់ ដែលបោះចេញដោយ ក.ស.ភ. ស្របតាមសមាមាត្រនៃការកាន់កាប់ភាគហ៊ុនរបស់ខ្លួន។
- ភាគហ៊ុនិកប្រភេទ "ក" និងប្រភេទ "ខ" មានសិទ្ធិទទួលបានទ្រព្យសម្បត្តិដែលនៅសល់ បន្ទាប់ពីមានការជម្រះបញ្ជី ការរំលាយ ឬការបញ្ចប់របស់ ក.ស.ភ. បន្ទាប់ពីភាគហ៊ុនិកប្រភេទ "គ" ដែលមានសិទ្ធិបុរិមាក្នុងការទទួលទ្រព្យសម្បត្តិដែលនៅសល់នេះ។
- ភាគហ៊ុនិកប្រភេទ "ខ" មានសិទ្ធិធ្វើបរិវត្តន៍ភាគហ៊ុនទាំងអស់របស់ខ្លួនទៅជាភាគហ៊ុនប្រភេទ "ក" ដោយ ១ ភាគហ៊ុនប្រភេទ "ខ" ទៅជាភាគហ៊ុនប្រភេទ "ក" លុះត្រាតែមានលក្ខខណ្ឌ៖

- បន្ទាប់ពីរយៈពេល ៥ឆ្នាំ ចាប់ពីពេល ក.ស.ភ. បានចុះបញ្ជីលក់លើទីផ្សារមូលបត្រកម្ពុជា
- ភាគលាភអប្បបរមាដែលធានាជូនភាគហ៊ុនិកប្រភេទ "ក" ត្រូវបានបែងចែករួចរាល់
- សិទ្ធិបរិវត្តន៍ ត្រូវអនុវត្តចំពោះភាគហ៊ុនប្រភេទ "ខ" ទាំងអស់ដោយក្នុងនោះមានភាគហ៊ុនប្រភេទ "ខ" ដែលបោះផ្សាយ និងដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ។

### *ខ. ការបែងចែកប្រភេទភាគហ៊ុនិក (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨)*

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ២២៣ | ៧៦៦.៨២៥ | ៣,៧០% |
| | | នីតិបុគ្គល | ៤ | ៨៣១.៨៧០ | ៤,០២% |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ១៣០ | ៩៥៨.៨៥០ | ៤,៦៤% |
| | | នីតិបុគ្គល | ៣ | ២១៨.៩៥៨ | ១,០៦% |
| ចាប់ពី ៥% ដល់តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ១.៣៦០.៣៧០ | ៦,៥៨% |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ១៦.៥៤៧.៤៩២ | ៨០% |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |

### *គ. អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតដែលកាន់កាប់មូលបត្រកម្មសិទ្ធិរបស់ ក.ស.ភ.*

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ* |
|---|---|---|---|
| អភិបាល | ៥ | ១២៣.៨៦៣ | ០,៦០% |
| បុគ្គលិកជាន់ខ្ពស់ | ៧ | ៧៤.៣៣៣ | ០,៣៦% |
| និយោជិត | ៥៩ | ៧៤.៨៣១ | ០,៣៦% |
| ***សរុប*** | ***៧១*** | ***២៧៣.០២៧*** | ***១,៣២%*** |

**ទិន្នន័យភាគរយត្រូវបានយកចំនួនមូលបត្រប្រៀបធៀបនឹងចំនួនមូលបត្រមានសិទ្ធិបោះឆ្នោតសរុប (២០.៦៨៤.៣៦៥)។*

### *ឃ. ការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់*

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ពុំមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ទេ។

### *ង. អត្តសញ្ញាណភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥ភាគរយឡើងទៅ ស្ថិតក្នុងស្ថានភាពអសាធនភាព*

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ពុំមានភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥ភាគរយឡើងទៅ ស្ថិតក្នុងស្ថានភាពអសាធនភាពនោះទេ។

### ច. កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក

សម្រាប់ឆ្នាំ២០១៨ ក.ស.ភ. បានរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៣ នាថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៨ នៅទីស្នាក់ការកណ្តាល ក.ស.ភ. (ចំណតផែ TS៣) ដោយបានរាយការណ៍អំពីលទ្ធផលការងារឆ្នាំ២០១៧ និងទិសដៅអនុវត្តការងារឆ្នាំ២០១៨ ដូចខាងក្រោមៈ

- **លទ្ធផលការងារទូទៅសម្រេចបានឆ្នាំ២០១៧**
  - បានអនុវត្តគម្រោងសាងសង់ទីលានផ្ទុកកុងតឺន័រជំហានទី២ (ប្លង់B) និងសាងសង់ច្រាំងទន្លេប្រវែង ៥៦០ ម៉ែត្រ នៅចំណតផែកុងតឺន័រ LM១៧
  - បានបញ្ចប់ការងារសាងសង់ទីលានស្តុកសំបកកុងតឺន័រ ដោយចាក់ថ្មម៉ិច ក្នុងទំហំ ១២.០០០ ម៉ែត្រក្រឡា ស្ថិតក្នុងប្លង់ B នៅចំណតផែកុងតឺន័រ LM១៧
  - បានទិញដីនៅក្បែរចំណតផែកុងតឺន័រ LM១៧ ក្នុងទំហំ ៧.០៣៩,៥៥ ម៉ែត្រក្រឡា និងទិញដីទំហំ ១២.៥៤៥,២០ ម៉ែត្រក្រឡា សម្រាប់បម្រុងទុកអភិវឌ្ឍជាទីតាំងចំណតផែរណប នៅកោះរកា ស្រុកពាមជរ ខេត្តព្រៃវែង
  - បានទិញប៉ុងតុងទំហំ ១៥ម x ៤២ម x ២,៥ម ចំនួន ២ គ្រឿង ដើម្បីត្រៀមបម្រុងបំពាក់គ្រឿងចក្រលើកដាក់ សម្រាប់ផ្តល់សេវាកម្មលើកដាក់តាមដងទន្លេជូនអតិថិជន
  - បានទិញរថយន្តដឹកកុងតឺន័រចំនួន ១២ គ្រឿង និងសឺមីរ៉ឺម៉កដឹកកុងតឺន័រទំហំ ៤០ ហ្វីត ចំនួន ៣៦ គ្រឿង ដើម្បីសម្រួលដល់ការងារដឹកជញ្ជូនកុងតឺន័រនៅចំណតផែកុងតឺន័រ LM១៧។
- **លទ្ធផលការងារអាជីវកម្មឆ្នាំ២០១៧**
  - ស្ថិតិកុងតឺន័រឆ្លងកាត់ ក.ស.ភ. គិតជា ធីអ៊ីយូ រួមមាន ការនាំចូលជាសំបកមានចំនួន ៣២.៦១៤ ធីអ៊ីយូ និងការនាំចូលជាទំនិញមានចំនួន ៥៦.៨៩៥ ធីអ៊ីយូ និងការនាំចេញជាសំបកមានចំនួន ១៥.២០៧ ធីអ៊ីយូ និងការនាំចេញជាទំនិញមានចំនួន ៨០.០៨៩ ធីអ៊ីយូ
  - ស្ថិតិនាវាឆ្លងកាត់ ក.ស.ភ. រួមមាន
    - នាវាដឹកកុងតឺន័រ សញ្ជាតិបរទេស មាន ៣៣%
    - នាវាដឹកកុងតឺន័រ សញ្ជាតិកម្ពុជា មាន ៤%
    - នាវាដឹកទំនិញទូទៅ សញ្ជាតិបរទេស មាន ២០%
    - នាវាដឹកប្រេងឥន្ធនៈ និងហ្គាស មានចំនួន ២៦% និង
    - នាវាទេសចរណ៍អន្តរជាតិមានចំនួន ១៧%។
- **ស្ថានភាពភាគហ៊ុន ក្នុងឆ្នាំ២០១៧**
  - ភាគលាភឆ្នាំ២០១៧ ស្មើនឹង ៦% នៃតម្លៃ IPO
    - ភាគលាភដែលបែងចែកសរុបឆ្នាំ២០១៧ ស្មើនឹង ១.២៧០.៨៤៧.៣៨៦ រៀល
    - តម្លៃភាគហ៊ុនជាមធ្យមប្រចាំខែ និងប្រចាំថ្ងៃ ឆ្នាំ២០១៧ ស្មើនឹង ៥.០៩៥ រៀល
    - តម្លៃភាគហ៊ុនបច្ចុប្បន្នស្មើនឹង ៥.៣៩០ រៀល (គិតត្រឹមថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៨)
    - ចំនួនភាគហ៊ុនិកសរុបរបស់ ក.ស.ភ. បច្ចុប្បន្ន ស្មើនឹង ២៨៤ រូប ដែលក្នុងនោះរួមមាន នីតិបុគ្គលចំនួន ១០ ក្រុមហ៊ុន និងរូបវន្តបុគ្គល ចំនួន ២៧៤ រូប។

- **លទ្ធផលហិរញ្ញវត្ថុឆ្នាំ២០១៧**
  - ផលអាជីវកម្ម-សេវាកម្ម មានចំនួនសរុប ១៨.៨៥៦.២៩៦ ដុល្លារអាមេរិក កើនឡើងប្រមាណ ១៦% ធៀបនឹងការអនុវត្តឆ្នាំ២០១៦ ដែលមានចំនួន ១៦.៣០០.៤២២ ដុល្លារអាមេរិក
  - ចំណូលផ្សេងៗ មានចំនួនសរុប ៦០៣.៩៦៨ ដុល្លារអាមេរិក ថយចុះប្រមាណ ៣៨% ធៀបនឹងការអនុវត្តឆ្នាំ២០១៦ ដែលមានចំនួន ៩៦៧.៩០៤ ដុល្លារអាមេរិក
  - ចំណាយដំណើរការ (ចំណាយថ្លៃដើម និងចំណាយរដ្ឋបាលទូទៅ) មានចំនួនសរុប ១២.០២២.០១៣ ដុល្លារអាមេរិក កើនឡើងប្រមាណ ៧% ធៀបនឹងការអនុវត្តឆ្នាំ២០១៦ ដែលមានចំនួន ១១.២៣៩.៣៧៥ ដុល្លារអាមេរិក
  - ចំណាយហិរញ្ញប្បទាន មានចំនួន ១.២៥៤.៧៦៧ ដុល្លារអាមេរិក ថយចុះប្រមាណ ២% ធៀបនឹងការអនុវត្តឆ្នាំ២០១៦ ដែលមានចំនួន ១.២៧២.៣៨៥ ដុល្លារអាមេរិក
  - ចំណាយពន្ធប្រាក់ចំណេញមានចំនួនសរុប ៨២១.៦៥១ ដុល្លារអាមេរិក កើនឡើងប្រមាណ ២៣% ធៀបនឹងការអនុវត្តឆ្នាំ២០១៦ ដែលមានចំនួន ៦៦៩.១៧៦ ដុល្លារអាមេរិក
  - ប្រាក់ចំណេញសុទ្ធ មានចំនួនសរុប ៥.៣៦១.៨៣៣ ដុល្លារអាមេរិក កើនឡើងប្រមាណ ៣១% ធៀបនឹងការអនុវត្តឆ្នាំ២០១៦ ដែលមានចំនួន ៤.០៨៧.៣៩០ ដុល្លារអាមេរិក។
- **ផែនការអាជីវកម្មប្រតិបត្តិការ និងទិសដៅសម្រាប់ឆ្នាំ២០១៨**

**- ផែនការវិនិយោគឆ្នាំ២០១៨**
  - បញ្ចប់គម្រោងសាងសង់ទីលានផ្ទុកកុងតឺន័រជំហានទី២ (ប្លង់ B) និងសាងសង់ច្រាំងទន្លេប្រវែង ៥៦០ ម៉ែត្រ នៅចំណតផែកុងតឺន័រ LM១៧ ក្នុងឆ្នាំ២០១៨ ដើម្បីបង្កើនសមត្ថភាពផ្ទុកកុងតឺន័រឱ្យបានចំនួន ៣០០.០០០ ធីអ៊ីយូ ក្នុងមួយឆ្នាំ
  - បង្កើនឃ្លាំងត្រជាក់ និងឃ្លាំងស្ងួត នៅចំណតផែកុងតឺន័រ LM១៧
  - ទិញរថយន្តដឹកកុងតឺន័រចំនួន ២៤គ្រឿង និងស៊ីមីរ៉ឺម៉កដឹកកុងតឺន័រ ៤០ ហ្វីត ចំនួន ២៤គ្រឿង ដើម្បីផ្តល់សេវាដឹកជញ្ជូនក្រៅផែ
  - ដំឡើង Conveyor (មេគង្គលើ មេគង្គក្រោម ទន្លេសាប) ចំនួន ៤ខ្សែ ដើម្បីផ្តល់សេវាលើកដាក់ទំនិញនៅតាមដងទន្លេ។

**- ផែនការហិរញ្ញវត្ថុឆ្នាំ២០១៨**
  - គ្រោងបង្កើនចំណូលឱ្យបានចំនួន ២០.៤៩១.៩៥១ ដុល្លារអាមេរិក ស្មើនឹង ៩% បើធៀបនឹងការអនុវត្តជាក់ស្តែងឆ្នាំ២០១៧ ដែលមានចំនួន ១៨.៨៥៦.២៩៦ ដុល្លារអាមេរិក

- គ្រោងបង្កើនប្រាក់ចំណេញសុទ្ធនៃការិយបរិច្ឆេទ ឱ្យបានចំនួន ៥.៨១៦.៣៤១ ដុល្លារអាមេរិក កើនឡើង ៨% បើធៀបនឹងការអនុវត្តជាក់ស្តែងឆ្នាំ២០១៧ ដែលមានចំនួន ៥.៣៦១.៨៣៣ ដុល្លារអាមេរិក។

## ឆ. គោលនយោបាយភាគលាភ

### ឆ.១. គោលនយោបាយភាគលាភរបស់ ក.ស.ភ.

ដើម្បីលើកទឹកចិត្តដល់វិនិយោគិនដែលទិញភាគហ៊ុនប្រភេទ"ក" របស់ ក.ស.ភ. ក្រុមប្រឹក្សាភិបាល បានអនុម័តគោលនយោបាយភាគលាភពិសេស ដែលធានានូវទិន្នផលភាគលាភអប្បបរមាប្រចាំឆ្នាំ ស្មើនឹងចំនួន ៥% នៃទំហំវិនិយោគដោយគិតតាមថ្លៃមូលបត្រនៃ IPOសម្រាប់រយៈពេល ៥ ឆ្នាំបន្ទាប់ពីការចុះបញ្ជីលក់លើទីផ្សារមូលបត្រកម្ពុជា។ ការធានាទិន្នផលភាគលាភអប្បបរមាស្មើនឹងចំនួន ៥% នេះគឺនឹងផ្តល់ជូនចំពោះមូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោតប្រភេទ"ក" តែប៉ុណ្ណោះ។ រាជរដ្ឋាភិបាលដែលជាភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ"ខ" និងមូលបត្រកម្មសិទ្ធិគ្មានសិទ្ធិបោះឆ្នោតប្រភេទ"គ" មិនទទួលបានការធានាភាគលាភនេះទេ ។ ភាគលាភអប្បបរមានេះត្រូវបានធានានូវ ទិន្នផលភាគលាភប្រចាំឆ្នាំ អាចជាសាច់ប្រាក់ ឬជាភាគហ៊ុន។

ក្នុងករណីដែលភាគលាភអប្បបរមាត្រូវបានធានាជាសាច់ប្រាក់ គឺស្មើនឹងអត្រា ៥% នៃចំនួនភាគហ៊ុនប្រភេទ"ក" សរុប ដែលបានកាន់កាប់មុនថ្ងៃអិចឌីវីឌិនដ៍(Ex-Dividend Date) គុណនឹងថ្លៃធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

ប្រសិនបើភាគលាភអប្បបរមាត្រូវបានធានា ពុំអាចត្រូវបានបែងចែកពេញលេញក្នុងឆ្នាំសារពើពន្ធណាមួយទេ នោះចំណែកនៃភាគលាភអប្បបរមាត្រូវបានធានានឹងត្រូវបង្គរទៅឆ្នាំបន្ទាប់ ឬទៅពេលវេលាសមស្របណាមួយដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

ក្នុងករណីដែល ក.ស.ភ. បែងចែកភាគលាភអប្បបរមាត្រូវបានធានា ជាភាគហ៊ុន នោះចំនួនភាគហ៊ុនអប្បបរមាត្រូវបានធានា ត្រូវគណនាដោយយកភាគលាភអប្បបរមាត្រូវបានធានា ចែកនឹងថ្លៃបិទការជួញដូរ១ថ្ងៃ នៅមុនថ្ងៃអិចឌីវីឌិនដ៍ (Ex-Dividend Date)។

ក្រោយពីបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយក្រុមប្រឹក្សាភិបាល បើពិនិត្យឃើញថាមានប្រាក់ចំណេញ នោះក្រុមប្រឹក្សាភិបាលនៃ ក.ស.ភ. អាចសម្រេចបែងចែកប្រាក់ចំណេញនោះដើម្បី៖

- ទូទាត់នូវការខាតបង់ឆ្នាំសារពើពន្ធមុន
- ក្រោយពីបានទូទាត់នូវការខាតបង់ឆ្នាំសារពើពន្ធមុនហើយប្រសិនបើនៅមានប្រាក់ចំណេញ នោះក្រុមប្រឹក្សាភិបាលអាចប្រើប្រាស់ប្រាក់ចំណេញនេះសម្រាប់៖
  - ➢ ថ្លៃងសរសើរដល់ថ្នាក់ដឹកនាំនិងនិយោជិតតាមលក្ខខណ្ឌខាងក្រោម៖
    - បើប្រាក់ចំណេញនៅសល់មានចំនួនចាប់ពី៥% ដល់ ១០%នៃចំណាយដំណើរការរបស់ ក.ស.ភ. សរុបក្នុងឆ្នាំនោះ ប្រាក់ថ្លៃងសរសើរត្រូវស្មើនឹង ១ខែនៃប្រាក់បៀវត្សរបស់ថ្នាក់ដឹកនាំនិងនិយោជិតម្នាក់ៗសរុបជាមធ្យមប្រចាំឆ្នាំ
    - បើប្រាក់ចំណេញនៅសល់មានចំនួនលើសពី១០% ដល់ ២០% នៃចំណាយដំណើរការ សរុបរបស់ក.ស.ភ. ក្នុងឆ្នាំនោះ ប្រាក់ថ្លៃងសសើរត្រូវស្មើនឹង ២ខែនៃប្រាក់បៀវត្សរបស់ថ្នាក់ដឹកនាំនិងនិយោជិត សរុបជាមធ្យមប្រចាំឆ្នាំ

- បើប្រាក់ចំណេញលើសពី២០% នៃចំណាយដំណើរការសរុបរបស់ ក.ស.ភ. ក្នុងឆ្នាំនោះ ប្រាក់ថ្លៃងសសើរស្មើនឹង ៣ខែនៃប្រាក់បៀវត្សរបស់ថ្នាក់ដឹកនាំនិងនិយោជិតសរុបជាមធ្យមប្រចាំឆ្នាំ។

➢ បង្កើតមូលនិធិបម្រុងតាមច្បាប់ចំនួន ៥% និងមូលនិធិបម្រុងសេរីចំនួន ៥% នៃប្រាក់ចំណេញសុទ្ធ

➢ មូលនិធិ ៥% លើប្រាក់ចំណេញសម្រាប់បម្រើផលប្រយោជន៍សង្គម ដែលត្រូវកត់ត្រាចូលក្នុងបន្ទុកក្នុងឆ្នាំដែលធ្វើប្រតិ្តការចំណាយនោះ

➢ ប្រាក់ចំណេញដែលសល់ក្រោយការបែងចែកខាងលើ ត្រូវបែងចែកជាភាគលាភឱ្យភាគហ៊ុនិក ទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

➢ ប្រាក់ចំណេញនៅសល់ចុងក្រោយ ត្រូវបង្វិលចូលមូលនិធិអភិវឌ្ឍន៍ ក.ស.ភ.។

## *ឆ.២. ព័ត៌មានប្រវត្តិសាស្ត្រអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ*

### ❖ ការបែងចែកភាគលាភសម្រាប់ឆ្នាំ២០១៥

យោងតាមកិច្ចប្រជុំលើកទី១៧ អាណត្តិទី៥ របស់ក្រុមប្រឹក្សាភិបាល ក.ស.ភ. នាថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ក្រុមប្រឹក្សាភិបាលរបស់ ក.ស.ភ. បានសម្រេចធ្វើការបែងចែកភាគលាភសម្រាប់ ឆ្នាំ២០១៥ ជាសាច់ប្រាក់ ជូនភាគហ៊ុនិកដែលកាន់កាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ក" ដោយយកមូលដ្ឋានភាគលាភអប្បបរមាចំនួន ៥% ចែកនឹង ១០ (១/១០) ហើយភាគលាភសរុបត្រូវបែងចែក (Total Dividend) មានចំនួន ១០៥.៩០០.៧៧៥រៀល (មួយរយប្រាំលាន ប្រាំបួនរយពាន់ ប្រាំពីររយចិតសិបប្រាំរៀលគត់) ហើយភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (Dividend Per Share)មានចំនួន ២៥,៦០រៀល (ម្ភៃប្រាំរៀល និងហុកសិបសេន) ព្រមទាំងបានសម្រេចបង្ករភាគលាភសម្រាប់ឆ្នាំ២០១៥ ដោយទុកបូកជាមួយភាគលាភអប្បបរមា ឆ្នាំ២០១៦ ដែលនឹងធ្វើការទូទាត់ នៅក្នុងអំឡុង ខែមីនា ឬ ខែមេសា ឆ្នាំ២០១៧ ដោយផ្អែកលើហេតុផល ដូចខាងក្រោម៖

១- ក.ស.ភ. ទើបតែបានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិជាផ្លូវការនៅដំណាច់ ឆ្នាំ២០១៥ ប៉ុណ្ណោះ

២- ក.ស.ភ. ត្រូវការប្រាក់ចំណេញរក្សាទុក សម្រាប់អនុវត្តផែនការអភិវឌ្ឍន៍ ឆ្នាំ២០១៦ របស់ខ្លួន។

### ❖ ការបែងចែកភាគលាភសម្រាប់ឆ្នាំ២០១៦

យោងតាមកិច្ចពិភាក្សាក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៥ អាណត្តិទី៦ នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៧ អង្គប្រជុំបានសម្រេចលើការបែងចែកភាគលាភជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" របស់ ក.ស.ភ. ប្រចាំឆ្នាំ២០១៦ និងភាគលាភបង្ករឆ្នាំ២០១៥ ដូចខាងក្រោម៖

១. ភាគលាភដែលបែងចែកជូនភាគហ៊ុនិកកាន់កាប់មូលបត្រមានសិទ្ធិបោះឆ្នោតប្រភេទ "ក"

- ប្រភេទភាគលាភដែលត្រូវបែងចែក៖ ជាសាច់ប្រាក់
- រយៈពេលភាគលាភ៖ ប្រចាំឆ្នាំ២០១៦
- អនុបាតនៃការបែងចែកភាគលាភ៖ ៦,៣៩%
- ភាគលាភសរុបដែលត្រូវបែងចែក៖ ១.០៥៩.០៣៩.៤៨៨ រៀល

- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ៖ ២៥៦ រៀល
- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ៖ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧

២. ភាគលាភបង្គរប្រចាំឆ្នាំ២០១៥ ចំនួន ១០៥.៩០៣.៩៥៩ រៀល (ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិមានចំនួន ២៥,៦០ រៀល និងអនុបាតនៃការបែងចែកភាគលាភចំនួន ០,៨២% នឹងធ្វើការទូទាត់ជាមួយភាគលាភឆ្នាំ២០១៦។ ភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភបង្គរឆ្នាំ២០១៥ គឺជាភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិក ដែលប្រកាសយោងតាមកាលបរិច្ឆេទកំណត់ទុកនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧។ ភាគលាភសរុប (ប្រចាំឆ្នាំ២០១៦ និងភាគលាភបង្គរឆ្នាំ២០១៥) មានចំនួន ១.១៦៤.៩៤៣.៨៣៧រៀល នឹងបានទូទាត់រួចរាល់នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧។

❖ **ការបែងចែកភាគលាភសម្រាប់ឆ្នាំ២០១៧**

យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងកិច្ចប្រជុំលើកទី១០ អាណត្តិទី៦ នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ អង្គប្រជុំបានសម្រេចលើការបែងចែកភាគលាភប្រចាំឆ្នាំ ២០១៧ ជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" របស់ ក.ស.ភ. ដូចខាងក្រោម៖

- ភាគលាភដែលត្រូវបែងចែក៖ ជាសាច់ប្រាក់
- រយៈពេលភាគលាភ៖ ប្រចាំឆ្នាំ២០១៧
- អនុបាតនៃការបែងចែកភាគលាភ៖ ៥,៨៦%
- ភាគលាភសរុបដែលត្រូវបែងចែក៖ ១.២៧០.៨៤៧.៣៨៦ រៀល
- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ៖ ៣០៧ រៀល
- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ៖ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨
- កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ៖ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨

## ៣. ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា

### *ក. សមាសភាពក្រុមប្រឹក្សាភិបាល*

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ ក្លាយជាអភិបាល | កាលបរិច្ឆេទ បញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១. | ឯកឧត្តម **ហ៊ី បាវី** | ប្រធាន | ២២ មិថុនា ២០១៦ | ២១ មិថុនា ២០១៩ |
| ២. | ឯកឧត្តម **សួន រចនា** | សមាជិក | ២២ មិថុនា ២០១៦ | ២១ មិថុនា ២០១៩ |
| ៣. | ឯកឧត្តម **កែន សម្បត្តិ** | សមាជិក | ២២ មិថុនា ២០១៦ | ២១ មិថុនា ២០១៩ |
| ៤. | ឯកឧត្តម **ប៉ែន សុវិជាតិ** | សមាជិក | ២២ មិថុនា ២០១៦ | ២១ មិថុនា ២០១៩ |
| ៥. | លោក **ហ្វី អានវ៉ានិថ** | សមាជិក | ៦ មិថុនា ២០១៦ | ៥ មិថុនា ២០១៩ |
| ៦. | លោក **ឌិត សុចល** | សមាជិក | ៦ មិថុនា ២០១៦ | ៥ មិថុនា ២០១៩ |
| ៧. | លោកស្រី **ជួន សុខេម** | សមាជិក | ២២ មិថុនា ២០១៦ | ២១ មិថុនា ២០១៩ |

*ឈ្មោះលេខាធិការរបស់កំពង់ផែស្វយ័តភ្នំពេញ គឺលោក **គង់ ចាន់នី** ប្រធានលេខាធិការដ្ឋាន។*

### *ខ. ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត*

| ល.រ | ឈ្មោះរបស់អភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល ឬភាគហ៊ុនិក ឬ កម្មសិទ្ធករ ឬសហកម្មសិទ្ធិករ |
|---|---|---|---|
| ១ | ឯកឧត្តម **សួន រចនា** | ក្រុមហ៊ុន Star Shipping | ភាគហ៊ុនិក |
| ២ | លោក **ហ្វី អានវ៉ានិថ** | ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FTB) | អភិបាល |

### *គ. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល*

ក្រុមប្រឹក្សាភិបាលមានតួនាទី និងភារកិច្ចកំណត់ទិសដៅអភិវឌ្ឍន៍ និងត្រួតពិនិត្យការគ្រប់គ្រងទូទៅរបស់ ក.ស.ភ.។ ក្នុងក្របខណ្ឌនេះ ក្រុមប្រឹក្សាភិបាល មានអំណាចៈ

- សម្រេចលើផែនការអភិវឌ្ឍន៍ ក្នុងក្របខណ្ឌនៃការតម្រង់ទិស កំណត់ដោយរាជរដ្ឋាភិបាល
- ពិនិត្យអនុម័តផែនការអាជីវកម្ម សេវាកម្ម ផែនការហិរញ្ញវត្ថុ និងវិនិយោគរបស់ ក.ស.ភ.
- អនុម័តលើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍គណនេយ្យ ហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការចាត់ចែង និងភារកិច្ចទូទៅរបស់ ក.ស.ភ.
- ចាត់ចែងឱ្យដំណើរការនូវគណៈកម្មាធិការ និងគណៈកម្មការដូចមានកំណត់ដោយអត្ថបទស្តីពីការបង្កើត ក.ស.ភ. ឬដោយលក្ខន្តិកៈរបស់ ក.ស.ភ. និងបង្កើតបន្ថែមទៀតប្រសិនបើចាំបាច់
- សម្រេចចំនួនក្របខណ្ឌបុគ្គលិក ដែលអនុញ្ញាតសម្រាប់ ក.ស.ភ.

- វាយតម្លៃក្នុងចន្លោះពេលទៀងទាត់ នូវកម្រិតទំហំនៃការធ្វើឱ្យសម្រេចនូវគោលដៅដែលកំណត់ដោយ ក.ស.ភ. និងដាក់ចុះនូវវិធានការសម្រាប់កែលម្អចាំបាច់
- សម្រេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់ ក.ស.ភ. ព្រមទាំងលក្ខន្តិកៈ និងកាំបៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ និងលាភការសម្រាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាន
- កំណត់របបផែនការជ្រើសរើស ការតម្លើងឋានៈ និងការផ្តល់លាភការសម្រាប់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់
- ជ្រើសរើស និងកំណត់លាភការសម្រាប់ផ្តល់ឱ្យសវនការគណនី
- ធ្វើសំណើកែសម្រួលលក្ខន្តិកៈ
- កំណត់ថ្លៃឈ្នួលពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម សេវាកម្មលើកំពង់ផែ
- អនុម័តលើលទ្ធកម្មនានា យោងតាមច្បាប់ និងបទបញ្ញត្តិជាធរមាន
- សម្រេចលើការបើក និងបិទគ្រប់ការិយាល័យ សេវាដ្ឋាន សាខា ទីភ្នាក់ងារ ឬតំណាងទាំងអស់ដែលចាំបាច់សម្រាប់អនុវត្តឱ្យសម្រេចគោលដៅ និងភារកិច្ចរបស់ ក.ស.ភ.
- អនុម័តរាល់កិច្ចសន្យាទាំងឡាយណាដែលពុំអាចអនុវត្តតាមតារាងថ្លៃឈ្នួល និងតាមប្រកាសស្តីពីការគ្រប់គ្រងលទ្ធកម្មនៃសហគ្រាសសាធារណៈ ដែលអគ្គនាយកឆ្លងយោបល់ក្រុមប្រឹក្សាភិបាល។

# ក្រុមប្រឹក្សាភិបាល



**ឯកឧត្តម ហ៊ី បាវី**

ប្រធានក្រុមប្រឹក្សាភិបាល

អគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ

- ❖ <u>ជនជាតិ</u> ខ្មែរ
- ❖ <u>សញ្ជាតិ</u> ខ្មែរ
- ❖ <u>ថ្ងៃខែឆ្នាំកំណើត</u> ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៥៥
- ❖ <u>ប្រវត្តិនៃការសិក្សា</u>
  - ឆ្នាំ១៩៧៤ បានបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យដូនពេញ
  - ឆ្នាំ២០០៨ បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែករដ្ឋបាលធុរកិច្ចពីសកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី
  - ឆ្នាំ២០០៩ បានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ពីសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាកម្ពុជា។
- ❖ <u>បទពិសោធន៍ការងារ</u>
  - ឆ្នាំ១៩៧៩ បានចាប់បម្រើការងារនៅ ក.ស.ភ. រហូតមកដល់បច្ចុប្បន្ន
  - ពីឆ្នាំ២០០០ - បច្ចុប្បន្ន ជាអគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល ក.ស.ភ.។



**ឯកឧត្តម សួន រចនា**

សមាជិកក្រុមប្រឹក្សាភិបាល

តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន

- ❖ <u>ជនជាតិ</u> ខ្មែរ
- ❖ <u>សញ្ជាតិ</u> ខ្មែរ
- ❖ <u>ថ្ងៃខែឆ្នាំកំណើត</u> ថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៥៤
- ❖ <u>ប្រវត្តិនៃការសិក្សា</u>
  - ឆ្នាំ១៩៧៣ បានបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យ ១៨ មីនា

(បច្ចុប្បន្នវិទ្យាល័យព្រះយុគន្ធរ)

- ឆ្នាំ១៩៧៥ បានបញ្ចប់ការសិក្សាពីមហាវិទ្យាល័យវេជ្ជសាស្ត្រ។

❖ **បទពិសោធន៍ការងារ**

- ឆ្នាំ២០០៩ - បច្ចុប្បន្ន ជារដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន
- ឆ្នាំ២០១៥ - បច្ចុប្បន្ន ជាសមាជិកក្រុមប្រឹក្សាភិបាល នៃ ក.ស.ភ.។



**ឯកឧត្តម កែន សម្បត្តិ**

**សមាជិកក្រុមប្រឹក្សាភិបាល**

**តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

❖ **ជនជាតិ** ខ្មែរ

❖ **សញ្ជាតិ** ខ្មែរ

❖ **ថ្ងៃខែឆ្នាំកំណើត** ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៦៨

❖ **ប្រវត្តិនៃការសិក្សា**

- ឆ្នាំ១៩៩៥ បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកសេដ្ឋកិច្ច ពីសកលវិទ្យាល័យ Lomonosov State ប្រទេសរុស្ស៊ី
- ឆ្នាំ២០០០ បានបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែកគោលនយោបាយសាធារណៈ ពីសកលវិទ្យាល័យ Saitama ប្រទេសជប៉ុន
- ឆ្នាំ២០០៨ បានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ចពីសកលវិទ្យាល័យ International ប្រទេសអង់គ្លេស។

❖ **បទពិសោធន៍ការងារ**

- ឆ្នាំ២០០៩ -២០១៣ បំពេញតួនាទីជាទីប្រឹក្សា និងនាយករងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឆ្នាំ២០១៣-បច្ចុប្បន្ន +ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  + ជាសមាជិកក្រុមប្រឹក្សាភិបាល ក.ស.ភ.។



**ឯកឧត្តម ប៉ែន សុវិជាតិ**

សមាជិកក្រុមប្រឹក្សាភិបាល

តំណាងក្រសួងពាណិជ្ជកម្ម

- **ជនជាតិ** ខ្មែរ
- **សញ្ជាតិ** ខ្មែរ
- **ថ្ងៃខែឆ្នាំកំណើត** ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៦៣
- **ប្រវត្តិនៃការសិក្សា**
  - ឆ្នាំ១៩៩០ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចពីវិទ្យាស្ថានសេដ្ឋកិច្ចប្រទេសកម្ពុជា
  - ឆ្នាំ១៩៩៧ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកពាណិជ្ជសាស្ត្រ ពីសកលវិទ្យាល័យ New England ប្រទេសអូស្ត្រាលី។
- **បទពិសោធន៍ការងារ**
  - ឆ្នាំ១៩៩៨ - ២០០០ បំពេញតួនាទីជា អនុប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម
  - ឆ្នាំ២០០០ - ២០០៧ ជាអនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា
  - ឆ្នាំ២០០៧ - ២០១២ ជាប្រធាននាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់នៃក្រសួងពាណិជ្ជកម្ម
  - ពីដើមឆ្នាំ២០១២ - ឆ្នាំ២០១៤ បានបម្រើការងារជាអគ្គនាយករងនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
  - ពីឆ្នាំ២០១៤-បច្ចុប្បន្ន
    + ជាអគ្គនាយក នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសនៃក្រសួងពាណិជ្ជកម្ម
    + ជាសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញាកម្ពុជា
    + ជាសមាជិកក្រុមប្រឹក្សាភិបាល ក.ស.ភ.។



**លោក ហ្គី អានវ៉ានិថ**
សមាជិកក្រុមប្រឹក្សាភិបាល
អភិបាលឯករាជ្យ

- **ជនជាតិ** ខ្មែរ
- **សញ្ជាតិ** ខ្មែរ
- **ថ្ងៃ ខែ ឆ្នាំកំណើត** ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៥៣
- **ប្រវត្តិនៃការសិក្សា**
  - ១៩៥៩-១៩៧០ បានបញ្ចប់ការសិក្សានៅវិទ្យាល័យដេកាត (Lycée Descartes) រាជធានីភ្នំពេញ ប្រទេសកម្ពុជា
  - ១៩៧២ គណិតវិទ្យា ភាសាបារាំង នៅមហាវិទ្យាល័យ ស្តេនីឡា (Stanislas) ទីក្រុងម៉ុងរ៉េអាល់ ប្រទេសកាណាដា
  - ១៩៧៦ B.A.Sc. វិស្វកម្មឧស្សាហកម្ម, សាលាពហុបច្ចេកទេសនៃ សកលវិទ្យាល័យម៉ុងរ៉េអាល់ បាក់កាឡូរ៉េអា (Universite de Montreal Baccalaureat) ប្រទេសកាណាដា
  - ឆ្នាំ១៩៨០ អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម នៅសកលវិទ្យាល័យ វេស្ទើនអុងតារីយ៉ូ (Western Ontario University) ទីក្រុងឡុង ប្រទេសកាណាដា។

- **បទពិសោធន៍ការងារ**
  - សីហា ១៩៧៦-សីហា ១៩៧៨ ជំនួយការប្រធានផ្នែកបច្ចេកទេស នៃ Bechtel Quebec Ltd/ James Bay Energy Corporation
  - មិថុនា ១៩៨០-មីនា ១៩៨២ មន្ត្រីវិភាគឥណទាន នៃធនាគារ តូរ៉ុនតូ ដូមីញាន ក្រុងតូរ៉ុនតូ ប្រទេសកាណាដា
  - មីនា ១៩៨២-សីហា ១៩៨៣ មន្ត្រីតំបន់ នៃធនាគារ តូរ៉ុនតូ ដូមីញាន ក្រុងតូរ៉ុនតូ
  - សីហា ១៩៨៣-ឧសភា ១៩៨៤ ជំនួយការនាយក នៃធនាគារ តូរ៉ុនតូ ដូមីញាន ក្រុងតូរ៉ុនតូ
  - ឧសភា ១៩៨៤-ឧសភា ១៩៨៦ មន្ត្រីផ្នែកគណនេយ្យ (សាជីវកម្ម និងធនាគាររដ្ឋាភិបាល) នៃធនាគារ តូរ៉ុនតូ ដូមីញាន ក្រុងតូរ៉ុនតូ
  - មិថុនា ១៩៨៦-ធ្នូ ១៩៨៨ នាយកផ្នែកគណនេយ្យ (សាជីវកម្ម និងធនាគាររដ្ឋាភិបាល) នៃធនាគារម៉ុងរ៉េអាល់ ក្រុងម៉ុងរ៉េអាល់
  - ធ្នូ ១៩៨៨-ឧសភា១៩៩៤ ជំនួយការរតនាភិបាល នៃ The Laurentian Group Corporation ក្រុងម៉ុងរ៉េអាល់
  - មិថុនា ១៩៩៤ -មីនា២០០៤ នាយក និងជាប្រធានផ្នែកសាជីវកម្មនៃធនាគារ Credit Agricole Indosuez ភ្នំពេញ

- មេសា ២០០៣-កក្កដា ២០០៤ អគ្គលេខាធិការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
- កក្កដា ២០០៤-មិថុនា ២០០៥ ប្រធានខុទ្ទកាល័យ ក្រសួងសាធារណការ និងដឹកជញ្ជូន
- មិថុនា ២០០៥-ធ្នូ ២០០៥ នាយកជាន់ខ្ពស់នៃធនាគារ ANZ Royal ភ្នំពេញ
- ធ្នូ ២០០៥-មេសា ២០០៩ អគ្គនាយករង និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB)
- មីនា ២០០៣-បច្ចុប្បន្ន សាស្ត្រាចារ្យគម្រោងមូលនិធិអភិវឌ្ឍន៍តំបន់ទន្លេមេគង្គ (MPDF)/IFC
- មេសា ២០០៩-បច្ចុប្បន្ន អគ្គនាយក និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា(FTB)
- មិថុនា ២០១៦-បច្ចុប្បន្ន សមាជិកក្រុមប្រឹក្សាភិបាល ក.ស.ភ.។



**លោក ឱត សុចល**

**សមាជិកក្រុមប្រឹក្សាភិបាល**

**អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន**

- **ជនជាតិ** ខ្មែរ
- **សញ្ជាតិ** ខ្មែរ
- **ថ្ងៃ ខែ ឆ្នាំកំណើត** ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៩
- **ប្រវត្តិនៃការសិក្សា**
  - ឆ្នាំ១៩៩៦ មធ្យមសិក្សាទុតិយភូមិ វិទ្យាល័យកំពង់ថ្ម ខេត្តកំពង់ធំ
  - ឆ្នាំ១៩៩៦-២០០០ បរិញ្ញាបត្រជំនាញគណនេយ្យ នៅសកលវិទ្យាល័យ ជាស៊ីមកំចាយមារ ខេត្តព្រៃវែង
  - ឆ្នាំ២០០២-២០០៤ សញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុ នៅសកលវិទ្យាល័យ Wuhan University of Technology នៃប្រទេសចិន។
- **បទពិសោធន៍ការងារ**
  - តុលា ២០០១-ឧសភា ២០០៥ មន្ត្រីត្រួតពិនិត្យដល់ទីកន្លែង និងលើឯកសារនៃនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា
  - ឧសភា២០០៥-តុលា ២០០៦ ប្រធានផ្នែកទំនាក់ទំនងខាងហិរញ្ញប្បទានពាណិជ្ជកម្មនៃនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុសម្រាប់អាជីវកម្មនៃធនាគារ ANZ Royal
  - វិច្ឆិកា ២០០៦-មីនា២០០៨ ប្រធានផ្នែកទំនាក់ទំនងជាន់ខ្ពស់ទទួលបន្ទុកផ្នែកសាជីវកម្មនៃធនាគារ ANZ Royal

- មេសា ២០០៨-តុលា២០០៩ ប្រធានផ្នែកទំនាក់ទំនងនៃនាយកដ្ឋានកសិកម្ម និងពាណិជ្ជកម្ម នៃធនាគារ ANZ Royal ប្រទេសញូហ្សេឡែន
- តុលា ២០០៩-មីនា ២០១០ នាយកនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម នៃធនាគារ ANZ Royal
- មេសា ២០១០-មីនា ២០១៦ នាយកនាយកដ្ឋានសេវាកម្មធនាគារសម្រាប់ពាណិជ្ជកម្មនៃធនាគារ ANZ Royal
- មីនា ២០១៦-បច្ចុប្បន្ន អគ្គនាយករងនៃធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា(FTB)
- មិថុនា ២០១៦-បច្ចុប្បន្ន សមាជិកក្រុមប្រឹក្សាភិបាល ក.ស.ភ.។



## លោកស្រី ជួន សុខេម
**សមាជិកក្រុមប្រឹក្សាភិបាល**
**តំណាងនិយោជិតកំពង់ផែស្វយ័តភ្នំពេញ**

❖ <u>ជនជាតិ</u> ខ្មែរ
❖ <u>សញ្ជាតិ</u> ខ្មែរ
❖ <u>ថ្ងៃ ខែ ឆ្នាំកំណើត</u> ថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៦៨
❖ <u>ប្រវត្តិនៃការសិក្សា</u>
- ឆ្នាំ១៩៩២ បានបញ្ចប់មធ្យមសិក្សាទុតិយភូមិ ពីវិទ្យាល័យបាក់ទូក
- ឆ្នាំ២០០៧ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកគណនេយ្យ/ហិរញ្ញវត្ថុ ពីសកលវិទ្យាល័យធនធានមនុស្ស
- ឆ្នាំ២០០៨ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែករដ្ឋបាលសាធារណៈ ពីសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា។

❖ <u>បទពិសោធន៍ការងារ</u>
- ឆ្នាំ១៩៩៣-សីហា ២០០៥ បុគ្គលិកការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ
- សីហា ២០០៥-តុលា ២០០៨ ប្រធានក្រុមនៃអង្គភាពលទ្ធកម្ម ក.ស.ភ.
- តុលា ២០០៨-សីហា ២០១០ អនុប្រធានការិយាល័យរដ្ឋបាល ក.ស.ភ.
- សីហា ២០១០-សីហា ២០១៥ ប្រធានការិយាល័យរដ្ឋបាល ក.ស.ភ.
- សីហា ២០១៥-បច្ចុប្បន្ន ប្រធាននាយកដ្ឋានរដ្ឋបាល ក.ស.ភ.
- មិថុនា ២០១៦-បច្ចុប្បន្ន សមាជិកក្រុមប្រឹក្សាភិបាល ក.ស.ភ.។

## *ឃ. សេចក្តីសម្រេច និងលទ្ធផលការងាររបស់ក្រុមប្រឹក្សាភិបាល*

### ១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី៩ អាណត្តិទី៦ ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៨

- ❖ បានពិនិត្យ និងទទួលស្គាល់នូវរបាយការណ៍ស្តីពីលទ្ធផលបឋមផ្នែកអាជីវកម្ម និងហិរញ្ញវត្ថុឆ្នាំ២០១៧ របស់ ក.ស.ភ.
- ❖ បានពិនិត្យ និងសម្រេចឱ្យ ក.ស.ភ. ធ្វើកិច្ចសហការជាមួយក្រុមហ៊ុន KTC International Co., Ltd. ក្រោមទម្រង់ជាការជួលអចលនទ្រព្យ និងគ្រឿងចក្រវិញ ជំនួសឱ្យការចូលទុនធ្វើអាជីវកម្មរួមគ្នា
- ❖ បានពិនិត្យ និងសម្រេចឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន ខ្ចីថវិការបស់ ក.ស.ភ. ដើម្បីទិញកាណូតដឹកអ្នកដំណើរតាមផ្លូវទឹក Taxi Boat ចំនួន ២ គ្រឿង ហើយក្រសួងនឹងប្រគល់កាណូតទាំង ២ គ្រឿងនេះ ឱ្យនាយកដ្ឋានណាមួយ ឬអង្គភាពណាមួយក្រោមចំណុះក្រសួង ជាអ្នកធ្វើប្រតិបត្តិការសេវាដឹកអ្នកដំណើរតាមផ្លូវទឹកនេះ។ ក្រសួងនឹងសងត្រឡប់មកឲ្យ ក.ស.ភ. នូវកម្ចីខាងលើ ជាក្រោយវិញ។
- ❖ បានពិនិត្យ និងសម្រេចឱ្យ ក.ស.ភ. បន្តធ្វើការសហការជាមួយក្រុមហ៊ុន ហ្គ្រីន ត្រេដ (Green Trade) លើការបង្កើតរោងចក្រកែច្នៃស្រូវ-អង្ករ នៅចំណតផែកុងតឺន័រ LM១៧
- ❖ បានពិនិត្យ និងអនុញ្ញាតជាគោលការណ៍ឱ្យ ក.ស.ភ. ស្នើសុំអាជ្ញាបណ្ណពីក្រសួងរ៉ែ និងថាមពល មុននឹងចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU) ជាមួយក្រុមហ៊ុន Infunde Development Pte. Ltd. លើគម្រោងផ្គត់ផ្គង់ថាមពលអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ (Solar Power) នៅចំណតផែកុងតឺន័រ LM១៧។

### ២. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១០ អាណត្តិទី៦ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨

- ❖ បានសម្រេចអនុម័តរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទ២០១៧ ដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ KPMG
- ❖ បានពិភាក្សា និងសម្រេចលើការកំណត់ប្រាក់ថ្លៃងសរសើរជូនថ្នាក់ដឹកនាំ និងនិយោជិត ក.ស.ភ. ប្រចាំឆ្នាំ២០១៧ ចំនួន ៣ខែ នៃប្រាក់បៀវត្សសរុបជាមធ្យមប្រចាំឆ្នាំ និងការបែងចែកប្រាក់ចំណេញចូលមូលនិធិនានាសម្រាប់ឆ្នាំ២០១៧
- ❖ បានពិភាក្សា និងសម្រេចលើការបែងចែកភាគលាភជូនភាគហ៊ុនិករបស់ ក.ស.ភ. ប្រចាំឆ្នាំ២០១៧ និងការផ្ទេរចូលមូលនិធិអភិវឌ្ឍន៍សហគ្រាស ដូចខាងក្រោម៖

**ក).** បែងចែកភាគលាភជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ "ក" ចំនួន ៦% នៃថ្លៃ IPO ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

- ❖ ប្រភេទភាគលាភដែលត្រូវបែងចែក (Type of Dividend): ជាសាច់ប្រាក់
- ❖ រយៈពេលភាគលាភ (Period of dividend): ប្រចាំឆ្នាំ២០១៧
- ❖ អនុបាត នៃការបែងចែកភាគលាភ (Dividend Payout Ratio ): ៥,៨៦%
- ❖ ភាគលាភសរុបដែលត្រូវបែងចែក (Total Dividend): ១.២៧០.៨៤៧.៣៨៦ រៀល

- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (Dividend per Share): ៣០៧ រៀល
- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគលាភដែលត្រូវទទួលបានភាគលាភ (Record Date): ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨
- កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date): ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨។

**ខ**). បែងចែកភាគលាភជូនភាគហ៊ុនិកប្រភេទ "ខ" (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ទឹកប្រាក់ចំនួន ២.២៤២.៧០៨ ពាល់រៀល (ពីរប៊ីលាន ពីររយសែសិបពីរលាន ប្រាំពីររយប្រាំបីពាន់រៀលគត់)។

**គ**). ផ្ទេរចូលក្នុងមូលនិធិអភិវឌ្ឍន៍សហគ្រាសចំនួន ៨២% ដែលមានទឹកប្រាក់ចំនួន ១៦.០០៦.១៩៧ ពាន់រៀល (ស្មើនឹង ៣.៩៥៧.០៣២ ដុល្លារអាមេរិក)។

- បានពិភាក្សា និងសម្រេចលើការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៣ ឆ្នាំ២០១៨ របស់ ក.ស.ភ. ដូចខាងក្រោមៈ
  - កាលបរិច្ឆេទប្រារព្ធមហាសន្និបាតភាគហ៊ុនិកលើកទី៣: ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៨
  - កាលបរិច្ឆេទកំណត់ទុក (Record Date): ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨
  - ទីកន្លែងនៃមហាសន្និបាតភាគហ៊ុនិកលើកទី៣: សាលប្រជុំជាន់ទី៣ នៃអគាររដ្ឋបាលទីស្នាក់ការកណ្តាល (ចំណតផែថ្មTS៣) ដែលមានអាសយដ្ឋាន ស្ថិតនៅអគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
  - របៀបវារៈ នៃមហាសន្និបាតភាគហ៊ុនិកលើកទី៣ គឺរបាយការណ៍ស្តីពីលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងទិសដៅការងារអនុវត្តបន្តឆ្នាំ២០១៨។
- បានសម្រេចអនុម័តកិច្ចសន្យារវាង ក.ស.ភ. និងក្រុមហ៊ុន SYC CO., LTD. ស្តីពីការផ្តល់សេវាកម្មដឹកជញ្ជូន
- បានសម្រេចយល់ព្រមផ្ទេរសិទ្ធិឱ្យទៅអគ្គនាយក រួមនឹងប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ ចុះហត្ថលេខាបញ្ជាក់លើរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆ្នាំ ដោយអនុវត្តចាប់ពីឆ្នាំ២០១៨ នេះតទៅ
- បានសម្រេចអនុញ្ញាតឱ្យ ក.ស.ភ. ធ្វើលិខិតស្នើសុំការលើកលែងការពិន័យ និងកាតព្វកិច្ចផ្សេងៗទៅក្រសួងរ៉ែ និងថាមពល
- បានយល់ព្រមឱ្យ ក.ស.ភ. លើកគម្រោងបន្ថែមសម្រាប់សាងសង់ទីលានផ្ទុកកុងតឺន័រត្រជាក់បន្ថែមលើគម្រោងសាងសង់ទីលានជំហានទី២ នៅចំណតផែកុងតឺន័រ LM១៧ ដែលនឹងកំពុងដំណើរការសាងសង់ ដោយត្រូវអនុវត្តការងារតាមនីតិវិធីច្បាប់ជាធរមាន។

### ៣. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១១ អាណត្តិទី៦ កាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៨

- ❖ បានពិនិត្យ និងសម្រេចអនុម័តរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្មរយៈពេល ៥ខែ ដើមឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុរយៈពេល ៤ខែ ដើមឆ្នាំ២០១៨ របស់ ក. ស. ភ.
- ❖ បានពិនិត្យ និងសម្រេចឱ្យ ក. ស. ភ. ធ្វើការកែសម្រួលខ្លឹមសារនៃសេចក្តីព្រាងកិច្ចសន្យាស្តីពីការជួលដីរបស់កំពង់ផែស្វយ័តភ្នំពេញ ពីគល់ស្ពានជ្រោយចង្វារ មកដល់ផ្សាររាត្រីឱ្យទៅក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប រួចស្នើសុំការពិនិត្យ និងសម្រេចពីក្រសួងអាណាព្យាបាលទាំងពីរ
- ❖ បានពិនិត្យ និងសម្រេចទទួលស្គាល់ខ្ទង់ចំណាយរបស់ ក.ស.ភ. លើការផ្គត់ផ្គង់ប្រេង និងការថែទាំកាណូតដឹកអ្នកដំណើរតាមផ្លូវទឹក (Taxi Boat) និងសម្រេចឱ្យ ក.ស.ភ. ធ្វើរបាយការណ៍បូកសរុបចំណាយជូនទៅក្រសួងសាធារណការ និងដឹកជញ្ជូន នៅពេលមានការប្រគល់ទទួលពីក្រសួងសាធារណការ និងដឹកជញ្ជូន ឱ្យទៅរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីមានមូលដ្ឋានក្នុងការស្នើសុំការទូទាត់ត្រឡប់មក ក.ស.ភ. វិញ
- ❖ បានពិនិត្យ និងសម្រេចឱ្យ ក.ស.ភ. ឧបត្ថម្ភថវិកាចំនួន ១០០ លានរៀល ដល់ "មូលនិធិគន្ធៈបុប្ផាកម្ពុជា" សម្រាប់ឆ្នាំ២០១៨ និងបានអនុញ្ញាតជាគោលការណ៍ឱ្យ ក.ស.ភ. បន្តផ្តល់ការឧបត្ថម្ភគាំទ្រដល់មូលនិធិគន្ធៈបុប្ផាកម្ពុជា និងកាកបាទក្រហមកម្ពុជា នៅឆ្នាំបន្តបន្ទាប់ខាងមុខទៀត
- ❖ បានពិនិត្យ និងសម្រេចតែងតាំងលោកស្រី ជួន សុខេម ជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុជំនួសលោក តោ នី ដែលបានចូលនិវត្ត
- ❖ បានពិនិត្យ និងសម្រេចឯកភាពឱ្យ ក. ស. ភ. ទិញដីបន្ថែម ចំនួន ២ ហិកតា សម្រាប់ត្រៀមបម្រុងក្នុងការពង្រីកហេដ្ឋារចនាសម្ព័ន្ធ នៃចំណតផែកុងតឺន័រ LM១៧ នៅថ្ងៃខាងមុខ ដោយត្រូវអនុវត្តតាមនីតិវិធីនៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- ❖ បានពិនិត្យ និងសម្រេចអនុញ្ញាតជាគោលការណ៍ឱ្យ ក.ស.ភ. ធ្វើការសិក្សាពីផលសេដ្ឋកិច្ច និងតម្លៃជួលដីឃ្លាំងក្រុមហ៊ុន ហ្វ្រីន ត្រេដ ទំហំ ៧.៥៨៣,៦៨ ម៉ែត្រក្រឡា ជាមុនសិន រួចដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចលើលទ្ធផលនៃការសិក្សានាពេលក្រោយ។

### ៤. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១២ អាណត្តិទី៦ នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨

- ❖ បានពិនិត្យ និងសម្រេចអនុម័តរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម សម្រាប់រយៈពេល ៨ខែ ដើមឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុប៉ាន់ស្មាន (មិនទាន់ធ្វើសវនកម្ម) សម្រាប់រយៈពេល ៧ខែ ដើមឆ្នាំ២០១៨ របស់ ក.ស.ភ.
- ❖ បានពិនិត្យ និងសម្រេចឱ្យ ក.ស.ភ. ស្នើសុំការអនុញ្ញាតពីក្រសួងអាណាព្យាបាលទាំងពីរ (ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ដើម្បីលុបបំណុលសេវាវាស់ស្ទង់ដែលក្រសួងរ៉ែ និងថាមពល នៅជំពាក់ ក. ស. ភ. ចំនួន USD ៥៣.៥៨៨,១០ (ហាសិបបីពាន់ ប្រាំរយប៉ែតសិបប្រាំបីដុល្លារអាមេរិក និងដប់សេន)

❖ បានពិនិត្យ និងទទួលជ្រាបអំពីការធ្វើវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឱ្យទៅក្រុមហ៊ុន យុនណាន សេងមៅ អ៊ិនវេសមិន (ខេមបូឌា) ឯ.ក លើទីតាំងដីទីលានស្តុកសំបកកុងតឺន័រ (ICD) ដែលបានជួលឱ្យក្រុមហ៊ុន ដើម្បីអភិវឌ្ឍជា "មជ្ឈមណ្ឌលពាណិជ្ជកម្ម Triumph កម្ពុជា" សម្រាប់ឱ្យក្រុមហ៊ុនប្រើប្រាស់ក្នុងគោលបំណងស្របតាមផ្លូវច្បាប់

❖ បានពិនិត្យ និងសម្រេចឱ្យ ក.ស.ភ. ៖

+ សម្របសម្រួលជាមួយជាមួយភាគីក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប ដោះស្រាយបញ្ហានានា ដែលនៅសេសសល់
+ លើកសំណើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលយកសំណូមពរលើការស្នើសុំពន្យារពេលក្នុងការបង់ប្រាក់ឈ្នួលរបស់ក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប
+ ធ្វើរបាយការណ៍មួយជូនទៅក្រសួងអាណាព្យាបាលទាំងពីរ អំពីការដោះស្រាយផលប៉ះពាល់ ពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍ "មជ្ឈមណ្ឌលពាណិជ្ជកម្មចំរុះ THE CITY GATE"

❖ បានពិនិត្យ និងសម្រេចឱ្យ ក.ស.ភ. លើកសំណើសុំធ្វើការរុះរើ ឬផ្លាស់ប្តូរទៅទីតាំងថ្មីនូវអគារ ឬឃ្លាំង នៅលើទីតាំងទាំង ៣ កន្លែង របស់ ក.ស.ភ. ដូចជានៅទីតាំងដី ICD, ចំណតផែកុងតឺន័រ LM១៧, នៅទីតាំងដី ក.ស.ភ. ពីគល់ស្ពានជ្រោយចង្វារ ដល់ផ្សាររាត្រី ជាកញ្ចប់ទៅក្រសួងអាណាព្យាបាលទាំងពីរ ដើម្បីស្នើសុំបង្កើតគណៈកម្មការចុះពិនិត្យ និងវាយតម្លៃសំណង់អគារ ឬឃ្លាំង ដែលមានក្នុងបញ្ជីសារពើភ័ណ្ឌរបស់ ក.ស.ភ. មុននឹងធ្វើការរុះរើ ឬវាយកំទេចចោល

❖ បានពិនិត្យ និងសម្រេចឱ្យ ក.ស.ភ. ស្នើសុំការបំភ្លឺពីមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ លើការគិតពន្ធប្រភេទផ្សេងៗ នៃកញ្ចប់ថវិកាដែលទទួលបានពីការជួលដីឱ្យទៅក្រុមហ៊ុន ចៀន ឈឹង ថៃ គ្រុប មុននឹងមានវិធានការជាក្រោយ

❖ បានពិនិត្យ និងសម្រេចទុកការស្នើនូវភាគលាភពិសេសពីសំណាក់ភាគហ៊ុនិកឯកជន ស្ថិតនៅក្នុងការពិចារណាជាក្រោយទៀត ដោយរង់ចាំពិនិត្យមើលលទ្ធផលអាជីវកម្មនាបំណាច់ឆ្នាំ២០១៨ របស់ ក.ស.ភ. ក្រោយពីការបិទបញ្ជី និងធ្វើសវនកម្មរួចដោយសវនករឯករាជ្យ

❖ បានពិនិត្យ និងអនុញ្ញាតឱ្យ ក.ស.ភ. ពិនិត្យ និងចរចាអំពីតម្លៃជួលដីជាមួយក្រុមហ៊ុន ហ្វ្រើន គ្រេដ ឱ្យបានសមស្របដោយគោរពទៅតាមនីតិវិធី នៃបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន រួចលើកសំណើសុំការអនុញ្ញាតជួលទីតាំងដីខាងលើនេះ ពីក្រសួងអាណាព្យាបាលបច្ចេកទេស (ក្រសួងសាធារណការ និងដឹកជញ្ជូន) និងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

### ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៣ អាណត្តិទី៦ នាថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨

❖ បានពិនិត្យ និងអនុម័តលើរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម សម្រាប់រយៈពេល ១១ខែ ដើមឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុ សម្រាប់រយៈពេល ១០ខែ ដើមឆ្នាំ២០១៨ របស់ ក.ស.ភ.

- បានពិនិត្យ និងអនុម័តផែនការអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ឆ្នាំ២០១៩ របស់ ក. ស. ភ.
- បានពិភាក្សា និងសម្រេចស្នើឱ្យ ក.ស.ភ. សហការជាមួយភាគីកូរ៉េ ធ្វើការសិក្សាលម្អិតបន្ថែមអំពីផលសេដ្ឋកិច្ច, Return on Investment សម្រាប់ ក.ស.ភ. ផ្ទាល់ និងអំពីរយៈពេលដែល ក.ស. ភ. អាចមានលទ្ធភាពទទួលបានផលចំណេញពីគម្រោងនេះត្រលប់មកវិញជាមុន មុននឹងធ្វើការពិចារណាលើការស្នើសុំឥណទានសម្បទានពីសាធារណរដ្ឋកូរ៉េ ជាក្រោយ ហើយស្នើឱ្យ ក.ស.ភ. ធ្វើលិខិតផ្លូវការមួយទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនដំណឹងទៅភាគីកូរ៉េអំពីការសម្រេចនេះ
- បានពិនិត្យ ពិភាក្សា និងឯកភាពលើតម្លៃជួលដីជាមួយក្រុមហ៊ុនហ្វ្រីន ត្រេដ ដើម្បីបង្កើតជាចំណតផែស្ងួត និងសម្រាប់ផ្តល់សេវាកម្មពាក់ព័ន្ធនឹងឡូជីស្ទីក ពាណិជ្ជកម្ម ឧស្សាហកម្ម និងទេសចរណ៍ និងស្នើឱ្យ ក.ស.ភ. លើកសំណើទាំងអស់នេះ ជូនក្រសួងអាណាព្យាបាលទាំងពីរ ដើម្បីសុំការសម្រេចយល់ព្រម
- បានពិនិត្យ ពិភាក្សា និងឯកភាពសម្រេចលើការបោះឆ្នោតជ្រើសតាំង និងជ្រើសរើសសមាសភាពនៃក្រុមប្រឹក្សាភិបាល អាណត្តិទី៧ ដូចខាងក្រោម÷
  - សម្រាប់អភិបាលជាតំណាងនិយោជិត, អភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ក.ស.ភ. នឹងរៀបចំការបោះឆ្នោតជ្រើសតាំងផ្អែកតាមបែបបទ និងនីតិវិធី ដែលបានកំណត់
  - សម្រាប់អភិបាលផ្សេងទៀត តំណាងមកពីក្រសួងពាក់ព័ន្ធដូចជា ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និងក្រសួងពាណិជ្ជកម្ម ក.ស.ភ. នឹងស្នើទៅក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីគោរពស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល លើការរក្សាទុកសមាសភាពដដែល ក្នុងអាណត្តិទី៧ នៃក្រុមប្រឹក្សាភិបាលរបស់ ក.ស.ភ.។
  - ចំពោះការចូលកាន់ដំណែងរបស់សមាជិកនៃក្រុមប្រឹក្សាភិបាលអាណត្តិទី៧, កំណត់យកកាលបរិច្ឆេទនៃការតែងតាំងក្រុមប្រឹក្សាភិបាលអាណត្តិទី៧ ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល គឺជាពេលវេលានៃការចូលកាន់តំណែងរបស់សមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី៧ ដើម្បីបង្កលក្ខណៈងាយស្រួល ក្នុងដំណើការរៀបចំការបោះឆ្នោតជ្រើសតាំង និងការរៀបចំស្នើតែងតាំងក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិបន្តបន្ទាប់ទៀត។
- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យក្រុមហ៊ុន យុនណាន សេងម៉ៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក ប្តូរឈ្មោះគម្រោងពី "មជ្ឈមណ្ឌលផ្គត់ផ្គង់គ្រឿងសំណង់ CMSC" ទៅជា "មជ្ឈមណ្ឌលពាណិជ្ជកម្ម Triumph កម្ពុជា" វិញ ដោយ ក.ស.ភ. ត្រូវស្នើសុំការសម្រេចពីក្រសួងអាណាព្យាបាលទាំងពីរជាបន្តទៀត។

### *ង. ការបណ្តុះបណ្តាលអភិបាល*

សម្រាប់ឆ្នាំ២០១៨ អភិបាលរបស់ ក.ស.ភ. ចំនួន ១រូប គឺ ឯកឧត្តម **កែន សម្បត្តិ** អភិបាលតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលការបណ្តុះបណ្តាលស្តីពី "អ្នកដឹកនាំក្នុងការអភិវឌ្ឍ

(Leaders in Development)" របស់ Harvard Kennedy School ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ នៅទីក្រុង Cambridge រដ្ឋ Massachusetts នៃសហរដ្ឋអាមេរិក។

### *ច. គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល*

សម្រាប់ឆ្នាំ២០១៨ ក.ស.ភ. ពុំមានបង្កើតគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាលបន្ថែមទេ។

## ៤. បុគ្គលិកជាន់ខ្ពស់

### ក. សមាសភាពបុគ្គលិកជាន់ខ្ពស់



**ឯកឧត្តម ហ៊ី បាវី**

អគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ

- <u>ជនជាតិខ្មែរ</u> — សញ្ជាតិខ្មែរ
- <u>ថ្ងៃ ខែ ឆ្នាំកំណើត</u> — ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៥៥
- <u>ប្រវត្តិនៃការសិក្សា</u>
  - ឆ្នាំ១៩៧៤ — បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យដូនពេញ
  - ឆ្នាំ២០០៨ — បញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែករដ្ឋបាលធុរកិច្ចពីសកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី
  - ឆ្នាំ២០០៩ — បញ្ចប់ថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ពីសកលវិទ្យាល័យចំរើនពហុ-បច្ចេកវិទ្យាកម្ពុជា។
- <u>បទពិសោធន៍ការងារ</u>
  - ឆ្នាំ១៩៧៩ — បានចាប់បម្រើការងារនៅ ក.ស.ភ. រហូតមកដល់បច្ចុប្បន្ន
  - ពីឆ្នាំ២០០០ - បច្ចុប្បន្ន — ជាអគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល ក.ស.ភ.។



**លោក ម៉ម រិទ្ធី**

មន្ត្រីត្រួតពិនិត្យរដ្ឋ

- <u>ជនជាតិខ្មែរ</u> — សញ្ជាតិខ្មែរ
- <u>ថ្ងៃ ខែ ឆ្នាំកំណើត</u> — ថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧២
- <u>ប្រវត្តិនៃការសិក្សា</u>
  - ឆ្នាំ១៩៨៥ — បញ្ចប់ថ្នាក់មធ្យមសិក្សាកំរិត២ នៅសាលាដូនពេញ

- ឆ្នាំ១៩៩៦ — បញ្ចប់ថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចកសិកម្ម ពីសាកលវិទ្យាល័យកសិកម្ម និងព្រៃឈើ ទីក្រុងហូជីមិញ ប្រទេសវៀតណាម
- ឆ្នាំ២០០៧ — ទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ពីសកលវិទ្យាល័យឯកទេសនៃកម្ពុជា។

❖ **បទពិសោធន៍ការងារ**

- ឆ្នាំ១៩៩១ — បានចូលបម្រើការងារជាមន្ត្រីនៅនាយកដ្ឋានរបបគណនេយ្យនៃក្រសួងហិរញ្ញវត្ថុ
- ពីឆ្នាំ២០១៣-បច្ចុប្បន្ន — ជាអនុប្រធាននាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពីឆ្នាំ២០០១-បច្ចុប្បន្ន — ជាមន្ត្រីត្រួតពិនិត្យរដ្ឋអមក.ស.ភ.។



**លោកស្រី ជួន សុខេម**
**អគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ**

❖ **ជនជាតិ** — ខ្មែរ
❖ **សញ្ជាតិ** — ខ្មែរ
❖ **ថ្ងៃ ខែ ឆ្នាំកំណើត** — ថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៦៨
❖ **ប្រវត្តិនៃការសិក្សា**

- ឆ្នាំ២០០៧ — បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យហិរញ្ញវត្ថុពីសកលវិទ្យាល័យធនធានមនុស្ស បន្ទាប់មកទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែករដ្ឋបាលសាធារណៈនៅសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា

❖ **បទពិសោធន៍ការងារ**

- ឆ្នាំ១៩៨៦ — បានចូលបម្រើការងារនៅ ក.ស.ភ.
- ឆ្នាំ២០០៩ — ជាអនុប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ
- ឆ្នាំ២០១០-២០១៥ — ជាប្រធានការិយាល័យរដ្ឋបាល
- ឆ្នាំ២០១៥- ខែមិថុនា ឆ្នាំ២០១៨ — ជាប្រធាននាយកដ្ឋានរដ្ឋបាល
  ខែមិថុនា ឆ្នាំ២០១៨-បច្ចុប្បន្ន — ជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ។



## លោក ភុយ ម៉ុនធន

**អគ្គនាយករងបច្ចេកទេស**

- ជនជាតិ ខ្មែរ
- សញ្ជាតិ ខ្មែរ
- ថ្ងៃ ខែ ឆ្នាំកំណើត ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៦៤
- ប្រវត្តិនៃការសិក្សា
  - ឆ្នាំ១៩៨៨ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ
  - ឆ្នាំ១៩៩៤ បញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រម៉ាស៊ីន ពីសកលវិទ្យាល័យសំណង់ម៉ាស៊ីនលើកដាក់
  - ឆ្នាំ២០០០ បញ្ចប់ថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្របច្ចេកទេស នៅសកលវិទ្យាល័យសាន់ពែទែរប៊ួកនៃប្រទេសរុស្ស៊ី។
- បទពិសោធន៍ការងារ
  - ឆ្នាំ១៩៨៥ ចូលបម្រើការងារនៅ ក.ស.ភ.
  - ឆ្នាំ២០០៩-២០១៥ ជានាយកវិស្វកម្ម
  - ខែសីហា ឆ្នាំ២០១៥-កញ្ញា ឆ្នាំ២០១៦ ជាប្រធាននាយកដ្ឋានវិស្វកម្ម
  - ខែកញ្ញា ឆ្នាំ២០១៦ ដល់បច្ចុប្បន្ន ជាអគ្គនាយករងទទួលបន្ទុកបច្ចេកទេស។



## លោក ហៀក តិរុណា

**អគ្គនាយករងកិច្ចការផែ**

- ជនជាតិ ខ្មែរ
- សញ្ជាតិ ខ្មែរ
- ថ្ងៃ ខែ ឆ្នាំកំណើត ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៧២
- ប្រវត្តិនៃការសិក្សា
  - ឆ្នាំ១៩៩០ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ

- ឆ្នាំ១៩៩៧ បញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្របើកបរនាវាផ្លូវសមុទ្រ (Master of Science Degree in Engineering of Navigation on Sea Routes) ពីសកលវិទ្យាល័យ Murmansk State Technical នៃប្រទេសរុស្ស៊ី
- ឆ្នាំ២០០១ បញ្ចប់ថ្នាក់អនុបណ្ឌិត (MBA-Maritime Management) ពីសកលវិទ្យាល័យ Australian Maritime នៃប្រទេសអូស្ត្រាលី។

❖ <u>បទពិសោធន៍ការងារ</u>

- ឆ្នាំ១៩៩៧ ចូលបម្រើការងារនៅ ក.ស.ភ.
- ឆ្នាំ២០១១ ជានាយកផ្នែកជលធារាសាស្ត្រ
- ឆ្នាំ២០១៨ - បច្ចុប្បន្ន ជាអគ្គនាយករងកិច្ចការផែ។



**លោកស្រី ហ៊ី ផានិន**

**អគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ**

❖ <u>ជនជាតិ</u> ខ្មែរ

❖ <u>សញ្ជាតិ</u> ខ្មែរ

❖ <u>ថ្ងៃ ខែ ឆ្នាំកំណើត</u> ថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៨៥

❖ <u>ប្រវត្តិនៃការសិក្សា</u>

- ឆ្នាំ២០០៣ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ពីវិទ្យាល័យ Killester
- ឆ្នាំ២០០៨ បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកភ័ស្តុភារ និងការគ្រប់គ្រងបណ្ដាញផ្គត់ផ្គង់នៅសកលវិទ្យាល័យ RMIT
- ឆ្នាំ២០១២ បញ្ចប់ថ្នាក់អនុបណ្ឌិតជំនាញលើការគ្រប់គ្រង ពីសកលវិទ្យាល័យ Charles Sturt University ពីប្រទេសអូស្ត្រាលី

❖ <u>បទពិសោធន៍ការងារ</u>

- ខែមិថុនា ឆ្នាំ២០០៨ បានចូលបម្រើការងារនៅ ក.ស.ភ.
- ខែកញ្ញា ឆ្នាំ២០០៩ - ខែធ្នូ ឆ្នាំ២០១១ ជានាយកផែនការ/ទីផ្សារ
- ខែសីហា ឆ្នាំ២០១៥ - ខែកុម្ភៈ ឆ្នាំ២០១៧ ជាប្រធាននាយកដ្ឋានផែនការ/ទីផ្សារ
- ខែកុម្ភៈ ឆ្នាំ២០១៧ - បច្ចុប្បន្ន ជាអគ្គនាយករងទទួលបន្ទុកអាជីវកម្ម/ប្រតិបត្តិការផែ។



## លោក គែវ សុផាណ្ណារ៉ា

ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង

| | |
|---|---|
| ❖ ជនជាតិ | ខ្មែរ |
| ❖ សញ្ជាតិ | ខ្មែរ |
| ❖ ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៣ |
| ❖ ប្រវត្តិនៃការសិក្សា | |
| - ឆ្នាំ១៩៩១ | បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ |
| - ឆ្នាំ២០០៥ | បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកវិស្វករ ពីវិទ្យាស្ថានពហុបច្ចេកវិទ្យាភ្នំពេញ និង ទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសកលវិទ្យាល័យជាតិគ្រប់គ្រង។ |
| ❖ បទពិសោធន៍ការងារ | |
| - ពីខែមករា ឆ្នាំ១៩៩៧ | បានចូលបម្រើការងារនៅ ក.ស.ភ. |
| - ឆ្នាំ២០១០ | ជាប្រធានការិយាល័យផែនការ |
| - ឆ្នាំ២០១៤-២០១៥ | ជាប្រធានអង្គភាពលទ្ធកម្ម |
| - ឆ្នាំ២០១៥-បច្ចុប្បន្ន | ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង។ |



## លោក ជី វិចិត្រ

ប្រធាននាយកដ្ឋានរដ្ឋបាល

| | |
|---|---|
| ❖ ជនជាតិ | ខ្មែរ |
| ❖ សញ្ជាតិ | ខ្មែរ |
| ❖ ថ្ងៃ ខែ ឆ្នាំកំណើត | ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ |
| ❖ ប្រវត្តិនៃការសិក្សា | |
| - ឆ្នាំ១៩៩៥ | បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិពីវិទ្យាល័យទួលទំពូង |
| - ឆ្នាំ២០០១ | បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកពាណិជ្ជកម្មពីសកលវិទ្យាល័យន័រតុន |

- ឆ្នាំ២០១០ បញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រគ្រប់គ្រង និងដឹកជញ្ជូនតាមសមុទ្រ ពីសកលវិទ្យាល័យ Antwerp នៃប្រទេសប៊ែលហ្សិក។

❖ **<u>បទពិសោធន៍ការងារ</u>**

- ឆ្នាំ១៩៩៧ បានចូលបម្រើការងារនៅ ក.ស.ភ.
- ឆ្នាំ២០០៩ ជាប្រធានការិយាល័យផែនការ
- ឆ្នាំ២០១៣ ជានាយកប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧
- ឆ្នាំ២០១៥ ជាប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧
- ខែមិថុនា ឆ្នាំ២០១៦ ជាប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស
- ខែកុម្ភៈ ឆ្នាំ២០១៧ ជាប្រធាននាយកដ្ឋានវិស្វកម្ម
- ខែមិថុនា ឆ្នាំ២០១៨ ជាប្រធាននាយកដ្ឋានរដ្ឋបាល។



## លោក គង់ សុធា

**ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស**

❖ **<u>ជនជាតិ</u>** ខ្មែរ

❖ **<u>សញ្ជាតិ</u>** ខ្មែរ

❖ **<u>ថ្ងៃ ខែ ឆ្នាំកំណើត</u>** ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៦៨

❖ **<u>ប្រវត្តិនៃការសិក្សា</u>**

- ឆ្នាំ១៩៨៨ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យបឹងត្របែក
- ឆ្នាំ២០០២ សញ្ញាបត្របរិញ្ញាបត្រផ្នែកគ្រប់គ្រងសហគ្រាស ពីសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ច
- ឆ្នាំ២០០៦ សញ្ញាបត្រអនុបណ្ឌិតផ្នែកវិទ្យសាស្ត្រសេដ្ឋកិច្ច ពីសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា។

❖ **<u>បទពិសោធន៍នៃកាងារ</u>**

- ឆ្នាំ១៩៨៩ បានចូលបម្រើការងារនៅ ក.ស.ភ.
- ឆ្នាំ២០១០ ជាប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ
- ឆ្នាំ២០១៤ ជាប្រធានការិយាល័យបុគ្គលិក
- ខែសីហា ឆ្នាំ២០១៥-បច្ចុប្បន្ន ជាប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស។



**កញ្ញា ឈាវ វណ្ណធា**

**ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ**

- **ជនជាតិ** ខ្មែរ
- **សញ្ជាតិ** ខ្មែរ
- **ថ្ងៃ ខែ ឆ្នាំកំណើត** ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៨៣
- **ប្រវត្តិនៃការសិក្សា**
  - ឆ្នាំ២០០១ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យ ហ៊ុន សែន ខ្សាច់កណ្តាល
  - ឆ្នាំ ២០០៦ បរិញ្ញាបត្រផ្នែកគណនេយ្យ ពីសកលវិទ្យាល័យន័រតុន
- **បទពិសោធន៍នៃកាងារ**
  - ឆ្នាំ២០០៨ បានចូលបម្រើការងារនៅ ក.ស.ភ.
  - ឆ្នាំ២០១០ ជាអនុប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ
  - ឆ្នាំ២០១៤ ជាប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ
  - ឆ្នាំ២០១៥ ជាប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ។



**លោក ហ៊ី សុខ**

**ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផៃ TS៣**

- **ជនជាតិ** ខ្មែរ
- **សញ្ជាតិ** ខ្មែរ
- **ថ្ងៃខែឆ្នាំកំណើត** ថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៨២
- **ប្រវត្តិនៃការសិក្សា**
  - ឆ្នាំ១៩៩៩ បានបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យទួលទំពូង
  - ឆ្នាំ ២០០៤ បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ ផ្នែកវិទ្យាសាស្ត្រកសិកម្មនៅ សាកលវិទ្យាល័យភូមិន្ទកសិកម្ម
  - ឆ្នាំ ២០១២ បានបញ្ចប់ វគ្គវិក្រឹត្យការមន្ត្រីមធ្យម ឯកទេស រដ្ឋបាលទូទៅ នៅ

សាលាភូមិន្ទរដ្ឋបាល

- ឆ្នាំ ២០១៣ បានបញ្ចប់ថ្នាក់បរិញ្ញាជាន់ខ្ពស់នីតិសាស្ត្រ ផ្នែករដ្ឋបាលសាធារណៈ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

❖ **<u>បទពិសោធន៍ការងារ</u>**

- ឆ្នាំ ២០០៨ បានចូលបម្រើការងារនៅ នៅ ក.ស.ភ.
- ឆ្នាំ ២០១២ អនុប្រធានអង្គភាពផែស្ងួត ICD
- ឆ្នាំ ២០១៣ ប្រធានអង្គភាពផែស្ងួត ICD
- ឆ្នាំ ២០១៣ អនុប្រធានសេវាដ្ឋាននាវាចរណ៍
- ឆ្នាំ ២០១៥ ប្រធានការិយាល័យបុគ្គលិក/បណ្តុះបណ្តាល

  ខែឧសភា ឆ្នាំ ២០១៨-បច្ចុប្បន្ន ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែ TS៣



**លោក យឹម ឿន**

**ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧**

❖ **<u>ជនជាតិ</u>** ខ្មែរ

❖ **<u>សញ្ជាតិ</u>** ខ្មែរ

❖ **<u>ថ្ងៃខែឆ្នាំកំណើត</u>** ថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៦២

❖ **<u>ប្រវត្តិនៃការសិក្សា</u>**

- ឆ្នាំ១៩៨៦ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិពីសាលាបំពេញវិជ្ជាមជ្ឈឹម
- ឆ្នាំ១៩៩៣ បញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្របើកបរនាវាផ្លូវសមុទ្រ (Master of Science Degree in Engineering of Navigation on Sea Routes) នៅសកលវិទ្យាល័យ Odessa State Maritime Academy នៃប្រទេសអ៊ុយក្រែន។

❖ **<u>បទពិសោធន៍ការងារ</u>**

- ឆ្នាំ១៩៧៩ បានចូលបម្រើការងារ នៅ ក.ស.ភ.
- ឆ្នាំ២០០៩ ជាប្រធានការិយាល័យនាវាចរណ៍
- ឆ្នាំ២០១១ ជានាយកសេវាកម្ម នាវាចរណ៍
- ឆ្នាំ២០១៥-ខែមិថុនា ឆ្នាំ២០១៦ ជាប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍។
- ខែមិថុនា ឆ្នាំ២០១៦-បច្ចុប្បន្ន ជាប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧។



## លោក ឡៅ វីរ៉ាយ៉ា
ប្រធាននាយកដ្ឋានជលធារសាស្ត្រ

- <u>ជនជាតិ</u> ខ្មែរ
- <u>សញ្ជាតិ</u> ខ្មែរ
- <u>ថ្ងៃ ខែ ឆ្នាំកំណើត</u> ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៨៧
- <u>ប្រវត្តិនៃការសិក្សា</u>
  - ឆ្នាំ២០០៤ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យបាក់ទូក
  - ឆ្នាំ២០០៨ បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ពីសកលវិទ្យាល័យភូមិន្ទភ្នំពេញ។
- <u>បទពិសោធន៍ការងារ</u>
  - ពីខែកញ្ញា ឆ្នាំ២០០៩ បានចូលបម្រើការងារ នៅ ក.ស.ភ.
  - ឆ្នាំ២០១២ ជាអនុប្រធានសេវាដ្ឋាននាវាចរណ៍
  - ឆ្នាំ២០១៤ ជាប្រធានសេវាដ្ឋានថៃទាំពោងសញ្ញា
  - ចាប់ពីខែសីហា ឆ្នាំ២០១៥-បច្ចុប្បន្ន ជាប្រធាននាយកដ្ឋានជលធារសាស្ត្រ។



## លោក សយ សេរីសុខឧត្តម:
ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផែ/ផែក្នុងស្រុក

- <u>ជនជាតិ</u> ខ្មែរ
- <u>សញ្ជាតិ</u> ខ្មែរ
- <u>ថ្ងៃ ខែ ឆ្នាំកំណើត</u> ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៨៤
- <u>ប្រវត្តិនៃការសិក្សា</u>
  - ឆ្នាំ២០០០ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ពីវិទ្យាល័យព្រះស៊ីសុវត្ថិ
  - ឆ្នាំ២០០៣ បញ្ចប់ថ្នាក់បរិញ្ញាបត្ររង ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង
  - ឆ្នាំ២០០៩ បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ ពីសកលវិទ្យាល័យកូឡូញ ប្រទេសអាល្លឺម៉ង់

- ឆ្នាំ២០១២ បញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ ពីសកលវិទ្យាល័យ Chales Sturt University of Australia។

❖ **បទពិសោធន៍ការងារ**

- ពីខែកញ្ញា ឆ្នាំ២០០៩ បានចូលបម្រើការងារនៅ ក.ស.ភ.
- ឆ្នាំ២០១០ ជាអនុប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ
- ឆ្នាំ២០១៣ ជាប្រធានសេវាដ្ឋានផែក្នុងស្រុក
- ចាប់ពី ខែសីហា ឆ្នាំ២០១៥-បច្ចុប្បន្ន ជាប្រធានសេវាដ្ឋានមណ្ឌលអាជីវកម្មផែក្នុងស្រុករបស់ ក.ស.ភ.។



## លោក ហ៊ុន សុខាល័យ

**ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ**

❖ **ជនជាតិ** ខ្មែរ

❖ **សញ្ជាតិ** ខ្មែរ

❖ **ថ្ងៃ ខែ ឆ្នាំកំណើត** ថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៨២

❖ **ប្រវត្តិនៃការសិក្សា**

- ឆ្នាំ១៩៩៩ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ពីវិទ្យាល័យច្បារអំពៅ
- ឆ្នាំ២០០៤ បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ពីវិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រង
- ឆ្នាំ២០១០ បញ្ចប់ការសិក្សាអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រគ្រប់គ្រង និងដឹកជញ្ជូនតាមសមុទ្រពីសកលវិទ្យាល័យ Antwerp នៃប្រទេសបែលហ្សិក
- ឆ្នាំ២០១៣ បញ្ចប់ការសិក្សាអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច ពីសាកលវិទ្យាល័យ យ៉ុង ណាំ (Yeungnam Univeristy) នៃប្រទេសកូរ៉េខាងត្បូង។

❖ **បទពិសោធន៍ការងារ**

- ឆ្នាំ២០០៦ បានចូលបម្រើការងារនៅ ក.ស.ភ.
- ឆ្នាំ២០១០ ជាអនុប្រធានការិយាល័យកិច្ចការជំនួញ
- ឆ្នាំ២០១១ ជាប្រធានការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ថ្មី
- ឆ្នាំ២០១៣ ជាប្រធានអង្គភាពតម្លៃ/ទីផ្សារ
- ឆ្នាំ២០១៣ ជាប្រធានអង្គភាពវិក័យបត្រ
- ឆ្នាំ២០១៤ ជាប្រធានការិយាល័យតម្លៃ/ទីផ្សារ
- ខែកុម្ភៈ ឆ្នាំ២០១៧ ជាប្រធានស្តីទីនាយកដ្ឋានផែនការ/ទីផ្សារ
- ខែវិច្ឆិកា ឆ្នាំ២០១៧ ជាប្រធាននាយកដ្ឋានផែនការ/ទីផ្សារ។

❖ <u>ប្រវត្តិនៃការសិក្សា</u>

- ឆ្នាំ១៩៩៩ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យទួលទំពូង
- ឆ្នាំ២០០៤ បញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ពីសកលវិទ្យាល័យន័រតុន
- ឆ្នាំ២០១៣ បញ្ចប់វគ្គបច្ចេកទេសវាស់ស្ទង់សមុទ្រ Hydrographic Survey Category B នៃនាយកដ្ឋានវិទ្យាសាស្ត្រជលធារសាស្ត្រប្រទេសជប៉ុន។

❖ <u>បទពិសោធន៍ការងារ</u>

- ឆ្នាំ២០០៦ បានចូលបម្រើការងារនៅ ក.ស.ភ.
- ឆ្នាំ២០១០ ជាប្រធានផ្នែកព័ត៌មានវិទ្យា នៃការិយាល័យរដ្ឋបាល
- ឆ្នាំ២០១១ ជាអនុប្រធានអង្គភាពវាស់ស្ទង់នៃនាយកដ្ឋានជលធារសាស្ត្រ
- ឆ្នាំ២០១២ ជាប្រធានសេវាដ្ឋានថៃទាំពោងសញ្ញា
- ឆ្នាំ២០១៤ ជាប្រធានសេវាដ្ឋានហេដ្ឋារចនាសម្ព័ន្ធផៃ
- ខែមិថុនា ឆ្នាំ២០១៨-បច្ចុប្បន្ន ជាប្រធាននាយកដ្ឋានវិស្វកម្ម។



**លោក គង់ ចាន់នី**

**ប្រធានលេខាធិការដ្ឋាន**

❖ <u>ជនជាតិ</u> ខ្មែរ

❖ <u>សញ្ជាតិ</u> ខ្មែរ

❖ <u>ថ្ងៃ ខែ ឆ្នាំកំណើត</u> ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៨២

❖ <u>ប្រវត្តិនៃការសិក្សា</u>

- ឆ្នាំ២០០២ បញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យហ៊ុន សែន តាខ្មៅ
- ឆ្នាំ២០០៦ បញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្ត្រ ពីសកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ឆ្នាំ២០០៨ បញ្ចប់ថ្នាក់អនុបណ្ឌិតជំនាញនីតិសាស្ត្រ ពីសកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង៣ នៅរដ្ឋធានីហាណូយ នៃប្រទេសវៀតណាម។

❖ <u>បទពិសោធន៍ការងារ</u>

- ឆ្នាំ២០០៩ បានចូលបម្រើការងារនៅ ក.ស.ភ.
- ឆ្នាំ២០១១ ជាអនុប្រធានការិយាល័យរដ្ឋបាល
- ឆ្នាំ២០១៥-បច្ចុប្បន្ន ជាប្រធានក្រុមលេខានៃក្រុមប្រឹក្សាភិបាល ក.ស.ភ.
- ឆ្នាំ២០១៥-បច្ចុប្បន្ន ជាប្រធានលេខាធិការដ្ឋាន។

## ខ. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកជាន់ខ្ពស់

តួនាទី និងការទទួលខុសត្រូវ របស់បុគ្គលិកជាន់ខ្ពស់ ក.ស.ភ. មានដូចខាងក្រោម៖

### ខ.១ ឯកឧត្តម ហ៊ី បាវី (អគ្គនាយក) មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំការប្រជុំនៃក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកប្រតិបត្តិនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងការដាក់ឱ្យអនុវត្តនូវគោលនយោបាយ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ ក.ស.ភ. ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំ និងរបាយការណ៍គណនេយ្យ/ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- អនុវត្តតួនាទីជាអាជ្ញាធរ ដើម្បីគ្រប់គ្រងសណ្តាប់ធ្នាប់ទូទៅក្នុងមណ្ឌលអាជីវកម្មផែរបស់ ក.ស.ភ.
- កំណត់ចំនួនក្របខ័ណ្ឌបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល និងគោរពទៅតាមលក្ខន្តិកៈបុគ្គលិក
- អនុវត្តឋានានុក្រមរបស់ ក.ស.ភ. ចំពោះបុគ្គលិកទាំងអស់
- សម្រេច និងចុះហត្ថលេខាលើកិច្ចសន្យា ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្តីពីការបែងចែកអំណាច
- បំពេញកិច្ចការទូទៅក្នុងដំណើរការមុខងាររដ្ឋបាល និងការគ្រប់គ្រង ដែលចាំបាច់ក្នុងដំណើរការប្រក្រតីរបស់ ក.ស.ភ.។

### ខ.២ តួនាទី និងការទទួលខុសត្រូវរបស់អគ្គនាយករង

- លោកស្រី **ជួន សុខេម** អគ្គនាយករង ទទួលបន្ទុកការងាររដ្ឋបាល/ហិរញ្ញវត្ថុ
- លោក **ភុយ ម៉ិនធន** អគ្គនាយករង ទទួលបន្ទុកការងារបច្ចេកទេស
- លោក **ហៀក តិរុណា** អគ្គនាយករង ទទួលបន្ទុកការងារកិច្ចការផែ
- លោកស្រី **ហ៊ី ផានិន** អគ្គនាយករង ទទួលបន្ទុកការងារអាជីវកម្ម/ប្រតិបត្តិការផែ។

### ខ.៣ តួនាទី និងការទទួលខុសត្រូវរបស់ប្រធាននាយកដ្ឋាន

- លោក **កែវ សុផាណ្ណារ៉ា** (ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង)
  - *ការងារគ្រប់គ្រង*
    - ជាសេនាធិការផ្ទាល់ឱ្យអគ្គនាយក លើការងារសវនកម្ម
    - ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
  - *ការងារជំនាញ*
    - រៀបចំផែនការកម្មវិធីចុះធ្វើសវនកម្មប្រចាំឆ្នាំ

- ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ឱ្យស្របតាមស្តង់ដារគណនេយ្យអន្តរជាតិ (CIFRS)
- ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ
- ធ្វើសវនកម្មលើការគ្រប់គ្រង និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
- ធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីអំពីការចុះធ្វើសវនកម្មជូនថ្នាក់ដឹកនាំជ្រាប និងមានវិធានការកែលំអចំណុចខ្វះខាត
- ធ្វើអធិការកិច្ចលើករណីសង្ស័យ ឬវិវាទណាមួយដែលចង្អុលបង្ហាញដោយអគ្គនាយក
- សម្របសម្រួលការងារសវនកម្មជាមួយនឹងសវនកម្មផ្ទៃក្រៅ។

- *ការងារវាយតម្លៃ*
  - ពិនិត្យ និងតាមដានផែនការដែលបានដាក់ចេញ
  - តាមដានការអនុវត្តសកម្មភាព ឬអនុសាសន៍កែលំអលើចំណុចខ្វះខាតរបស់អង្គភាពដែលរកឃើញដោយសវនកម្មផ្ទៃក្រៅ ឬសវនកម្មជំនាញ
  - តាមដានត្រួតពិនិត្យគោលការណ៍ណែនាំ ឬគោលនយោបាយ ដែលដាក់ចេញដោយអង្គភាព
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ ការដាក់ពិន័យ ឬមានវិធានការដោះស្រាយ
  - រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ លោក **ជី ទិចិត្រ** (ប្រធាននាយកដ្ឋានរដ្ឋបាល)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ លើការងាររដ្ឋបាល ការងារសន្តិសុខ/សណ្តាប់ធ្នាប់ និងការងារព័ត៌មានវិទ្យា
  - អនុវត្ត និងតាមដានការគោរពន្ទ្ទរបទបញ្ជាផ្ទៃក្នុងរបស់ ក.ស.ភ.។
- *ការងារជំនាញ*
  - ត្រួតពិនិត្យ និងរៀបចំតាក់តែងឯកសាររដ្ឋបាល
  - គ្រប់គ្រងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ ក.ស.ភ.
  - រៀបចំសេវាផ្តល់ព័ត៌មានអំពីសេវាកម្មរបស់ ក.ស.ភ. ជូនអតិថិជន
  - ធ្វើទំនាក់ទំនង និងសហការជាមួយស្ថាប័នរដ្ឋ-ឯកជន ដែលពាក់ព័ន្ធនឹងវិស័យគ្រប់គ្រងថែរក្សា និងការពារទ្រព្យសម្បត្តិទាំងឡាយ ព្រមទាំងការរៀបចំបញ្ជីសារពើភ័ណ្ឌរបស់ ក.ស.ភ.

- ត្រួតពិនិត្យ និងរៀបចំសំណើសុំទិញ និងសំណើសុំដកសាច់ប្រាក់រាល់ការចំណាយការងាររដ្ឋបាល និងទិញសម្ភារការិយាល័យ សម្រាប់ប្រើប្រាស់ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- រៀបចំទីកន្លែងប្រជុំ និងការងារពិធីការសម្រាប់គ្រប់កម្មវិធីរបស់ ក.ស.ភ.
- ត្រួតពិនិត្យគ្រប់គ្រង និងថែទាំប្រព័ន្ធទឹក និងប្រព័ន្ធអគ្គិសនី ព្រមទាំងអនាម័យ
- គ្រប់គ្រង និងត្រួតពិនិត្យលើការប្រើប្រាស់ប្រេងឥន្ធនៈ
- គ្រប់គ្រង និងចាត់ចែងការងារអន្តរាគមន៍សណ្តាប់ធ្នាប់រួម និងការពារសុវត្ថិភាពជូនថ្នាក់ដឹកនាំ និងបុគ្គលិករបស់ ក.ស.ភ.
- រៀបចំបទបញ្ជាផ្ទៃកសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់របស់ ក.ស.ភ.
- ដឹកនាំ ត្រួតពិនិត្យការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធព័ត៌មានវិទ្យា ការបែងចែកសិទ្ធិប្រើប្រាស់អ៊ីនធឺណែត និងបណ្តាញ Network សម្រាប់អង្គភាពនានា និងការតបណ្តាញប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាព
- សម្របសម្រួល និងដោះស្រាយវិវាទនានាពាក់ព័ន្ធការងាររដ្ឋបាល។

- *ការងារវាយតម្លៃ*
  - វាយតម្លៃនិងគ្រប់គ្រងការងារលើបុគ្គលិកក្រោមឱវាទ អនុលោមតាមច្បាប់ការងារ និងលក្ខន្តិកៈសហគ្រាស ព្រមទាំងលក្ខន្តិកៈបុគ្គលិករបស់ ក.ស.ភ.
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងារបុគ្គលិកក្រោមឱវាទដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំ ក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ និងការដាក់ពិន័យ
  - ពិនិត្យ និងវាយតម្លៃដំណើរការប្រព្រឹត្តទៅនៃការងាររដ្ឋបាល ការងារសន្តិសុខ និងការងារព័ត៌មានវិទ្យា ជូនថ្នាក់ដឹកនាំដើម្បីជ្រាប និងមានវិធានការដោះស្រាយ
  - ពិនិត្យ និងវាយតម្លៃលើសំណើសុំផ្សេងៗពីគ្រប់អង្គភាព ដែលពាក់ព័ន្ធនឹងការចំណាយរដ្ឋបាលជូនថ្នាក់ដឹកនាំ ពិនិត្យ និងសម្រេច
  - ពិនិត្យ និងវាយតម្លៃលើគម្រោងរៀបចំកម្មវិធីជប់លៀងអាហារសាមគ្គី និងរង្វាន់លើកទឹកចិត្ត ប្រចាំឆ្នាំរបស់ ក.ស.ភ.
  - ពិនិត្យ និងវាយតម្លៃលើគម្រោងទិញសម្ភារការិយាល័យ ប្រើប្រាស់ក្នុងនាយកដ្ឋានចំណុះ និងគម្រោងរៀបចំឯកសណ្ឋានប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ និងបុគ្គលិក ក.ស.ភ.
  - តាមដាន និងវាយតម្លៃ ព្រមទាំងបូកសរុបជារបាយការណ៍ការងាររដ្ឋបាល ជូនថ្នាក់ដឹកនាំជ្រាប និងមានវិធានការដោះស្រាយ។

❖ **លោក គង់ សុធា** (ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ លើការងារគ្រប់គ្រងធនធានមនុស្ស និងការងារបណ្តុះបណ្តាល
  - ពិនិត្យ និងតាមដានការគោរពនូវបទបញ្ជាផ្ទៃក្នុង របស់ ក.ស.ភ.
  - គ្រប់គ្រងជីវប្រវត្តិ និងពិនិត្យរាល់សកម្មភាពការងាររបស់បុគ្គលិក ក.ស.ភ.។
- *ការងារជំនាញ*
  - ធានាដំណើរការនៃការគ្រប់គ្រងបុគ្គលិក ដោយអនុលោមទៅតាមលក្ខន្តិកៈ ក.ស.ភ. និងលក្ខន្តិកៈបុគ្គលិក ក.ស.ភ. ព្រមទាំងច្បាប់ការងារ
  - រៀបចំប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេស ប្រាក់បៀវត្ស ប្រាក់បន្ថែមម៉ោង ប្រាក់រង្វាន់សរសើរប្រចាំឆ្នាំជូនបុគ្គលិក ក.ស.ភ.
  - គ្រប់គ្រងបញ្ជីវត្តមានរបស់បុគ្គលិក ក.ស.ភ.
  - រៀបចំសំណុំបែបបទនិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ គ្រោះថ្នាក់ការងារ មរណភាព
  - ពិនិត្យ និងធ្វើសំណើលើការងារតម្លើងកាំថ្នាក់ប្រចាំឆ្នាំជូនបុគ្គលិក ក.ស.ភ.
  - ពិនិត្យ ផ្តល់យោបល់ជូនថ្នាក់ដឹកនាំលើសំណើព្យួរការងារ ផ្ទេរការងារ ការដំឡើងតួនាទី
  - រៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្សទាំងក្នុង និងក្រៅប្រទេស
  - រៀបចំជ្រើសរើសបុគ្គលិកតាមផែនការប្រចាំឆ្នាំរបស់ ក.ស.ភ.។
- *ការងារវាយតម្លៃ*
  - ពិនិត្យ និងវាយតម្លៃលើសមត្ថភាព និងសកម្មភាពការងាររបស់បុគ្គលិក ក. ស. ភ. ដើម្បី ផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ឬដំឡើងតួនាទី។

❖ កញ្ញា **ឈាង វណ្ណធា** (ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ លើការងារគណនេយ្យ និងហិរញ្ញវត្ថុ
  - ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- *ការងារជំនាញ*
  - ត្រួតពិនិត្យលើផែនការអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុប្រចាំឆ្នាំ
  - ត្រួតពិនិត្យការព្យាករណ៍ហិរញ្ញវត្ថុ
  - ត្រួតពិនិត្យចំណុចដែលអាចកាត់បន្ថយចំណាយ និងធ្វើឱ្យមានភាពប្រសើរឡើង
  - អនុវត្តគោលនយោបាយ និងនីតិវិធីចុះបញ្ជីការគណនេយ្យរបស់អង្គភាព
  - អនុវត្តគោលការណ៍នៃការប្រមូលចំណូល និងបំណុលពីអតិថិជន
  - ធានាការបង់ពន្ធរបស់អង្គភាពឱ្យបានទាន់ពេលវេលាតាមការកំណត់របស់ច្បាប់ពន្ធដារ

- គ្រប់គ្រង និងត្រួតពិនិត្យសាច់ប្រាក់ (ប្រចាំសប្តាហ៍, ប្រចាំខែ, និងប្រចាំឆ្នាំ)
- ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់គណនីធនាគាររបស់អង្គភាព (ប្រចាំខែ)
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- វិភាគ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំលើលទ្ធផលហិរញ្ញវត្ថុ និងបម្រែបម្រួល ព្រមទាំងប្រតិបត្តិការអាជីវកម្មរបស់អង្គភាព។

- *ការងារវាយតម្លៃ*
  - តាមដានត្រួតពិនិត្យគោលការណ៍ណែនាំ ឬគោលនយោបាយគណនេយ្យ
  - ធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងនីតិវិធីចុះបញ្ជីការគណនេយ្យប្រចាំឆ្នាំ
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការដំឡើងតួនាទី ការដាក់ពិន័យ ឬមានវិធានការដោះស្រាយ
  - រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ លោក **យឹម ឿន** (ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងប្រតិបត្តិការលើការងារប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧
  - ផ្តល់ការណែនាំដល់អង្គភាពក្រោមឱវាទអំពីលំហូរប្រតិបត្តិការ។
- *ការងារជំនាញ*
  - រៀបចំកាលវិភាគនិងចាត់ចែងនាវាចូលចត និងចេញពីផែនៅតាមដងយោងនីមួយៗ
  - រៀបចំ និងចាត់ចែងប្លង់របស់កុងតឺន័រទាំងនាំចូល និងនាំចេញ
  - ធានាឱ្យការធ្វើប្រតិបត្តិការលើកដាក់នៅលើទីលាន និងនៅស្ពានផែឱ្យស្របតាមស្តង់ដារ អន្តរជាតិ និងលក្ខណៈបច្ចេកទេស
  - ណែនាំដល់កម្មករបម្រើការងារនៅលើចំណតអំពីគោលការណ៍សន្តិសុខ និងសុវត្ថិភាព
  - ធានាឱ្យមានបរិយាកាសការងារល្អជាមួយបុគ្គលិកក្រោមឱវាទ
  - រក្សាទំនាក់ទំនងល្អក្នុងចំណោមថ្នាក់ដឹកនាំ និងកម្មករក្រោមឱវាទ
  - ជំរុញការលើកទឹកចិត្តដល់បុគ្គលិកក្រោមឱវាទ
  - ជំរុញគុណភាពការងារតាមរយៈការផ្តល់ការណែនាំ និងការបណ្តុះបណ្តាល
  - ធានាឱ្យការផ្តល់សេវាកាន់តែល្អ ប្រកបដោយប្រសិទ្ធភាព និងផលិតភាពខ្ពស់
  - ធ្វើបញ្ជី Check List ផ្នែកប្រតិបត្តិការ
  - ល្បាត និងត្រួតពិនិត្យសកម្មភាពប្រតិបត្តិការដើម្បីធានាថា បុគ្គលិកផ្នែកប្រតិបត្តិការទាំងអស់ពាក់សម្ភារការពារខ្លួន (PPE) និងប្រើប្រាស់នូវសម្ភារគ្រឿងចក្រឱ្យបានត្រឹមត្រូវ

- រៀបចំការប្រជុំប្រចាំខែជាមួយបុគ្គលិកក្រោមឱវាទ ដើម្បីពិភាក្សា និងដកពិសោធន៍ការងារកន្លងមក
- ចូលរួមស៊ើបអង្កេតគ្រោះថ្នាក់ការងារដែលបានកើតឡើង
- ត្រួតពិនិត្យមាត់ច្រកចេញ-ចូល។

• *ការងារវាយតម្លៃ*

- គណនា និងវាយតម្លៃការប្រើប្រាស់ទីលាន ស្ពានផែ និងគ្រឿងចក្រលើកដាក់
- ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ និងការដាក់ពិន័យ
- បូកសរុបរបាយការណ៍ប្រតិបត្តិការប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ។

❖ លោក **ងៀប វីរ៉ាយ៉ា** (ប្រធាននាយកដ្ឋានជលធារសាស្ត្រ)

• *ការងារគ្រប់គ្រង*

- ជាសេនាធិការឱ្យអគ្គនាយករងបច្ចេកទេស លើការងារជលធារសាស្ត្រ រួមមានការងារវាស់ស្ទង់ ការងារបំពាក់ពោងសញ្ញា និងការងារបូមស្តារប្រឡាយ
- ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។

• *ការងារជំនាញ*

- រៀបចំផែនការប្រចាំឆ្នាំលើការងារវាស់ស្ទង់ និងការងារបូមស្តារប្រឡាយនាវាចរណ៍
- រៀបចំគម្រោងផែនការប្រចាំឆ្នាំលើការបំពាក់ ការថែទាំ និងការជួសជុលពោងសញ្ញា និងបង្គោលសញ្ញាតាមផ្លូវនាវាចរណ៍ក្នុងដែនអាជីវកម្មរបស់ ក.ស.ភ.
- សិក្សានិងវាស់ស្ទង់ជម្រៅទឹកនៅក្នុងមណ្ឌលអាជីវកម្ម និងទីតាំងអភិវឌ្ឍន៍របស់ក.ស.ភ.
- អនុវត្តការងារបូមស្តារប្រឡាយនាវាចរណ៍ និងការងារបូមខ្សាច់ធ្វើអាជីវកម្ម
- គ្រប់គ្រងលើមធ្យោបាយបូមស្តារ និងមធ្យោបាយអូសទាញគ្រឿងចក្រ
- បំពាក់ពោងសញ្ញា និងបង្គោលសញ្ញាតាមផ្លូវនាវាចរណ៍ក្នុងមណ្ឌលអាជីវកម្ម
- គ្រប់គ្រង ថែរក្សា និងជួសជុលរាល់ពោងសញ្ញា បង្គោលសញ្ញា តាមផ្លូវនាវាចរណ៍ក្នុងមណ្ឌលអាជីវកម្មរបស់ ក.ស.ភ.។

• *ការងារវាយតម្លៃ*

- ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការដំឡើងតួនាទី ការដាក់វិន័យ
- សិក្សាស្រាវជ្រាវបច្ចេកទេស និងឧបករណ៍វាស់ស្ទង់គ្រប់ប្រភេទ
- ប្រមូលចងក្រងព័ត៌មាន និងឯកសារនានាពាក់ព័ន្ធនឹងផ្នែកជលធារសាស្ត្រ

- រៀបចំបូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីរាយការណ៍ជូនអគ្គនាយក ក.ស.ភ.។

❖ លោក **សយ សេរីសុខឧត្តម:** (ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផែភ្នំពេញ/ផែក្នុងស្រុក)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងកិច្ចការផែ លើការងារមណ្ឌលផែ/ផែក្នុងស្រុក ការងារផែទេសចរណ៍ ការងារចំណតផែទន្លេបិទ និងការងារផែប្រេង/ហ្គាស
  - ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- *ការងារជំនាញ*
  - រៀបចំផែនការគ្រប់គ្រង និងរៀបចំសណ្តាប់ធ្នាប់ និងចំណតផែក្នុងមណ្ឌលអាជីវកម្មផែ
  - គ្រប់គ្រងចំណត សេវាកម្មផែក្នុងស្រុក និងមណ្ឌលផែរាល់ការចូលចត របស់នាវា សាឡាង់ ទូក កាណូតផ្សេងៗ
  - គ្រប់គ្រងចំណតចេញ-ចូលនាវា នាវាទេសចរណ៍ជាតិ និងអន្តរជាតិ គ្រប់គ្រងចំណតរថយន្ត និងច្រកទ្វារចេញ-ចូល ប្រមូលថ្លៃឈ្នួល រៀបចំសណ្តាប់ធ្នាប់នាវាដឹកអ្នកដំណើរនៅផែបណ្តែត
  - គ្រប់គ្រងចំណតផែទន្លេបិទលើការងារប្រតិបត្តិការ និងដើរតួនាទីជាអាជ្ញាធរផែ រួមមានការងារលើកដាក់ ការងាររៀបចំចំណតផែ ការងារគ្រប់គ្រងនាវាចេញ-ចូល និងគ្រប់គ្រងចំណតផែប្រេង/ហ្គាសលើការងារសណ្តាប់ធ្នាប់ឱ្យមានសុវត្ថិភាព និងបរិស្ថានល្អ
  - គ្រប់គ្រងនាវាចេញ-ចូល និងប្រមូលស្ថិតិទំនិញឆ្លងកាត់
  - ថែរក្សាបរិយាកាសផែ និងប្រឡាយនាវាចរណ៍នៅតាមចំណតផែទាំងនោះ ឱ្យមានរបៀបរៀបរយសម្រាប់នាវាធ្វើនាវាចរណ៍ ចងពួរនាវា បោះយុថ្កា ព្រមទាំង ផ្ទេរ និងផ្ទុកទំនិញ។
- *ការងារវាយតម្លៃ*
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ និងការដាក់ពិន័យ
  - វាយតម្លៃរាល់ផលប៉ះពាល់ដែលបណ្តាលឱ្យខូចខាតដល់ចំណតផែ ដែលស្ថិតនៅក្នុងព្រំប្រទល់ផ្ទៃទឹកកំពង់ផែ និងមណ្ឌលផែ ជូនថ្នាក់ដឹកនាំជ្រាប និងមានដំណោះស្រាយ
  - រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ លោក **ហ៊ុន សុខាល័យ** (ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ លើការងារផែនការ/ស្ថិតិ ការងារតម្លៃ/ទីផ្សារ ការងារកិច្ចការជំនួញ និងការងារសិក្សាស្រាវជ្រាវ/អភិវឌ្ឍន៍ថ្មី

- ផ្ដល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។

- *ការងារជំនាញ*
  - រៀបចំផែនការអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ រយៈពេលខ្លី មធ្យម និងវែង
  - តាមដានការងារអាជីវកម្ម ជាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំសម្រាប់ ក.ស.ភ.
  - ចងក្រងទិន្នន័យ និងស្ថិតិរបស់ ក.ស.ភ. ដើម្បីធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ
  - រៀបចំផែនការយុទ្ធសាស្ត្រទីផ្សាររបស់ ក.ស.ភ. ដោយពឹងផ្អែកជាចម្បងទៅលើតម្លៃ គុណភាពសេវាកម្ម ការគ្រប់គ្រង និងឋបនីយភណ្ឌផែ
  - រៀបចំកិច្ចសន្យា កិច្ចព្រមព្រៀង និង MOU ជាមួយដៃគូអាជីវកម្មរបស់ ក.ស.ភ.
  - រៀបចំ និងចងក្រងបណ្ណផ្សាយពាណិជ្ជកម្ម (Brochure) និងប្រតិទិន (Calendar)
  - ផ្សព្វផ្សាយអំពីតារាងតម្លៃសេវាកម្មរបស់ ក.ស.ភ. ជូនអតិថិជន
  - បម្រើសេវាកម្ម (Customer Service) ជូនអតិថិជន
  - ផលិតវិក្កយបត្រ។

- *ការងារវាយតម្លៃ*
  - ពិនិត្យ និងផ្ដល់យោបល់លើគម្រោងសាងសង់ និងការចំណាយផ្សេងៗលើផ្នែកអាជីវកម្មរបស់ ក.ស.ភ. ជូនថ្នាក់ដឹកនាំ
  - វិភាគអំពីប្រសិទ្ធភាព និងផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍នីមួយៗរបស់ ក.ស.ភ.
  - សិក្សាពីបរិយាកាសប្រកួតប្រជែង និងវិនិយោគក្នុងវិស័យដឹកជញ្ជូន វិស័យភ័ស្តុភារ និង វិស័យកំពង់ផែ
  - សិក្សា និងវិភាគតម្លៃដឹកជញ្ជូនតាមផ្លូវទឹក ផ្លូវគោក ផ្លូវដែក និងផ្លូវអាកាស
  - វិភាគលើផលប៉ះពាល់ ចំណុចខ្លាំង ចំណុចខ្សោយ និងឱកាស ដោយផ្អែកលើមជ្ឈដ្ឋានខាងក្នុង និងខាងក្រៅរបស់អង្គភាព
  - តាមដានស្ថានការ និងនិន្នាការអភិវឌ្ឍសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស
  - តាមដានស្ថានការនៃការអភិវឌ្ឍ និងការប្រព្រឹត្តទៅរបស់កំពង់ផែនៅក្នុងប្រទេស និងកំពង់ផែនានានៅក្នុងប្រទេសជិតខាងក្នុងតំបន់ និងសកលលោក
  - សិក្សាអំពីភាពប្រកួតប្រជែងនៃតម្លៃសេវាកម្មរបស់ ក.ស.ភ.
  - សិក្សាលើគម្រោងស្រាវជ្រាវ និងការអភិវឌ្ឍថ្មីៗរបស់ ក.ស.ភ.
  - ធ្វើការស្ទង់មតិអំពីការផ្ដល់សេវាកម្មរបស់ ក.ស.ភ. ដើម្បីទទួលបានការវាយតម្លៃពីអ្នកប្រើប្រាស់លើចំណុចសកម្ម និងចំណុចអសកម្ម
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្ដល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការដំឡើងតួនាទី និងការដាក់វិន័យ

- រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ លោក **ហ៊ី សុខ (ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែ TS៣)**

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងប្រតិបត្តិការ លើការងារប្រតិបត្តិការចំណតផែ TS៣
  - ផ្តល់ការណែនាំដល់អង្គភាពក្រោមឱវាទអំពីលំហូរប្រតិបត្តិការ។
- *ការងារជំនាញ*
  - រៀបចំកាលវិភាគ និងចាត់ចែងនាវាចូលចត និងចេញពីផែនៅតាមដងយោងនីមួយៗ
  - រៀបចំ និងចាត់ចែងប្លង់របស់កុងតឺន័រទាំងនាំចូល និងនាំចេញ
  - ធានាឱ្យការធ្វើប្រតិបត្តិការលើកដាក់នៅលើទីលាន និងនៅស្ពានផែឱ្យស្របតាមស្តង់ដារអន្តរជាតិ និងលក្ខណៈបច្ចេកទេស
  - ផ្តល់ការណែនាំដល់កម្មករបម្រើការងារនៅលើចំណត អំពីគោលការណ៍សន្តិសុខ និងសុវត្ថិភាព
  - ធានាឱ្យមានបរិយាកាសការងារល្អជាមួយបុគ្គលិកក្រោមឱវាទ
  - រក្សាទំនាក់ទំនងល្អក្នុងចំណោមថ្នាក់ដឹកនាំ និងកម្មករក្រោមឱវាទ
  - ជំរុញការលើកទឹកចិត្តដល់បុគ្គលិកក្រោមឱវាទ
  - ជំរុញគុណភាពការងារតាមរយៈការផ្តល់ការណែនាំ និងការបណ្តុះបណ្តាល
  - ធានាឱ្យការផ្តល់សេវាកាន់តែល្អ មានប្រសិទ្ធភាព និងផលិតភាពខ្ពស់
  - ធ្វើបញ្ជី Check List ផ្នែកប្រតិបត្តិការ
  - ល្បាតនិងត្រួតពិនិត្យសកម្មភាពប្រតិបត្តិការ ដើម្បីធានាថាបុគ្គលិកផ្នែកប្រតិបត្តិការទាំងអស់ពាក់សម្ភារការពារពលកម្ម (PPE) និងប្រើប្រាស់សម្ភារគ្រឿងចក្របានត្រឹមត្រូវ
  - រៀបចំការប្រជុំប្រចាំខែជាមួយបុគ្គលិកក្រោមឱវាទ ដើម្បីពិភាក្សា និងដកពិសោធន៍ការងារកន្លងមក
  - ចូលរួមស៊ើបអង្កេតគ្រោះថ្នាក់ការងារដែលបានកើតឡើង
  - ត្រួតពិនិត្យមាត់ច្រកចេញ-ចូល។
- *ការងារវាយតម្លៃ*
  - បូកសរុបរបាយការណ៍ប្រតិបត្តិការប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
  - គណនា និងវាយតម្លៃការប្រើប្រាស់ទីលាន ស្ពានផែ និងគ្រឿងចក្រលើកដាក់
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់កម្មករ និងនិយោជិតក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការដំឡើង និងការដាក់វិន័យ។

❖ លោក **សាយ ចន្ថា** (ប្រធាននាយកដ្ឋានវិស្វកម្ម)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងបច្ចេកទេស លើការងារបច្ចេកទេស រួមមានការងារហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយគ្រឿងចក្រ
  - ផ្ដល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- *ការងារជំនាញ*
  - រៀបចំកំណត់ស្តង់ដារបច្ចេកទេសសម្រាប់ហេដ្ឋារចនាសម្ព័ន្ធផែ និងមធ្យោបាយគ្រឿងចក្ររបស់ ក.ស.ភ.
  - សិក្សា និងរៀបចំគម្រោងអភិវឌ្ឍន៍ផែលើផ្នែកបច្ចេកទេស
  - ត្រួតពិនិត្យ ថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផែ និងមធ្យោបាយគ្រឿងចក្រ
  - រៀបចំផែនការសម្ភារ និងគ្រឿងបន្លាស់សម្រាប់ការជួសជុលហេដ្ឋារចនាសម្ព័ន្ធផែ និងមធ្យោបាយគ្រឿងចក្រ។
- *ការងារវាយតម្លៃ*
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងារបុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការដំឡើងតួនាទី ការដាក់ពិន័យ ឬមានវិធានការដោះស្រាយ ដឹកនាំការប្រជុំផ្ទៃរៀងរាល់ខែ ដើម្បីដកពិសោធន៍លើការងារជំនាញបច្ចេកទេសវិស្វកម្ម។

❖ លោក **តុល សុខុម** (ប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍)

- *ការងារគ្រប់គ្រង*
  - ជាសេនាធិការឱ្យអគ្គនាយករងកិច្ចការផែ លើការងារនាវាចរណ៍ ការងារកណ្តូធារ និងការងារ SHE
  - ផ្ដល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- *ការងារជំនាញ*
  - ធានាការពារសុវត្ថិភាពដែនទឹកកំពង់ផែ និងគ្រប់គ្រងចលនានាវា
  - តាមដានត្រួតពិនិត្យការបំពុលទឹក
  - អនុវត្តបទបញ្ជា និងផ្តល់ការឯកភាពលើសកម្មភាពផ្សេងៗក្នុងតំបន់កំពង់ផែ
  - ធានាសុវត្ថិភាពប្រតិបត្តិការកំពង់ផែ និងនាវាទាំងឡាយនៅកំពង់ផែ
  - ដឹកនាំគណៈកម្មការធ្វើបែបបទចូល/ចេញកំពង់ផែរបស់នាវា
  - ធ្វើការណែនាំអំពីករណីនាវាដឹកជញ្ជូនទំនិញគ្រោះថ្នាក់
  - បដិសេធមិនឱ្យនាវាចាកចេញពីកំពង់ផែ ក្នុងករណីមិនទូទាត់ប្រាក់កម្រៃ ឬថ្លៃប្រើប្រាស់សេវាកម្មផ្សេងៗ

- ផ្តល់លិខិតអនុញ្ញាតចេញពីកំពង់ផែ (Port clearance) ដល់នាវា
- បញ្ជូនវិញ្ញាបនបត្រ (Certificate Manifest) ដល់អង្គភាពពាក់ព័ន្ធ និងបញ្ជូនវិញ្ញាបនបត្រប៉ាន់ស្មានសេវាកម្មទៅការិយាល័យកិច្ចការជំនួញដើម្បីចេញវិក្កយបត្រផ្លូវការជូនអតិថិជន
- បែងចែកកណ្តៀធារនាំផ្លូវនាវាចេញ-ចូល ក្នុងមណ្ឌលអាជីវកម្ម និងតាមបណ្តាខេត្តផ្សេងៗ
- គ្រប់គ្រង និងចាត់ចែងមធ្យោបាយនាវាសណ្តោង និងមធ្យោបាយនាវាចម្លង
- ពិនិត្យ និងបញ្ជូនព័ត៌មានមកដល់ និងចេញដំណើររបស់នាវា ដែលបានពីទីភ្នាក់ងារកម្ពុជានាវាចរណ៍កាំសាបឱ្យទៅអង្គភាពពាក់ព័ន្ធអនុវត្ត
- រៀបចំ និងគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយ សន្តិសុខ និងសុវត្ថិភាពរបស់នាវាចរណ៍ និងបរិស្ថានល្អក្នុងមណ្ឌលអាជីវកម្ម
- ចាត់ចែងសកម្មភាពនាវាតាមផែក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ និងចំណតផែអ្នកដំណើរ
- ណែនាំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយសុវត្ថិភាព សុខមាលភាព និងបរិស្ថានផែ ធានាឱ្យដំណើរការប្រតិបត្តិការផែ អនុលោមតាមស្តង់ដារអន្តរជាតិជាអាទិ៍ SHE (Safety, Health and Environment) ISPS Code IMDG Code
- ប្រតិបត្តិច្បាប់ តាមបទប្បញ្ញត្តិជាតិ និង បទប្បញ្ញត្តិអន្តរជាតិលើនាវាជាតិអន្តរជាតិ និងចំណតផែ។

- *ការងារវាយតម្លៃ*
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ ការដាក់ពិន័យ
  - វាយតម្លៃរាល់ការប៉ះទង្គិចគ្រោះថ្នាក់ដែលបណ្តាលឱ្យខូចខាតនាវាសាឡង់ និងចំណតផែដែលស្ថិតនៅក្នុងព្រំប្រទល់ផ្ទៃទឹកកំពង់ផែ មណ្ឌលផែ ជូនថ្នាក់ដឹកនាំជ្រាប និងមានដំណោះស្រាយ
  - តាមដានស្ថានភាពច្រាំងទន្លេ និងសកម្មភាពយកដីពីបាតទន្លេ និងផលប៉ះពាល់ក្នុងការកសាងផែ និងចំណតផែដែលមានស្រាប់
  - តាមដានពិនិត្យកំពស់ទឹកឡើងចុះប្រចាំថ្ងៃ និងផ្តល់ជំរៅទឹកប្រចាំខែ ដល់ស្ថាប័នពាក់ព័ន្ធនានា តាមរយៈទីភ្នាក់ងារកម្ពុជានាវាចរណ៍កាំសាប សម្រាប់ការកំណត់ជម្រៅស៊ីទឹករបស់នាវាចេញ-ចូល ក.ស.ភ.
  - រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

### *ឃ. ការបណ្តុះបណ្តាលបន្តសម្រាប់បុគ្គលិកជាន់ខ្ពស់*

សម្រាប់ឆ្នាំ២០១៨ នេះ ក.ស.ភ. បានចាត់បញ្ជូនបុគ្គលិកជាន់ខ្ពស់ ដើម្បីទៅចូលរួមការបណ្តុះបណ្តាលដូចខាងក្រោម៖

- **លោក ហ៊ុន សុខាល័យ** ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ ត្រូវបានចាត់តាំងដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការអភិវឌ្ឍកំពង់ផែ និងការប្រកួតប្រជែង" នៅប្រទេសសិង្ហបុរី ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៨។
- **លោក ហ៊ុន សុខាល័យ** ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ ត្រូវបានចាត់តាំងឱ្យទៅចូលរួមទស្សនកិច្ចផ្លូវការ ដើម្បីស្វែងយល់អំពីការអភិវឌ្ឍវិស័យភ័ស្តុភារកម្ម នៅប្រទេសថៃ ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨។
- **លោកស្រី ហ៊ឹ ផានិន** អគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ ត្រូវបានចាត់តាំងឱ្យទៅចូលរួមកម្មវិធី **"The 10th Pan-Beibu Gulf Economic Cooperation and the 2nd China-Indochina Peninsula Economic Coridor Development"** និងធ្វើទស្សនកិច្ចបន្តនៅទីក្រុង Qinzhou នៃសាធារណរដ្ឋប្រជាមានិតចិនចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨។
- **លោក យឹម ជឿន** ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ និង **លោក ហ៊ុន សុខាល័យ** ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ ត្រូវបានចាត់តាំងឱ្យទៅចូលរួមកម្មវិធី **"The Maritime Silk Road Forum"** នៅសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨។
- **លោកស្រី ហ៊ឹ ផានិន** អគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ ត្រូវបានចាត់តាំងឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីទីផ្សារមូលធនសម្រាប់ថ្នាក់ដឹកនាំនៃអនុតំបន់ទន្លេមេគង្គ កាលពីថ្ងៃទី១២-១៥ ខែកក្កដា ឆ្នាំ២០១៨ នៅប្រទេសថៃ។
- **លោក ហ៊ឺ សុង** ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែ TS៣ ត្រូវបានចាត់តាំងឱ្យទៅចូលរួមសិក្ខាសាលាស្តីពី "ការរៀបចំកម្មវិធីសិក្សា ដោយផ្តោតលើលទ្ធផលសិក្សារំពឹងទុក" ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ នៅសណ្ឋាគារភ្នំប្រុស ខេត្តកំពង់ចាម។

## ៥- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

គិតត្រឹមឆ្នាំ២០១៨ អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ. មិនមានការជាប់ពាក់ព័ន្ធក្នុងដំណើរការផ្លូវច្បាប់នោះទេ។

## ៦- លាភការ ឬប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

*ក. ឈ្មោះ តំណែងអភិបាល និងបុគ្គលិកជាន់ខ្ពស់ និងប្រាក់បំណាច់ ឬលាភការ ដែលទទួលបានខ្ពស់បំផុត ៖*

(ឯកតា៖ពាន់រៀល)

| ល.រ | ឈ្មោះអភិបាល និងបុគ្គលិកជាន់ខ្ពស់ | មុខតំណែងក្នុងក.ស.ភ. | ប្រាក់បៀវត្សរ៍ និងលាភការ មធ្យមប្រចាំខែ | ចំនួនសរុប "ប្រាក់បៀវត្សរ៍ និងលាភការ" |
|---|---|---|---|---|
| | | | ឆ្នាំ២០១៨ | |
| ១ | ហ៊ី បារី | ប្រធានអគ្គនាយក | ២១.២៤៧ | ២៥៤.៩៧១ |
| ២ | ណែម ធីម | ទីប្រឹក្សា | ៣.៩៩៥ | ៤៧.៩៤៨ |
| ៣ | តោ នី | ទីប្រឹក្សា | ៤.៦៤៣ | ៥៥.៧២២ |
| ៤ | ជួន សុខេម | អគ្គនាយករង | ១៥.១០៧ | ១៨១.២៨៥ |
| ៥ | កុយ ប៊ុនធន | អគ្គនាយករង | ៨.០២៣ | ៩៦.២៨៧ |
| ៦ | ហៀក ភិរុណ | អគ្គនាយករង | ៧.៩៣៨ | ៩៥.២៦៧ |
| ៧ | ហ៊ី ផានិន | អគ្គនាយករង | ៧.៩៣៨ | ៩៥.២៦៧ |
| ៨ | គង់ ចាន់នី | ប្រធានលេខាធិការដ្ឋាន | ៧.៤៧២ | ៨៩.៦៧៣ |
| ៩ | កែវ សុផាណ្ណារ៉ា | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | ៥.៩៧៧ | ៧១.៧៣៣ |
| ១០ | ជី វិចិត្រ | ប្រធាននាយកដ្ឋានរដ្ឋបាល | ៥.៩៦៧ | ៧១.៦១៣ |
| ១១ | គង់ សុធា | ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស | ៥.៩៩៧ | ៧១.៩៧៣ |
| ១២ | ឈាវ វណ្ណធា | ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ | ៦.៩៤២ | ៨៣.៣១៣ |
| ១៣ | សាយ ចន្ថា | ប្រធាននាយកដ្ឋានវិស្វកម្ម | ៦.៣៧១ | ៧៦.៤៥២ |
| ១៤ | ជៀប វីរ៉ាយ៉ា | ប្រធាននាយកដ្ឋានជលធារសាស្ត្រ | ៥.៩៥២ | ៧១.៤៣៣ |
| ១៥ | គុល សុខុម | ប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍ | ៥.៩៨៦ | ៧១.៨៣៨ |
| ១៦ | សយ សេរីសុវឌ្ឍនៈ | ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផែ/ផែក្នុងស្រុក | ៥.៩៤២ | ៧១.៣១៣ |
| ១៧ | ហ៊ុន សុខាល័យ | ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ | ៥.៩៥៧ | ៧១.៤៩៣ |
| ១៨ | ហ៊ី សុង | ប្រធាននាយកដ្ឋានប្រតិបត្តិការផែចាស់ TS៣ | ៥.៣៨៣ | ៦៤.៦០២ |
| ១៩ | យឹម ជឿន | ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ | ៦.០០១ | ៧២.០១៨ |
| សរុប | | | **១៤២.៨៣៨** | **១.៧១៤.២០១** |

**សម្គាល់៖*

*- លោកស្រី ជួន សុខេម ត្រូវបានតែងតាំងជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ កាលពីខែ មិថុនា ឆ្នាំ ២០១៨*

*- លោក សាយ ចន្ថា ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានវិស្វកម្ម និងលោក ហ៊ី សុង ជាប្រធាននាយកដ្ឋានប្រតិបត្តិការផែចាស់ TS៣ កាលពីខែ មិថុនា ឆ្នាំ ២០១៨*

- *លោក ជី វិចិត្រ ត្រូវបានផ្ទេរភារកិច្ចពីប្រធាននាយកដ្ឋានវិស្វកម្ម ទៅប្រធាននាយកដ្ឋានរដ្ឋបាល កាលពីខែមិថុនា ឆ្នាំ ២០១៨ ។*
- *បញ្ចប់ការផ្តល់ប្រាក់បៀវត្សរ៍ស្មើអគ្គនាយករង ជូន ឯកឧត្តម ណៃម ធីម ចាប់ពីខែ កក្កដា ឆ្នាំ ២០១៨*
- *លោក តោ នី ចូលនិវត្តន៍ចាប់ពីខែ សីហា ឆ្នាំ ២០១៨*

## *ខ. ចំនួនប្រាក់បំណាច់ ឬលាភការសរុប ដែលបើកឱ្យអភិបាលមិនប្រតិបត្តិ*

(ឯកតា៖ ពាន់រៀល)

| ល.រ | ឈ្មោះអភិបាលមិនប្រតិបត្តិ | មុខតំណែងក្នុង ក.ស.ភ | ប្រាក់បៀវត្សរ៍ / ប្រាក់បំណាច់ |
|---|---|---|---|
| | | | ឆ្នាំ ២០១៨ |
| ១ | ឯកឧត្តម សួន រចនា | អភិបាល | ៩៦.០០០ |
| ២ | ឯកឧត្តម កែន សម្បត្តិ | អភិបាល | ៩៦.០០០ |
| ៣ | ឯកឧត្តម ប៉ែន សុរិជាតិ | អភិបាល | ៩៦.០០០ |
| ៤ | លោក ហ៊្គី អានវ៉ានិថ | អភិបាលឯករាជ្យ | ៩៦.០០០ |
| ៥ | លោក ឌិត សុចល | អភិបាលមិនប្រតិបត្តិ | ៩៦.០០០ |
| ៦ | លោក ម៉ម រិទ្ធី | មន្ត្រីត្រួតពិនិត្យរដ្ឋ | ៩៦.០០០ |
| សរុប | | | **៥៧៦.០០០** |

**សម្គាល់៖ លោក ហ៊្គី អានវ៉ានិថ និង លោក ឌិត សុចល ត្រូវបានតែងតាំងដោយអនុក្រឹត្យលេខ ៦៧៦ អនក្រ.តត ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦*

## *គ. ចំនួនប្រាក់បៀវត្សរ៍សរុបសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់*

(ឯកតា៖ពាន់រៀល)

| ល.រ | ឈ្មោះអភិបាល និង បុគ្គលិកជាន់ខ្ពស់ | មុខតំណែងក្នុងក.ស.ភ. | ប្រាក់បំណាច់ និងលាភការសរុបសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំខាងមុខ |
|---|---|---|---|
| ១ | ឯកឧត្តម ហ៊ី បាវី | អភិបាល | ២៥៦.២៤៥ |
| ២ | ឯកឧត្តម សួន រចនា | អភិបាល | ៩៦.០០០ |
| ៣ | ឯកឧត្តម កែន សម្បត្តិ | អភិបាល | ៩៦.០០០ |
| ៤ | ឯកឧត្តម ប៉ែន សុរិជាតិ | អភិបាល | ៩៦.០០០ |
| ៥ | លោក ហ៊្គី អានវ៉ានិថ | អភិបាលឯករាជ្យ | ៩៦.០០០ |
| ៦ | លោក ឌិត សុចល | អភិបាលមិនប្រតិបត្តិ | ៩៦.០០០ |
| ៧ | លោក ម៉ម រិទ្ធី | មន្ត្រីត្រួតពិនិត្យរដ្ឋ | ៩៦.០០០ |
| ៨ | ណៃម ធីម | ទីប្រឹក្សា | ០ |
| ៩ | លោក តោ នី | ទីប្រឹក្សា | ០ |
| ១០ | លោកស្រី ជួន សុខេម | អគ្គនាយករង | ១៣៥.០០០ |

| | | | |
|---|---|---|---|
| ១១ | លោក កុយ ប៊ុនធន | អគ្គនាយករង | ៩៦.៧៦៨ |
| ១២ | លោក ហៀក ភិរុណ | អគ្គនាយករង | ៩៥.៧៤៣ |
| ១៣ | លោកស្រី ហ៊ី ផានិន | អគ្គនាយករង | ៩៥.៧៤៣ |
| ១៤ | លោក គង់ ចាន់នី | ប្រធានលេខាធិការដ្ឋាន | ៩០.១២១ |
| ១៥ | លោក កែវ សុផាណ្ណារ៉ា | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | ៧២.០៩១ |
| ១៦ | លោក ជី វិចិត្រ | ប្រធាននាយកដ្ឋានរដ្ឋបាល | ៧១.៩៧១ |
| ១៧ | លោក គង់ សុធា | ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស | ៧២.៣៣២ |
| ១៨ | កញ្ញា ឈាវ វណ្ណធា | ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ | ៨៣.៨៥៥ |
| ១៩ | លោក សាយ ចន្ថា | ប្រធាននាយកដ្ឋានវិស្វកម្ម | ៨៣.៨៥៥ |
| ២០ | លោក ជៀប វីរ៉ាយ៉ា | ប្រធាននាយកដ្ឋានជលធារសាស្ត្រ | ៧១.៧៩០ |
| ២១ | លោក តុល សុខុម | ប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍ | ៧២.១៩៧ |
| ២២ | លោក សយ សេរីសុវឌ្ឍនៈ | ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផែ/ផែក្នុងស្រុក | ៧១.៦៦៩ |
| ២៣ | លោក ហ៊ិន សុខាល័យ | ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ | ៧១.៨៥០ |
| ២៤ | លោក ហ៊ី សុង | ប្រធាននាយកដ្ឋានប្រតិបត្តិការផែចាស់ TS៣ | ៧១.៦២៤ |
| ២៥ | លោក យឹម ជឿន | ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ | ១៣០.៣៨០ |
| **សរុប** | | | **២.២១៩.២៣៤** |

*សម្គាល់៖

- *បញ្ចប់ការផ្តល់ប្រាក់បៀវត្សរ៍ស្មើអគ្គនាយករង ជូន ឯកឧត្តម ណៃម ធីម ចាប់ពីខែ កក្កដា ឆ្នាំ ២០១៨*
- *លោក តោ នី ចូលនិវត្តន៍ចាប់ពីខែ សីហា ឆ្នាំ ២០១៨*
- *ការប៉ាន់ស្មានប្រាក់បៀវត្សរ៍របស់បុគ្គលិកជាន់ខ្ពស់សម្រាប់រយៈពេល ១ឆ្នាំ ទៅមុខ ផ្អែកលើកំណើនរបស់ប្រាក់ TEUs និង ការប្រែប្រួលរបស់អាត្រាដុល្លារ។*

### *ឃ. ការបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើន ដល់អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬអនាគត*

ប្រាក់បៀវត្សរ៍របស់ក្រុមប្រឹក្សាភិបាល មានការកើនឡើង លុះត្រាតែមានការស្នើសុំតាមរយៈការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។ ទន្ទឹមនេះ ប្រាក់បៀវត្សរ៍ប្រចាំខែរបស់បុគ្គលិកជាន់ខ្ពស់ អាចនឹងមានការកើនឡើង ឬថយចុះ អាស្រ័យទៅតាមចំនួនកុងតឺន័រ TEUs ដែលឆ្លងការកំពង់ផែ ប្រចាំខែ។

## ៧. ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

### *ក. គោលការណ៍នៃក្រមសីលធម៌*

ក្រមសីលធម៌នេះ ជាក្រមប្រតិបត្តិ ដែលត្រូវអនុវត្តចំពោះក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក.ស.ភ.។

រាល់ការបំពានលើក្រមសីលធម៌នេះ អាចនឹងត្រូវទទួលទណ្ឌកម្មនានាទៅតាមនីតិវិធី ដែលប្រតិបត្តិដោយក្រុមប្រឹក្សាភិបាល។ គោលការណ៍ និងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមសីលធម៌នេះ ត្រូវបានតាក់តែងឡើង ដោយអនុលោមតាមច្បាប់ជាធរមាន ដើម្បីឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក.ស.ភ. គោរពប្រតិបត្តិតាម។ ក្រមសីលធម៌នេះ មិនត្រូវបានប្រើ ដើម្បីជំនួសការដោះស្រាយវិវាទតាមផ្លូវតុលាការនោះទេ។

យន្តការតាមដាន និងរក្សាតុល្យភាព (Checks and Balances) ដែលមានក្នុងក្រមសីលធម៌នេះ ត្រូវបានរៀបចំឡើង ដើម្បីធានាតុល្យភាពក្នុងការគ្រប់គ្រង និងការគោរពកាតព្វកិច្ចកំណត់ដោយច្បាប់ ព្រមទាំងការពារក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ពីការចោទប្រកាន់មិនត្រឹមត្រូវ ឬគ្មានហេតុផលណា មួយ។ ការចោទប្រកាន់បែបនេះ នឹងអាចមានផលប៉ះពាល់ដល់អាជីវកម្មរបស់ ក.ស.ភ. ឬប៉ះពាល់ផលប្រយោជន៍ដល់បុគ្គលណាម្នាក់។ សមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ ក.ស.ភ. អះអាង និងប្តេជ្ញាថានឹងគោរពតាមគោលការណ៍ និងកាតព្វកិច្ច ដូចមានចែងនៅក្នុងក្រមសីលធម៌នេះ។

- **និយមន័យ**

**ក្រុមប្រឹក្សាភិបាល** ៖ សំដៅដល់ក្រុមប្រឹក្សាភិបាលនៃកំពង់ផែស្វយ័តភ្នំពេញ។

**អភិបាល** ៖ សំដៅដល់សមាជិកនៃក្រុមប្រឹក្សាភិបាល ហើយអាចជាអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ ឬ អភិបាលឯករាជ្យ។

**អភិបាលឯករាជ្យ** ៖ សំដៅដល់សមាជិកឯករាជ្យ ដែលបំពេញតាមលក្ខខណ្ឌនៃជំពូកទី៥ នៃប្រកាសស្តីពី អភិបាលកិច្ចអាជីវកម្ម សម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ និងដែលជាទូទៅសំដៅដល់អភិបាល ដែលអាចមានភារកិច្ចដោយមិនមានទំនាស់ផលប្រយោជន៍ដែលកើតឡើងពាក់ព័ន្ធជាមួយ ក.ស.ភ.។

**អភិបាលប្រតិបត្តិ** ៖ សំដៅដល់អភិបាលដែលកាន់តំណែងជាបុគ្គលិកជាន់ខ្ពស់នៅក្នុង ក.ស.ភ.។

**អភិបាលមិនប្រតិបត្តិ** ៖ សំដៅដល់អភិបាលដែលមិនអនុវត្តនូវប្រតិបត្តិការប្រចាំថ្ងៃក្នុង ក.ស.ភ. ឬក៏ជាអភិបាលមិនប្រតិបត្តិជាតំណាងភាគហ៊ុនិកឯកជននិងសាធារណៈ។

**បុគ្គលិកជាន់ខ្ពស់** ៖ សំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខតំណែងចាប់ពីប្រធាននាយកដ្ឋាន រហូតដល់អគ្គនាយក រួមទាំងលេខាធិការរបស់ ក.ស.ភ. និងប្រធានសវនកម្មផ្ទៃក្នុង និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

- **ការបំពេញកាតព្វកិច្ចតាមច្បាប់ និងតាមក្រមសីលធម៌**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ ត្រូវតែប្រតិបត្តិតាមក្រមសីលធម៌ និងគោរពតាមច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តទាំងឡាយជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា។

- **ការធ្វើអាជីវកម្ម**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវបំពេញការងារក្នុងអាជីវកម្មរបស់ ក.ស.ភ. ដោយស្មោះត្រង់ គោរពតាមច្បាប់។

ភាពស្មោះត្រង់ និងការបំពេញកាតព្វកិច្ចតាមច្បាប់ មានន័យថា អភិបាល ឬបុគ្គលិកជាន់ខ្ពស់ត្រូវ ៖

-បំពេញតួនាទីជាមួយនឹងព័ត៌មានពេញលេញទាក់ទងនឹងកម្មវត្ថុពាក់ព័ន្ធ នឹងសេចក្តីសម្រេចណាមួយ

-បំពេញតួនាទីប្រកបដោយសុចរិត និងក្នុងគោលបំណងត្រឹមត្រូវ

-បំពេញតួនាទីដោយមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន ដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍អង្គភាព

-អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវមានគោលជំហរច្បាស់លាស់ ក្នុងការបម្រើផលប្រយោជន៍ របស់ភាគហ៊ុនិកទាំងអស់ ជាពិសេស ក្នុងពេលធ្វើការសម្រេចចិត្ត។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវជាប់ពាក់ព័ន្ធ ទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ជាមួយនឹងការជួញដូរផ្ទៃក្នុង ឬស៊ែលហ្វ៍ដៀលីង (Self-Dealing) ដែលមិនត្រឹមត្រូវ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈមួយអំពីទំនាស់ផលប្រយោជន៍របស់ខ្លួន ដែលកើតមានឡើងពាក់ព័ន្ធនឹង ក.ស.ភ.។ អភិបាល និងបុគ្គលិកជាន់ខ្ពស់នៃ ក.ស.ភ. ពុំត្រូវបានអនុញ្ញាតឱ្យធ្វើការជួញដូរមូលបត្រកម្មសិទ្ធិរបស់ ក.ស.ភ. ឡើយ ក្នុងកំឡុងពេលដូចខាងក្រោម៖

- ១០ថ្ងៃ នៃថ្ងៃធ្វើការ មុនការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ រហូតដល់១ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ
- ៧ថ្ងៃ នៃថ្ងៃធ្វើការ មុនកិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល រហូតដល់១ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយកិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ អាចចូលរួមក្នុងកិច្ចការជំនួញក្នុងនាម ក.ស.ភ. ដែលពួកគេមានផលប្រយោជន៍ លុះត្រាតែអភិបាល ឬបុគ្គលិកជាន់ខ្ពស់ទាំងនោះ អនុវត្តតាមគោលការណ៍ និងបែបបទទាំងអស់ ដែលបានអនុម័ត ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយ ក្នុងព្រះរាជាណាចក្រកម្ពុជា។

- **ការរក្សាការសម្ងាត់**

គ្មានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ មានសិទ្ធិចែកចាយ ថតចម្លង ផលិតជាថ្មី បញ្ជូន បង្ហាញ ឬលាតត្រដាង រាល់ព័ត៌មានសម្ងាត់ណាមួយ ដែលពាក់ព័ន្ធនឹងកិច្ចការរបស់ ក.ស.ភ.។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ត្រូវរក្សាយ៉ាងម៉ឺងម៉ាត់ នូវការសម្ងាត់នៃកិច្ចប្រជុំទាំងអស់ និងការពិភាក្សាផ្សេងៗ ព្រមទាំងការទំនាក់ទំនងនៃក្រុមប្រឹក្សាភិបាល លើកលែងតែក្រុមប្រឹក្សាភិបាល ឬច្បាប់តម្រូវផ្សេងពីនេះ ។

គ្មានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ប្រើប្រាស់នូវរាល់ព័ត៌មានណាមួយ ដែលផ្តល់ដោយ ក.ស.ភ. ឬទទួលបានតាមរយៈការបំពេញការងារជាអភិបាលទៅឱ្យ ក.ស.ភ. ទោះបីក្រោមរូបភាពណាក៏ដោយលើកលែងតែក្នុងគោលបំណងជួយសម្រួលដល់កាតព្វកិច្ចរបស់ខ្លួន នៅក្នុងក្រុមប្រឹក្សាភិបាល។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ត្រូវយកចិត្តទុកដាក់ជាពិសេស ក្នុងពេលបំពេញការងារទាក់ទងនឹង លទ្ធផលរបស់ក្រុមហ៊ុន ការប៉ាន់ស្មានព័ត៌មានហិរញ្ញវត្ថុផ្សេងទៀត ចំណេះដឹង និងបច្ចេកវិទ្យា ព្រមទាំងព័ត៌មានធនធានមនុស្ស។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវគោរពកាតព្វកិច្ចរក្សាការសម្ងាត់ ទោះបីក្រោយពីបានបញ្ចប់ការងាររបស់ខ្លួននៅ ក.ស.ភ. ក៏ដោយ។

❖ **ការគោរពសិទ្ធិចំពោះបុគ្គលិក ក.ស.ភ.**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវអនុវត្តអំណាចរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងធ្វើការវិនិច្ឆ័យឱ្យបានល្អ ចំពោះបុគ្គលិករបស់ ក.ស.ភ. ព្រមទាំងត្រូវឆ្លើយតបទៅតាមតម្រូវការនៃសមាជិករបស់ ក.ស.ភ. ដោយភាពទទួលខុសត្រូវ ការគោរព និងដោយមានវិជ្ជាជីវៈខ្ពស់។

ទំនាក់ទំនងរវាងមន្ត្រី និយោជិត និងអភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធ្វើឡើយដោយឈរលើគោលការណ៍នៃការជឿទុកចិត្ត ការគោរពគ្នាទៅវិញទៅមក និងស្មារតីគោរពសេចក្តីថ្លៃថ្នូររបស់បុគ្គលិកម្នាក់ៗ។

ក.ស.ភ. ត្រូវគោរពតាមគោលនយោបាយធនធានមនុស្សរបស់ខ្លួនដោយឥតលម្អៀង និងគោរពតាមច្បាប់ ដោយមិនត្រូវបង្កាច់បង្ខូច ឬមានការរើសអើងឡើយ។ រាល់ការគាបសង្កត់ ការរំខាន ការធ្វើទុក្ខបុកម្នេញ ឬការធ្វើទារុណកម្មខាងផ្លូវចិត្ត ឬផ្លូវកាយ ត្រូវបានហាមឃាត់។

គោលការណ៍ទាំងនេះ អនុវត្តលើអភិបាល និងបុគ្គលិកជាន់ខ្ពស់ ទាក់ទងនឹងការប្រព្រឹត្តរបស់ខ្លួន ចំពោះបុគ្គលិករបស់ ក.ស.ភ. និងបុគ្គលដែលមិនមែនជាបុគ្គលិកក្នុង ក.ស.ភ. ផងដែរ ។

❖ **ការការពារទ្រព្យសម្បត្តិ**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវការពារទ្រព្យសម្បត្តិទាំងអស់របស់ ក.ស.ភ.។ ទ្រព្យសម្បត្តិទាំងនោះ រួមមាន ទ្រព្យរូបី និងទ្រព្យអរូបី ដូចជាគំនិត ជំនាញ ចំណេះដឹង ចំណេះធ្វើ ដែលបង្កើតឡើងដោយ ក.ស.ភ.។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ មិនត្រូវប្រើប្រាស់ទ្រព្យសម្បត្តិ ឬធនធានរបស់ ក. ស. ភ សម្រាប់ហេតុផលផ្ទាល់ខ្លួន ឬដើម្បីផលប្រយោជន៍ដល់តតិយជនឡើយ។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ត្រូវរក្សាទ្រព្យសម្បត្តិរបស់ ក.ស.ភ. ឱ្យបានល្អគង់វង្ស គ្រប់ពេលវេលា និងមិនត្រូវឱ្យបុគ្គលណាម្នាក់ ដែលមិនទទួលបានការអនុញ្ញាតពីក្រុមប្រឹក្សាភិបាល មានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យសម្បត្តិរបស់ ក.ស.ភ. ឡើយ។

❖ **សវនកម្មផ្ទៃក្នុង**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធានានូវតម្លាភាព និងភាពស្មោះត្រង់ នៅពេលបំពេញការងារទាក់ទងជាមួយនឹងសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដើម្បីធានាថាភាពទន់ខ្សោយ និងគុណវិបត្តិចម្បងៗ អាចត្រូវបានកំណត់ និងកែតម្រូវបាន។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវធ្វើទង្វើណាមួយ ដែលនាំឱ្យរាំងស្ទះ ឬ លាក់បាំងព័ត៌មានណាមួយ ដល់ការធ្វើសវនកម្ម ឬការធ្វើអធិការកិច្ចណាមួយឡើយ ទោះបីជាការធ្វើឡើងនោះជាលក្ខណៈផ្ទៃក្នុង ដោយសវនករនៃ គ.ស.ភ. ក៏ដោយ។ រាល់ការប្រព្រឹត្តទង្វើទាំងនេះ គឺជាការបំពានយ៉ាងធ្ងន់ធ្ងរទៅលើក្រមសីលធម៌នេះ ហើយត្រូវបានហាមឃាត់ ។

❖ **សកម្មភាពអភិវឌ្ឍន៍**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវចូលរួមឱ្យអស់ពីលទ្ធភាពរបស់ខ្លួនជាប្រចាំ នៅក្នុងសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈ ព្រមទាំងបំពេញភារកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈវិជ្ជាជីវៈ និងឱ្យបានទាន់ពេលវេលាទៅតាមការណែនាំ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាល។

❖ **ផលប្រយោជន៍របស់ គ.ស.ភ.**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធ្វើការលះបង់ ដើម្បីបំពេញតាមតម្រូវការរបស់ គ.ស.ភ.។

អភិបាល ត្រូវបំពេញតួនាទីគ្រប់ពេលទាំងអស់ ដើម្បីជាឧត្តមប្រយោជន៍របស់ គ.ស.ភ. ហើយមិនមែនដើម្បីផលចំណេញ ឬការបង្កើនប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ខ្លួន ឬតតិយជនណាមួយឡើយ។ បុគ្គលិកទាំងអស់របស់ គ.ស.ភ. ដោយរាប់បញ្ចូលទាំងអភិបាល និងបុគ្គលិកជាន់ខ្ពស់ផង ត្រូវបំពេញនូវតួនាទី ដោយស្មោះត្រង់ និងដើម្បីផលប្រយោជន៍របស់ គ.ស.ភ. គ្រប់កាលៈទេសៈទាំងអស់។ បុគ្គលិកទាំងអស់ មិនត្រូវបរិហារជាសាធារណៈ និងវាយប្រហារណាមួយមកលើកិត្តិនាម និងភាពស្មោះត្រង់របស់ គ.ស.ភ. និងការវាយប្រហារមកលើវិជ្ជាជីវៈការងាររបស់បុគ្គលិក គ.ស.ភ.។

❖ **ទំនាស់ផលប្រយោជន៍**

អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ គ.ស.ភ. ត្រូវធានាថាសកម្មភាពខាងក្រៅ និងផលប្រយោជន៍ផ្ទាល់ខ្លួនត្រូវបានចែកឱ្យដាច់ពីតួនាទីនៅក្នុង គ.ស.ភ. និងមិនត្រូវប្រើឥទ្ធិពលទៅលើការសម្រេចអាជីវកម្មក្នុងនាម គ.ស.ភ. ឡើយ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ចាំបាច់ត្រូវប្រើនូវសុភវិនិច្ឆ័យ និងរក្សាផលប្រយោជន៍ គ.ស.ភ. ជាធំ។ ដើម្បីកុំឱ្យមានទំនាស់ផលប្រយោជន៍ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវជៀសវាងចេញពីស្ថានភាពណាមួយ ដែលអាចបណ្តាលឲ្យកើតមានទំនាស់ផលប្រយោជន៍។

នៅពេលដែលទំនាស់ផលប្រយោជន៍អាចនឹងកើតមានឡើង នោះអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ គ.ស.ភ. ត្រូវកំណត់ទំនាស់ផលប្រយោជន៍នោះ ហើយធ្វើការប្រកាសជាសាធារណៈ អំពីទំនាស់ផលប្រយោជន៍ និងធ្វើការដកខ្លួនចេញពីការពិភាក្សា និងការបោះឆ្នោតលើបញ្ហាទាំងនោះ (បើអនុវត្តបាន)។

❖ **អំពើពុករលួយ**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវផ្តល់ប្រាក់ឧបត្ថម្ភ ឬអំណោយដោយផ្ទាល់ ឬដោយប្រយោល មិនត្រូវធ្វើការសន្យា ឬផ្តល់ផលប្រយោជន៍ណាមួយទៅកាន់មន្ត្រីសាធារណៈ ឬប្រជាពលរដ្ឋដែលទទួលការទុកចិត្តក្នុងអាណត្តិសាធារណៈ តាមរយៈការបោះឆ្នោតដើម្បីឲ្យមន្ត្រីសាធារណៈនោះ ឬមន្ត្រីដែលជាប់ឆ្នោតនោះ (១) អនុវត្តសកម្មភាពណាមួយក្នុងតួនាទីរបស់គេ ឬក៏សម្របសម្រួលការងារណាមួយក្នុងតួនាទីរបស់ពួកគេ ឬ (២) មិនអនុវត្តកាតព្វកិច្ច ឬសម្របសម្រួលការងារណាមួយក្នុងតួនាទីរបស់ពួកគេ ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ មិនត្រូវទទួលយកអំណោយ ដែលត្រូវបានផ្តល់ឱ្យ ឬនឹងត្រូវផ្តល់ឱ្យដោយសារតែតួនាទីរបស់ខ្លួននៅក្នុង ក.ស.ភ.។

❖ **សកម្មភាពនយោបាយ**

ក.ស.ភ. គោរពតាមការប្តេជ្ញាចិត្តរបស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ ដែលចង់ចូលរួមក្នុងកិច្ចការសាធារណៈ ប៉ុន្តែ ក. ស. ភ. ត្រូវប្រកាន់គោលការណ៍អព្យាក្រឹតចំពោះវិស័យនយោបាយ។ ដូចនេះ អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ ក.ស.ភ. អាចអនុវត្តសេរីភាពបញ្ចេញមតិ និងធ្វើសកម្មភាពនយោបាយបាននៅក្រៅពីម៉ោងធ្វើការ ដោយចំណាយផ្ទាល់ខ្លួន និងផ្អែកលើគំនិតផ្ទាល់ខ្លួនប៉ុណ្ណោះ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក.ស.ភ. មិនត្រូវភ្ជាប់ ក.ស.ភ. ទៅនឹងសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេទេ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ពុំត្រូវពិភាក្សាពីសមាជិកភាពរបស់ ក.ស.ភ. ទៅក្នុងបរិបទនយោបាយណាមួយឡើយ។

❖ **ការបញ្ចប់អាណត្តិ**

ក្រោយពីបញ្ចប់ភារកិច្ចរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដែលចូលនិវត្តត្រូវប្រគល់ភ្លាមទៅឱ្យ ក.ស.ភ. វិញនូវឯកសារអេឡិចត្រូនិច និងឯកសារ ជាក្រដាស ឯកសារយោង និងឯកសារផ្សេងៗ ទៀត ដែលត្រូវបានផ្តល់ជូនក្នុងគោលបំណងបំពេញការងារ។ ការប្រគល់ជូនទៅវិញនូវឯកសារទាំងនេះ មិនបានលុបចោលនូវកាតព្វកិច្ចរក្សាការសម្ងាត់នូវព័ត៌មាន ដែលទទួលបានក្នុងរយៈពេលនៃការកាន់ មុខតំណែងនៅក្នុងក្រុមប្រឹក្សាភិបាល ឬតួនាទីជាន់ខ្ពស់នៅក្នុង ក.ស.ភ. នោះទេ។

❖ **ការបកស្រាយ**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមស្មារតី និងខ្លឹមសារនៃក្រមសីលធម៌នេះ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ មានភារកិច្ចយល់ដឹងអំពីក្រមសីលធម៌នេះ។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ដែលមានភាពស្រពិចស្រពិល ឬយល់មិនច្បាស់លើបទប្បញ្ញត្តិណាមួយ ត្រូវទាក់ទងទៅផ្នែកច្បាប់ ដោយផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យផ្នែកច្បាប់អាចផ្តល់យោបល់ ឬធ្វើការសម្រេចចិត្តសមស្របមួយ។

❖ ការកែប្រែ

ក្រមសីលធម៌នេះ អាចត្រូវបានធ្វើការកែប្រែ ដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដោយគោរពតាមលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាន ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយជាធរមាន។

**ខ- ការអនុវត្តក្រមសីលធម៌**

ក្រមសីលធម៌នេះ ត្រូវបានអនុម័ត ដោយក្រុមប្រឹក្សាភិបាលនៃកំពង់ផែស្វយ័តភ្នំពេញ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ និងមានអានុភាពចាប់ពីពេលក្រុមហ៊ុនទទួលបានការយល់ព្រមឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយគណៈកម្មការមូលបត្រកម្ពុជា និងត្រូវបានចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា។ ក្រុមប្រឹក្សាភិបាល ត្រូវចាត់វិធានការសមស្រប ក្នុងករណីមានការបំពារបំពានក្រមសីលធម៌នេះ។

## ៨. សិទ្ធិភាគីពាក់ព័ន្ធ

សម្រាប់ឆ្នាំ២០១៨ សិទ្ធិភាគីពាក់ព័ន្ធមិនទាន់បានអនុវត្តនោះទេ។

# ផ្នែកទី៤

# បញ្ជីរាយនាមភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតចំនួនច្រើន

## ១. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់

| ល.រ | ឈ្មោះ | សញ្ជាតិ | អាសយដ្ឋាន | លេខអត្តសញ្ញាណវិនិយោគិន (ប្រសិនបើមាន) | បរិមាណ | ភាគរយ |
|---|---|---|---|---|---|---|
| ១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ខ្មែរ | ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | គ្មាន | ១៦.៥៤៧.៩៩២ | ៨០% |
| **សរុប** | | | | | **១៦.៥៤៧.៩៩២** | **៨០%** |

## ២. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន

| ល.រ | ឈ្មោះ | សញ្ជាតិ | អាសយដ្ឋាន | លេខអត្តសញ្ញាណវិនិយោគិន (ប្រសិនបើមាន) | បរិមាណ | ភាគរយ |
|---|---|---|---|---|---|---|
| ១ | Mekong Strategic Infrastructure | បរទេស | Craigmor Chambers. Road Town. Tortola. Vg១១១០. Virgin Islands. British | F៥១៨៧៦៧៨៤៧៨៦ | ១.៣៦០.៣៧០ | ៦,៥៨% |
| **សរុប** | | | | | **១.៣៦០.៣៧០** | **៦,៥៨%** |

# ផ្នែកទី ៥

# ព័ត៌មានអំពីការជួញដូរមូលបត្ររបស់កំពង់ផែស្វយ័តភ្នំពេញ

## ១. ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

ឈ្មោះមូលបត្រកម្មសិទ្ធិ : **មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ក"**

អក្សរកូដមូលបត្រកម្មសិទ្ធិ : **KH1000040001**

ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ : **មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ក"**

តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ : **៤.០០០រៀល**

ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ : **៥.១២០រៀល**

បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ : **៨.១៣៦.៨៧៣ មូលបត្រ**

មូលធនូបនីយកម្មទីផ្សារ : **១០៥.៩០៣.៩៤៨.៨០០ រៀល**

ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត : **ផ្សារមូលបត្រកម្ពុជា**

កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ : **ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥**

## ២. ថ្លៃនិងបរិមាណជួញដូរ

| មូលបត្រកម្មសិទ្ធ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមា | ៥.១៦០ | ៥.៤០០ | ៥.៦០០ | ៥.៩៤០ | ៥.៥៦០ | ៥.៦០០ | ៥.៥០០ | ៥.៥០០ | ៦.៨០០ | ៦.៤២០ | ៦.៥៤០ | ៨.៥៤០ |
| | អប្បបរមា | ៥.១០០ | ៥.១៤០ | ៥.១២០ | ៥.០៤០ | ៥.២៦០ | ៥.៣០០ | ៥.១០០ | ៥.៣៨០ | ៥.៩២០ | ៦.២៤០ | ៦.៤០០ | ៦.៩៨០ |
| | មធ្យម | ៥.១៣០ | ៥.២៧០ | ៥.៣៦០ | ៥.២៨៩ | ៥.៩២៥ | ៥.៩៦០ | ៥.៣៩០ | ៥.៩៧៨ | ៦.០១៨ | ៦.៣៨២ | ៦.៩៣១ | ៧.៩៦៩ |
| បរិមាណជួញដូរ | អតិបរមា | ៥.០០០ | ៣០.១៦០ | ២១.០២០ | ៧៣.១៩៣ | ២.១៣០ | ៣៨.៣៧៦ | ១.៦៦០ | ១២.០៨៥ | ២.៩៨០ | ១.៦៤០ | ៣.៩៩៧ | ១៣.១៧១ |
| | អប្បបរមា | ០ | ០ | ០ | ១០ | ២០ | ១០ | ៥ | ១០ | ១០ | ១ | ១ | ៨៨ |
| | មធ្យម | ២.៥០០ | ១៥.០៨០ | ១០.៥១០ | ៥.១៥៩ | ៩១៣ | ៥.៥២៩ | ២៣៦ | ៨០៣ | ៩២៩ | ២៩៦ | ៧៩៦ | ២.៧៨៩ |

# ផ្នែកទី ៦

# របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តភ្នំពេញ

គណៈកម្មាធិការសវនកម្ម

នាយកដ្ឋានសវនកម្មផ្ទៃក្នុង

លេខ..០៧០.... នសផក-ក. ស. ភ.

## របាយការណ៍សវនកម្ម

## ស្តីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ ២០១៨

កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) មានតួនាទីជាអាជ្ញាធរផែ ប្រតិបត្តិករផែ ដែលធ្វើការគ្រប់គ្រងក្នុងអាជីវកម្មដឹកជញ្ជូនតាមដងទន្លេមេគង្គ ទន្លេសាប និងពើរតួនាទីជាបណ្តាញដឹកជញ្ជូនតាមផ្លូវទឹកប្រកបដោយប្រសិទ្ធភាព សមត្ថភាព តម្លាភាព ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងជាមួយដៃគូពាណិជ្ជកម្មក្នុង និងក្រៅប្រទេស។

ទន្ទឹមនឹងនេះ ការងារត្រួតពិនិត្យផ្ទៃក្នុង គឺជាកត្តាចម្បងពិមានសារៈសំខាន់បំផុតដែលជួយជំរុញដល់ ក. ស. ភ. ធ្វើប្រតិបត្តិការប្រចាំថ្ងៃឱ្យមានប្រសិទ្ធភាព និងសម្រេចបាននូវគោលដៅជាអាទិភាពរបស់ខ្លួនក្នុងសកម្មភាពមន្រ្តី បុគ្គលិក កម្មករជំនាញ ការកែសម្រួលបែបបទ ឯកសារតាមលិខិតបទដ្ឋានគតិយុត្ត ការផ្តល់ទំនុកចិត្ត ភាពទន់ភ្លន់នៃតម្លៃ និងសេវាកម្មសមស្របទៅនឹងទីផ្សារដែលប្រកបដោយគណនេយ្យភាព។

### ក. វាយតម្លៃប្រសិទ្ធភាពការអនុវត្តតាមអនុសាសន៍កន្លងមក (សម្រាប់ឆ្នាំ ២០១៥)

| លទ្ធផលការងារសវនកម្ម | ការកែលម្អ |
|---|---|
| **១. ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា** | |
| - គួរតែរៀបចំធ្វើរបាយការណ៍សកម្មភាពការងារ ក្រោយពេលផុតសុពលថែទាំ ផ្លាស់ប្តូរឧបករណ៍សម្រាប់ប្រព័ន្ធព័ត៌មានវិទ្យាតាមបណ្តានាយកដ្ឋានក្នុង ក. ស. ភ. | - អនុវត្តន៍បាន១០០% ជាក្រុមកុំព្យូទ័រ ប៉ុន្តែមិនទាន់បានធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរ។ |
| - ការរក្សាឯកសារដែលពាក់ព័ន្ធដូចជា ការរៀបចំផែនការប្រចាំឆ្នាំ សំណើសុំទិញសម្ភារគ្រប់ប្រភេទ និងឯកសារដែលពាក់ព័ន្ធទៅនឹងដំណើរការប្រតិបត្តិការការងារផ្នែកព័ត៌មានវិទ្យា គួរតែថតចម្លងរក្សាទុកនៅក្នុងការិយាល័យ ដើម្បីងាយស្រួលតាមដានការងារនៅឆ្នាំបន្តបន្ទាប់។ | - អនុវត្តបាន៧០%។ |
| **២. ការិយាល័យសន្តិសុខប្រព័ន្ធ** CCTV Camera | |
| - ចំពោះការគ្រប់គ្រង និងរៀបចំរបាយការណ៍សង្ខេបប្រចាំថ្ងៃ ឬឯកសារពាក់ព័ន្ធក្នុងប្រតិបត្តិការត្រូវថតចម្លងរក្សាទុកមួយច្បាប់ក្នុងការិយាល័យ | - អនុវត្តមិនទាន់បានពេញលេញ។ |

| | |
|---|---|
| - ត្រូវរាយការណ៍បូកសរុបប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំ ត្រូវមានចុះហត្ថលេខាទទួលស្គាល់ពីប្រធាននាយកដ្ឋាន ឬប្រធានការិយាល័យ | - អនុវត្តមិនទាន់បានពេញលេញ។ |
| - ប្រធានការិយាល័យសន្តិសុខ គួរតែរៀបចំកាលវិភាគវេនយាមប្រចាំការឡើងវិញ ដោយមានផ្លាស់ប្តូរថ្ងៃឈប់សម្រាកដល់បុគ្គលិកសន្តិសុខទាំងអស់គ្នា | - អនុវត្តមិនទាន់បានពេញលេញ។ |
| - គួរតែយកចិត្តទុកដាក់បណ្តុះបណ្តាលបន្ថែមទៀតដល់បុគ្គលិកដែលមានតួនាទីពាក់ព័ន្ធក្នុងការកត់ត្រាកុងតឺន័រចូល-ចេញនៅច្រកទ្វារឱ្យត្រឹមត្រូវតាមបទដ្ឋានក្នុងការសរសេរ និងរៀបចំរបាយការណ៍ | - អនុវត្តមិនទាន់បានពេញលេញ។ |
| - គួរតែមានបន្ទប់ត្រួតពិនិត្យ CCTV Camera ដាច់ដោយឡែក ងាយស្រួលតាមដានរាល់សកម្មភាពសន្តិសុខក្នុងតំបន់កំពង់ផែ និងទីលានស្តុកកុងតឺន័រ ជៀសវាងមានបញ្ហាកើតឡើងឧបទ្ទវហេតុ។ | - អនុវត្តបានពេញលេញ។ |

### ៣- ការិយាល័យបុគ្គលិក/បណ្តុះបណ្តាល

| | |
|---|---|
| - ជំរុញការធ្វើបច្ចុប្បន្នភាពលើការកំណត់អំពីតួនាទី និងភារកិច្ចឱ្យបានគ្រប់នាយកដ្ឋាន ដើម្បីងាយស្រួលក្នុងការប្រតិបត្តិការការងារប្រចាំថ្ងៃ | - អនុវត្តមិនទាន់បានពេញលេញ។ |
| - ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសគឺនៅមានកម្រិតនៅឡើយ បើប្រៀបធៀបជាមួយនិងគម្រោងផែនការឆ្នាំដែលបានគ្រោងឡើង | - អនុវត្តបានពេញលេញ។ |
| - ក្រោយពីបញ្ចប់បេសកកម្មក្នុង និងក្រៅប្រទេសរាល់ការបណ្តុះបណ្តាល និងកិច្ចការងារផ្សេងៗ ការិយាល័យត្រូវឱ្យសាមីជនសរសេររបាយការណ៍ ឬកំណត់ហេតុរបស់ខ្លួនឱ្យបានគ្រប់ៗគ្នាសម្រាប់ទុកជាឯកសារ | - អនុវត្តមិនទាន់បានពេញលេញ។ |
| - រាល់ការសុំច្បាប់ទៅពិនិត្យសុខភាពក្នុង និងក្រៅប្រទេស គួរតែមានលិខិតបញ្ជាក់ពិនិត្យសុខភាពអមជាមួយនៅពេលត្រលប់មកវិញ។ | - អនុវត្តបានពេញលេញ។ |

### ៤- ការិយាល័យបៀវត្សពលកម្ម

| | |
|---|---|
| - ចំពោះការចុះបេសកកម្មក្នុង និងក្រៅប្រទេសគួរតែមានការចុះហត្ថលេខារបស់សាមីខ្លួនលើឯកសារតារាងចំណាយឱ្យបានគ្រប់ៗគ្នា។ | - អនុវត្តបានពេញលេញ។ |

## ខ. លទ្ធផលការអង្កេតអវិជ្ជមាន

យោងតាមផែនការសវនកម្មប្រចាំឆ្នាំ ២០១៨ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានចុះត្រួតពិនិត្យតាមបណ្តានាយកដ្ឋាន ការិយាល័យ និងអង្គភាពដូចខាងក្រោម៖

១- អង្គភាពវិក្កយបត្រ LM១៧
២- ការិយាល័យកិច្ចការជំនួញ/ ប្រព័ន្ធ TOS
៣- ការិយាល័យបច្ចេកវិទ្យា/ ព័ត៌មានវិទ្យា
៤- ការិយាល័យសន្តិសុខ/ ប្រព័ន្ធ CCTV Camera
៥- ការិយាល័យបុគ្គលិក/ បណ្តុះបណ្តាល
៦- ការិយាល័យរៀបចំផែនការ/ ពាណិជ្ជកម្ម
៧- នាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ
៨- ការិយាល័យគណនេយ្យ
៩- ការិយាល័យហិរញ្ញវត្ថុ/ ទីផ្សារមូលបត្រ

**១- អង្គភាពវិក្កយបត្រ LM១៧ (ត្រីមាសទី១)**

*១.១. ការរៀបចំសៀវភៅចុះលេខរដ្ឋបាលចេញ-ចូល*

តាមការពិនិត្យនិងសាកសួរឃើញថា អង្គភាពពុំទាន់មានសៀវភៅចុះលេខចេញ-ចូល ដែលគេប្រើសម្រាប់កត់ត្រាលិខិត ឯកសារលិខិត ទីកន្លែងទទួល និងបញ្ជូនលិខិត តាមលេខរៀងបន្តបន្ទាប់នៃកាលបរិច្ឆេទ និងធ្វើការបិទបញ្ជីសៀវភៅនៅរាល់ដំណាច់ឆ្នាំ ។

*កត្តានេះធ្វើឱ្យការគ្រប់គ្រងលិខិតរដ្ឋបាលមានភាពពុំច្បាស់លាស់ ។*

**សំណូមពររបស់សវនករ៖** អង្គភាពវិក្កយបត្រ គួរតែមានសៀវភៅចូល-ចេញទុកសម្រាប់កត់ត្រា ដើម្បីឱ្យការគ្រប់គ្រងលិខិតរដ្ឋបាលមានភាពច្បាស់លាស់។

**មតិឆ្លើយតបសវនដ្ឋាន៖** តាមការបកស្រាយបំភ្លឺរបស់សវនដ្ឋាន នឹងធ្វើការកែសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ។

*១.២. បង្កើតវគ្គបណ្តុះបណ្តាលដល់មន្ត្រីរបស់ខ្លួន*

តាមការសាកសួរមន្ត្រីមួយចំនួន ដែលចូលបម្រើការងារថ្មី បានឱ្យដឹងថា មិនដែលបានរៀនវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធ TOS (Terminal Operating System) នៅឡើយទេ ដោយធ្វើការងារទៅបានដោយការសាកសួរមន្ត្រីចូលមុន ឬប្រធានរបស់ខ្លួនតែប៉ុណ្ណោះ ។

*កត្តានេះជាហេតុដែលធ្វើឱ្យការយល់ដឹងនៅមានកម្រិត ។*

**សំណូមពររបស់សវនករ៖** ដូចនេះ ដើម្បីឱ្យមន្ត្រីនៅក្នុងអង្គភាពមានការយល់ដឹងលម្អិតពីប្រព័ន្ធ TOS អង្គភាពគួរតែសហការជាមួយនាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស និងមន្ត្រីជំនាញខាងប្រព័ន្ធ TOS ដើម្បីស្នើសុំបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីរបស់អង្គភាពក្នុងការបង្កើនប្រសិទ្ធភាពការងារបន្ថែមទៀត។

**មតិឆ្លើយតបសវនដ្ឋាន៖** តាមការបកស្រាយបំភ្លឺរបស់សវនដ្ឋាន គួរតែមានបើកវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធ TOS ដល់មន្ត្រីរបស់អង្គភាពវិក្កយបត្រ (LM១៧) ។

### ១.៣. បន្តជំរុញដល់អតិថិជនបង់ថ្លៃសេវាឱ្យទាន់ពេលវេលា

សវនករសង្កេត និងពិនិត្យឃើញថាអតិថិជនមួយចំនួនបានដាក់ទំនិញចូល (Container) និងដាក់ចុះនាវា ដើម្បីដឹកទៅប្រទេសគោលដៅ ប៉ុន្តែអតិថិជនមិនទាន់បង់សេវានៅឡើយ ។

*កត្តាបង់ថ្លៃសេវាយឺតនេះបណ្តាលមកពីអតិថិជននៅមានកម្រិតក្នុងការយល់ដឹងផ្នែកប្រព័ន្ធ TOS និងខាងនាវានៅមានភាពយឺតយ៉ាវក្នុងការផ្តល់ព័ត៌មាន ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ការបើកបញ្ជីនាវា (Export ចេញទៅក្រៅប្រទេស) របស់អង្គភាពវិក្កយបត្រ LM១៧ និងអង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧ ។*

**សំណូមពររបស់សវនករ៖** ដូចនេះអង្គភាពវិក្កយបត្រ LM១៧ ត្រូវជំរុញដល់អតិថិជនឱ្យមកបង់ថ្លៃសេវាបានឱ្យស្របទាន់ពេលវេលា ឬក៏មុនកុងតឺន័រដាក់ចុះនាវា ។

**មតិឆ្លើយតបសវនដ្ឋាន៖** តាមការបកស្រាយបំភ្លឺរបស់សវនដ្ឋាន បានធ្វើការប្រជុំជាមួយអង្គភាពពាក់ព័ន្ធ និងថ្នាក់លើកំពុងធ្វើការពង្រឹងឡើងវិញ និងខិតខំជំរុញបន្ថែមផ្នែក Export ដល់អតិថិជនឱ្យបង់សេវាបានទាន់ពេលវេលា ។

### ១.៤. ផលលំបាកនៃប្រព័ន្ធ TOS (Terminal Operating System) ដែលមិនអាចធ្វើការបូកសរុបរបាយការណ៍ប្រចាំថ្ងៃ ខែ និងឆ្នាំ

តាមការសាកសួរព័ត៌មានអង្គភាពវិក្កយបត្របានឱ្យដឹងថាប្រព័ន្ធ TOS មិនអាចធ្វើការបូកសរុបរបាយការណ៍ប្រចាំថ្ងៃ ខែ និងឆ្នាំ នៅឡើយទេ ជាហេតុធ្វើឱ្យមានភាពលំបាកដោយអង្គភាពត្រូវធ្វើការបូកសរុបដោយយោងទៅតាមរបាយការណ៍ប្រចាំថ្ងៃខាងលើឡើង និងធ្វើការបូកបន្ថែមជាមួយកម្មវិធី Excel។

*កត្តានេះអាចជាហេតុធ្វើឱ្យការងារមានភាពយឺតយ៉ាវ ។*

**សំណូមពររបស់សវនករ៖** ដើម្បីមានភាពងាយស្រួល និងប្រសិទ្ធភាពការងារ អង្គភាពវិក្កយបត្រគួរតែសហការជាមួយផ្នែកពាក់ព័ន្ធដែលកាន់កាប់លើប្រព័ន្ធ TOS បំពេញបន្ថែមទៅលើមុខងារដែលខ្វះចន្លោះនៅលើប្រព័ន្ធ TOS ។

**មតិឆ្លើយតបសវនដ្ឋាន៖** តាមការបកស្រាយបំភ្លឺរបស់សវនដ្ឋាន កំពុងរៀបចំធ្វើសំណើទៅខាងការិយាល័យបច្ចេកវិទ្យា/ព័ត៌មាន និងអ្នកជំនាញកម្មវិធីប្រព័ន្ធ TOS ដើម្បីធ្វើការកែលម្អឡើងវិញនូវទម្រង់សម្រាប់បូកសរុបរបាយការណ៍ប្រចាំថ្ងៃ ខែ ឆ្នាំ ។

### ១.៥. កង្វះខាតក្នុងការរក្សាទុកលិខិតរដ្ឋបាល

សវនករសង្កេតឃើញថាលិខិតរដ្ឋបាលរបស់អង្គភាពវិក្កយបត្រ មិនបានធ្វើការរក្សាច្បាប់ដើមទុកទេ គឺមានតែនៅក្នុងប្រព័ន្ធកុំព្យូទ័រតែប៉ុណ្ណោះ ជាហេតុធ្វើឱ្យការគ្រប់គ្រងឯកសារមានភាពមិនច្បាស់លាស់ ។

*កត្តានេះអាចធ្វើអោយការគ្រប់គ្រងនៅមានភាពខ្វះចន្លោះ ។*

**សំណូមពររបស់សវនករ៖** ដើម្បីឱ្យការគ្រប់គ្រងលិខិតរដ្ឋបាលមានភាពច្បាស់លាស់អង្គភាពគួរតែធ្វើការរក្សាពាល់ឯកសារច្បាប់ចម្លងទុកក្នុងអង្គភាព ។

**មតិឆ្លើយតបសវនដ្ឋាន៖** តាមការបកស្រាយបំភ្លឺរបស់សវនដ្ឋាន នឹងធ្វើការកែសម្រួលនូវចំនុចខ្វះខាតឱ្យបានល្អប្រសើរ ។

### *១.៦. ការចុះហត្ថលេខាទៅលើដំណើរការឯកសារ (Tax Invoice)*

សវនករពិនិត្យឃើញថា មានចំនុចខ្វះចន្លោះនៅលើដំណើរការឯកសារ (Tax Invoice) ក្នុងការចុះហត្ថលេខាពីអតិថិជន ប្រធាននាយកដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ ភាគច្រើនមិនបានធ្វើការចុះហត្ថលេខានៅលើឯកសារឡើយ ។

*កត្តានេះ ធ្វើឱ្យឯកសារមិនមានលក្ខណៈគតិយុត្តទៅតាមទម្រង់រដ្ឋបាល ។*

**សំណូមពររបស់សវនករ៖** អង្គភាពគួរតែសហការ និងជំរុញផ្នែកពាក់ព័ន្ធទាំងអស់ ដែលមានតួនាទីចុះហត្ថលេខានៅលើសន្លឹកឯកសារ ដើម្បីឱ្យមានការទទួលខុសត្រូវទាំងខាងអតិថិជន និងជំនាញ ជៀសវាងនៅពេលមានបញ្ហាផ្សេងៗ កើតមានឡើងដោយប្រការណាមួយ ។

**មតិឆ្លើយតបសវនដ្ឋាន៖** តាមការបកស្រាយបំភ្លឺរបស់សវនដ្ឋាន រាល់សន្លឹកឯកសារដែលចេញពីអង្គភាពវិក្កយបត្រ ប្រធាននាយកដ្ឋាន និងបេឡាគួរតែពង្រឹងឡើងវិញទៅលើការចុះហត្ថលេខារបស់អតិថិជន ដើម្បីឱ្យឯកសារមានភាពគតិយុត្ត ។

### *១.៧. អំពីតារាងវេនយាមប្រចាំការរបស់បុគ្គលិកនៃអង្គភាពវិក្កយបត្រ I.M ១៧*

អង្គភាពបានរៀបចំតារាងវេនយាមប្រចាំការ របស់បុគ្គលិកប្រចាំខែ រៀងរាល់ខែក្នុងឆ្នាំហើយ ប៉ុន្តែនៅពុំទាន់មានការចូលរួមចុះហត្ថលេខាពីប្រធាននាយកដ្ឋាននៅឡើយ ។

*កត្តាមួយនេះធ្វើឱ្យមានចន្លោះខ្វះខាតក្នុងការទទួលខុសត្រូវវេនយាមប្រចាំការ ។*

**សំណូមពររបស់សវនករ៖** អង្គភាពគួរតែបញ្ជូនតារាងវេនយាមប្រចាំការ ឱ្យប្រធាននាយកដ្ឋានចុះហត្ថលេខាត្រូវតាមរចនាសម្ព័ន្ធរបស់ ក. ស. ភ. ដើម្បីឱ្យឯកសារមានលក្ខណៈ គតិយុត្តទៅតាមទម្រង់រដ្ឋបាល ក. ស. ភ. ។

**មតិឆ្លើយតបសវនដ្ឋាន៖** តាមការបកស្រាយបំភ្លឺរបស់សវនដ្ឋាន នឹងធ្វើការកែសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ។

### *១.៨. អំពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់អង្គភាពវិក្កយបត្រ I.M ១៧*

សវនករបានពិនិត្យលើឯកសារ និងសាកសួរប្រធាន អនុប្រធាន បុគ្គលិកក្នុងអង្គភាពឃើញថា៖ តួនាទីភារកិច្ចបានបែងចែកទៅតាមជំនាញក្នុងអង្គភាពបាន និងកំពុងបំពេញការងារមានគ្រប់ៗរូបទាំងមន្ត្រី និងបុគ្គលិកទៅតាមរចនាសម្ព័ន្ធក្នុងអង្គភាព។ ប៉ុន្តែចំណុចខ្លះនៅមិនទាន់បានសមស្របចំពោះមន្ត្រីបុគ្គលិក កំពុងអនុវត្តនៅឡើយ។

*កត្តានេះធ្វើឱ្យការអនុវត្តតួនាទីមិនស្របទៅតាមឋានានុក្រម ។*

**សំណូមពររបស់សវនករ៖** អង្គភាពគួរតែសម្របសម្រួលពាក្យពេចន៍នៅចំនុចខ្លះក្នុងភារកិច្ចដល់បុគ្គលិក និងផ្តល់ភារកិច្ចបន្ថែមដល់មន្ត្រីទទួលបន្ទុកក្នុងការងារ ដើម្បីពង្រឹងការទទួលខុសត្រូវកាន់តែខ្ពស់។

**មតិឆ្លើយតបសវនដ្ឋាន៖** តាមការបកស្រាយពន្យល់របស់សវនដ្ឋាន និងធ្វើការកែសម្រួលនូវចំណុចតួនាទីខាងលើឱ្យបានល្អប្រសើរ ។

## ២- ការិយាល័យកិច្ចការជំនួញ/ប្រព័ន្ធ TOS

### *២.១. អំពីសៀវភៅកត់ត្រាចេញ-ចូល*

សវនករពិនិត្យឃើញថា ការិយាល័យមានសៀវភៅចុះលេខចេញហើយ តែមិនទាន់មានសៀវភៅចុះលេខចូល។ ដូចនេះ គួរតែមានសៀវភៅចុះលេខចូលមួយបន្ថែមទៀត ដើម្បីងាយស្រួលគ្រប់គ្រង និងកត់ត្រារាល់លិខិតបទដ្ឋាន ដែលបានបញ្ជូនមកការិយាល័យបានដឹងគ្រប់ព័ត៌មាន និងអាចតាមដានលេខរៀង កាលបរិច្ឆេទ ខ្លឹមសារនៃលិខិត និងទីកន្លែង ។

*កត្តានេះការគ្រប់គ្រងឯកសាររដ្ឋបាល និងឯកសារពាក់ព័ន្ធជាមួយអតិថិជននៅមិនទាន់បានគ្រប់ជ្រុងជ្រោយ ។*

**សំណូមពររបស់សវនករ៖** ការិយាល័យកិច្ចការជំនួញ/ប្រព័ន្ធ TOS ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងសៀវភៅរដ្ឋបាលចេញ-ចូលសម្រាប់កត់ត្រាឱ្យបានទៀងទាត់ និងបិទបញ្ជីរៀងរាល់ដំណាច់ឆ្នាំ ។

**មតិឆ្លើយតបសវនដ្ឋាន៖** ចំពោះឆ្នាំ២០១៧ កន្លងទៅ សវនដ្ឋាន គឺពុំបានកត់ត្រាសៀវភៅចូល ប៉ុន្តែសៀវភៅចេញ គឺបានកត់ត្រា និងបានបិទបញ្ជីចុងឆ្នាំ។ ដោយឡែកសម្រាប់ឆ្នាំ២០១៨នេះ សវនដ្ឋាន បានរៀបចំកត់ត្រាសៀវភៅចុះលេខចូល-ចេញ ។

### *២.២. ការធ្វើបច្ចុប្បន្នភាពអំពីតួនាទី និងភារកិច្ចរបស់មន្ត្រី*

តាមការសាកសួរ សវនករសង្កេតឃើញថាការិយាល័យកិច្ចការជំនួញ/ប្រព័ន្ធ TOS បានសរសេរអំពីតួនាទី និងភារកិច្ចដល់មន្ត្រីរបស់ខ្លួនរួចរាល់ហើយតាំងពីឆ្នាំ២០១៥ ប៉ុន្តែបច្ចុប្បន្នដោយសារមានការផ្លាស់ប្តូរតួនាទី និងភារកិច្ចមន្ត្រីនៅក្នុងការិយាល័យ និងបានផ្ទេរភារកិច្ចត្រង់ចំណុច (តាមដានបំណុលថ្លៃពន្ធនាគ និងថ្លៃលើកដាក់កុងតឺន័ររបស់ក្រុមហ៊ុនដៃគូសហការ ដែលទទួលព័ត៌មានពីការិយាល័យតម្លៃ ទីផ្សារ) ឱ្យទៅការិយាល័យគណនេយ្យទទួលខុសត្រូវវិញ។

*កត្តានេះធ្វើឱ្យមានការភាន់ច្រឡំអំពីការអនុវត្តតួនាទី និងភារកិច្ចក្នុងការិយាល័យ ។*

**សំណូមពររបស់សវនករ៖** ដើម្បីឱ្យមានភាពច្បាស់លាស់ និងទំនួលខុសត្រូវខ្ពស់ក្នុងការបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាព ការិយាល័យកិច្ចការជំនួញ/ប្រព័ន្ធ TOS គួរតែធ្វើបច្ចុប្បន្នភាពឡើងវិញអំពីតួនាទី និងភារកិច្ចរបស់មន្ត្រីក្នុងការិយាល័យ ។

**មតិឆ្លើយតបរបស់វនដ្ឋាន៖** បានធ្វើការកែប្រែ និងកំពុងធ្វើបច្ចុប្បន្នភាពឡើងវិញអំពីតួនាទី និងភារកិច្ចរបស់មន្ត្រីក្រោមឱវាទ ដើម្បីដាក់ជូនលោកប្រធាននាយកដ្ឋាន ។

***២.៣. ការធ្វើរបាយការណ៍ប្រចាំខែ ឆ្នាំ***

តាមការសាកសួរ សវនករសង្កេតឃើញថា ការិយាល័យកិច្ចការជំនួញ/ប្រព័ន្ធ TOS បានធ្វើរបាយការណ៍បូកសរុបចំណូលប្រចាំខែ ធ្វើទៅឱ្យការិយាល័យគណនេយ្យសម្រាប់ធ្វើការផ្ទៀងផ្ទាត់តែប៉ុណ្ណោះដោយមិនបានដាក់ជូនប្រធាននាយកដ្ឋានសាមី និងឯកឧត្តមប្រតិភូពិនិត្យ និងជ្រាប ។

*កត្តានេះធ្វើឱ្យមានភាពខ្វះចន្លោះក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ការិយាល័យ ។*

**សំណូមពររបស់សវនករ៖** ដើម្បីបង្ហាញពីលទ្ធផលការងារ ការិយាល័យគួរតែធ្វើរបាយការណ៍បូកសរុបចំណូលប្រចាំខែ និងឆ្នាំដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងជ្រាប ។

**មតិឆ្លើយតបរបស់វនដ្ឋាន៖** ពកភាព និងរៀបចំរបាយការណ៍បូកសរុបចំណូលប្រចាំខែ និងឆ្នាំ តាមរយៈលោកប្រធាននាយកដ្ឋាន ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងជ្រាបជារបាយការណ៍តាមឋានានុក្រម ។

***២.៤. ការចុះហត្ថលេខាលើវិក្កយបត្រគ្រប់ប្រភេទ***

តាមការពិនិត្យ និងសាកសួរបុគ្គលិក និងមន្ត្រី សវនករសង្កេតឃើញថា វិក្កយបត្រមួយចំនួនដូចជា (ថ្លៃឈ្នួលលើកដាក់, ថ្លៃចូលទីតាំង, ពន្ធ និងឈ្នួលផែ) មិនមានការចុះហត្ថលេខាពីភាគីខាងក្រុមហ៊ុនដែលជាដៃគូសហការទេ ជាហេតុធ្វើឱ្យឯកសារនៅមានភាពខ្វះចន្លោះ ។

*កត្តានេះធ្វើឱ្យឯកសារមិនមានលក្ខណៈគតិយុត្ត ។*

**សំណូមពររបស់សវនករ៖** ដូចនេះការិយាល័យកិច្ចការជំនួញ/ប្រព័ន្ធ TOS គួរតែសហការជាមួយអង្គភាពពាក់ព័ន្ធពង្រឹងការចុះហត្ថលេខាលើឯកសារដើម្បីឱ្យមានលក្ខណៈគតិយុត្ត ។

**មតិឆ្លើយតបរបស់វនដ្ឋាន៖** បច្ចុប្បន្ន វិក្កយបត្រថ្លៃពន្ធនាវា (Port Dues &Charge) និងថ្លៃលើកដាក់ក្រោមដងយោង (Stevedoring Charge) ចំពោះក្រុមហ៊ុនមួយចំនួន គឺអ្នកទទួលវិក្កយបត្រ ពុំបានចុះហត្ថលេខាទទួលលើវិក្កយបត្រទេ ប៉ុន្តែគាត់ចុះហត្ថលេខាលើសៀវភៅប្រគល់ទទួលរបស់បុគ្គលិកសវនដ្ឋាន។ ជាមួយសវនដ្ឋានពកភាព និងធ្វើការពង្រឹងកិច្ចការងារនេះបន្ថែមទៀត ដើម្បីឱ្យគ្រប់វិក្កយបត្រទាំងអស់មានការចុះហត្ថលេខាទទួលពីអតិថិជន ឬតំណាងក្រុមហ៊ុន ។

***២.៥ របាយការណ៍សរុបប្រចាំខែអំពីចំណូលច្រកទ្វា ( Gate Fee ) LM ១៧***

សវនករពិនិត្យ និងសាកសួរឃើញថា ការិយាល័យបានធ្វើរបាយការណ៍បូកសរុបចំណូលច្រកទ្វារជារៀងរាល់ខែ (Gate Fee) ក៏ប៉ុន្តែនៅក្នុងខែខ្លះបានធ្វើការសរុបរបាយការណ៍ឆ្លងខែនៃសប្តាហ៍ទី២ ។

*កត្តានេះ អាចធ្វើឱ្យការផ្ទៀងផ្ទាត់របាយការណ៍ចំណូលច្រកទ្វារប្រចាំខែ (Gate Fee) ជាមួយអង្គភាពពាក់ព័ន្ធមានភាពយឺតយូរ ។*

**សំណូមពររបស់សវនករ៖** ដូចនេះក្នុងការពន្លឿនរបាយការណ៍ប្រចាំខែ (Gate Fee) ការិយាល័យកិច្ចការជំនួញ/ប្រព័ន្ធ TOS គួរតែជំរុញឱ្យការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera បញ្ជូនរបាយការណ៍ស្ថិតិសកម្មភាពថយន្តដឹកពញ្ជនកុងតឺន័រប្រចាំថ្ងៃ ដើម្បីឱ្យសវនដ្ឋានងាយស្រួលក្នុងការបូកសរុបរបាយការណ៍ប្រចាំខែឱ្យទាន់ពេលវេលា។

**មតិឆ្លើយតបសវនដ្ឋាន៖** ឯកភាព និងនឹងជំរុញឱ្យអង្គភាពច្រកទ្វារ LM១៧ បញ្ជូនរបាយការណ៍ស្ថិតិចំណូលច្រកទ្វារ (Gate Fee LM១៧) ប្រចាំថ្ងៃមកសវនដ្ឋាន ដើម្បីធ្វើការបូកសរុប និងផ្ទៀងផ្ទាត់ចំណូលជាមួយការិយាល័យគណនេយ្យឱ្យបានទាន់ពេលវេលា ។

### *២.៦. ការជំរុញការអនុវត្តប្រព័ន្ធ TOS (Terminal Operating System)*

តាមការពិនិត្យ និងសាកសួរ សវនករសង្កេតឃើញថា ក្នុងការផលិតគ្រប់វិក្កយបត្រ សវនដ្ឋានផលិតតាម Excel មិនទាន់បានអនុវត្តតាមប្រព័ន្ធ TOS (Terminal Operating System) នៅឡើយ។ ចំពោះវិក្កយបត្រផ្នែកនេះក្នុងប្រព័ន្ធ TOS មានរួចស្រេចហើយ ។

*កត្តានេះធ្វើឱ្យការអនុវត្តប្រព័ន្ធ TOS (Terminal Operating System) បំពេញមិនទាន់គ្រប់លក្ខខណ្ឌ ។*

**សំណូមពររបស់សវនករ៖** ដូចនេះក្នុងការជំរុញប្រព័ន្ធ TOS (Terminal Operating System) ឱ្យដំណើរការអាចយកមកអនុវត្តក្នុងការផលិតគ្រប់វិក្កយបត្របាន សវនដ្ឋានគួរតែបង្កើនការសហការជាមួយការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា ដើម្បីរកដំណោះស្រាយ ។

**មតិឆ្លើយតបសវនដ្ឋាន៖** សវនដ្ឋាន បានទទួលគោលការណ៍ពីថ្នាក់ដឹកនាំក្នុងការអនុវត្តប្រព័ន្ធ TOS ដើម្បីគិតលុយថ្លៃពន្ធនាវា (Port Dues & Charge) និងថ្លៃលើកដាក់ក្រោមជងយោង (Stevedoring Charge) ចំពោះនាវាដឹកជញ្ជូនកុងតឺន័រជាដំហានដំបូងសិន ដោយគ្រោងនឹងចាប់ផ្តើមអនុវត្តពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៨ ខាងមុខនេះ នៅពេលដែលការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា ដោះស្រាយបញ្ហាបន្តិចបន្តួចដែលនៅសេសសល់ជាមួយខាង Supporting Team នៅប្រទេសឥណ្ឌា ។

### *២.៧. អំពីការផលិតវិក្កយបត្រទូទាត់ថ្លៃឈ្នួលផ្សេងៗក្នុង ក. ស. ភ.*

ផ្អែកតាមការសាកសួរ បុគ្គលិក និងមន្ត្រីក្នុងការិយាល័យ សវនករពិនិត្យឃើញថា បុគ្គលិកកំពុងទទួលបន្ទុកការងារធ្វើវិក្កយបត្រថ្លៃឈ្នួលទីតាំង ស្ថានីយចតកាណូត រោង ទីតាំងជួលដីបន្ត ទីតាំងជួលនៅក្នុងមណ្ឌលអាជីវកម្មកំពង់ផែ អគារធ្វើការិយាល័យ ធ្វើអាជីវកម្ម និងឃ្លាំង ប៉ុន្តែមិនដែលស្គាល់ទីតាំងដែលត្រូវគិតតម្លៃឈ្នួលនោះទេ ។

*កត្តានេះធ្វើឱ្យមន្ត្រី បុគ្គលិកធ្វើវិក្កយបត្រមានភាពមិនច្បាស់លាស់ក្នុងការរៀបចំឯកសារ ។*

**សំណូមពររបស់សវនករ៖** ដើម្បីឱ្យការផលិតវិក្កយបត្រថ្លៃឈ្នួលផ្សេងៗ ឱ្យមានភាពច្បាស់លាស់ មន្ត្រី ឬបុគ្គលិកដែលកំពុងអនុវត្តការងារផ្ទាល់គួរតែស្គាល់ពីទីតាំងទាំងអស់នោះ។

**មតិឆ្លើយតបសវនដ្ឋាន៖** ឯកភាព និងដើម្បីឆ្លើយតបទៅនឹងអនុសាសន៍របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ក. ស. ភ. សវនដ្ឋាននឹងស្នើសុំគោលការណ៍ពី ឯកឧត្តមប្រតិភូ ចាត់បញ្ជូនបុគ្គលិកដែលទទួលការងារ

ផលិតផលក្នុងយបព្រៃថ្លៃចូលផ្សេងៗ ដើម្បីមានលទ្ធភាពចុះទៅពិនិត្យ និងស្គាល់ឱ្យបានច្បាស់អំពីទីតាំងទាំងអស់ដែល ក. ស. ត. បានចូលទៅឱ្យក្រុមហ៊ុន ឬអតិថិជន។

## ៣-ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា (ត្រីមាសទី២)

### *៣-១. អំពីសៀវភៅកត់ត្រាចេញ-ចូល*

សវនករពិនិត្យឃើញថា ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា មានសៀវភៅចុះលេខចេញដែលចុះបន្តពីឆ្នាំចាស់ និងមិនមានសៀវភៅចុះលេខចូល ។ ដូចនេះគួរតែមានសៀវភៅចុះលេខចូលមួយបន្ថែមទៀត ដើម្បីងាយស្រួលគ្រប់គ្រង និងកត់ត្រារាល់លិខិតបទដ្ឋាន ដែលបានបញ្ជូនមកការិយាល័យឱ្យបានដឹងគ្រប់ព័ត៌មាន និងអាចតាមដានលេខរៀង កាលបរិច្ឆេទ ខ្លឹមសារនៃលិខិត និងទីកន្លែង ។

*កត្តានេះធ្វើឱ្យការគ្រប់គ្រងឯកសាររដ្ឋបាល នៅមិនទាន់គ្រប់ជ្រុងជ្រោយ ។*

**សំណូមពររបស់សវនករ៖** ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងសៀវភៅរដ្ឋបាលចេញ-ចូលសម្រាប់កត់ត្រាឱ្យបានទៀងទាត់ ដោយត្រូវកត់ត្រាដាច់ដោយឡែកពីឆ្នាំចាស់ និងបិទបញ្ជីរៀងរាល់ដំណាច់ឆ្នាំ។

**មតិឆ្លើយតបសវនដ្ឋាន៖** បច្ចុប្បន្នការិយាល័យមានសៀវភៅចុះលេខចេញ ចំនួនពីរក្បាល (សៀវភៅចុះលេខចេញរដ្ឋបាល និងសៀវភៅចុះលេខចេញគណៈកម្មការស្តីពីសំណើសុំផ្សេងៗ) ប៉ុន្តែសវនដ្ឋាននឹងធ្វើការកែសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ។

### *៣-២. ការធ្វើបច្ចុប្បន្នភាពអំពីតួនាទី និងភារកិច្ចរបស់មន្ត្រី*

តាមការសាកសួរ សវនករសង្កេតឃើញថា ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា បានសរសេរអំពីតួនាទី និងភារកិច្ចដល់មន្ត្រីរបស់ខ្លួនរួចរាល់ហើយតាំងពីឆ្នាំ២០១៥ ប៉ុន្តែបច្ចុប្បន្នដោយសារមានការផ្លាស់ប្តូរតួនាទី និងភារកិច្ចមន្ត្រីមួយចំនួននៅក្នុងការិយាល័យ និងបានឈប់អនុវត្តត្រង់ចំណុច (គ្រប់គ្រងថែទាំ GPS) ។

*កត្តានេះធ្វើឱ្យមានការភ័ន្តច្រឡំអំពីការអនុវត្តតួនាទី និងភារកិច្ចក្នុងការិយាល័យ ។*

**សំណូមពររបស់សវនករ៖** ដើម្បីឱ្យមានភាពច្បាស់លាស់ និងទំនួលខុសត្រូវខ្ពស់ក្នុងការបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាព សវនដ្ឋានគួរតែធ្វើបច្ចុប្បន្នភាពឡើងវិញអំពី តួនាទី និងភារកិច្ចរបស់មន្ត្រី ក្នុងការិយាល័យ ។

**មតិឆ្លើយតបសវនដ្ឋាន៖** បច្ចុប្បន្នការិយាល័យបានរៀបចំរចនាសម្ព័ន្ធរួចហើយ និងកំពុងតែរៀបចំកែសម្រួលតួនាទី និងភារកិច្ចឡើងវិញ ។

*៣-៣. បន្តជំរុញការអនុវត្តកម្មវិធីកុំព្យូទ័រគ្រប់គ្រងលិខិតស្នាមរដ្ឋបាល ក. ស. ភ.*

សវនករសង្កេត និងពិនិត្យឃើញថា ដោយសារលំហូរនៃលិខិតស្នាមរដ្ឋបាល ក.ស.ភ.មានការកើនឡើង ដែលធ្វើឱ្យការិយាល័យរដ្ឋបាលផ្នែកគ្រប់គ្រងលិខិតស្នាមចេញ/ចូល មានការលំបាក នៅពេលខ្លះការបញ្ជូនឯកសារខុសគោលដៅ និងអាចឈានដល់ការបាត់បង់ឯកសារ ដែលជាហេតុធ្វើឱ្យម្ចាស់ឯកសារមិនអាចតាមដានលិខិតស្នាមរបស់ខ្លួនបានទេ ឬក៏ត្រូវមកសួរនាំដល់កន្លែងផ្នែកគ្រប់គ្រងលិខិតចូលចេញ និងដល់លេខាធិការដ្ឋានទៀតផង។ ដូចនេះនៅឆ្នាំ ២០១៦ ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា បានបង្កើតកម្មវិធីកុំព្យូទ័រគ្រប់គ្រងលិខិតស្នាមរដ្ឋបាលដើម្បីជួយសម្រួលក្នុងការគ្រប់គ្រង។ ប៉ុន្តែមកដល់ពេលបច្ចុប្បន្ន នៅមិនទាន់បានអនុវត្តកម្មវិធីនេះនៅឡើយទេ។

*កត្តានេះធ្វើឱ្យការគ្រប់គ្រងលិខិតស្នាមរដ្ឋបាលនៅមានការលំបាក ។*

**សំណូមពររបស់សវនករ៖** ដូចនេះ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការគ្រប់គ្រង និងតាមដានលិខិតស្នាមរដ្ឋបាល ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា គួរតែរកមូលហេតុដែលធ្វើឱ្យអ្នកប្រើប្រាស់មិនអនុវត្ត និងបន្តជំរុញការអនុវត្តកម្មវិធីកុំព្យូទ័រឱ្យដំណើរការក្នុងឆ្នាំ ២០១៨នេះ ។

**មតិឆ្លើយតបសវនដ្ឋាន៖** ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា និងធ្វើសំណើសុំអនុវត្តកម្មវិធីកុំព្យូទ័រគ្រប់គ្រងលិខិតស្នាមរដ្ឋបាល ជូនថ្នាក់ដឹកនាំរដ្ឋបាល ដើម្បីជំរុញការប្រើប្រាស់ប្រព័ន្ធឱ្យដំណើរការឡើងវិញ។

*៣-៤. អំពីការគ្រប់គ្រងគណនីប្រើប្រាស់ក្នុងប្រព័ន្ធ និងការកំណត់សិទ្ធិប្រើប្រាស់កម្មវិធីទៅតាមតួនាទី និងភារកិច្ច*

សវនករពិនិត្យឃើញថា ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា ពុំទាន់មានការគ្រប់គ្រងគណនីប្រើប្រាស់ក្នុងប្រព័ន្ធ និងការកំណត់សិទ្ធិប្រើប្រាស់កម្មវិធីទៅតាមតួនាទី និងភារកិច្ចរបស់មន្ត្រី បុគ្គលិកនៅឡើយ ។

*កត្តានេះអាចបណ្តាលឱ្យមានភាពមិនច្បាស់លាស់ក្នុងការគ្រប់គ្រងគណនីមន្ត្រី បុគ្គលិក ចូលបំរើការថ្មី ដែលផ្លាស់ប្តូរតួនាទី ភារកិច្ច, លាលែងពីការងារ, ត្រូវបញ្ឈប់ពីការងារ និងចូលនិវត្តន៍ ដែលអាចបង្កឱ្យមានការបញ្ចេញព័ត៌មានផ្ទៃក្នុង ក.ស.ភ. សម្ងាត់ផ្សេងៗជាយថាហេតុ ។*

**សំណូមពររបស់សវនករ៖** ដូចនេះការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា គួរយកចិត្តទុកដាក់ខ្ពស់ក្នុងការគ្រប់គ្រងគណនីប្រើប្រាស់ក្នុងប្រព័ន្ធ និងការកំណត់សិទ្ធិប្រើប្រាស់កម្មវិធីទៅតាមតួនាទី ភារកិច្ច និងស្នើសុំការចូលរួមសហការជាមួយនាយកដ្ឋានបុគ្គលិក/ធនធានមនុស្សក្នុងការផ្តល់ព័ត៌មានអំពីចំនួនមន្ត្រីបុគ្គលិកដែលចូលបំរើការថ្មី ដែលផ្លាស់ប្តូរតួនាទីភារកិច្ច ,លាលែងពីការងារ ,ត្រូវបញ្ឈប់ពីការងារ និងចូលនិវត្តន៍ ។

**មតិឆ្លើយតបខាងសវនដ្ឋាន៖** ការិយាល័យបច្ចេកវិទ្យា /ព័ត៌មានវិទ្យា នឹងរៀបចំដាក់ឱ្យដំណើរការគ្រប់គ្រងនាយកដ្ឋាននៃប្រព័ន្ធ Domain Controller បន្ទាប់មកនឹងធ្វើការសហការជាមួយនាយកដ្ឋានបុគ្គលិក/ធនធានមនុស្សក្នុងការផ្តល់ព័ត៌មានដែលត្រូវការ ។

### *៣-៥. ការស្នើសុំតម្លើងកម្មវិធីផ្សេងៗនៅតាមបណ្តានាយកដ្ឋាន*

តាមការសាកសួរ ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យាបានជួយដំឡើងកម្មវិធីប្រើប្រាស់ដូចជា កម្មវិធីគ្រប់គ្រងវត្តមានរបស់បុគ្គលិក, កម្មវិធីរក្សាទុកឯកសាររបស់បុគ្គលិក និងកម្មវិធីជាច្រើនទៀតតាមបណ្តានាយកដ្ឋានផ្សេងៗតាមតម្រូវការ ប៉ុន្តែមិនបានធ្វើសំណើជាលាយលក្ខណ៍អក្សរស្នើសុំមកការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យាទេ ដោយទំនាក់ទំនងតាមទូរស័ព្ទ ឬក៏ផ្ទាល់មាត់ ។

*កត្តានេះធ្វើឱ្យការងារនៅខ្វះចន្លោះ និងខុសពីនីតិវិធីរដ្ឋបាល ។*

**សំណូមពររបស់សវនករ៖** ដើម្បីឱ្យងាយស្រួលក្នុងការគ្រប់គ្រង តាមដាន ទៅលើការអនុវត្តការងារសវនដ្ឋាន គួរជំរុញឱ្យនាយកដ្ឋានផ្សេងៗ ដែលមានគោលបំណងចង់ដំឡើងកម្មវិធីយកទៅអនុវត្តបម្រើការងារដល់ ក. ស. ភ. ត្រូវតែធ្វើសំណើជាលាយលក្ខណ៍អក្សរ ដែលបានអនុញ្ញាតដោយថ្នាក់ដឹកនាំ ។

**មតិឆ្លើយតបនាងសវនដ្ឋាន៖** យល់ស្របតាមការរកឃើញរបស់សវនករ សវនដ្ឋាននឹងធ្វើការកែសម្រួលនូវ ចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ។

### *៣-៦. ការតាមដាន និងរបាយការណ៍ប្រព័ន្ធ Firewall និង Antivirus*

តាមការពិនិត្យ និងសាកសួរសវនករសង្កេតឃើញថា របាយការណ៍តាមដានប្រព័ន្ធសុវត្ថិភាព Firewall និង Antivirus របស់ផ្នែករចនាសម្ព័ន្ធបណ្តាញកុំព្យូទ័រជូនទៅ ប្រធានការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា គឺបានធ្វើក្នុងរយៈពេល៦ ខែម្តង ។

*កត្តានេះធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការកំណត់ហានិភ័យពីប្រព័ន្ធតាមដានសុវត្ថិភាពរបស់ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា ។*

**សំណូមពររបស់សវនករ៖** ដូចនេះ ផ្នែករចនាសម្ព័ន្ធបណ្តាញកុំព្យូទ័រគួរធ្វើរបាយការណ៍តាមដានប្រព័ន្ធសុវត្ថិភាព Firewall និង Antivirus ជូនប្រធានការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា ក្នុងមួយសប្តាហ៍ម្តង។

**មតិឆ្លើយតបខាងសវនដ្ឋាន៖** យល់ស្របតាមការរកឃើញរបស់សវនករ សវនដ្ឋាននឹងធ្វើការកែសម្រួលនូវ ចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ។

### *៣-៧. ការរៀបចំរចនាសម្ព័ន្ធបណ្តាញកុំព្យូទ័រ*

ការរៀបចំរចនាសម្ព័ន្ធខ្សែបណ្តាញកុំព្យូទ័ររបស់សវនដ្ឋាន នៅក្នុង ក.ស.ភ. មិនទាន់មានភាពល្អប្រសើរនៅឡើយ ដោយទីតាំងរក្សាទុកឧបករណ៍ Switch នៅមិនទាន់មានសុវត្ថិភាព និងស្របតាមស្តង់ដារ។ ដោយ Switch មួយចំនួនបានដាក់ក្នុងប្រអប់រួចហើយ និងមួយចំនួនទៀតមិនទាន់បានដាក់ក្នុងប្រអប់នៅឡើយ។

*កត្តានេះអាចធ្វើឱ្យគ្មានសុវត្ថិភាព និងបង្កឱ្យមានហានិភ័យខូចខាត ឬដាច់ខ្សែឧបករណ៍ក្នុងកាលៈទេសៈណាមួយ ។*

**សំណូមពរសវនករ៖** ដូចនេះការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា គួរយកចិត្តទុកដាក់បន្ថែមក្នុងការរៀបចំរចនាសម្ព័ន្ធបណ្តាញខ្សែឱ្យមានសុវត្ថិភាពឡើងវិញ ។

**មតិឆ្លើយតបខាងសវនដ្ឋាន៖** យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើការកែសម្រួលនូវ ចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ដោយរៀបចំឱ្យមានប្រអប់ចាក់សោរនេបករណ៍ Switch។

***៣-៤. ការគ្រប់គ្រង និងធ្វើរបាយការណ៍បូកសរុបលើឧបករណ៍អេឡិចត្រូនិច បរិក្ខារកុំព្យូទ័រ និងកម្មវិធីកុំព្យូទ័រ ប្រចាំខែ ត្រីមាស និងឆ្នាំ***

ការិយាល័យបច្ចេកវិទ្យាព័ត៌មានវិទ្យា បានរក្សាទុកសំណើសុំទិញឧបករណ៍អេឡិចត្រូនិច បរិក្ខារកុំព្យូទ័រ និងកម្មវិធីកុំព្យូទ័រពីបណ្តាអង្គភាពដែលនៅក្រោម ក.ស.ភ. ប៉ុន្តែសវនដ្ឋានមិនបានធ្វើជារបាយការណ៍បូកសរុបលើឧបករណ៍ទាំងនោះនៅឡើយទេ។

*កត្តានេះធ្វើឱ្យមានភាពខ្វះចន្លោះ ក្នុងការតាមដានចំនួនឧបករណ៍អេឡិចត្រូនិច បរិក្ខារកុំព្យូទ័រ និងកម្មវិធីកុំព្យូទ័រ ។*

**សំណូមពររបស់សវនករ៖** ដើម្បីសម្រួលក្នុងការគ្រប់គ្រង និងតាមដានចំនួនឧបករណ៍អេឡិចត្រូនិច បរិក្ខារកុំព្យូទ័រ និងកម្មវិធីកុំព្យូទ័រផ្សេងៗ សវនដ្ឋានគួរធ្វើរបាយការណ៍បូកសរុប ប្រចាំខែ ត្រីមាស និងឆ្នាំ ។

**មតិឆ្លើយតបខាងសវនដ្ឋាន៖** កន្លងមកបានកត់ត្រាចូលទៅក្នុងប្រព័ន្ធដែលការិយាល័យបានរៀបចំ ប៉ុន្តែមិនបានធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរទេ ក្នុងរយៈកាលកំណត់ណាមួយ។ យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើរបាយការណ៍រៀងរាល់ ៣ខែម្តង ។

*៣-៥. របាយការណ៍សរុបបញ្ហាប្រព័ន្ធ Terminal Operating System (TOS) ប្រចាំឆ្នាំ*

សវនករពិនិត្យឃើញថា សវនដ្ឋានបានធ្វើរបាយការណ៍ជាប្រចាំនៃអំពីការដោះស្រាយប្រព័ន្ធ TOS ប៉ុន្តែមិនបានធ្វើរបាយការណ៍បូកសរុបប្រចាំឆ្នាំនៅឡើយទេ ។

*កត្តានេះធ្វើឱ្យមានភាពខ្វះចន្លោះក្នុងការសរុបអំពីប្រភេទ និងប្រភពបញ្ហា ដែលធ្វើឱ្យប្រព័ន្ធ TOS មិនអាចដំណើរការបាន ។*

**សំណូមពររបស់សវនករ៖** ដូចនេះ ដើម្បីឱ្យប្រព័ន្ធ TOS ដំណើរការបានល្អប្រសើរ និងមិនមានបញ្ហារាំងស្ទះដល់ប្រតិបត្តិការការងាររបស់ ក.ស.ភ ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា គួរតែធ្វើរបាយការណ៍បូកសរុបប្រចាំឆ្នាំ អំពីចំនួនដងនៃប្រភេទ និងប្រភពបញ្ហាឱ្យបានច្បាស់ ដើម្បីស្រួលរកដំណោះស្រាយកាត់បន្ថយកំហុស និងដាក់វិធានការចំពោះបញ្ហាណាដែលកើតឡើងមកពីប្រភពដដែលៗ និងដូចគ្នាជាញឹកញាប់ ។

**មតិឆ្លើយតបខាងសវនដ្ឋាន៖** យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើការកែសម្រួលនូវ ចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ។

### *៣-១០. គោលការណ៍ និងបទបញ្ញត្តិបច្ចេកវិទ្យា/ព័ត៌មានវិទ្យា (Information Technology Policy (IT Policy) & Standard Operating Procedure (SOP)*

តាមការពិនិត្យនិងសាកសួរ សវនករសង្កេតឃើញថា ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា នៅពុំទាន់មានគោលការណ៍ និងបទបញ្ញត្តិបច្ចេកវិទ្យា/ព័ត៌មានវិទ្យានៅឡើយទេ។

*កត្តានេះធ្វើឱ្យការរៀបចំប្រព័ន្ធបច្ចេកវិទ្យា/ព័ត៌មានវិទ្យា ពុំទាន់មានប្រសិទ្ធភាពស្របទៅនឹងការផ្តល់សេវាអាជីវកម្មកំពង់ផែការគ្រប់គ្រងប្រព័ន្ធសុវត្ថិភាព សន្តិសុខបច្ចេកវិទ្យា/ព័ត៌មានវិទ្យា របស់ ក.ស.ក. ដោយមិនទាន់ស្របទៅតាមស្តង់ដារជាតិ និងអន្តរជាតិ។*

**សំណូមពររបស់សវនករ៖** ដូចនេះសវនដ្ឋាន គួរសិក្សាពីលទ្ធភាពបង្កើតគោលការណ៍ និងបទបញ្ញត្តិបច្ចេកវិទ្យា/ព័ត៌មានវិទ្យា ឱ្យស្របតាមស្តង់ដាជាតិ និងអន្តរជាតិដូចជា National Institute of Standards and Technology ( NIST) និង Information Technology Infrastructure Library ( ITIL ) ។

**មតិឆ្លើយតបខាងសវនដ្ឋាន៖** យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើការកែសម្រួលនូវ ចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ។

### *៣-១១. ការធ្វើការសាកល្បងលើប្រព័ន្ធសុវត្ថិភាព (Penetration Test)*

ការសាកល្បងលើប្រព័ន្ធសុវត្ថិភាព (Penetration Test) របស់ផ្នែករចនាសម្ព័ន្ធបណ្តាញកុំព្យូទ័រ នៃការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា ពុំទាន់មានជាគោលការណ៍ និងឯកសារអំណះអំណាងក្រោយការសាកល្បង នៃប្រតិបត្តិការលើការវាយតម្លៃហានិភ័យសុវត្ថិភាពប្រព័ន្ធ (Risk Assessment)។

*កត្តានេះធ្វើឱ្យប្រព័ន្ធសុវត្ថិភាព និងសន្តិសុខនៃបច្ចេកវិទ្យា/ព័ត៌មានវិទ្យា ក.ស.ក. នៅមានចន្លោះប្រហោងដែលអាចបណ្តាលឱ្យមានបញ្ហាដូចជាប្រព័ន្ធដំណើរការមិនបានល្អ ហានិភ័យបាត់បង់ទិន្នន័យ ប្រឈមនឹងការវាយលុកដែលព្យាយាមលួច ឬបំផ្លាញទិន្នន័យពីបណ្តា Hackers ។*

**សំណូមពររបស់សវនករ៖** ដូចនេះការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា គួររៀបចំជាគោលការណ៍ និងឯកសារអំណះអំណាងក្រោយការសាកល្បងនៃការប្រតិបត្តិការលើការវាយតម្លៃហានិភ័យសុវត្ថិភាពប្រព័ន្ធ (Risk Assessment)។

**មតិឆ្លើយតបខាងសវនដ្ឋាន៖** យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ និងធ្វើការកែសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ។ ដោយហេតុថានៅមិនទាន់មានបុគ្គលិកបានសិក្សាកម្មវិធី Penetration Test និង Hackers ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យានឹងស្នើសុំនាយកដ្ឋានបុគ្គលិក/ធនធានមនុស្សបញ្ជូនបុគ្គលិកឱ្យចូលរៀនវគ្គបណ្តុះបណ្តាលនេះ ។

### *៣-១២. បញ្ហាប្រឈមដែលធ្វើឱ្យប្រតិបត្តិការប្រព័ន្ធ Terminal Operating System (TOS) ដំណើរការមិនរលូន*

តាមការសាកសួរ សវនករពិនិត្យឃើញថា កត្តាដែលធ្វើឱ្យប្រព័ន្ធ Terminal Operating System (TOS) មានបញ្ហាកើតឡើងតាមបណ្តាផ្នែកនីមួយៗរួមមាន៖

- **ភាគីអតិថិជន (អ្នកកត់ការ, ក្រុមហ៊ុន Line)**: អតិថិជនពុំទាន់សហការធ្វើ ឬមកទទួលទូកុងតឺន័រពីកំពង់ផែ (Export, Import) ប្រើប្រាស់ប្រព័ន្ធឱ្យបានពេញលេញនៅឡើយទេ និងពុំបានធ្វើការ Booking ជាមុន
- **ផ្នែកកាំសាប ឬក្រុមហ៊ុននាវា** : ពុំទាន់សហការផ្តល់ព័ត៌មាន Loading list និងប្លង់កុងតឺន័រនៅលើនាវាឱ្យបានទាន់ពេលវេលា
- **អង្គភាពច្រកទ្វារ**: ផ្ទៀងផ្ទាត់ព័ត៌មានកុងតឺន័រ និងលេខឡានទុស និងប្រមូល Gate Fee ក្រៅពីប្រព័ន្ធ TOS (ប្រព័ន្ធគិតលុយចំណតឡាន (Parking System) របស់ក្រុមហ៊ុន Blue)
- **ការិយាល័យបច្ចេកវិទ្យាព័ត៌មានវិទ្យា**: ពុំមាន Disaster Recovery Site (DRSite) សម្រាប់អនុវត្តការងារក្នុងពេលប្រព័ន្ធ TOS មានបញ្ហា
- **អង្គភាពរៀបចំប្រតិបត្តិការចំណតផែ LM១៧** : ពុំទាន់បានអនុវត្តការងាររៀបចំទីតាំងកុងតឺន័រនៅលើទីលាន CY ដោយប្រើប្រាស់ប្រព័ន្ធ TOS
- **អង្គភាពវិក្កយបត្រ LM១៧** : Container Export មួយចំនួននាំចេញតាមនាវាមុន ទើបធ្វើវិក្កយបត្រទូទាត់តាមក្រោយ ជាហេតុធ្វើឱ្យប៉ះពាល់ក្នុងប្រព័ន្ធ TOS ក្នុងការបិទប្រតិបត្តិការជាមួយនាវា ( Close vessel Operation ) ចំពោះនាវាណាដែលមកដល់បន្ទាប់ទៀត។

*កត្តានេះធ្វើឱ្យប្រតិបត្តិការប្រព័ន្ធTerminal Operating System (TOS) ដំណើរការមិនល្អេន ។*

**សំណូមពររបស់សវនករ៖** ដូចនេះការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា បន្តជំរុញធ្វើការសហការជាមួយបណ្តាអង្គភាពពាក់ព័ន្ធដើម្បីរកដំណោះស្រាយធ្វើឱ្យការអនុវត្តប្រតិបត្តិការប្រព័ន្ធ TOS កាន់តែមានប្រសិទ្ធភាព ។

**មតិឆ្លើយតបខាងសវនដ្ឋាន៖** យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើការកែសម្រួលនូវ ចំនុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ។

*៣-១៣. បន្តជំរុញការអនុវត្តប្រព័ន្ធ Terminal Operating System (TOS) អោយបំពេញគ្រប់មុខងារ*

តាមការពិនិត្យ និងសាកសួរ ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា ប្រព័ន្ធ Terminal Operating System (TOS) នៅពុំទាន់អនុវត្តមិនទាន់បានគ្រប់លក្ខខណ្ឌ និងមុខងារដែលជាតម្រូវការមានដូចខាងក្រោម ៖

- ពេលមាន Re-Export ប្រព័ន្ធតែងតែបាត់ចំនួនទូកុងតឺន័រនៅពេលធ្វើ Stevedoring Invoice
- ពុំទាន់មានឧបករណ៍ Radio Data Terminal គ្រប់គ្រាន់សម្រាប់បំពេញការងារប្រតិបត្តិការ (Real Data Entry)

  ប្រព័ន្ធពុំទាន់កែតម្រូវទម្រង់វិក្កយបត្រឱ្យបានត្រឹមត្រូវ (Show Accumulation TEUS for Stevedoring invoice)
- ប្រព័ន្ធពុំទាន់អាចប្រមូលថ្លៃ Stuffing/Un-stuffing
- ប្រព័ន្ធពុំទាន់អាចប្រមូលថ្លៃកុងតឺន័រត្រជាក់ (Reefer Container)

- ប្រព័ន្ធពុំទាន់អាចប្រមូលថ្លៃ Storage ចំពោះទំនិញនាំចេញ
- ប្រព័ន្ធពុំទាន់អាចធ្វើរបាយការណ៍បូកសរុបប្រចាំខែ និងឆ្នាំ តាមផ្នែកនីមួយៗ
- ប្រព័ន្ធពុំទាន់អាចប្រមូលថ្លៃទំនិញពយ
- ប្រព័ន្ធពុំទាន់អាចប្រមូលថ្លៃ នាវាដឹកប្រេង/ហ្គាស និងនាវាទេសចរណ៍នៅឡើយទេ ។

*កត្តានេះអាចធ្វើឱ្យមានផលប៉ះពាល់ដល់ការទូទាត់ចំណូល និងការអនុវត្តប្រព័ន្ធ TOS មិនទាន់អស់លទ្ធភាព។*

**សំណូមពររបស់សវនករ៖** ដូចនេះដើម្បីជំរុញការអនុវត្តប្រព័ន្ធ TOS ឱ្យអស់សក្តានុពល និងងាយស្រួលក្នុងការគ្រប់គ្រងចំណូលឱ្យមានប្រសិទ្ធភាព សវនដ្ឋាន និងអង្គភាពពាក់ព័ន្ធគ្រប់ផ្នែកគួរមានកិច្ចសហការធ្វើសំណើជូនដល់ថ្នាក់លើក្នុងការបំពេញចន្លោះខ្វះខាតរបស់មុខងារប្រព័ន្ធ TOS ឱ្យបានគ្រប់លក្ខខណ្ឌ ។

**មតិឆ្លើយតបខាងសវនដ្ឋាន៖** យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើការកែសម្រួលនូវចំនុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ដោយសហការជាមួយអង្គភាពពាក់ព័ន្ធនិង Developer ដើម្បីបំពេញចន្លោះខ្វះខាតខាងលើ ។

### *៣-១៩. អំពីសម្ភារការពារសុវត្ថិភាពពេលបំពេញការងារ*

តាមការសាកសួរ និងសភាពជាក់ស្តែង សវនករសង្កេតឃើញថា ការងារតខ្សែបណ្តាញប្រព័ន្ធកុំព្យូទ័ររបស់មន្ត្រី បុគ្គលិក នៅការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា មានការប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ ដោយមន្ត្រី បុគ្គលិកដែលជាអ្នកតខ្សែបណ្តាញប្រព័ន្ធកុំព្យូទ័រត្រូវធ្វើការឡើងតនៅលើពិដាន ការតដោយផ្ទាល់ពីប្រទាំងការឡើងបង្គោល និងឡើងពិនិត្យកាមេរ៉ាសុវត្ថិភាព តាមអគាររដ្ឋបាលទាំង២ (ផែ TS៣ និងផែ LM17) ពុំមានបំពាក់ឯកសណ្ឋាន ការពារសុវត្ថិភាពឱ្យបានត្រឹមត្រូវ ដូចជា (មួក អាវ ស្រោមដៃ ស្បែកជើង និងឧបករណ៍សុវត្ថិភាពផ្សេងៗទៀត) ដើម្បីបញ្ចៀសគ្រោះថ្នាក់ផ្សេងៗដែលកើតឡើងដោយចៃដន្យ ។

*កត្តានេះ អាចបណ្តាលឱ្យមានគ្រោះថ្នាក់កើតឡើងដោយប្រការចៃដន្យណាមួយក្នុងការតខ្សែបណ្តាញប្រព័ន្ធកុំព្យូទ័ររបស់ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា ។*

**សំណូមពរសវនករ៖** ដូចនេះសវនដ្ឋាន គួរតែយកចិត្តទុកដាក់ឱ្យបានខ្ពស់លើផ្នែកសុវត្ថិភាពពេលចុះបំពេញការងារតខ្សែបណ្តាញប្រព័ន្ធកុំព្យូទ័រ និងពិនិត្យកាមេរ៉ាសុវត្ថិភាព ដោយធ្វើការសហការជាមួយការិយាល័យសុវត្ថិភាព/ សុខមាលភាព/បរិស្ថានផែ ក្នុងការផ្គត់ផ្គង់សម្ភារការពារ ឧបករណ៍សុវត្ថិភាព និងការបង្ហាត់បង្រៀនពីវិធី ក្បួន ខ្នាត សុវត្ថិភាពការងារផងដែរ។

**មតិឆ្លើយតបខាងសវនដ្ឋាន៖** យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើការកែសម្រួលនូវ ចំនុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ។

## ៤- ការិយាល័យសន្តិសុខ/ ប្រព័ន្ធ CCTV Camera (ត្រីមាសទី៣)

### *៤-១. អំពីសៀវភៅកត់ត្រាចូល-ចេញ*

តាមការពិនិត្យ និងសាកសួរ ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera មានសៀវភៅសម្រាប់កត់ត្រាលិខិតចូល-ចេញតែមួយរួមគ្នា។ ដូចនេះសវនដ្ឋានគួរតែធ្វើការបែងចែកសៀវភៅចូល-ចេញដាច់ដោយឡែកពីគ្នា ដើម្បីងាយស្រួលក្នុងការតាមដាន និងគ្រប់គ្រងរាល់លិខិតបទដ្ឋាន។

*កត្តានេះធ្វើឱ្យការគ្រប់គ្រងឯកសាររដ្ឋបាល នៅមិនទាន់គ្រប់ជ្រុងជ្រោយ។*

**សំណូមពររបស់សវនករ៖** ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងសៀវភៅរដ្ឋបាលចូល-ចេញសម្រាប់កត់ត្រាឱ្យបានទៀងទាត់ ដោយត្រូវកត់ត្រាដាច់ដោយឡែកពីគ្នា។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើការសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ។

### *៤-២. អំពីបញ្ជីវត្តមានប្រចាំថ្ងៃរបស់បុគ្គលិកសន្តិសុខប្រចាំការនៅចំណតផែកុងតឺន័រ LM១៧*

ជាគោលការណ៍ ការគ្រប់គ្រងវត្តមានបុគ្គលិក ដើម្បីលើកកម្ពស់វិន័យការងារ មនសិការវិជ្ជាជីវៈ និងធានាបាននូវប្រសិទ្ធភាពការងារ សវនករពិនិត្យឃើញថា បញ្ជីវត្តមានប្រចាំថ្ងៃរបស់អង្គភាពច្រកទ្វារ LM១៧ នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ ដោយបុគ្គលិកមួយចំនួនពុំបានចុះហត្ថលេខាជាប្រចាំនោះទេ។

*កត្តានេះធ្វើឱ្យការគ្រប់គ្រងវត្តមាន បុគ្គលិកនៅមានចន្លោះប្រហោង និងពុំទាន់បានល្អប្រសើរ។*

**សំណូមពររបស់សវនករ៖** ដូចនេះការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera គួរជំរុញអង្គភាពច្រកទ្វារ LM១៧ ពង្រឹងការចុះហត្ថលេខាលើវត្តមានប្រចាំថ្ងៃបន្ថែមទៀត។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើការសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ។

### *៤-៣. បន្តជំរុញការសហការជាមួយអង្គភាពពាក់ព័ន្ធលើសំណើសុំផ្សេងៗដែលមានចំណារ និងឯកភាពពីថ្នាក់ដឹកនាំ*

តាមការពិនិត្យ និងសាកសួរសវនករសង្កេតឃើញថា ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera បានធ្វើសំណើដូចជា៖

-ជួសជុលច្រកទ្វាចំនួន ០៤កន្លែងនៅផែថ្មី TS៣ (លេខ ៥២ សណ.សស ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨)

-សុំផ្សាររបាំងដែកសារឡើងវិញនៅមាត់ច្រកទ្វារចំណតផែថ្មី TS៣ (លេខ ៩៧ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨)

-ជួសជុលរបងបាក់នៅផ្នែកខាងជើងអគាររដ្ឋបាលនៃចំណតផែថ្ម TS៣ (លេខ ៦៨ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨)

-ជួសជុលប្រព័ន្ធ CCTV Camera នៅចំណតផែកុងតឺន័រ TS៣ (លេខ ៨១ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧)

-ជួសជុលប្រព័ន្ធ CCTV Camera នៅចំណតផែកុងតឺន័រ LM១៧ (លេខ ១២៣ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧)

-សុំធ្វើជំបូលសំយាបសម្រាប់ដាក់រថយន្តតូច និងម៉ូតូនៅចំណតផែកុងតឺន័រ LM១៧ (លេខ ២៦៨ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦)

-សុំធ្វើពាងយាមចល័តចំនួន ០២ និងបន្ទប់ទឹកអមទាំងបង្គន់អនាម័យចំនួន ០៨ កន្លែង នៅចំណតផែកុងតឺន័រ LM១៧ (លេខ ៦០ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៧)

-ធ្វើផងទង់ជាតិ នៅ LM១៧

*កត្តានេះអាចធ្វើឱ្យប៉ះពាល់ដល់ការប្រតិបត្តិ និងការគ្រប់គ្រងផែនសមត្ថកិច្ចការងាររបស់បុគ្គលិកសន្តិសុខ ។*

**សំណូមពររបស់សវនករ៖** ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera គួរតែបន្តសហការជាមួយអង្គភាពពាក់ព័ន្ធបន្ថែមទៀត ក្នុងការតាមដាន លើការអនុវត្តសំណើសុំផ្សេងៗដែលមានចំណារ និងឯកភាពពីថ្នាក់ដឹកនាំ ។

**មតិឆ្លើយតបសវនដ្ឋាន៖** យល់ស្របតាមការរកឃើញរបស់សវនករ សវនដ្ឋាននឹងធ្វើការសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ។

***៤-៤. កង្វះខាតមធ្យោបាយ ឧបករណ៍ សម្ភារសម្រាប់យាមប្រចាំការ និងសង្គ្រោះពេលមានឧបទ្ទវហេតុកើតឡើងដោយចៃដន្យ***

តាមការសាកសួរ ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera នៅមានកង្វះខាតផ្នែកមធ្យោបាយ ឧបករណ៍ និងសម្ភារមួយចំនួនដូចជា៖

-អូប៉េរ ឬឆាកភ្លើង

-រថយន្តប្រចាំការ

-រថយន្តពន្លត់អគ្គិភ័យ

*កត្តានេះធ្វើឱ្យមានការខ្វះចន្លោះក្នុងការរក្សាសន្តិសុខ និងសុវត្ថិភាពជូន ក.ស.ភ.។*

**សំណូមពររបស់សវនករ៖** ជួរផ្ទះ សវនដ្ឋានគួរតែធ្វើការសហការជាមួយការិយាល័យសុវត្ថិភាព/សុខមាលភាព/បរិស្ថានផែ ដើម្បីសិក្សា និងរកដំណោះស្រាយអំពីបញ្ហាខាងលើ ដើម្បីសង្គ្រោះហេតុការណ៍ដែលកើតឡើងដោយចៃដន្យឱ្យបានទាន់ពេលវេលា។

**មតិឆ្លើយតបសវនដ្ឋាន៖** យល់ស្របតាមការរកឃើញរបស់សវនករ សវនដ្ឋាននឹងធ្វើការសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ។ កន្លងមកការិយាល័យទាំងពីរបានសហការគ្នាទៅវិញទៅមក

និងបានចូលរួមគ្រប់គ្រងបណ្តុះបណ្តាល ដល់បុគ្គលិក ក.ស.ភ. ដើម្បីរក្សាសុវត្ថិភាព និងសន្តិសុខបានល្អប្រសើរ។ ចំពោះថវិកាពន្លត់អគ្គិភ័យ ការិយាល័យសន្តិសុខបានលើកចូលក្នុងគម្រោងឆ្នាំ២០១៩រួចហើយ។

*៨-៥. អំពីកង្វះខាតក្នុងការកំណត់អត្តសញ្ញាណរបស់មន្ត្រីនិយោជិត និងអតិថិជនដែលចូល-ចេញ ក.ស.ភ.*

ក្រោយពីបានពិនិត្យ និងធ្វើការសាកសួរសវនករសង្កេតឃើញថា ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera នៅមានការខ្វះចន្លោះក្នុងការកំណត់អត្តសញ្ញាណមន្ត្រី និយោជិត និងអតិថិជនដែលចូល-ចេញក.ស.ភ.។

*កត្តានេះអាចបណ្តាលឱ្យមានហានិភ័យបាត់បង់ទ្រព្យសម្បត្តិរ និងមានភាពអសន្តិសុខផ្សេងៗ បង្កឡើងក្នុងបរិវេណ ក.ស.ភ. ដោយងាយ។*

**សំណូមពររបស់សវនករ៖** ដូចនេះ ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera គួររៀបចំ និងពង្រឹងបន្ថែមទៀតក្នុងការកំណត់អត្តសញ្ញាណរបស់មន្ត្រី និយោជិត និងអតិថិជនដែលចូល-ចេញ ក.ស.ភ. ឱ្យមានភាពល្អប្រសើរជាងមុន។

**មតិឆ្លើយតបសវនដ្ឋាន៖** ការលើកឡើងរបស់សវនករពិតជាត្រឹមត្រូវ ក៏ប៉ុន្តែកំពុងស្នើឱ្យមានការសហការពីមន្ត្រីនិយោជិត គ្រប់ស្ថាប័នទាំងអស់រួមទាំងអតិថិជន ពីព្រោះបទបញ្ជាផ្ទៃក្នុងគឺបានបិតប្រកាសនៅគ្រប់ច្រកចូល-ចេញ ក.ស.ភ.។ ជាមួយគ្នានេះ ដែរ បុគ្គលិក ក.ស.ភ. ទាំងអស់គឺបានកាត់សម្លៀកបំពាក់ ក ស ភ ជារៀងរាល់ឆ្នាំផងដែរ។ ដូចនេះ ត្រូវប្រើប្រាស់ឯកសណ្ឋាន ក ស ភ ដើម្បីងាយស្រួលក្នុងការកំណត់អត្តសញ្ញាណ។

*៨-៦. ការបញ្ចូលសំណើសុំទិញ Rolling Paper ទៅក្នុងផែនការប្រចាំឆ្នាំ*

ឆ្លងតាមការត្រួតពិនិត្យ សវនករសង្កេតឃើញថា សំណើសុំទិញ Rolling Paper ដែលទុកសម្រាប់បោះពុម្ពវិក័យប័ត្រ ចំណូលច្រកទ្វារ (Gate fee) ជូនដល់អតិថិជនពេលដែលរថយន្តដឹកជញ្ជូនកុងតឺន័រចូល-ចេញ នៅចំណតផែកុងតឺន័រ LM17 គឺធ្វើឡើង២-៣ ដងក្នុងមួយឆ្នាំ ។

*កត្តានេះធ្វើឱ្យអក្ខភាពច្រកទ្វារ LM១៧ ជួបការលំបាកនៅពេលខ្វះ Rolling Paper សម្រាប់ប្រើប្រាស់។*

**សំណូមពររបស់សវនករ៖** ដូចនេះការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera គួរតែសិក្សាលើកជាគម្រោងស្នើសុំទិញ Rolling Paper បញ្ចូលទៅក្នុងផែនការទិញសម្ភារការិយាល័យប្រចាំឆ្នាំ ដើម្បីបំពេញតម្រូវការជាក់ស្តែង ។

**មតិឆ្លើយតបសវនដ្ឋាន៖** យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើការសម្រួលចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ កន្លងមកសវនដ្ឋានបានស្នើសុំជាកញ្ចប់រួចហើយ។

### *៤-៧. កង្វះខាតក្នុងការតាមដាន និងថែរក្សាទិន្នន័យរបស់ប្រព័ន្ធការពារសុវត្ថិភាព CCTV Camera*

ក្រោយពីបានពិនិត្យ និងធ្វើការសាកសួរ សវនករសង្កេតឃើញថា ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera នៅមានការខ្វះចន្លោះក្នុងការតាមដាន ទិន្នន័យដែលរក្សាទុកនៅក្នុងម៉ាស៊ីន Digital Video Record "DVR" ។

*កត្តានេះអាចធ្វើឱ្យការគ្រប់គ្រង និងការរក្សាទុកទិន្នន័យវីដេអូ មានភាពមិនច្បាស់លាស់ ខ្វះការធ្វើបច្ចុប្បន្នភាព អាចបណ្តាលឱ្យបាត់បង់ទិន្នន័យវីដេអូដែលបានរក្សាទុកក្នុងរយៈពេលណាមួយ ។*

**សំណូមពររបស់សវនករ៖** ដូចនេះការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera គួររៀបចំ និងកំណត់កាលវិភាគតាមដានលើម៉ាស៊ីន Digital Video Record "DVR" ដោយពិនិត្យលើបច្ចុប្បន្នភាព ដើម្បីការពារការបាត់បង់ទិន្នន័យវីដេអូដែលរក្សាទុក និងវាយតម្លៃពីគុណភាពជាប្រចាំរៀងរាល់ ខែ ឆ្នាំ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើការសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ។

### *៤-៨. ការកំណត់ទីតាំងបំពាក់ប្រព័ន្ធ CCTV Camera សុវត្ថិភាពបន្ថែមនៅចំណតផែកុងតឺន័រ LM ១៧ (Phase I)*

តាមការពិនិត្យ និងសាកសួរសវនករសង្កេតឃើញថា ដោយសារកន្លងមកការធ្វើចរាចរណ៍របស់រថយន្តដឹកកុងតឺន័រចូល-ចេញនៅលើទីលាន RTG (Phase I) នៅចំណតផែកុងតឺន័រ ធ្លាប់បង្កឱ្យមានការប៉ះទង្គិចជាមួយ និងកុងតឺន័រនៅលើទីលាន ហើយកាមេរ៉ាដែលបានបំពាក់នៅលើទីលាន (Phase I) តាមប្រង៉ុចទាំង៤ ដែលមានកម្ពស់ ៣២ម៉ែត្រ គឺអាចមើលឃើញគ្រប់ជ្រុងទាំងអស់តែនៅផ្នែកខាងក្រៅតែប៉ុណ្ណោះ ប៉ុន្តែទូកុងតឺន័រដែលស្ថិតនៅផ្នែកខាងក្នុង គឺមិនអាចមើលឃើញ និងចាប់រូបភាពបានទេ។

*កត្តានេះធ្វើឱ្យមានភាពខ្វះចន្លោះក្នុងការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាព។*

**សំណូមពររបស់សវនករ៖** ដូចនេះការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera គួរតែធ្វើការសហការជាមួយអង្គភាពពាក់ព័ន្ធចុះសិក្សា និងបំពាក់ប្រព័ន្ធ CCTV Camera បន្ថែមទៀតនៅផ្នែកខាងក្នុងលើផ្លូវ RTG នៃចំណតផែកុងតឺន័រ LM១៧។

**មតិឆ្លើយតបសវនដ្ឋាន៖** យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើការសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ដោយផ្អែកតាមការសិក្សារបស់ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា បានបញ្ជាក់ថាពុំអាចដំឡើងបានទេ ដោយសារវាអាចរាំងស្ទះជាមួយនឹងប្រតិបត្តិការ។

### *៤-៩. អំពីរបាយការណ៍របស់ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera*

តាមការសាកសួរ ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera រាល់ទិន្នន័យដែលផ្ញើពីអង្គភាពច្រកទ្វារ LM១៧ គឺមិនបានធ្វើជាលាយលក្ខណ៍អក្សរនោះទេ ដោយផ្ញើតាមប្រព័ន្ធសារអេឡិចត្រូនិច ដើម្បីអោយប្រធានធ្វើជារបាយការណ៍។ ដូចនេះរបាយការណ៍មួយចំនួនដែលប្រធានការិយាល័យធ្វើឡើងគឺ

មិនមានការចុះហត្ថលេខាសង្ខេប (Initial Signature) របស់អ្នកផ្តល់ទិន្នន័យ ឬរបាយការណ៍រួមចំណែកទទួលខុសត្រូវ ដែលធ្វើឱ្យឯកសារពុំមានលក្ខណៈគតិយុត្តនៅឡើយទេ ។

*កត្តានេះធ្វើឱ្យឯកសារមានភាពមិនពេញលេញ និងមិនស្របតាមបទដ្ឋាន និតិវិធីថវិកា ។*

**សំណូមពររបស់សវនករ៖** ដូចនេះ ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera គួរតែបន្ថែមការយកចិត្តទុកដាក់ពលឯកសាររបស់សាមីសវនដ្ឋាន ដោយឱ្យមានការចុះហត្ថលេខាពីអ្នកផ្តល់ទិន្នន័យ ឬរបាយការណ៍ក្នុងការចុះហត្ថលេខាសង្ខេប (Initial Signature) រួមចំណែកទទួលខុសត្រូវ ។

**មតិឆ្លើយតបសវនដ្ឋាន៖** យល់ស្របតាមការរកឃើញរបស់សវនករ សវនដ្ឋាននឹងធ្វើការសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ។

### *៤-១០. អំពីទីតាំងសម្រាប់ផ្ទុកទំនិញគ្រោះថ្នាក់នៅចំណតផែកុងតឺន័រ LM១៧*

តាមការសាកសួរ សវនករពិនិត្យឃើញថាសម្រាប់ផ្ទុកទំនិញគ្រោះថ្នាក់គឺបានសាងសង់ និងបំពាក់ផ្លាកសញ្ញាបានត្រឹមត្រូវ ក៏ប៉ុន្តែដាក់ស្លែងបែរដោយកស់បកកុងតឺន័រមកដាក់លាយឡំគ្នាជាមួយនឹងទំនិញគ្រោះថ្នាក់ទៅវិញ។

*កត្តានេះអាចធ្វើឱ្យមានផលប៉ះពាល់ដល់ទំនិញផ្សេងទៀត និងអាចកើតមានឧបទ្ទវហេតុកើតឡើងដោយប្រការណាមួយ ។*

**សំណូមពររបស់សវនករ៖** ដូចនេះការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera គួរតែសហការជាមួយអង្គភាពរៀបផែនប្រតិបត្តិការក្នុងការផ្ទុកទំនិញគ្រោះថ្នាក់ដាច់ដោយឡែកពីគេ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** យល់ស្របតាមការរកឃើញរបស់សវនករ សវនដ្ឋាននឹងធ្វើការកែសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ តែប៉ុន្តែការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera ធ្លាប់បានសហការជាច្រើនលើកមកហើយជាមួយអង្គភាពរៀបផែនប្រតិបត្តិការ និងអង្គភាពរៀបចំប្រតិបត្តិការចំណតផែ ហើយរៀបចំទៀតទីលានដាក់ទំនិញគ្រោះថ្នាក់ ទើបចាក់ធ្មួយហើយក្នុងខែតុលា ឆ្នាំ ២០១៨ នេះ។

### *៤-១១. ការអនុគ្រោះបង់ថ្លៃ (Gate Fee) ជាមួយក្រុមហ៊ុនមួយចំនួនតាមក្រោយ*

សវនករពិនិត្យឃើញថា ក្នុងរបាយការណ៍ស្តីពីសកម្មភាពរថយន្តដឹកជញ្ជូនកុងតឺន័រ ប្រចាំថ្ងៃ ដែលធ្វើឡើងដោយការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera នៅចំណតផែកុងតឺន័រ LM១៧ បានបង្ហាញថាយ៉ាងតិចមានចំនួន ០៥ក្រុមហ៊ុន ដែលទូទាត់ថ្លៃ (Gate Fee) ពេលក្រោយ។ ប៉ុន្តែសវនករសង្កេតឃើញថា ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera បានតម្កល់កិច្ចសន្យាតែមួយក្រុមហ៊ុនគត់ ដើម្បីធ្វើការអនុគ្រោះបង់ថ្លៃ (Gate Fee) ដែលចុះនៅក្នុងកិច្ចសន្យាលេខ ៣២៨ ក. ស. ក/PPAP ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១៥ ត្រង់ ប្រការ៣៖ តម្លៃ និងនីតិវិធីទូទាត់ (ជាសាច់ប្រាក់) **ចំនុច ៣.២:** (ភាគី ខ ត្រូវធ្វើការទូទាត់ជូន ភាគី ក ក្នុងរយៈពេលមួយសប្តាហ៍ម្តង (ថ្ងៃទី១ សប្តាហ៍បន្ទាប់) បន្ទាប់ពីទទួលបានវិក្កយបត្រចក្រម្ចារ (Receipt Truck Gate Fee)។ ក្នុងករណីបង់ថ្លៃយឺតយ៉ាវភាគី ខ ត្រូវទទួលការពិន័យ ២% (ពីរភាគរយ) លើថ្លៃច្រកទ្វារ

ដែលត្រូវបង់ចាប់ពីរយៈពេល៣(បី)ថ្ងៃក្រោយការកំណត់។ ប្រាក់ពិន័យនេះត្រូវគណនាតាមរូបមន្តការប្រាក់សមាស។ ក្នុងករណីខកខានបង់ថ្លៃច្រកទ្វារក្នុងរយៈពេល ០១ (មួយ)ខែ ជាប់គ្នានេះ ភាគី ក មានសិទ្ធិលុបកិច្ចសន្យា និងត្រូវអនុវត្តតាមនីតិវិធីច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា)។

*កត្តានេះអាចប៉ះពាល់ដល់ការគ្រប់គ្រងចំណូលច្រកទ្វារ (Gate Fee) ។*

**សំណូមពររបស់សវនករ៖** ដើម្បីបង្កើនការទុកចិត្តលើការធ្វើអាជីវកម្មរបស់ខ្លួនឱ្យល្អប្រសើរ សវនដ្ឋានគួរជំរុញសហការជាមួយអង្គភាពដែលពាក់ព័ន្ធក្នុងការធ្វើលិខិតស្នាម/កិច្ចសន្យា ជាមួយក្រុមហ៊ុនមួយចំនួនដែលបានស្នើសុំអនុគ្រោះបង់ថ្លៃ (Gate Fee)។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើការសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ តាមការពិតការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera មានតួនាទីថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ ជូន ក.ស.ក. គឺពុំគួរជាប់ពាក់ព័ន្ធទៅលើការទទួល និងទារសាច់ប្រាក់ជាផ្លូវការណាមួយពីអតិថិជនឡើយ ដូចនេះការិយាល័យសន្តិសុខប្រព័ន្ធ/ CCTV Camera សំណូមពរ ក. ស. ក. គួរពិចារណាទៅលើអង្គភាពច្រកទ្វារថាតើគួរស្ថិតនៅក្រោមនិកាយរបស់អង្គភាពរៀបចំប្រតិបត្តិការចំណតផែ ឬអង្គភាពហិរញ្ញវត្ថុ ។

### *៤-១២. អំពីរបាយការណ៍បូកសរុបប្រចាំថ្ងៃចំណូលច្រកទ្វារ (Gate fee) តាមប្រព័ន្ធ Blue Parking System*

តាមការពិនិត្យលើរបាយការណ៍បូកសរុបប្រចាំថ្ងៃចំណូលច្រកទ្វារ (Gate fee) ដែលទាញចេញពីប្រព័ន្ធ Blue Parking System គឺនៅមិនទាន់បំពេញគ្រប់លក្ខខណ្ឌដោយមិនអាចបង្ហាញពីការិយបរិច្ឆេទ ចំនួនសរុបទូរកុងតឺន័រ (TEUs) និងឈ្មោះអ្នកទទួលខុសត្រូវប្រចាំវេននីមួយៗ ។

*កត្តានេះធ្វើឱ្យមានផលលំបាកក្នុងការផ្ទៀងផ្ទាត់ និងពុំទាន់មានភាពច្បាស់លាស់។*

**សំណូមពររបស់សវនករ៖** ដូចនេះការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera គួរសហការជាមួយការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា ដើម្បីទំនាក់ទំនងទៅកាន់ក្រុមហ៊ុនផ្គត់ផ្គង់ក្នុងការបំពេញចន្លោះខ្វះខាតរបស់ Blue Parking System ឱ្យស្របទៅតាមតម្រូវការជាក់ស្តែង ។

**មតិឆ្លើយតបសវនដ្ឋាន៖** យល់ស្របតាមការបកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើការសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ។

### *៤-១៣. អំពីប្រព័ន្ធសម្រាប់ទូទាត់ប្រាក់ចំណូលច្រកទ្វារ (Gate Fee)*

តាមការពិនិត្យ និងសាកសួរ សវនករសង្កេតឃើញថា អង្គភាពច្រកទ្វារ LM១៧ នៃការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera ពុំទាន់អាចប្រើប្រាស់ប្រព័ន្ធ Terminal Operation System "TOS" ក្នុងការទូទាត់ប្រាក់ចំណូល ច្រកទ្វារ (Gate Fee) នៅឡើយទេ គឺនៅប្រើប្រាស់ប្រព័ន្ធ Blue Parking System ដែលផ្គត់ផ្គង់ពីក្រុមហ៊ុនក្នុងស្រុក ។

*កត្តានេះធ្វើឱ្យការប្រើប្រាស់ប្រព័ន្ធ TOS មិនទាន់អាចបំពេញបានគ្រប់លក្ខខណ្ឌ ដោយមិនអាចគ្រប់គ្រងចំនួនសរុបខ្ទង់កុងតឺន័រ (TEUs) និងចំណូលច្រកទ្វារ (Gate Fee) ទៅក្នុងប្រព័ន្ធ TOS ជាមួយនឹងចំណូលពីផ្នែកផ្សេងៗទៀត ។*

**សំណូមពររបស់សវនករ៖** ដូចនេះការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera គួរសហការជាមួយការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា បញ្ចូលការទូទាត់ចំណូលច្រកទ្វារ (Gate Fee) ទៅក្នុងប្រព័ន្ធ TOS ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឱ្យមានសុក្រឹត្យភាព ។

**មតិឆ្លើយតបសវនដ្ឋាន៖** យល់ស្របតាមការរកឃើញរបស់សវនករ សវនដ្ឋាននឹងធ្វើការសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ។

### *៥-១៥. អំពីការងារប្រតិបត្តិការច្រកចូល-ចេញ Gate in/Gate out ក្នុងប្រព័ន្ធ Terminal Operation System "TOS" របស់ការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera*

តាមការពិនិត្យ និងសាកសួរសវនករសង្កេតឃើញថា អង្គភាពច្រកទ្វារនៅចំណតផែកុងតឺន័ LM១៧ នៃការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera នៅពុំទាន់អាចប្រើប្រាស់ប្រព័ន្ធ "TOS" លើការងារប្រតិបត្តិការ Gate in/ Gate out ឱ្យបានទាន់ពេលវេលានៅឡើយទេ ដោយធ្វើការបញ្ចូលទិន្នន័យតាមក្រោយពេលថយន្តចូល-ចេញជាក់ស្តែង ។

*កត្តានេះធ្វើឱ្យការប្រើប្រាស់ប្រព័ន្ធ "TOS" ពុំដំណើរការបានពេញលក្ខណៈ និងបង្កបញ្ហាផ្សេងៗពាក់ព័ន្ធដល់ប្រព័ន្ធ និងអង្គភាពពាក់ព័ន្ធផ្សេងៗ។*

**សំណូមពររបស់សវនករ៖** ដូចនេះការិយាល័យសន្តិសុខ/ប្រព័ន្ធ CCTV Camera គួរជំរុញអង្គភាពច្រកទ្វារ និងសហការជាមួយការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យាបន្ថែមទៀត ក្នុងការប្រើប្រាស់ប្រព័ន្ធ "TOS" ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

**មតិឆ្លើយតបសវនដ្ឋាន៖** យល់ស្របតាមការរកឃើញរបស់សវនករ សវនដ្ឋាននឹងធ្វើការសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ។

## ៥- ការិយាល័យបុគ្គលិក/បណ្តុះបណ្តាល (ត្រីមាសទី៤)

### *៥-១. អំពីរបាយការណ៍ស្តីពីការចំណាយវគ្គបណ្តុះបណ្តាល*

ក្រោយពីបានពិនិត្យរបាយការណ៍ និងធ្វើការសាកសួរសវនករសង្កេតឃើញថាការិយាល័យបុគ្គលិក/បណ្តុះបណ្តាល ពុំទាន់បានអនុវត្តឱ្យពេញលេញទៅលើចំណាយបណ្តុះបណ្តាលធនធានមនុស្សបើធៀបនឹងផែនការឆ្នាំ២០១៨ដែលបានគ្រោងទុក។

*កត្តាទាំងនេះអាចធ្វើឱ្យផែនការឆ្នាំ២០១៨ ក្នុងការចំណាយវគ្គបណ្តុះបណ្តាលមិនបានសម្រេចដល់គោលដៅ។*

**សំណូមពររបស់សវនករ៖** ដូចនេះ ការិយាល័យបុគ្គលិកបណ្តុះបណ្តាល គួរយកចិត្តទុកដាក់លើការបណ្តុះបណ្តាលកម្មករនិយោជិត និងបុគ្គលិកជាប់កិច្ចសន្យា ដើម្បីឆ្លើយតបនឹងការលើកផែនការ និងអភិវឌ្ឍធនធានមនុស្សនៅ ក. ស. ក. ឱ្យកាន់តែប្រសើរ។

**មតិឆ្លើយតបសវនដ្ឋាន៖** ការិយាល័យបុគ្គលិកបណ្តុះបណ្តាល សម្រាប់គម្រោងបណ្តុះបណ្តាលក្នុងឆ្នាំ២០១៨ ដែលអនុវត្តមិនទាន់បានពេញលេញ និងព្យាយាមបន្តអនុវត្តឱ្យបានល្អប្រសើរតាមផែនការឆ្នាំខាងមុខ។

***៥-២. បន្តជំរុញ និងដំណើរការប្រព័ន្ធគ្រប់គ្រងវត្តមាន "Finger Print Attendant Management" របស់កម្មករ និយោជិត និងបុគ្គលិកជាប់កិច្ចសន្យា ក. ស. ក.***

យោងលិខិត ២៥៨ កបក/CT ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យដំណើរការឡើងវិញនូវម៉ាស៊ីនតាមដានវត្តមាននៅចំណតផែពហុបំណង TS៣ និងចំណតផែកុងតឺន័រ LM១៧។ សវនករពិនិត្យឃើញថា តាមរបាយការណ៍ខាងលើ ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា និងការិយាល័យបុគ្គលិក/បណ្តុះបណ្តាល បានធ្វើការសហការគ្នាដើម្បីដំណើរការម៉ាស៊ីន "Finger Print Attendant Management" ឡើងវិញក្នុងការងាយស្រួលគ្រប់គ្រងវត្តមានរបស់កម្មករ និយោជិត និងបុគ្គលិកជាប់កិច្ចសន្យា។ ប៉ុន្តែប្រព័ន្ធនេះបានផ្អាកការអនុវត្ត និងមិនបានប្រើប្រាស់រហូតដល់ពេលបច្ចុប្បន្ន។

*កត្តាទាំងនេះធ្វើឱ្យការអនុវត្តការងាររបស់កម្មករនិយោជិត និងបុគ្គលិកជាប់កិច្ចសន្យា ក.ស.ក. ងាយនឹងល្មើសផ្នែក ៗ នៃបទបញ្ជាផ្ទៃក្នុងស្តីពីពេលវេលាធ្វើការ។*

**សំណូមពររបស់សវនករ៖** សវនដ្ឋានគួរធ្វើការសិក្សា និងសហការជាមួយអង្គភាពពាក់ព័ន្ធឡើងវិញ ដើម្បីជំរុញប្រព័ន្ធខាងលើឱ្យដំណើរការជាផ្លូវការ និងការគ្រប់គ្រងវត្តមានរបស់កម្មករ និយោជិត និងបុគ្គលិកជាប់កិច្ចសន្យាគោរពឱ្យបានខ្ជាប់ខ្ជួនតាមបទបញ្ជាផ្ទៃក្នុង ក. ស. ក. ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥។

**មតិឆ្លើយតបសវនដ្ឋាន៖** បានឯកភាពតាមមតិយោបល់របស់សវនករ និងខិតខំពន្លឿនការងារគ្រប់គ្រងវត្តមានតាមប្រព័ន្ធ "Finger Print Attendant Management" ។

***៥-៣. អំពីការបែងចែកតួនាទីក្នុងការធ្វើលិខិតនទ្ទេសនាម និងសេចក្តីជូនដំណឹងផ្សេងៗ***

តាមការសង្កេតឃើញរបស់សវនករ ការធ្វើលិខិតនទ្ទេសនាម សេចក្តីជូនដំណឹងផ្សេងៗ គឺមិនទាន់បានបែងចែកតួនាទីគ្នាឱ្យបានច្បាស់លាស់ជាមួយ លេខាធិការដ្ឋាន និងការិយាល័យរដ្ឋបាល។

*កត្តានេះអាចបណ្តាលឱ្យមានកង្វះខាតលើទំនួលខុសត្រូវការបែងចែកតួនាទីតាមនាយកដ្ឋាន។*

**សំណូមពររបស់សវនករ៖** ការិយាល័យបុគ្គលិកបណ្តុះបណ្តាល គួរតែធ្វើការពិភាក្សាឡើងវិញជាមួយអង្គភាពពាក់ព័ន្ធខាងលើ ដើម្បីបែងចែកតួនាទីក្នុងការធ្វើលិខិតនទ្ទេសនាម សេចក្តីជូនដំណឹងផ្សេងៗ។

**មតិឆ្លើយតបសវនដ្ឋាន៖** តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន និងធ្វើការពិភាក្សាកែសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ។

*៥-៤. អំពីនីតិវិធីបញ្ជូនលិខិតចេញ និងឯកសារផ្សេងៗ*

ក្រោយពីបានពិនិត្យ និងធ្វើការសាកសួរសវនករសង្កេតឃើញថា ការបែងចែកលិខិតផ្សេងៗតាមបណ្ដាអង្គភាព ការិយាល័យបុគ្គលិក/បណ្ដុះបណ្ដាល នៅមិនទាន់មាននីតិវិធីក្នុងការបញ្ជូនលិខិតចេញសម្រាប់ឱ្យបណ្ដាអង្គភាពផ្សេងៗចុះហត្ថលេខាទទួល។

*កត្តាទាំងនេះអាចធ្វើឱ្យមានការភ័ន្តច្រឡំ ឬបាត់បង់ឯកសារ។*

**សំណូមពររបស់សវនករ៖** ការិយាល័យបុគ្គលិកបណ្ដុះបណ្ដាល គួររៀបចំនីតិវិធីបញ្ជូនលិខិតចេញ ចុះជាការកត់ត្រាពលិខិតផ្សេងៗដែលបានផ្ដល់ជូនបណ្ដាអង្គភាពក្រោមឱវាទ ក.ស.ភ. ។

**មតិឆ្លើយតបសវនដ្ឋាន៖** តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន និងធ្វើតាមអនុសាសន៍របស់សវនករ។

## ៦- ការិយាល័យរៀបគ្រោងពលកម្ម

*៦-១. អំពីកង្វះខាតក្នុងការធ្វើរបាយការណ៍បូកសរុបប្រាក់បៀវត្ស និងចំណាយបេសកកម្ម*

តាមការពិនិត្យ និងសាកសួរ ការិយាល័យបៀវត្សពលកម្មមិនទាន់បានបូកសរុបប្រាក់បៀវត្ស និងចំណាយបេសកកម្មប្រចាំឆមាស និងឆ្នាំ ។

*កត្តានេះអាចធ្វើឱ្យពិបាករកនូវទិន្នន័យសរុបបានទាន់ពេលវេលា និងខ្វះព័ត៌មានលម្អិតជូនថ្នាក់ដឹកនាំ។*

**សំណូមពររបស់សវនករ៖** ដូចនេះការិយាល័យបៀវត្សពលកម្ម គួរតែធ្វើការបូកសរុបរបាយការណ៍ប្រាក់បៀវត្ស និងចំណាយបេសកកម្មប្រចាំឆមាស ឆ្នាំ ដើម្បីមានភាពងាយស្រួល ថែមទាំងមានទិន្នន័យក្នុងការប្រៀបធៀបចំណាយជាក់ស្ដែងទៅនឹងចំណាយផែនការប្រចាំឆ្នាំ ។

**មតិឆ្លើយតបសវនដ្ឋាន៖** យល់ស្របតាមការលើកស្រាយបំភ្លឺរបស់សវនករ សវនដ្ឋាននឹងធ្វើការកែសម្រួលនូវចំណុចខ្វះខាតនាងលើឱ្យបានល្អប្រសើរ ។

## ៧- នាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ

*៧-១. បន្តបំពេញគោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យរបស់ ក.ស.ភ.*

តាមការពិនិត្យ និងសាកសួរសវនករសង្កេតឃើញថា សវនដ្ឋានបានកំពុងនឹងរៀបរៀងសៀវភៅ "គោលនយោបាយ និងនីតិវិធីគណនេយ្យ របស់ ក. ស. ភ." ក្នុងគោលបំណង៖

- បង្ហាញឱ្យកាន់តែច្បាស់នៅតួនាទី និងភារកិច្ចរបស់នាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ
- ការកត់ត្រាប្រតិបត្តិការគណនេយ្យ (ការគ្រប់គ្រងចំណូល/ចំណាយ ទ្រព្យសកម្ម សន្និធិ ការគ្រប់គ្រងសាច់ប្រាក់ជាដើម) ដើម្បីឱ្យស្របទៅតាមគោលនយោបាយ និងនីតិវិធីគណនេយ្យ
- និងបង្កើនគណនេយ្យភាព និងតម្លាភាព។

នាពេលបច្ចុប្បន្ន សវនដ្ឋានមិនទាន់បានបញ្ចប់ការរៀបរៀងសៀវភៅនេះនៅឡើយ។ ដោយបានធ្វើការកែសម្រួលនូវចំណុចមួយចំនួនក្រោយពីដាក់ឱ្យអនុវត្តសាកល្បងពីផ្នែកដែលពាក់ព័ន្ធ ទៅលើផ្នែកចំណាយ និងការគ្រប់គ្រងសាច់ប្រាក់។

*កត្តាទាំងនេះអាចធ្វើឱ្យប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងនីតិវិធីរបស់ នាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ ពុំទាន់មានភាពច្បាស់លាស់ពេលការអនុវត្តការងារជាក់ស្ដែងប្រចាំថ្ងៃ។*

**សំណូមពររបស់សវនករ៖** សវនដ្ឋានគួរតែបន្តធ្វើបច្ចុប្បន្នភាពនិងបញ្ចប់ការរៀបរៀងសៀវភៅ "គោលនយោបាយ និងនីតិវិធីគណនេយ្យរបស់ គ. ស. ក." ដើម្បីឱ្យមានតម្លាភាព និងគណនេយ្យភាពនៅក្នុងប្រព័ន្ធគណនេយ្យរបស់ គ. ស. ក. ដើម្បីធ្វើជាមូលដ្ឋានក្នុងការគ្រប់គ្រង។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន នឹងបញ្ចប់ជាស្ថាពរទៅលើផ្នែកចំណាយ និងការគ្រប់គ្រងសាច់ប្រាក់ ព្រមទាំងផ្នែកផ្សេងៗទៀតដូចជា ផ្នែកចំណូល ទ្រព្យសកម្ម និងសន្និធិជាបន្តទៀត។ ដូចនេះនាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ នឹងធ្វើបច្ចុប្បន្នភាពរៀបរៀងឱ្យបានឆាប់រហ័សនាពេលខាងមុខ។

### *៧-២. អំពីរចនាសម្ព័ន្ធនាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ*

ឆ្លងតាមការត្រួតពិនិត្យរបស់សវនករឃើញថា សវនដ្ឋានបានធ្វើការកែសម្រួល ផ្លាស់ប្តូរ និងបន្ថែមតួនាទីភារកិច្ចនៅក្នុងរចនាសម្ព័ន្ធថ្មីក្នុងឆ្នាំ ២០១៧ ដែលនៅមានភាពខ្វះចន្លោះការងារអនុវត្តន៍ជាក់ស្តែងមិនទាន់មានបុគ្គលិកដាក់តាមប្រអប់តួនាទីដែលមានក្នុងរចនាសម្ព័ន្ធ (ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងបុគ្គលិកមួយចំនួន)។

*កត្តានេះធ្វើឱ្យរចនាសម្ព័ន្ធរបស់សវនដ្ឋាន នៅខ្វះបុគ្គលិកកាន់តាមមុខតំណែងការងារ។*

**សំណូមពររបស់សវនករ៖** សវនដ្ឋានគួរតែពិនិត្យមើលបុគ្គលិកមានសមត្ថភាពដើម្បីបញ្ចូលទៅកាន់តាមប្រអប់នៃរចនាសម្ព័ន្ធរបស់នាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ ដើម្បីឱ្យការងាររបស់នាយកដ្ឋានកាន់តែមានប្រសិទ្ធភាព។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** បច្ចុប្បន្ននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ កំពុងពិនិត្យមើលធ្វើការបណ្តុះបណ្តាលបន្ថែមទៀតទៅបុគ្គលិកដែលអនុវត្តការងារផ្ទាល់ក្នុងនាយកដ្ឋាន ដើម្បីមានសមត្ថភាពគ្រប់គ្រាន់អាចមកបំពេញក្នុងប្រអប់រចនាសម្ព័ន្ធដែលខ្វះចន្លោះ។

### *៧-៣. ការធ្វើបច្ចុប្បន្នភាពអំពីតួនាទី និងភារកិច្ចរបស់មន្ត្រីនៅក្នុងនាយកដ្ឋាន*

សវនករពិនិត្យឃើញថា បច្ចុប្បន្នសាមីអង្គភាពបានធ្វើការកែសម្រួល ផ្លាស់ប្តូរ និងបន្ថែមតួនាទីភារកិច្ចតាមផ្នែករបស់នាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុរួចហើយ។ ប៉ុន្តែពុំទាន់បានផ្តល់ជូនការធ្វើតួនាទីភារកិច្ចបុគ្គលនៅក្នុងនាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ។

*កត្តានេះអាចធ្វើឱ្យមានការភាន់ច្រឡំក្នុងការបែងចែកតួនាទីភារកិច្ចរបស់បុគ្គលិក និងធ្វើឱ្យខ្វះទំនួលខុសត្រូវក្នុងការបំពេញការងារក្នុងនាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ។*

**សំណូមពររបស់សវនករ៖** ដើម្បីឱ្យមានប្រសិទ្ធភាព និងបង្កើនការទទួលខុសត្រូវអនុវត្តការងារនៅក្នុងនាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ សវនដ្ឋានគួរធ្វើការបែងចែកតួនាទីភារកិច្ចរបស់បុគ្គលិកដាច់ដោយឡែកពីគ្នា។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន ដោយសារការិយាល័យបុគ្គលិក/បណ្តុះបណ្តាល បានជូនដំណឹងមកនាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ ដោយគ្រាន់តែបច្ចុប្បន្នភាពអំពីតួនាទីតាមផ្នែក ដូចនេះបើការិយាល័យបុគ្គលិក/បណ្តុះបណ្តាល ជូនដំណឹងមក ដោយយកតាមបុគ្គលនាពេលខាងមុខនោះ នាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ នឹងប្រគល់ជូន។

### ៨- ការិយាល័យគណនេយ្យ

*៨-១. កង្វះខាតនីតិវិធីគ្រប់គ្រងគ្រឿងបន្លាស់រថយន្ត រថយន្ត ប្រេងឥន្ធនៈ និងសម្ភារការិយាល័យ*

ក្រោយពីបានពិនិត្យ និងធ្វើការសាកសួរសវនករសង្កេតឃើញថា ការបើកគ្រឿងបន្លាស់រថយន្ត រថយន្ត ប្រេងឥន្ធនៈ និងសម្ភារការិយាល័យចេញពីឃ្លាំងសម្ភារក្នុងកំឡុងបន្ទាន់ពុំបានកត់ត្រា និងការចុះហត្ថលេខាពីអង្គភាពស្នើសុំនិង ហើយពុំមានចុះ ថ្ងៃ ខែ ឆ្នាំ លើការបើកបណ្ណាសម្ភារទាំងអស់នោះ។

*កត្តាទាំងនេះអាចធ្វើឱ្យការគ្រប់គ្រងឃ្លាំងសម្ភារមានការធ្វេសប្រហែស ដែលអាចបណ្តាលឱ្យបាត់បង់ និងមិនច្បាស់លាស់ក្នុងការគ្រប់គ្រងគ្រឿងបន្លាស់រថយន្ត និងរថយន្ត ប្រេងឥន្ធនៈ និងសម្ភារការិយាល័យ។*

**សំណូមពររបស់សវនករ៖** ការិយាល័យគណនេយ្យ គួរជំរុញបន្ថែមទៅកាន់ផ្នែកឃ្លាំងសម្ភារក្នុងការកត់ត្រា និងមានការចុះហត្ថលេខាពីអ្នកស្នើសុំនិងប្រើប្រាស់មុនលើការបើកបណ្ណាសម្ភារទាំងអស់នោះប្រចាំ ថ្ងៃ ខែ ឆ្នាំ។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន ដើម្បីសម្រួលដល់ដំណើរការអាជីវកម្មរបស់ ក.ស.ភ. អង្គភាពពាក់ព័ន្ធភាគច្រើនបានធ្វើការស្នើសុំនិងជាបន្ទាន់នៅគ្រឿងបន្លាស់រថយន្ត រថយន្ត ប្រេងឥន្ធនៈ និងសម្ភារការិយាល័យ ហើយសន្យានឹងធ្វើលិខិតស្នើសុំនិងតាមក្រោយ ដែលជាហេតុធ្វើឱ្យការិយាល័យមិនបានកត់ត្រាមុន។ ការិយាល័យគណនេយ្យ នឹងរៀបចំសៀវភៅ ដើម្បីកត់ត្រាអំពីការនិង និងមានការចុះហត្ថលេខាពីសាមីអង្គភាពចាប់ពីឆ្នាំ២០១៩ នេះតទៅ។

*៨-២. បន្តជំរុញដល់ការទិញមានវិក្កយបត្រត្រឹមត្រូវ*

សវនករពិនិត្យ និងសង្កេតឃើញថា មានវិក្កយបត្រចំណាយមួយចំនួនទិញពីរូបវន្តបុគ្គល ដែលមិនបានបំពេញគ្រប់និទ្ទេសសំខាន់ៗមួយចំនួន ដូចជា៖

- មិនមានឈ្មោះសហគ្រាស អាសយដ្ឋាន និងលេខទូរស័ព្ទអ្នកផ្គត់ផ្គង់
- មិនមានលេខរៀងវិក្កយបត្រតាមលំដាប់

*កត្តានេះអាចធ្វើឱ្យវិក្កយបត្រចំណាយនៅមានភាពខ្វះខាតតាមសេចក្តីប្រកាសរបស់អគ្គនាយកដ្ឋានពន្ធដារ។*

**សំណូមពររបស់សវនករ៖** ការិយាល័យគណនេយ្យ គួរតែណែនាំបន្ថែម និងជំរុញផ្នែកពាក់ព័ន្ធចំណាយទាំងអស់ធ្វើការស្នើសុំវិក្កយបត្រតាមទម្រង់ស្តង់ដារពន្ធដារដែលបានកំណត់។

**មតិឆ្លើយតបរបស់សវនដ្ឋាន៖** ស្នើសុំឱ្យអ្នកទិញ និងអ្នកបំពេញបេសកកម្មនានាដូចជា អង្គភាពលទ្ធកម្ម ការិយាល័យរដ្ឋបាល និងនាយកដ្ឋានបុគ្គលិក/បណ្តុះបណ្តាល ពេលការទិញត្រូវមានវិក្កយបត្រ (Invoice) តាមទម្រង់ត្រឹមត្រូវ។

### ៩-ការិយាល័យហិរញ្ញវត្ថុ/ផ្សារមូលបត្រ

*៩-១. អំពីកង្វះខាតរបាយការណ៍បកស្រាយវិភាគលើចំណូល ចំណាយ និងព័ត៌មានហិរញ្ញវត្ថុក្នុង ក.ស.ភ.*

ក្រោយពីបានពិនិត្យ និងធ្វើការសាកសួរសវនករសង្កេតឃើញថា ការិយាល័យហិរញ្ញវត្ថុ/ផ្សារមូលបត្របានរៀបចំការវិភាគ ផ្នែកចំណូល ចំណាយ អនុបាទ ប្រចាំត្រីមាស និងប្រចាំឆ្នាំទៅគណៈកម្មការមូលបត្រកម្ពុជា។ ប៉ុន្តែកង្វះខាតរបាយការណ៍អំពីការបកស្រាយលើការវិភាគចំណូល ចំណាយ និងវិភាគព័ត៌មានហិរញ្ញវត្ថុស្តីពីស្ថានភាពហិរញ្ញវត្ថុផ្ទៃក្នុងជូនថ្នាក់ដឹកនាំរបស់ ក.ស.ភ.។

*កត្តាទាំងនេះអាចធ្វើឱ្យការផ្តល់ព័ត៌មានវិភាគលើចំណូល ចំណាយ និងស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ. ពុំទាន់ច្បាស់លាស់។*

**សំណូមពររបស់សវនករ៖** ដូចនេះ ការិយាល័យហិរញ្ញវត្ថុ/ផ្សារមូលបត្រ គួរធ្វើរបាយការណ៍ស្តីពីការបកស្រាយវិភាគលើចំណូល ចំណាយ និងស្ថានភាពហិរញ្ញវត្ថុជូនថ្នាក់ដឹកនាំ។

**មតិឆ្លើយតបសវនដ្ឋាន៖** តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន និងធ្វើការកែសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ។

***៥-២. ពុំទាន់បានកំណត់រយៈពេលធ្វើរបាយការណ៍ទៅលើទ្រព្យសកម្មរយៈពេលវែង ដែលមានអាយុកាលប្រើប្រាស់ និងធ្វើការជំរះបញ្ជីចេញពីបញ្ជីសារពើភណ្ឌរបស់ ក.ស.ភ.***

ក្រោយពីបានពិនិត្យ និងធ្វើការសាកសួរសវនករសង្កេតឃើញថា ការិយាល័យហិរញ្ញវត្ថុ/ផ្សារមូលបត្រ នៅពុំទាន់បានកំណត់ពេលវេលារៀបចំរបាយការណ៍ និងរាយការណ៍ទៅលើទ្រព្យសកម្មរយៈពេលវែងដែលអស់អាយុកាល និងទ្រព្យសកម្មរយៈពេលវែងមិនអាចប្រើប្រាស់បាន ដែលបានសរសេរក្នុងតួនាទី និងភារៈកិច្ចរបស់ការិយាល័យហិរញ្ញវត្ថុ/ផ្សារមូលបត្រ។

*កត្តាទាំងនេះអាចធ្វើឱ្យព័ត៌មានទាក់ទងទ្រព្យសកម្មរយៈពេលវែងដែលអស់អាយុកាល និងទ្រព្យសកម្មជំនួសឲ្យទ្រព្យសកម្មរយៈពេលវែងដែលមិនអាចប្រើប្រាស់បាន ពុំទាន់មានជារបាយការណ៍នៅឡើយ។*

**សំណូមពររបស់សវនករ៖** ដូច្នេះ ការិយាល័យហិរញ្ញវត្ថុ/ផ្សារមូលបត្រ គួរជំរុញការងាររៀបចំពេលវេលាធ្វើរបាយការណ៍លើទ្រព្យសកម្មរយៈពេលវែងដែលមិនអាចប្រើប្រាស់បានជូនដល់ថ្នាក់ដឹកនាំដើម្បីបានជ្រាប។

**មតិឆ្លើយតបសវនដ្ឋាន៖** តាមការស្រាយបំភ្លឺរបស់សវនដ្ឋាន និងធ្វើការកែសម្រួលនូវចំណុចខ្វះខាតខាងលើឱ្យបានល្អប្រសើរ ដោយកំណត់រយៈពេលធ្វើរបាយការណ៍ និងបញ្ចូលនីតិវិធីបន្ថែមក្នុង "គោលនយោបាយ និងនីតិវិធីគណនេយ្យរបស់ ក.ស.ភ."។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែ ... ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០១៩
**ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង**

**បានឃើញ និងឯកភាព**
ថ្ងៃសុក្រ ១០កើត ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែ មីនា ឆ្នាំ២០១៩
**ប្រធានគណៈកម្មាធិការសវនកម្ម**

**ឃ្វី សេនច៉ានិច**

# ផ្នែកទី ៧

# របាយការណ៍ហិរញ្ញវត្ថុ
# ដែលធ្វើសវនកម្មដោយសវនករឯករាជ្យ

លេខបញ្ជីកាណិជ្ជកម្ម៖
Co. ៧១៧៥ Et/២០០៤



## ៣២. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣២.២ ស.រ.ហ.អ.ក ថ្មីដែលបានចេញផ្សាយ ប៉ុន្តែនឹងចូលជាធរមានសម្រាប់ការិយបរិច្ឆេទចាប់ពី ឬបន្ទាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ (ត)

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តស្តង់ដារគណនេយ្យ វិសោធនកម្ម និងការបកស្រាយមានដូចខាងក្រោម៖ (ត)

*ស.រ.ហ.អ.ក ១៧ កិច្ចសន្យាធានារ៉ាប់រង (ត)*

ស្តង់ដារអនុញ្ញាតឱ្យមានជម្រើសរវាងការទទួលស្គាល់ ការផ្លាស់ប្តូរតាមអត្រាអប្បហារនៅក្នុងរបាយការណ៍ចំណូល ឬទទួលស្គាល់ដោយផ្ទាល់នៅក្នុងប្រាក់ចំណូលផ្សេងៗទៀត។ ជម្រើសនេះ គឺទំនងជាឆ្លុះបញ្ចាំងពីរបៀបដែលក្រុមហ៊ុនធានារ៉ាប់រង បកស្រាយពី ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួនក្រោម ស.រ.ហ.អ.ក ៩ ។

ជម្រើសម្យ៉ាងទៀត គឺវិធីសាស្ត្របែងចែកបុព្វលាភ ត្រូវបានអនុញ្ញាតសម្រាប់បំណុលសម្រាប់ការធានារ៉ាប់រងដែលនៅសល់សម្រាប់កិច្ចសន្យារយៈពេលខ្លីដែលត្រូវបានបង្ហាញលើការធានារ៉ាប់រងមិនមានជីវិត។

ការផ្លាស់ប្តូរគំរូនៃការវាស់ស្ទង់ទូទៅដែលគេហៅថា សម្រាប់កិច្ចសន្យាមួយចំនួន "វិធីសាស្ត្រកំលៃអថេរ" ដែលបានបង្ហាញលើការធានារ៉ាប់រងមានជីវិត ដែលអ្នកធ្វើគោលនយោបាយ ចែករំលែកជាការទទួលបានមកវិញនូវតម្លៃមូលដ្ឋាន។ នៅពេលអនុវត្តវិធីកំណត់តម្លៃអថេរ ការប្រែប្រួលតម្លៃទីផ្សារនៃភាគហ៊ុនក្រុមហ៊ុននៃតម្លៃមូលដ្ឋាន ត្រូវបានរួមបញ្ចូលនៅក្នុងចំណេញកម្រិតនៃកិច្ចសន្យាសេវា។ ជាលទ្ធផលក្រុមហ៊ុនធានារ៉ាប់រងដែលប្រើវិធីសាស្ត្រនេះទំនងជាមិនសូវប្រែប្រួលខ្លាំងជាងវិធីសាស្ត្រទូទៅទេ។

ច្បាប់ថ្មីនេះ នឹងប៉ះពាល់ដល់របាយការណ៍ហិរញ្ញវត្ថុ និងសូចនាករលទ្ធផលសំខាន់ៗរបស់ក្រុមហ៊ុនទាំងអស់ដែលបានចេញកិច្ចសន្យាធានារ៉ាប់រង ឬកិច្ចសន្យាវិនិយោគដែលមានលក្ខណៈពិសេសនៃការចូលរួម។

*វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ និង ស.គ.អ.ក ២៨ ការលក់ ឬការចែកចាយនៃទ្រព្យ រវាងអ្នកវិនិយោគនិងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន*

វិសោធនកម្មបញ្ជាក់ពីវិសាលភាពនៃប្រាក់ចំណេញឬខាត ដែលត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនលក់ ឬរួមចំណែកទ្រព្យសកម្មទៅឱ្យក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុនរបស់ខ្លួន។ នៅពេលប្រតិបត្តិការពាក់ព័ន្ធនឹងអាជីវកម្មការចំណេញ ឬខាតត្រូវបានទទួលស្គាល់ពេញលេញ ផ្ទុយទៅវិញ នៅពេលដែលប្រតិបត្តិការទាក់ទងនឹងទ្រព្យសកម្ម ដែលមិនមែនជាអាជីវកម្មនោះការចំណេញឬខាតត្រូវបានទទួលស្គាល់តែទៅលើវិសាលភាពនៃផលប្រយោជន៍ វិនិយោគិនដែលមិនទាក់ទងគ្នានៅក្នុងក្រុមហ៊ុនរួមទុន ឬ ក្រុមហ៊ុនបុត្រសម្ព័ន្ធ។

# ផ្នែកទី ៧

# របាយការណ៍ហិរញ្ញវត្ថុ
# ដែលធ្វើសវនកម្មដោយសវនករឯករាជ្យ

លេខបញ្ជីពាណិជ្ជកម្ម៖
Co.៧១៧៥ Et/២០០៤

១

**កំពង់ផែស្វយ័តភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់ជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ **កំពង់ផែស្វយ័តភ្នំពេញ** ហៅកាត់ថា **"ក.ស.ភ"** សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

### សកម្មភាពចម្បង

ក.ស.ភ គឺជានីតិបុគ្គលដែលមានស្វ័យភាពបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ ហើយបេសកកម្មចម្បងគឺសេវាកម្មកំពង់ផែ និងសេវាដែលពាក់ព័ន្ធផ្សេងទៀត។

ក.ស.ភ មានគោលដៅទទួលរ៉ាប់រងក្នុងការគ្រប់គ្រង ថែទាំ និងធ្វើអាជីវកម្មសេវាកំពង់ផែ ព្រមទាំងអនិស្សរវត្ថុនៃកំពង់ផែ ដើម្បីប្រតិបត្តិការពង្រីក និងអភិវឌ្ឍន៍ សម្រាប់តម្រូវការខាងពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្មទេសចរណ៍ និងអ្នកដំណើរ និងចាត់វិធានការចាំបាច់គ្រប់បែបយ៉ាងឱ្យ ក.ស.ភ រីកចម្រើនលូតលាស់ទៅមុខ។

ក.ស.ភ មានភារកិច្ចជាអាជ្ញាធរ និងប្រតិបត្តិករផែ រួមមាន៖

- ផ្តល់កណ្តាលការកិច្ច នាំនាវាចេញ-ចូលកំពង់ផែ
- ផ្តល់ចំណតនាវា
- ផ្តល់ទីតាំងសម្រាប់នាវាធ្វើការផ្ទុសផុល និងចាក់ប្រេង
- ត្រួតពិនិត្យការប្រតិបត្តិតាមលក្ខណៈបច្ចេកទេស និងជម្រុញកិច្ចការពារសុវត្ថិភាព បរិស្ថាន សណ្តាប់ធ្នាប់ក្នុងមណ្ឌលអាជីវកម្មរបស់កំពង់ផែ
- ត្រួតពិនិត្យឯកសារសម្គាល់នាវា ដើម្បីបំពេញបែបបទនាវាចេញ-ចូលផែ
- បណ្តុះបណ្តាលធនធានមនុស្សផ្នែកនាវាចរណ៍ និងផ្នែកកំពង់ផែតាមរយៈវិទ្យាស្ថាននាវាចរណ៍កម្ពុជា
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែ តាមរយៈសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេស ដើម្បីពង្រីកចំណតផែកុងតឺន័រ ផែទំនិញរាយ-ទំនិញចាក់ធារ ចំណតផែរណប ចំណតផែអ្នកដំណើរ និងទេសចរណ៍
- បង្កើតតំបន់គាំទ្រកំពង់ផែ រួមមាន តំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្ម តំបន់កែច្នៃផលិតផលកសិកម្ម និងតំបន់ភ័ស្តុភារកម្ម
- ចាត់វិធានការនានា ដើម្បីធានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានជាធរមាន ពាក់ព័ន្ធនឹងកំពង់ផែ និងមធ្យោបាយដឹកជញ្ជូននានាតាមផ្លូវទឹក
- លើកដាក់ ផ្ទេរ ផ្ទុក រក្សាស្តុកទំនិញ
- ដឹកជញ្ជូនទំនិញក្នុងទីលានផែ និងរវាងកំពង់ផែ និងតំបន់ផលិតកម្មរោងចក្រ
- ផ្តល់សេវាកម្មភណ្ឌាគារគយមានដែនកំណត់ ភណ្ឌាគារគយបណ្តោះអាសន្ន និងទីលានស្តុកកុងតឺន័រ
- ផ្តល់សេវាកម្មអូសទាញនាវា ពាក់ និងដោះឡូរ
- ផ្តល់សេវាកម្មផ្គត់ផ្គង់ភ័ស្តុភារ ទឹកស្អាត អនាម័យផល់នាវា
- ផ្តល់សេវាកម្មរើ និងច្រកទំនិញដាក់កុងតឺន័រ
- ផ្តល់សេវាកម្មជួសជុល និងថែទាំសំបកកុងតឺន័រ
- ផ្តល់សេវាកម្មចំណតផែទេសចរណ៍ និងអ្នកដំណើរ និងបម្លាយសេវាកម្មផែក្នុងស្រុក

លេខបញ្ជីពាណិជ្ជកម្ម៖
Co.៧១៧៥ Et/២០០៤



**កំពង់ផែស្វយ័តភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល(ត)**

**សកម្មភាពចម្បង (ត)**

នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ក.ស.ភ ទទួលបានជោគជ័យនៅការចុះបញ្ជីនៅលើផ្សារមូលបត្រកម្ពុជា ("ផ.ម.ក")។ ចំនួនភាគហ៊ុនសរុប (មានសិទ្ធិបោះឆ្នោត) មានចំនួន ២០.៦៨៤.៣៦៥ភាគហ៊ុន ដែលមាន ៤.១៣៦.៨៧៣ ជាភាគហ៊ុនប្រភេទ "ក" ដែលមានតម្លៃចារឹក ៤.០០០រៀលក្នុងមួយហ៊ុន។ បន្ទាប់ពីបានចុះបញ្ជីចំនួន៨០% នៃហ៊ុនសរុបត្រូវបានកាន់កាប់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក.ស.ភ បានទទួលសាច់ប្រាក់ពីការលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈបានចំនួន ៥.១៩៣.៩១៥ដុល្លារអាមេរិក និងចំណាយប្រតិបត្តិការចំនួន ៩០១.៥៤០ដុល្លារអាមេរិក។

បុព្វលាភភាគហ៊ុន សំដៅលើចំនួនទឹកប្រាក់លើសពីតម្លៃចារឹក នៃភាគហ៊ុននីមួយៗ ដែលក្រុមហ៊ុនទទួលបានពីការបោះផ្សាយលក់ភាគហ៊ុន និង បន្ទាប់ពីកាត់កងនូវចំណាយប្រតិបត្តិការផ្សេងៗ ដែលកើតចេញផ្ទាល់ពីការបោះផ្សាយភាគហ៊ុន។

## ១២. ទុនបម្រុង

| | ទុនបម្រុងតាមច្បាប់<br>ដុល្លារអាមេរិក | ទុនបម្រុងទូទៅ<br>ដុល្លារអាមេរិក | មូលនិធិអភិវឌ្ឍន៍<br>សហគ្រាស<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|
| **ថ្ងៃទី១ ខែមករា ឆ្នាំ២០១៨** | ៧៩៥.៣១១ | ៧៩៥.៣១១ | ១២.៣៥៥.៦៦១ | ១៣.៩៤៦.២៨៣ |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុក | ២៦៨.០៩២ | ២៦៨.០៩២ | ៤.១៩២.៦៧៥ | ៤.៧២៨.៨៥៩ |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | **១.០៦៣.៤០៣** | **១.០៦៣.៤០៣** | **១៦.៥៤៨.៣៣៦** | **១៨.៦៧៥.១៤២** |
| *(គិតជាពាន់រៀល)* | *៤.២៧២.៧៥៣* | *៤.២៧២.៧៥៣* | *៦៦.៤៩១.២១៥* | *៧៥.០៣៦.៧២១* |
| **ថ្ងៃទី១ ខែមករា ឆ្នាំ២០១៧** | ៥៩០.៩៤១ | ៥៩០.៩៤១ | ១០.១២៦.៧៦៨ | ១១.៣០៨.៦៥០ |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុក | ២០៤.៣៧០ | ២០៤.៣៧០ | ២.២២៨.៨៩៣ | ២.៦៣៧.៦៣៣ |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | **៧៩៥.៣១១** | **៧៩៥.៣១១** | **១២.៣៥៥.៦៦១** | **១៣.៩៤៦.២៨៣** |
| *(គិតជាពាន់រៀល)* | *៣.២១០.៦៧១* | *៣.២១០.៦៧១* | *៤៩.៨៧៩.៨០៣* | *៥៦.៣០១.១៤៥* |

នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រុមប្រឹក្សាភិបាលបានអនុម័តនូវការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងផ្សេងៗ ចំនួន ៤.៧២៨.៨៥៩ ដុល្លារអាមេរិក។

យោងតាមលក្ខន្តិកៈរបស់ ក.ស.ភ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ ២០១៦ ត្រង់មាត្រា៦៦ បានចែងថាប្រាក់ចំណេញ របស់ ក.ស.ភ បន្ទាប់ពីកាត់កងនឹងការខាតយោងពីឆ្នាំមុន (ប្រសិនបើមាន) អាចត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

- សម្រាប់ទុនបម្រុងតាមច្បាប់ ៥%
- សម្រាប់ទុនបម្រុងទូទៅ ៥%
- សមតុល្យនៅសល់សម្រាប់ភាគលាភ និងមូលនិធិសម្រាប់អភិវឌ្ឍន៍សហគ្រាស

## ១៣. ប្រាក់កម្ចី

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **រយៈពេលវែង** | | | | |
| ចំណតផែកុងតឺន័រ LM១៧ | ២៤.៨៣៩.៦៨៩ | ៩៩.៨០៥.៨៧០ | ២៦.៩០៩.៥៦៣ | ១០៨.៦៣៤.៣១០ |
| **រយៈពេលខ្លី** | | | | |
| ចំណតផែកុងតឺន័រ LM១៧ | ២.០៦៩.៨៧៤ | ៨.៣១៧.១៥៦ | ២.០៦៩.៨៧៤ | ៨.៣៥៦.៤៨៥ |
| | ២៦.៩០៩.៥៦៣ | ១០៨.១២៣.០២៦ | ២៨.៩៧៩.៤៣៧ | ១១៦.៩៩០.៧៩៥ |

ក) ចំណតផែកុងតឺន័រ LM១៧ តំណាងឱ្យកិច្ចព្រមព្រៀងខ្ចីបន្តរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក.ស.ក សម្រាប់ការខ្ចីប្រាក់បានមកពី The Import-Export Bank of China ("the Eximbank") ស្ថិតនៅក្រោមកិច្ចព្រមព្រៀងកម្ចីឥណទានអតិថិជនដែលពេញចិត្ត (Preferred Buyer) លេខ (២០១០)២៩(១៣៦) នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១០ សម្រាប់ការសាងសង់ចំណតផែកុងតឺន័រ LM១៧។
ចំនួនទឹកប្រាក់ដែលបានប្រគល់ឱ្យ ក.ស.ក ខ្ចីបន្តនេះ ត្រូវបានចាត់ទុកថាបានឱ្យ ក.ស.ក នៅថ្ងៃដូចគ្នាតាមរូបិយប័ណ្ណ និងក្នុងចំនួនទឹកប្រាក់ដូចដែលបានបើកដោយធនាគារ Eximbank សម្រាប់កម្មវត្ថុផ្តល់ ហិរញ្ញប្បទានដើម្បីអនុវត្តគម្រោង។ ក.ស.ក បង់ការប្រាក់រៀងរាល់ពាក់កណ្តាលឆ្នាំម្តង ដោយអត្រាការប្រាក់ ៤% ក្នុង១ឆ្នាំ។ ប្រាក់កម្ចីបន្តនេះ គឺសម្រាប់រយៈពេល ២០ឆ្នាំ រួមបញ្ចូលទាំងថេរវេលាអនុគ្រោះមិនលើសពី ៧ ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាកិច្ចព្រមព្រៀងកម្ចីនេះ។

ខ) កម្ចី ត្រូវបានចាត់ថ្នាក់ ជាបំណុលហិរញ្ញវត្ថុបានវាស់វែងតាម amortised cost។

គ) កម្ចី ត្រូវសងពីរដងក្នុងមួយឆ្នាំ គឺនៅថ្ងៃទី២០ ខែកុម្ភៈ និងទី២០ ខែសីហា ដែលចាប់ផ្តើមទូទាត់ប្រាក់ដើមពីខែកុម្ភៈ ឆ្នាំ២០១៨ នេះតទៅ។

ឃ) តម្លៃទីផ្សារ នៃកម្ចីរបស់ ក.ស.ក ជាកម្រិត ៣ នៅក្នុងឋានានុក្រមតម្លៃទីផ្សារ។ មិនមានការផ្លាស់ប្តូររវាងកម្រិតនៅក្នុងឋានានុក្រមក្នុងអំឡុងពេលនៃឆ្នាំហិរញ្ញវត្ថុទេ។
បច្ចេកទេសវាយតម្លៃ ត្រូវបានប្រើ និងធាតុចូលសំខាន់ៗ ដើម្បីវាយតម្លៃលើកម្ចី ដែលបានវាស់វែងនៅកម្រិតទី៣ ត្រូវបានពិពណ៌នាដូចខាងក្រោម៖

| បំណុលហិរញ្ញវត្ថុ | ការវាយតម្លៃ និង បច្ចេកទេសប្រើ | ធាតុចូលដែល មិនអាចអង្កេត | អន្តរទំនាក់ទំនងរវាងធាតុចូលដែលមិនសំខាន់ និងតម្លៃទីផ្សារ |
|---|---|---|---|
| កម្ចី | វិធីសាស្ត្រអប្បហារនៃលំហូរសាច់ប្រាក់ | ៨,០០% | អត្រាអប្បហារខ្ពស់ ធ្វើឱ្យតម្លៃទីផ្សារនៃបំណុលហិរញ្ញវត្ថុមានតម្លៃទាប |

ង) កម្ចី ដែលមិនត្រូវបានធ្វើឡើងដោយតម្លៃទីផ្សារ និងចំនួនដែលត្រូវបានគេចាត់ទុកជាតម្លៃប្រហាក់ប្រហែលនៃតម្លៃទីផ្សារមានដូចខាងក្រោម៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ចំនួននៅសល់ ដុល្លារអាមេរិក | តម្លៃទីផ្សារ ដុល្លារអាមេរិក | ចំនួននៅសល់ ដុល្លារអាមេរិក | តម្លៃទីផ្សារ ដុល្លារអាមេរិក |
| កម្ចី (អត្រាថេរ) | ២៦.៩០៩.៥៦៣ | ២៤.៩១៦.៣៦៦ | ២៨.៩៧៩.៤៣៧ | ២៦.៨៣៣.០០៩ |

## ១៣. ប្រាក់កម្ចី (ត)

ច) តារាងខាងក្រោមនេះបង្ហាញ ពីតម្រូវការនៃអត្រាការប្រាក់ដែលមានប្រសិទ្ធិភាព ជាមធ្យមគិតត្រឹមចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗនិងកាលកំណត់ដែលនៅសល់នៃកម្ចីរបស់ ក.ស.ភ ដែលត្រូវបានប៉ះពាល់នឹងហានិភ័យអត្រាការប្រាក់៖

| ៣១ ធ្នូ ២០១៨ | អត្រាការប្រាក់ដែលមានប្រសិទ្ធិភាពអាត្រាក្នុងមួយឆ្នាំ % | តិចជាង ១ឆ្នាំ ដុល្លារអាមេរិក | ១ - ២ ឆ្នាំ ដុល្លារអាមេរិក | ២ - ៥ ឆ្នាំ ដុល្លារអាមេរិក | ច្រើនជាង ៥ឆ្នាំ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| កម្ចី (អត្រាថេរ) | ៤,០០ | ២.០៦៩.៩៧៤ | ២.០៦៩.៩៧៤ | ៦.២០៩.៩២២ | ១៦.៥៥៩.៧៩៣ | ២៦.៩០៩.៦៦៣ |
| **៣១ ធ្នូ ២០១៧** | | | | | | |
| កម្ចី (អត្រាថេរ) | ៤,០០ | ២.០៦៩.៩៧៤ | ២.០៦៩.៩៧៤ | ៦.២០៩.៩២២ | ១៨.៦២៩.៧៦៧ | ២៨.៩៧៩.៦៣៧ |

ឆ) តារាងខាងក្រោមសង្ខេបទម្រង់កាលកំណត់នៃការខ្ចីប្រាក់របស់ ក.ស.ភ នៅចុងការិយបរិច្ឆេទរបាយការណ៍នីមួយៗ ដោយផ្អែកទៅលើកាតព្វកិច្ចទូទាត់សងដែលមិនបានបញ្ចុះតម្លៃតាមកិច្ចសន្យាដូចខាងក្រោម៖

| ៣១ ធ្នូ ២០១៨ | តម្រូវការឬក្នុងរយៈពេលមួយឆ្នាំ ដុល្លារអាមេរិក | ពីមួយទៅប្រាំឆ្នាំ ដុល្លារអាមេរិក | លើសពីប្រាំឆ្នាំ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|
| កម្ចី | ២.០៦៩.៩៧៤ | ៨.២៧៩.៨៩៦ | ១៦.៥៥៩.៧៩៣ | ២៦.៩០៩.៦៦៣ |
| **៣១ ធ្នូ ២០១៧** | | | | |
| កម្ចី | ២.០៦៩.៩៧៤ | ៨.២៧៩.៨៩៦ | ១៨.៦២៩.៧៦៧ | ២៨.៩៧៩.៦៣៧ |

ជ) កម្ចីទាំងអស់ត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក។

## ១៤. សំវិធានធនលើមូលនិធិសោធននិវត្តន៍

ចំនួនទឹកប្រាក់ដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុមានដូចខាងក្រោម៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **កាតព្វកិច្ចសោធននិវត្តន៍** | | | | |
| តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ | ៦២០.៩៦១ | ២.៤៩៩.០២២ | ៥៩៧.៤៦១ | ២.៤១១.៩៥០ |
| តម្លៃទីផ្សារនៃទ្រព្យកម្មសិទ្ធិ | - | - | - | - |
| | ៦២០.៩៦១ | ២.៤៩៩.០២២ | ៥៩៧.៤៦១ | ២.៤១១.៩៥០ |
| **អត្ថប្រយោជន៍ផ្សេងទៀត** | | | | |
| បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) | ២៣.៦៨៣ | ៩៥.១៥៨ | ២១.៨១៨ | ៨៨.០៧៩ |
| បំណុលដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៦៤៤.៦៤៤ | ២.៥៩០.១៨០ | ៦១៩.២៧៩ | ២.៥០០.០២៩ |

បម្រែបម្រួលនៅក្នុងកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ក្នុងកំឡុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | ២០១៨ | ២០១៧ |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| នាថ្ងៃទី១ ខែមករា | ៥៩៧.៤៦១ | ៥១៤.២០៧ |
| ប្រាក់ចំណាយលើសេវាកម្មបច្ចុប្បន្ន | ៤១.២៨៨ | ៣៥.៥៣៦ |
| ចំណាយការប្រាក់ | ៣៦.១២០ | ៣៣.៦២៨ |
| អត្ថប្រយោជន៍បានបង់ | (១៧.៧៥៥) | (១៣.២១៤) |
| ការវាយតម្លៃឡើងវិញ | (៣៦.១៥៣) | ២៧.៣០៤ |
| នាថ្ងៃទី៣១ ខែធ្នូ | ៦២០.៩៦១ | ៥៩៧,៤៦១ |
| *(គិតជាពាន់រៀល)* | *២.៤៩៩.០២២* | ២.៤១១.៩៥០ |

## ១៤. សំវិធានធនលើមូលនិធិសោធននិវត្តន៍(ត)

បម្រែបម្រួលនៅក្នុងអត្ថប្រយោជន៍ផ្សេងទៀតដែលបានកំណត់ក្នុងកំឡុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | ២០១៨<br>ដុល្លារអាមេរិក | ២០១៧<br>ដុល្លារអាមេរិក |
|---|---|---|
| នាថ្ងៃទី១ ខែមករា | ២១.៨១៨ | ១៦.៧៥២ |
| ប្រាក់ចំណាយដែលបានគ្រោង | (២១.៨១៨) | (១៦.៧៥២) |
| ចំណាយបន្ថែម | ២៣.៦៨៣ | ២១.៨១៨ |
| នាថ្ងៃទី៣១ ខែធ្នូ | ២៣.៦៨៣ | ២១.៨១៨ |
| *(គិតជាពាន់រៀល)* | *៩៥.១៥៨* | *៨៨.០៧៩* |

ចំណាយតម្លៃដែលបានទទួលស្គាល់ជាមួយ ប្រាក់បៀវត្ស ប្រាក់កម្រៃ និងចំណាយដែលពាក់ព័ន្ធនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេង មានដូចខាងក្រោម៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **កាតព្វកិច្ចសោធននិវត្តន៍** | | | | |
| ប្រាក់ចំណាយលើសេវាកម្មបច្ចុប្បន្ន | ៤១.២៨៨ | ១៦៧.០១០ | ៣៥.៥៣៦ | ១៤៣.៧៤៣ |
| ចំណាយការប្រាក់ | ៣៦.១២០ | ១៤៦.១០៥ | ៣៣.៦២៨ | ១៣៦.០២៥ |
| **អត្ថប្រយោជន៍ផ្សេងទៀត** | | | | |
| ចំណាយបន្ថែម | ២៣.៦៨៣ | ៩៥.៧៩៨ | ២១.៨១៨ | ៨៨.២៥៤ |
| | ១០១.០៩១ | ៤០៨.៩១៣ | ៩០.៩៨២ | ៣៦៨.០២២ |

ក) កាតព្វកិច្ចសោធននិវត្តន៍

ការសន្មត់លើការគណនា actuarial ត្រូវបានកំណត់ដូចខាងក្រោម៖

| | |
|---|---|
| អត្រាអប្បហារ (១) | ៦,០០% (ឆ្នាំ២០១៧៖៦,២៥%) |
| | ២០% (ឆ្នាំ២០១៧៖២១%) ក្នុង១ឆ្នាំ និងថយចុះតាមលំដាប់៥%រាល់ឆ្នាំរហូត |
| អត្រាកំណើនប្រាក់បៀវត្ស | ដល់ឆ្នាំ២០៣៤ សម្រាប់បៀវត្សគោល និងបៀវត្សសរុប |
| អត្រាសេវាន (២) | តារាងអាយុរបស់ប្រទេសថៃឆ្នាំ២០១៧ |
| ពិការភាព | ១០% (ឆ្នាំ២០១៧៖១០%) នៃអត្រាសេវាន |
| អត្រាបុគ្គលិកលាលែង | ១,១% (ឆ្នាំ២០១៧៖១,១%) |

(១) អត្រាអប្បហារ

ដោយសារព័ត៌មានអំពីប័ណ្ណបំណុលពាណិជ្ជកម្ម ឬប័ណ្ណបំណុលរបស់រាជរដ្ឋាភិបាល មិនទាន់មាន ដូច្នេះ ក.ស.ភ បានកំណត់ ដោយប្រើប្រាស់អត្រាការប្រាក់បញ្ញើរយៈពេលវែងជាមធ្យមរបស់ធនាគារចម្បងៗនៅកម្ពុជា។

## ១៤. សំវិធានធនលើមូលនិធិសោធននិវត្តន៍(ត)

ក) កាតព្វកិច្ចសោធននិវត្តន៍ (ត)

(២) អត្រារស់រាន

ការសន្មតនៃអាយុរស់នៅនាពេលអនាគត គឺផ្អែកលើតារាងស្ថិតិអាយុដែលបានផ្សាយជាសាធារណៈ។ ដោយសារតែតារាងនេះមិនមាននៅក្នុងកម្ពុជា ក.ស.ភ បានប្រើប្រាស់តារាងស្ថិតិអាយុរបស់ប្រទេសថៃ ឆ្នាំ២០១៧ ដោយមិនមានកែប្រែឡើយ (សូមមើលព័ត៌មានការប្រៀបធៀបខាងក្រោម)។ អត្រានេះគឺបានបោះពុម្ពផ្សាយនៅឆ្នាំ ២០១៧។ ដោយសារតែនិយោជិតដែលធ្វើការក្នុងវិស័យផ្លូវការ មានអាយុកាលរស់នៅល្អជាងប្រជាជនទូទៅសំវិធានធនត្រូវបានធ្វើឡើង។

អាយុប៉ាន់ស្មាននៅពេលកើត (ប្រទេសកម្ពុជា)

| | |
|---|---|
| បុរស | ៦១ឆ្នាំ |
| ស្ត្រី | ៦៤ឆ្នាំ |

អាយុប៉ាន់ស្មាននៅពេលកើត ផ្អែកតាមអត្រាប្រទេសថៃ TM២០១៧

| | |
|---|---|
| បុរស | ៦៦ឆ្នាំ |
| ស្ត្រី | ៧៤ឆ្នាំ |

ការវិភាគរំញោច

- ការថយចុះនូវអត្រាអប្បហាចំនួន ០,២៥% អាចធ្វើឱ្យកើនឡើងគម្រោងអត្ថប្រយោជន៍ដែលបានកំណត់ចំនួន ២,២៧%។ ការកើនឡើងនូវអត្រាអប្បហាចំនួន ០,២៥% អាចធ្វើឱ្យថយចុះគម្រោងអត្ថប្រយោជន៍ដែលបានកំណត់ចំនួន ២,១៩%។
- ការថយចុះនូវអត្រាកើនឡើងនៃប្រាក់បៀវត្ស ចំនួន០,៥០% អាចធ្វើឱ្យកើនឡើងគម្រោងអត្ថប្រយោជន៍ដែលបានកំណត់ចំនួន ៤,០៦%។ ការកើនឡើងនូវអត្រានៃប្រាក់បៀវត្សចំនួន០,៥០% អាចធ្វើឱ្យកើនឡើងគម្រោងអត្ថប្រយោជន៍ ដែលបានកំណត់ចំនួន ៤,៣៣%។

ខ) អត្ថប្រយោជន៍ផ្សេងៗ

ក.ស.ភ បានកាត់ទុកចំនួន ៣%នៃមូលដ្ឋានប្រាក់បៀវត្សប្រចាំខែ សម្រាប់បង់ទៅឱ្យបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) ជាប្រចាំឆ្នាំ។ បន្ទាប់ពីចូលនិវត្តន៍និយោជិតកម្មករ និងទទួលបានប្រាក់ចូលនិវត្តន៍ប្រចាំខែ ពីបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលវិញ។

## ១៥. កិច្ចសន្យាបំណុល

| | ២០១៨ | |
|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **បំណុលរយៈពេលវែង** | | |
| ចំណូលពន្យារ | ១៤.៦២៥.០០០ | ៥៨.៧៦៣.២៥០ |
| **បំណុលរយៈពេលខ្លី** | | |
| ចំណូលពន្យារ | ២២៥.០០០ | ៩០៤.០៥០ |

## ១៥. កិច្ចសន្យាបំណុល (ត)

ក) កិច្ចសន្យាបំណុល គឺជាចំណូលពន្យារ ដែលកើតឡើងពីកិច្ចសន្យាជួលដែលមានរយៈពេល ៥០ឆ្នាំ ជាមួយក្រុមហ៊ុនចៀន ពើង តៃ គ្រុប។ តម្លៃសរុប ត្រូវបានកាត់បន្ថយដោយប្រើវិធីរំលស់ថេរសម្រាប់រយៈពេល ៥០ឆ្នាំ។

ខ) ចំណូលនេះនឹងរំពឹងទុកថា នឹងអាចទទួលស្គាល់នៅពេលអនាគត ដែលទាក់ទងទៅនឹងកាតព្វកិច្ចអនុវត្ត ដែលមិនបានអនុវត្តទាំងស្រុង (ឬបានខ្លះ) នៅចុងការិយបរិច្ឆេទនៃរបាយការណ៍គឺចំនួន ៣០០.០០០ ដុល្លារ អាមេរិក ជារៀងរាល់ឆ្នាំ។

## ១៦. គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **គណនីអ្នកផ្គត់ផ្គង់** | | | | |
| ភាគីទីបី | ៤៩៤.២៥៩ | ១.៩៨៥.៩៣៣ | ៤០៦.៧៩៥ | ១.៦៤២.២៣២ |
| **គណនីត្រូវបង់ផ្សេងៗ** | | | | |
| ការប្រាក់ត្រូវបង់ | ៣៩៧.៦៦៥ | ១.៥៩៧.៨១៨ | ៤៤១.៤២២ | ១.៧៨២.០២១ |
| បុរេប្រទានពីអ្នកផ្គត់ផ្គង់ | ៣៥០.៥៧៩ | ១.៤០៨.៦២៦ | ២៤៨.១១៤ | ១.០០១.៦៣៦ |
| ភាគលាភត្រូវបង់ | - | - | ៥២.៤៦៧ | ២១១.៨០៥ |
| ភាគលាភធានាត្រូវបង់ | ២៦៣.៥៧៤ | ១.០៥៥.០៤០ | ២៦២.៩៤៥ | ១.០៦១.៥២៥ |
| ពន្ធត្រូវបង់ផ្សេងៗ | ១១៨.៨០៧ | ៤៧៧.៣៦៧ | ១៥៣.៣៥៩ | ៦១៩.០៥៤ |
| បំណុលត្រូវបង់ផ្សេងៗ | ១.០៦៧.០៦៦ | ៤.២៨៧.៤៧១ | ៩៤៥.៧៨៣ | ៣.៨១៨.១២៦ |
| | ២.១៩៧.៦៩១ | ៨.៨៣០.៣២២ | ២.១០៤.០៥០ | ៨.៤៩៤.២១១ |
| | ២.៦៩១.៩៥០ | ១០.៨១៦.២៥៥ | ២.៥១០.៨៤៥ | ១០.១៣៦.៤៤៣ |

ក) គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ ត្រូវបានចាត់ថ្នាក់ជាបំណុលហិរញ្ញវត្ថុ វាស់វែងតាម amortised cost។

ខ) គណនីអ្នកផ្គត់ផ្គង់ គឺមិនត្រូវបានគិតការប្រាក់ ហើយលក្ខខណ្ឌឥណទានពាណិជ្ជកម្មធម្មតាដែលផ្តល់ដោយ ក.ស.ក មានរយៈពេលចាប់ពី ១ ដល់ ២ខែ (២០១៧៖១ ដល់ ២ខែ)។

គ) ភាគលាភមានការធានាគឺមានធានាយ៉ាងតិចបំផុតចំនួន ៥% ក្នុងមួយឆ្នាំ ដោយគិតតាមតម្លៃ IPO សម្រាប់រយៈពេលយ៉ាងហោចណាស់ ៥ ឆ្នាំចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០។ តម្លៃបច្ចុប្បន្ននៃភាគលាភមានការធានា ទាំងនេះមានចំនួន ៩៣៦.១៤៥ ដុល្លារអាមេរិក។ ត្រូវបានគេរំពឹងថានឹងត្រូវបានទូទាត់ក្នុងរយៈពេល ៥ ឆ្នាំទៅឱ្យភាគហ៊ុនិក ប្រភេទ "ក" ។

ឃ) ទម្រង់ហានិភ័យរូបិយប័ណ្ណនៃគណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗមានដូចខាងក្រោម៖

| | ២០១៨ | ២០១៧ |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ដុល្លារអាមេរិក | ១.៣៧៣.២៨៦ | ១.១៩២.៨២៣ |
| ខ្មែររៀល | ១.៣១៨.៦៦៤ | ១.៣១៨.០៦២ |
| | ២.៦៩១.៩៥០ | ២.៥១០.៨៤៥ |

## ១៦. គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗ (ត)

ង) ទុប្រង់កាលបរិច្ឆេទនៃគណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវបង់ផ្សេងៗរបស់ ក.ស.ក នៅចុងការិយបរិច្ឆេទនៃរបាយការណ៍ដោយផ្អែកទៅលើកាតព្វកិច្ចទូទាត់សង ដែលមិនទាន់ទូទាត់ ត្រូវសងត្រឡប់តាមតម្រូវការឬក្នុងរយៈពេលមួយឆ្នាំ។

## ១៧. កតិសន្យា

ក) ភតិសន្យាជួល

<u>ក.ស.ភ ជាអ្នកជួល</u>

ក.ស.ភ បានចុះកិច្ចសន្យាជួលដែលមិនអាចលុបចោលមុនកាលកំណត់ នឹងត្រូវពិនិត្យផ្លាស់ប្តូរប្រចាំឆ្នាំ ដើម្បីធ្វើការគណនាថ្លៃជួលប្រចាំខែ ដោយយោងទៅតាមអត្រាទីផ្សារ។ នៅចុងឆ្នាំ ក.ស.ភ នៅសល់កាតព្វកិច្ចត្រូវបង់ក្រោមកិច្ចសន្យាជួលដែលមិនអាចលុបចោលមុនកាលកំណត់៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| មិនលើសពី ១ឆ្នាំ | ២.៣២៤ | ៩.៣៣៨ | ៥៥.៧៦៧ | ២២៥.១៣១ |
| លើសពី ១ឆ្នាំ មិនលើសពី ៥ឆ្នាំ | - | - | ២.៦៣៣ | ១០.៦២៩ |
| | ២.៣២៤ | ៩.៣៣៨ | ៥៨.៤០០ | ២៣៥.៧៦០ |

<u>ក.ស.ភ ជាម្ចាស់</u>

ក.ស.ភ បានចុះកិច្ចសន្យាជួលដែលមិនអាចលុបចោលមុនកាលកំណត់ លើទ្រព្យសកម្មវិនិយោគមួយចំនួនសម្រាប់រយៈពេល ៥០ឆ្នាំ។ ការជួលនេះ មិនមានឃ្លាមួយណាមួយ ដើម្បីធ្វើឱ្យការពិនិត្យឡើងវិញលើថ្លៃជួលប្រចាំឆ្នាំរាស្រ័យលើលក្ខខណ្ឌទីផ្សារទូទៅនោះទេ។

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| មិនលើសពី ១ឆ្នាំ | ៣០០.០០០ | ១.២០៥.៤០០ | - | - |
| លើសពី ១ឆ្នាំ មិនលើសពី ៥ឆ្នាំ | ១.៥០០.០០០ | ៦.០២៧.០០០ | - | - |
| លើសពី ៥ឆ្នាំ | ១៣.០៥០.០០០ | ៥២.៤៣៤.៩០០ | - | - |
| | ១៤.៨៥០.០០០ | ៥៩.៦៦៧.៣០០ | - | - |

ខ) កតិសន្យាមូលធន

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ការចំណាយមូលធនទាក់ទងនឹងការទិញ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | | | |
| បានចុះកិច្ចសន្យា ប៉ុន្តែមិនទាន់បានទទួលពីអ្នកផ្គត់ផ្គង់ | ៤៧៨.៨២៤ | ១.៩២៣.៩១៥ | ២៦៧.៧៥០ | ១.០៨០.៩០៧ |

## ១៨. ចំណូល

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណូលលើកដាក់ក្រោមដងយោង | ៨.៧៤៦.១០៤ | ៣៥.៣៧៧.៩៩១ | ៧.៧៣៧.៤៦៩ | ៣១.២៩៨.០៦២ |
| ចំណូលលើកដាក់លើទីលាន | ៧.៣៥០.៩៨៧ | ២៩.៧៣៤.៧៤២ | ៦.៥៩៨.១០៩ | ២៦.៦៨៩.៣៥១ |
| ចំណូលពីកិច្ចការផែ | ៣.៤១៣.៧៩៧ | ១៣.៨០៨.៨០៩ | ៣.១៦៥.៦១៩ | ១២.៨០៤.៩២៩ |
| ចំណូលពីច្រកទ្វារ | ៧៨៧.៣៩៧ | ៣.១៨៥.០២១ | ៦៧០.៣២៩ | ២.៧១១.៤៨១ |
| ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ | ៣៦៩.៨៩៣ | ១.៤៩៦.២១៧ | ៤២៦.០៧៣ | ១.៧២៣.៤៦៥ |
| ចំណូលពីថ្លៃឈ្នួលថ្លឹងកុងតឺន័រ | ៦.៧៣៥ | ២៧.២៤៣ | ២៨.១២៩ | ១១៣.៧៨២ |
| ចំណូលពីការរៀបចំទំនិញ | ១៤.៣០០ | ៥៧.៨៤៤ | - | - |
| ចំណូលពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ | ៣១.៣៤៦ | ១២៦.៧៩៥ | ៣៨.៤៧៥ | ១៥៥.៦៣១ |
| ចំណូលពីការវាស់ស្ទង់ | - | - | ១៩១.១៤៦ | ៧៧៣.១៨៦ |
| ចំណូលពីការដឹកជញ្ជូន | ២.១៤៣ | ៨.៦៦៨ | ៧២៨ | ២.៩៤៥ |
| ចំណូលពីការជួសជុល និងថែទាំកុងតឺន័រ | ២២៦ | ៩១៤ | ២១៩ | ៨៨៥ |
| | ២០.៧២២.៩២៨ | ៨៣.៨២៤.២៤៤ | ១៨.៨៥៦.២៩៦ | ៧៦.២៧៣.៧១៧ |

ចំណូលដែលបានមកពីសេវាកម្ម គឺត្រូវទទួលស្គាល់ នៅពេលដែលសេវាកម្មត្រូវបានប្រគល់ជូន អតិថិជន និងការទទួលយកដោយអតិថិជន។

មិនមានការផ្លាស់ប្តូរហិរញ្ញប្បទានសំខាន់ៗ នៅក្នុងចំណូលដែលកើតឡើងពីសេវាកម្មដែលបានផ្តល់ឱ្យនោះទេ ដោយសេវាកម្មដែលត្រូវបានធ្វើឡើងនៅលើលក្ខខណ្ឌឥណទានធម្មតាដែលមិនលើសពី ១២ខែ។

## ១៩. ថ្លៃដើមសេវាកម្ម

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ថ្លៃដងយោង | ១.៧៣៥.៨០០ | ៧.០២១.៣១១ | ១.៥១៥.៩៣៨ | ៦.១៣១.៩៦៩ |
| រំលស់ | ២.៦១៩.៦៧៧ | ១០.៥៩៦.៥៩៣ | ២.៥០៨.៨៥៨ | ១០.១៤៨.៣៣១ |
| ប្រេងឥន្ធនៈ | ៨៣៨.៧៩០ | ៣.៣៩២.៩០៦ | ៦០៨.៤៧៨ | ២.៤៦១.២៩៤ |
| ប្រាក់បៀវត្ស និង ប្រាក់ឈ្នួល | ១.៣៦១.០១០ | ៥.៥០៥.២៨៥ | ១.១៩៨.០០១ | ៤.៨៤៥.៩១៤ |
| ចំណាយការថែទាំ និងជួសជុល | ៥១០.៥៥៦ | ២.០៦៥.១៩៧ | ៣៨៤.២៩៤ | ១.៥៥៤.៤៦៩ |
| ចំណាយលើការគ្រប់គ្រងអាជីវកម្មខ្សាច់ | ៦.៦០៨ | ២៦.៧៣១ | ៣៨.៥០៧ | ១៥៥.៧៦១ |
| ចំណាយលើការវាស់ស្ទង់ | - | - | ៧.៤៧២ | ៣០.២២៤ |
| ចំណាយការថែទាំ និងជួសជុលកុងតឺន័រ | ១៧៧ | ៧១៦ | ១៨៧ | ៧៥៦ |
| ចំណាយផ្សេងៗ | ១៦២.១៦៤ | ៦៥៥.៩៥៤ | ១៩៩.០៥៩ | ៨០៥.១៩៤ |
| | ៧.២៣៤.៧៨២ | ២៩.២៦៤.៦៩៣ | ៦.៤៦០.៧៩៤ | ២៦.១៣៣.៩១២ |

## ២០. ចំណូលផ្សេងៗ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណូលពីការជួល | ៦៥៧.៥៤៣ | ២.៦៥៩.៨០២ | ៣១៧.៧០៨ | ១.២៨៥.១២៩ |
| ចំណូលពីការប្រាក់ | ៦១៥.៥០១ | ២.៤៨៩.៧០២ | ២២៦.០៥១ | ៩១៤.៣៧៦ |
| លុបចោលលើឱនភាពនៃការខាតបង់នៃគណនីពាណិជ្ជដែលបានកត់ត្រា | ១១៤.៨៤៧ | ៤៦៤.៧១៨ | - | - |
| ចំណូលផ្សេងៗ | ៦៩.៧១៧ | ២៨២.០០៥ | ៦០.២០៩ | ២៤៣.៥៤៦ |
| | ១.៤៥៧.៦៥៨ | ៥.៨៩៦.២២៧ | ៦០៣.៩៦៨ | ២.៤៤៣.០៥១ |

ក) ចំណូលពីការជួល

ចំណូលពីការជួល ត្រូវបានទទួលស្គាល់តាមមូលដ្ឋានតម្លៃថេរ ធៀបនឹងរយៈពេលជួលសរុបនៃរយៈពេលជួលដែលកំពុងបន្ត។

ខ) ចំណូលពីការប្រាក់

ចំណូលពីការប្រាក់ ត្រូវបានទទួលស្គាល់នៅពេលវាត្រូវបានបង្ករ ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ដែលមានប្រសិទ្ធភាព។

## ២១. ចំណាយទូទៅ និងចំណាយរដ្ឋបាល

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗ | ៣.៥០៣.៤០២ | ១៤.១៧២.៨៧៩ | ៣.១៤៦.១៧១ | ១២.៧២៦.២៦២ |
| ចំណាយទឹក ភ្លើង និង ប្រេងឥន្ធនៈ | ៤៤០.០៧៩ | ១.៧៨០.១២០ | ៤៤០.៥០០ | ១.៧៨១.៨២៣ |
| រំលស់ | ៣៤៣.៥៧៨ | ១.៣៨៩.៧៧៣ | ៣៨៥.៣១៧ | ១.៥៥៨.៦០៧ |
| កម្រៃសម្រាប់ក្រុមប្រឹក្សាភិបាល | ២០៩.១៩៧ | ៨៤៦.២០២ | ២០៩.២២០ | ៨៤៦.២៩៥ |
| ចំណាយសន្តិសុខ | ៤៩២.១៦៨ | ១.៩៩០.៨២០ | ៣៨៦.៦១៣ | ១.៥៦៣.៨៥០ |
| ចំណាយផ្គត់ផ្គង់សម្ភារៈការិយាល័យ | ៩១.៣៤៨ | ៣៦៩.៥០៣ | ១០២.៥៧១ | ៤១៤.៩០០ |
| ចំណាយលើការកំសាន្ត | ២១៦.២៥៤ | ៨៧៤.៧៤៧ | ១៩២.០២៣ | ៧៧៦.៧៣៣ |
| ចំណាយការជួសជុល និងថែទាំ | ១៤៦.៧៤៤ | ៥៩៣.៥៧៩ | ១៣៧.១៨១ | ៥៥៤.៨៩៧ |
| ចំណាយទំនាក់ទំនងផ្សេងៗ | ៥៩.៥៧៨ | ២៤០.៩៩៣ | ៥៣.៨៤៦ | ២១៧.៨០៧ |
| ចំណាយលើថ្លៃវិជ្ជាជីវៈ | ៣៩.០៥៧ | ១៥៧.៩៨៦ | ៥១.២១៨ | ២០៧.១៧៧ |
| ចំណាយលើការធ្វើដំណើរ | ៥៦.៦០៤ | ២២៨.៩៦៣ | ១០៩.៧២៥ | ៤៤៣.៨៣៨ |
| ចំណាយផ្សេងៗ | ៣៦៦.១៨០ | ១.៤៨១.១៩៧ | ៣១៦.១២៤ | ១.២៧៨.៧២០ |
| ការជម្រះចេញពីបញ្ជីនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៨.៧៦៨ | ៣៥.៤៦៧ | - | - |
| ការខាតបង់លើការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥២.២៤៦ | ២១១.៣៣៥ | - | - |
| ចំណាយពន្ធផ្សេងៗ | ៦៧.៦៦៩ | ២៧៣.៧២១ | ៣០.៧១០ | ១២៤.២២២ |
| | ៦.០៩៣.២៧២ | ២៤.៦៤៧.២៨៥ | ៥.៥៦១.២១៩ | ២២.៤៩៥.១៣១ |

## ២២. ចំណាយហិរញ្ញប្បទាន

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយការប្រាក់លើកម្ចី | ១.០៩៤.៧២៩ | ៤.៤២៨.១៧៩ | ១.១៩៩.១៨៥ | ៤.៦៨៨.៩០៣ |
| ផលប៉ះពាល់នៃភាគលាភធានាត្រូវបង់ | ៧៥.៤៩៨ | ៣០៥.៣៨៥ | ៥៥.៥៨២ | ៣៨៦.៦៣០ |
| | ១.១៧០.២២៧ | ៤.៧៣៣.៥៦៤ | ១.២៥៤.៧៦៧ | ៥.០៧៥.៥៣៣ |

## ២៣. ចំណាយពន្ធលើប្រាក់ចំណេញ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណាយពន្ធលើប្រាក់ចំណេញ៖ | | | | |
| ពន្ធប្រាក់ចំណេញក្នុងគ្រា | ២.១៨១.០២០ | ៨.៨២២.២២៦ | ៥៤៣.៧៩១ | ២.៣៦១.៤៣៥ |
| (លើស)/ខ្វះ ទទួលស្គាល់ចំណូលពន្ធកាលពីឆ្នាំមុន | (៥៩.១៥៧) | (២៣៩.២៩០) | ៧.២៦៥ | ២៩.៣៨៦ |
| | ២.១២១.៨៦៣ | ៨.៥៨២.៩៣៦ | ៥៥១.០៥៦ | ២.៣៩០.៨២១ |
| ពន្ធពន្យារ ៖ | | | | |
| ភាពខុសគ្នាបណ្តោះអាសន្ន | (២.៦៧៤.២២២) | (១០.៨១៧.២២៨) | ២៣០.៥៩៥ | ៩៣២.៧៥៧ |
| ខ្វះ ទទួលស្គាល់ចំណូលពន្ធកាលពីឆ្នាំមុន | ១៣៣.៩២៦ | ៥៤១.៧៣១ | - | - |
| | (២.៥៤០.២៩៦) | (១០.២៧៥.៤៩៧) | ២៣០.៥៩៥ | ៩៣២.៧៥៧ |
| | (៤១៨.៤៣៣) | (១.៦៩២.៥៦១) | ៧៨១.៦៥១ | ៣.៣២៣.៥៧៨ |

ផ្អែកលើច្បាប់ស្តីពីសារពើពន្ធរបស់ព្រះរាជាណាចក្រកម្ពុជា ក.ស.ភ មានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញក្នុងអត្រា ២០% (២០១៧៖២០%) លើប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមាក្នុងអត្រា ១% (២០១៧៖១%) នៃចំណូលសរុប ប្រសិនបើមួយណាមានចំនួនច្រើនជាង។ បន្ទាប់ពីបានចុះបញ្ជីជាផ្លូវការនៅលើផ្សារមូលបត្រកម្ពុជា ក.ស.ភ មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តពន្ធដារដូចខាងក្រោម៖

- ការកាត់បន្ថយអត្រាពន្ធលើប្រាក់ចំណេញ និងពន្ធកាត់ទុកចំនួន៥០% (ជាពិសេសសម្រាប់ពន្ធកាត់ទុកលើការប្រាក់ និង/ឬ លទ្ធផលនៃភាគលាភពីអ្នកកាន់ និង/ឬ ការទិញ លក់ភាគហ៊ុនរដ្ឋាភិបាល មូលធន និងបំណុល) សម្រាប់រយៈពេលបីឆ្នាំដោយអនុលោមតាមអនុក្រឹត្យលេខ ១អនក្រ.បក ចេញដោយរាជរដ្ឋាភិបាលកម្ពុជានាថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥។ នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ គណៈកម្មការមូលបត្រកម្ពុជា ("គ.ម.ក") បានផ្ញើលិខិតទៅកាន់អគ្គនាយកដ្ឋានពន្ធដារ ដែលបញ្ជាក់ថា ក.ស.ភ នឹងមានសិទ្ធិទទួលបាននូវការលើកទឹកចិត្តពន្ធដែលមានសុពលភាពចាប់ពីឆ្នាំ២០១៦តទៅ។

## ២៣. ចំណាយពន្ធលើប្រាក់ចំណេញ (ត)

នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ ក.ស.ភ បានដាក់លិខិតទៅ គ.ម.ក ដើម្បីសុំការសម្របសម្រួលទៅអគ្គនាយកដ្ឋានពន្ធដារ ដើម្បីទទួលបានការអនុម័តជាលាយលក្ខណ៍អក្សរលើការកាត់បន្ថយពន្ធចំនួន ៥០% នៃពន្ធលើប្រាក់ចំណេញរបស់ ក.ស.ភ សម្រាប់ឆ្នាំ២០១៦។ នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ គ.ម.ក បានដាក់លិខិតទៅ កាន់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីទទួលបានការអនុម័តជាលាយលក្ខណ៍អក្សរ ទៅលើការលើកទឹកចិត្តពន្ធដារនេះ។ ការស្នើសុំនេះ ទទួលបានការអនុម័តពីអគ្គនាយកដ្ឋានពន្ធដារ នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ជាមួយការលើកទឹកចិត្តពន្ធដារ ៣ឆ្នាំ ដែលចាប់ពីឆ្នាំ២០១៦ តទៅ។

- ការពន្យារពេលបណ្តោះអាសន្ន លើប្រាក់រំដោះពន្ធលើប្រាក់ចំណេញ សម្រាប់រយៈពេល ៣ឆ្នាំ យោងតាមប្រកាសលេខ ៨៥៥ សហវ.ប្រក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥។ នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ គណៈកម្មការមូលបត្រកម្ពុជា ("គ.ម.ក") បានផ្ញើលិខិតទៅកាន់អគ្គនាយកដ្ឋានពន្ធដារ ដែលបញ្ជាក់ថា ក.ស.ភ នឹងមានសិទ្ធិទទួលបាននូវការលើកទឹកចិត្តពន្ធដែលមានសុពលភាពចាប់ពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ តទៅ។

តួលេខក្នុងការសម្របសម្រួលរវាងចំណាយពន្ធ និងផលគុណនៃប្រាក់ចំណេញគណនេយ្យនឹងអត្រាពន្ធដាររបស់ ក.ស.ភ មានដូចខាងក្រោម៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ប្រាក់ចំណេញមុនពេលបង់ពន្ធ | ៧.៦៨២.៣០៥ | ៣១.០៧៤.៩២៤ | ៦.១៨៣.៤៨៤ | ២៥.០១២.១៩២ |
| ពន្ធគណនាតាមអត្រាពន្ធស្របច្បាប់ ២០% (២០១៧: ២០%) | ១.៥៣៦.៤៦១ | ៦.២១៤.៩៨៥ | ១.២៣៦.៦៩៧ | ៥.០០២.៤៣៨ |
| *ឥទ្ធិពលពន្ធដារទៅលើ៖* | | | | |
| ចំណាយដែលមិនអាចកាត់កងបាន | ១៥១.៣៥៧ | ៦១២.២៣៩ | ២៨៧.៥២៨ | ១.១៦៣.០៥១ |
| ការលើកទឹកចិត្តពន្ធដារនិងប្រាក់ឧបត្ថម្ភ | (២.១៨១.០២០) | (៨.៨២២.២២៦) | (៧០៩.៨៣៩) | (២.៨៧១.២៩៧) |
| សំវិធានធនខ្វះលើពន្ធនៃប្រាក់ចំណេញក្នុងការិយបរិច្ឆេទមុន | | | | |
| ចំណូលពន្ធ | (៥៩.១៥៧) | (២៣៩.២៩០) | ៧.២៦៥ | ២៩.៣៨៦ |
| ពន្ធពន្យារ | ១៣៣.៩២៦ | ៥៤១.៧៣១ | - | - |
| ចំណាយពន្ធសរុប | (៤១៨.៤៣៣) | (១.៦៩២.៥៦១) | ៨២១.៦៥១ | ៣.៣២៣.៥៧៨ |

## ២៤. ចំណេញក្នុងមួយភាគហ៊ុន

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ចំណេញសម្រាប់ផ្តល់ដល់ភាគហ៊ុនិកធម្មតា | ៨.១៣៦.៨៩១ | ៣២.៦១៣.៧២៥ | ៥.៣៣៤.៥២៥ | ២១.៥៧៨.១៦៥ |
| ចំនួនភាគហ៊ុនធម្មតាដែលបានដាក់លក់គិតជាមធ្យម | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ | ២០.៦៨៤.៣៦៥ |
| ចំណេញក្នុងមួយភាគហ៊ុនគោល | ០,៣៩ | ១,៥៩ | ០,២៦ | ១,០៥ |
| ចំណេញក្នុងមួយភាគហ៊ុនដែលថយចុះ | ០,៣៩ | ១,៥៩ | ០,២៦ | ១,០៥ |

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ត្រូវបានគណនាដោយកែប្រែចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមានដោយសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។

គិតត្រឹមដំណាច់ការិយបរិច្ឆេទនេះ ក.ស.ភ មិនមានភាគហ៊ុនដែលមានសក្តានុពលអាចផ្ទេរទៅជាភាគហ៊ុនធម្មតានោះទេ។ ដូចនេះចំណេញក្នុងមួយភាគហ៊ុនថយចុះ គឺមានតម្លៃស្មើនឹងចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន។

## ២៥. ភាគលាភត្រូវបង់

នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រុមប្រឹក្សាភិបាលបានអនុម័តនៅក្នុងការចែកភាគលាភសម្រាប់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ទៅកាន់ភាគហ៊ុនិក តាមប្រភេទភាគហ៊ុនដូចខាងក្រោម៖

- ភាគហ៊ុនិកដែលកាន់ភាគហ៊ុនប្រភេទ "ក" ទទួលបានភាគលាភធានាសរុបចំនួន ២៦២.៩៤៩ដុល្លារអាមេរិក(សមមូលទៅនឹង១.០៥១.៧៩៦.០០០រៀល) និង ភាគលាភបន្ថែមចំនួន ៥២.៤៦៧ដុល្លារអាមេរិក នឹងត្រូវបានទូទាត់នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨។ ភាគលាភនោះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧។
- ភាគហ៊ុនិកដែលកាន់ភាគហ៊ុនប្រភេទ "ខ" ទទួលបានភាគលាភសរុបចំនួន ៥៥៣.២០៣ដុល្លារអាមេរិក (សមមូលទៅនឹង ២.២៤២.៧០៨.០០០រៀល) នឹងត្រូវបានទូទាត់នៅថ្ងៃទី១១ ខែកក្កដាឆ្នាំ២០១៨។

## ២៦. ការលាតត្រដាងពីភាគីពាក់ព័ន្ធ

(ក) ភាគីមួយត្រូវបានចាត់ទុកថាជាសម្ព័ន្ធញាតិជាមួយ ក.ស.ភ ប្រសិនបើភាគីនោះមានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោល ឬមានឥទ្ធិពលជាខ្លាំងលើភាគីមួយទៀតក្នុងការសម្រេចចិត្ត ហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬបើក្រុមហ៊ុន និងភាគីនោះស្ថិតក្រោមការគ្រប់គ្រង ឬមានឥទ្ធិពលជាខ្លាំង។ សម្ព័ន្ធញាតិ អាចជារូបវន្ត ឬនីតិបុគ្គល។

ថ្នាក់ដឹកនាំសំខាន់ៗរបស់ក្រុមហ៊ុនរួមមានបុគ្គលទាំងឡាយណា (រួមបញ្ចូលទាំងអគ្គនាយក ក.ស.ភ) ដែលមានសិទ្ធិ និងទំនួលខុសត្រូវក្នុងការគ្រោង ដឹកនាំ និងគ្រប់គ្រង សកម្មភាពរបស់ ក.ស.ភ ដោយផ្ទាល់ ឬដោយប្រយោល។

## ២៦. ការលាតត្រដាងពីភាគីពាក់ព័ន្ធ (ត)

(ខ) ក.ស.ភ មានប្រតិបត្តិការជាមួយនឹងសម្ព័ន្ធញាតិក្នុងការិយបរិច្ឆេទនេះដូចខាងក្រោម៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| <u>ញាតិសម្ព័ន្ធ</u> | | | | |
| ក.ស.ហ | | | | |
| ចំណាយការប្រាក់ | ១.០៩៤.៧២៩ | ៤.៤២៨.១៧៩ | ១.១៥៩.១៨៥ | ៤.៦៨៨.៩០៣ |
| <u>ក.ស.ហ និង ក.ស.ជ</u> | | | | |
| អំណោយសទ្ធាទាន | ៤១.៨១៣ | ១៦៩.១៣៤ | ៧៤.២៧៦ | ៣០០.៤៤៥ |

(គ) អត្ថប្រយោជន៍គណៈគ្រប់គ្រងសំខាន់ៗ

អត្ថប្រយោជន៍គណៈគ្រប់គ្រងសំខាន់ៗ សម្រាប់ដំណាច់ការិយបរិច្ឆេទមានដូចខាងក្រោម៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ប្រាក់បៀវត្ស និងចំណាយផ្សេងៗ | ២០៩.១៩៧ | ៨៤៦.២០២ | ២០៩.២២០ | ៨៤៦.២៩៥ |

## ២៧. ការគ្រប់គ្រងមូលធន និងហានិភ័យហិរញ្ញវត្ថុ

ក) ការគ្រប់គ្រងមូលធន

កម្មវត្ថុបឋមរបស់ ក.ស.ភ ក្នុងការគ្រប់គ្រងមូលធន គឺដើម្បីធានាបានថា ក.ស.ភ អាចបន្តប្រតិបត្តិការរបស់ខ្លួន ដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយស្របពេល ជាមួយគ្នានេះធ្វើឱ្យមានកំណើនផលលាភដល់ភាគហ៊ុនិក តាមរយៈការធ្វើឱ្យប្រសើរឡើងនូវអនុបាតបំណុល និងមូលធនៗ ពុំមានការផ្លាស់ប្តូរយុទ្ធសាស្ត្រទូទៅរបស់ក្រុមហ៊ុនទេ។

ក.ស.ភ បានរៀបចំរចនាសម្ព័ន្ធ និងធ្វើនិយ័តកម្មលើមូលធនរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃលក្ខខណ្ឌសេដ្ឋកិច្ច។ ដើម្បីរក្សា និងធ្វើនិយ័តកម្មលើរចនាសម្ព័ន្ធមូលធន ក.ស.ភ អាចធ្វើនិយ័តកម្មលើការចំណាយភាគលាភទៅលើភាគហ៊ុនិក បង្វិលភាគហ៊ុនឱ្យទៅភាគហ៊ុនិក ឬបោះផ្សាយភាគហ៊ុនថ្មី។ ពុំមានការប្រែប្រួលលើកម្មវត្ថុគោលនយោបាយ ឬដំណើរការផ្សេងៗទេ នៅក្នុងការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។

ក.ស.ភ គ្រប់គ្រង និងថែរក្សា ដោយប្រុងប្រយ័ត្ននូវបំណុលសរុប និងធានាឱ្យបាននូវអនុលោមភាពនៃតម្រូវការមូលធនផ្នែកខាងក្រៅ។

## ២៧. ការគ្រប់គ្រងមូលធន និងហានិភ័យហិរញ្ញវត្ថុ (ត)

ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

កម្មវត្ថុនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ ក.ស.ភ គឺដើម្បីបង្កើនប្រសិទ្ធភាពតម្លៃសម្រាប់ភាគហ៊ុនិក ហើយទន្ទឹមគ្នានេះក៏ដើម្បីកាត់បន្ថយសក្តានុពលនៃផលប៉ះពាល់មិនល្អដែលអាចកើតឡើងដោយសារការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវលើការកំណត់កម្មវត្ថុនេះ និងគោលការណ៍មូលដ្ឋាននៃការគ្រប់គ្រង ហានិភ័យហិរញ្ញវត្ថុរបស់ ក.ស.ភ។ ហេតុនេះគណៈគ្រប់គ្រងបង្កើតគោលការណ៍លម្អិតដូចជាកម្រិតសិទ្ធិអំណាចត្រួតពិនិត្យការកំណត់ការទទួលខុសត្រូវ និងវាស់វែងអត្តសញ្ញាណហានិភ័យ និងកំណត់ផលប៉ះពាល់ ដោយអនុលោមតាមកម្មវត្ថុ និងគោលការណ៍មូលដ្ឋានដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ក.ស.ភ ត្រូវបានផ្សារភ្ជាប់យ៉ាងចម្បងទៅនឹង ហានិភ័យរូបិយប័ណ្ណបរទេស ហានិភ័យអត្រាការប្រាក់ ហានិភ័យឥណទាន និងហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់។ ព័ត៌មានស្តីពីការគ្រប់គ្រងហានិភ័យដែលពាក់ព័ន្ធមានដូចខាងក្រោម៖

(១) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់គឺជា ហានិភ័យដែលតម្លៃទីផ្សារ ឬលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ អាចនឹងប្រែប្រួលដោយសារតែការប្រែប្រួលនៃអត្រាការប្រាក់ទីផ្សារ។

ការប្រឈមរបស់ ក.ស.ភ ទៅនឹងហានិភ័យអត្រាការប្រាក់ គឺទាក់ទងទៅនឹងប្រាក់បញ្ញើ និងកម្ចី។ ក.ស.ភ គ្រប់គ្រងហានិភ័យអត្រាការប្រាក់របស់ខ្លួនដោយត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើអត្រាការប្រាក់ទីផ្សារ។ ក.ស.ភ ពុំបានប្រើប្រាស់ ឧបករណ៍និស្សន្ទហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយហានិភ័យរបស់កាតព្វកិច្ចបំណុលដែលត្រូវសងនោះទេ។

*ការវិភាគលើភាពងាយរងផលប៉ះពាល់នៃអត្រាការប្រាក់*

តារាងខាងក្រោមបង្ហាញពីការវិភាគលើភាពងាយរងផលប៉ះពាល់ នៃអត្រាការប្រាក់របស់ ក.ស.ភ នៅចុងការិយបរិច្ឆេទ ដោយឈរលើគោលការណ៍បម្រែបម្រួល ០.១% និងកត្តាអថេរផ្សេងទៀតមិនមានការប្រែប្រួល៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **ផលចំណេញបន្ទាប់ពីកាត់ពន្ធ** | | | | |
| - កំណើន ០,១% (២០១៧:០,១%) | (៥.៥២៨) | (៣៨.៥៤០) | (២០.៦៥៥) | (៨៣.៥៥០) |
| - កំហយ ០,១% (២០១៧:០,១%) | ៥.៥២៨ | ៣៨.៥៤០ | ២០.៦៥៥ | ៨៣.៥៥០ |

## ២៧. ការគ្រប់គ្រងមូលធន និងហានិភ័យហិរញ្ញវត្ថុ (ត)

ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(២) ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ ក.ស.ភ ដោយសមភាគីមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យា។ ក.ស.ភ ប្រឈមនឹងហានិភ័យឥណទានភាគច្រើនពីការលក់ជាឥណទាន។ តាមគោលការណ៍របស់ ក.ស.ភ ត្រូវត្រួតពិនិត្យជាប្រចាំទៅលើស្ថានភាពហិរញ្ញវត្ថុរបស់សមភាគី ដើម្បីធានាថា ក.ស.ភ ប្រឈមនឹងហានិភ័យឥណទានតិចបំផុត។

ហានិភ័យឥណទានដែល ក.ស.ភ ងាយរងផលប៉ះពាល់គឺ តាមរយៈគណនីពាណិជ្ជពីអតិថិជន។ ក.ស.ភ គ្រប់គ្រងហានិភ័យឥណទានដែលបានមកពីការផ្ដល់សេវា ដោយធានាថាអតិថិជនទាំងនោះមានហិរញ្ញវត្ថុ និងប្រវត្តិឥណទានល្អ។ ក.ស.ភ បានស្វែងរកការវិនិយោគលើទ្រព្យសកម្មសាច់ប្រាក់ដោយមានសុវត្ថិភាព និងផលចំណេញជាមួយស្ថាប័នហិរញ្ញវត្ថុស្របច្បាប់។

ក.ស.ភ កំណត់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមាននៅក្នុងលំនាំដើម នៅពេលដែលការសន្យាទូទាត់មិនបានអនុវត្ត និងពេលដែលមានព័ត៌មានពីខាងក្នុង និងខាងក្រៅបញ្ជាក់ថាទ្រព្យសកម្មនោះមិនអាចទទួលបានមកវិញ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានលុបចោលនៅពេលដែលគ្មានការរំពឹងទុកសមហេតុផលនៃការទទួលនូវសាច់ប្រាក់តាមកិច្ចសន្យា។

<u>ការប្រឈមមុខចំពោះហានិភ័យឥណទាន និងទម្រង់នៃការគិតគូរលើហានិភ័យឥណទាន</u>

ការប្រឈមនឹងហានិភ័យឥណទានធំបំផុតរបស់ ក.ស.ភ តំណាងដោយតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មហិរញ្ញវត្ថុនីមួយៗ។

នៅចុងការិយបរិច្ឆេទនៃរបាយការណ៍ ប្រមាណ៩១% (២០១៧: ៧០%) គណនីពាណិជ្ជរបស់ ក.ស.ភ គឺជំពាក់ដោយអតិថិជនចម្បងបួន។

ក.ស.ភ មិនបានព្យាករណ៍នូវចំនួនដែលបានកត់ត្រាទុកនៅចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដែលអាចនឹងមានតម្លៃខុស ពីអ្វីដែលនឹងត្រូវបានទទួលនោះទេ។

(៣) ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់

ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់ កើតឡើងពីការគ្រប់គ្រងរបស់ ក.ស.ភ ទៅលើមូលធនបង្វិល។ វាគឺជាហានិភ័យមួយដែល ក.ស.ភ នឹងជួបប្រទះផលលំបាកក្នុងការបំពេញនូវកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដែលដល់កាលកំណត់ត្រូវសង។

ក.ស.ភ គ្រប់គ្រង លំហូរសាច់ប្រាក់ពីប្រតិបត្តិការ និងភាពមានស្រាប់នៃមូលនិធិយ៉ាងសកម្ម ដើម្បីធានាបាននូវរាល់តម្រូវការប្រតិបត្តិការ វិនិយោគ និង ហិរញ្ញប្បទាន។ នៅក្នុងយុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល ក.ស.ភ រក្សានូវកម្រិតសាច់ប្រាក់ និងសាច់ប្រាក់សមមូលគ្រប់គ្រាន់សម្រាប់គាំទ្រដល់សកម្មភាពប្រតិបត្តិការរបស់ ក.ស.ភ។

## ២៨. ចរម្រៀកនៃព័ត៌មាន

ផ្នែកប្រតិបត្តិការ ត្រូវបានរាយការណ៍តាមរបៀបដែលត្រូវគ្នា ជាមួយនឹងរបាយការណ៍ផ្ទៃក្នុងដែលបានផ្តល់ ក.ស.ភ ក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ អ្នកដែលទទួលខុសត្រូវក្នុងការបែងចែកធនធាន និងវាយតម្លៃលទ្ធផលនៃផ្នែកប្រតិបត្តិការ ត្រូវបានកំណត់ថាជាក្រុមអ្នកគ្រប់គ្រងសំខាន់។ ក.ស.ភ បានធ្វើប្រតិបត្តិការ នៅក្នុងផ្នែកមួយដែលជាអាជីវកម្មដែលទាក់ទងនឹងផែ។

## ២៩. ប្រតិបត្តិការសំខាន់ៗក្នុងកំឡុងការិយបរិច្ឆេទ

នៅថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៨ ក.ស.ភ បានចុះកិច្ចសន្យាជួលដែលមានរយៈពេល ៥០ឆ្នាំ ជាមួយក្រុមហ៊ុនចៀន ឈើង ថៃ គ្រុប សម្រាប់ជួលដីដែលមានទីតាំង ចាប់ពី គល់ស្ពានជ្រោយចង្វារ មកដល់ផ្សាររាត្រី (តាមបណ្តោយផ្លូវព្រះស៊ីសុវត្ថិ) ដែលមានទំហំ ៩២.៥៣៨ ម៉ែត្រការ៉េ។

## ៣០. យថាភាពនៃពន្ធ

នៅក្នុងប្រទេសកម្ពុជា បទបញ្ញត្តិស្តីពីពន្ធដារ រួមមាន អនុក្រឹត្យ ប្រកាស សារាចរណែនាំ និងសេចក្តីជូនដំណឹងផ្សេងៗ ដែលជារឿយៗតែងមានការកែតម្រូវតាមរយៈការធ្វើវិសោធនកម្ម របស់អគ្គនាយកដ្ឋានពន្ធដារ ដែលកត្តានេះអាចនាំឱ្យភាគីពាក់ព័ន្ធ អាចនឹងធ្វើការបកស្រាយផ្សេងៗពីគ្នា ទៅលើបទដ្ឋានគតិយុត្តិទាំងនោះ។ តាមនីតិវិធីច្បាប់ មន្ត្រីពន្ធដារនឹងចុះធ្វើការត្រួតពិនិត្យឡើងវិញ ដើម្បីធ្វើការដាក់ពិន័យ តាមកំរិតទោសទណ្ឌ និងការពិន័យលើការប្រាក់ជាដើម ចំពោះបទល្មើស ពាក់ព័ន្ធនឹងពន្ធដារ។ ភាពបំរែបំរួលជាញឹកញាប់នៃច្បាប់ពន្ធដារ អាចនាំឱ្យកើតមានជាហានិភ័យយ៉ាងខ្ពស់ចំពោះអង្គភាពនាពេលខាងមុខ។ ថ្នាក់គ្រប់គ្រងជឿជាក់ថា ខ្លួនមានហេតុផលសមរម្យ និងគ្រប់គ្រាន់សំរាប់សំវិធានធនលើបំណុលពន្ធ ដោយផ្អែកលើការបកស្រាយរបស់បទបញ្ញត្តិនៃពន្ធនាពេល បច្ចុប្បន្ន។

## ៣១. ព្រៀបធៀបតួលេខ

តួលេខប្រៀបធៀបដែលត្រូវបានធ្វើចំណាត់ថ្នាក់សារជាថ្មី ដើម្បីឱ្យស្របទៅនឹងរបាយការណ៍ហិរញ្ញវត្ថុក្នុងការិយបរិច្ឆេទបច្ចុប្បន្ន។

| | កំណត់ឡើងវិញ | | កំណត់ពីមុន | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| **តារាងតុល្យការ** | | | | |
| **មូលធន** | | | | |
| ទុនបម្រុង | ១៣.៩៤៦.២៨៣ | ៥៦.៣០១.១៤៥ | - | - |
| ទុនបម្រុងតាមច្បាប់ | - | - | ៧៩៥.៣១១ | ៣.២១០.៦៧១ |
| ទុនបម្រុងទូទៅ | - | - | ៧៩៥.៣១១ | ៣.២១០.៦៧១ |
| មូលនិធិអភិវឌ្ឍន៍ | - | - | ១២.៣៥៥.៦៦១ | ៤៩.៨៧៩.៨០៣ |
| **តារាងលំហូរសាច់ប្រាក់** | | | | |
| សាច់ប្រាក់សុទ្ធបានមកពីសកម្មភាព ប្រតិបត្តិការ | ៩.៩៨២.៤៥៥ | ៤០.៣៦១.១៥០ | ៨.៨២៣.២៩៩ | ៣៥.៦៩០.២៤៣ |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាព ហិរញ្ញប្បទាន | (២.១៣៨.៤២១) | (៨.៦៤៨.៦៨៤) | (៨២៥.៦៦១) | (៣.៣៣៩.៧៩៩) |

## ៣២. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី

### ៣២.១ ការអនុវត្តនូវ ស.រ.ហ.អ.ក ថ្មី ក្នុងការិយបរិច្ឆេទ

ក.ស.ភ បានអនុវត្តនូវស្តង់ដារគណនេយ្យ វិសោធនកម្ម និងការបកប្រែក្នុងការិយបរិច្ឆេទ ដូចខាងក្រោម៖

| | **ថ្ងៃចូលជាធរមាន** |
|---|---|
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដាស.រ.ហ.អ.ក ខួប២០១៤ ដល់ ២០១៦* | ១ មករា ២០១៨ |
| ស.រ.ហ.អ.ក ១៥ *ចំណូលពីកិច្ចសន្យាជាមួយអតិថិជន* | ១ មករា ២០១៨ |
| ការបញ្ជាក់ពី ស.រ.ហ.អ.ក ១៥ | ១ មករា ២០១៨ |
| ស.រ.ហ.អ.ក ៩ *ឧបករណ៍ហិរញ្ញវត្ថុ (ចេញផ្សាយដោយ ក.ប.ស.គ.អ នៅខែកក្កដាឆ្នាំ ២០១៤)* | ១ មករា ២០១៨ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ២ *ការបែងចែក និង ការវាស់វែងតំលៃនៃប្រតិបត្តិការទូទាត់ផ្អែកលើប័ណ្ណភាគហ៊ុន* | ១ មករា ២០១៨ |
| វិសោធនកម្មលើ ស.គ.អ.ក *២៨ ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដាស.រ.ហ.អ.ក ខួប២០១៤ ដល់ ២០១៦* | ១ មករា ២០១៨ |
| ការបកស្រាយ ២២ *ប្រតិបត្តិការរូបិយប័ណ្ណបរទេស និងបុរេប្រទាននៃតម្លៃតបស្នង* | ១ មករា ២០១៨ |
| វិសោធនកម្មលើ ស.គ.អ.ក ៤០ *ការផ្ទេរទ្រព្យសម្បត្តិវិនិយោគ* | ១ មករា ២០១៨ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ៤ *ដោយអនុវត្ត ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ ជាមួយ ស.រ.ហ.អ.ក ៤ កិច្ចសន្យាធានារ៉ាប់រង* | យោងតាម ស.រ.ហ.អ.ក ៤ កថាខណ្ឌ ៤៦ និង ៤៨ |

ការដាក់ឱ្យប្រើប្រាស់នូវវិសោធនកម្មខាងលើ ស្តង់ដារគណនេយ្យ និង ការបកស្រាយមិនមានឥទ្ធិពលទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ លើកលែងតែការដាក់ឱ្យប្រើប្រាស់នូវ ស.រ.ហ.អ.ក ១៥ និង ស.រ.ហ.អ.ក ៩ ដែលនិងត្រូវបានបរិយាយដូចខាងក្រោម។

(ក) *ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ*

ស.រ.ហ.អ.ក ៩ ត្រូវបានយកមកប្រើប្រាស់ជំនួស ស.រ.ហ.អ.ក ៣៩ ឧបករណ៍ហិរញ្ញវត្ថុ ទាក់ទងនិងការទទួលស្គាល់ និង ការវាស់វែង សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ គឺបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ២០១៨ ដែលនិងគ្រប់ដណ្តប់ទៅលើបីផ្នែក របស់គណនេយ្យសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ការបែងចែក ការវាស់វែង និងគណនីការពារហានិភ័យ (Hedge Accounting)។

ក.ស.ភ បានអនុវត្ត ស.រ.ហ.អ.ក ៩ ដោយមានការដាក់ពាក្យស្នើសុំដំបូងនៅថ្ងៃទី១ ខែមករា ឆ្នាំ ២០១៨។ ក.ស.ភ មិនបានកំណត់ឡើងវិញនូវព័ត៌មានប្រៀបធៀប ដែលនៅតែបន្តដើម្បីរាយការណ៍នៅក្រោម ស.គ.អ.ក ៣៩។ ភាពខុសគ្នាដែលកើតមានពីការអនុវត្ត ស.រ.ហ.អ.ក ៩ ត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងចំណេញរក្សានិងសមាសភាគផ្សេងទៀតនៃមូលធន។

## ៣២. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣២.១ ការអនុវត្តនូវ ស.រ.ហ.អ.ក ថ្មី ក្នុងការិយបរិច្ឆេទ (ត)

(ក) <u>*ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ (ត)*</u>

(១) ចំណាត់ថ្នាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ក.ស.ក បានធ្វើចំណាត់ថ្នាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ចូលទៅក្នុងប្រភេទនៃការវាយតម្លៃអាស្រ័យលើគំរូអាជីវកម្មនៃ ក.ស.ក សម្រាប់ការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលក្ខខណ្ឌនៃលំហូរសាច់ប្រាក់នៃកិច្ចសន្យាហិរញ្ញវត្ថុ ដូចខាងក្រោម៖

- ត្រូវបានវាស់វែងតាម amortised cost និង
- ត្រូវបានវាស់វែងជាបន្តបន្ទាប់ក្នុងតម្លៃទីផ្សារ តាមរយៈប្រាក់ចំណូលផ្សេងៗទៀត ឬតាមរយៈប្រាក់ចំណេញឬខាត។

ខាងក្រោមនេះជាការសង្ខេបខាងក្រោម ជាការផ្លាស់ប្តូរសំខាន់ៗ៖

- សកម្មដែលអាចលក់បាន ("AFS") ទុករហូតដល់កាលកំណត់ ("HTM") និងប្រាក់កម្ចីនិងគណនេយ្យដែលត្រូវទទួល ("L&R") ប្រភេទទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានលុបចោល។
- ប្រភេទទ្រព្យសកម្មហិរញ្ញវត្ថុថ្មីមួយ ត្រូវបានវាស់វែងតាម amortised cost ("AC") ត្រូវបានចាប់ផ្តើម។ នេះសំដៅទៅលើទ្រព្យសកម្មហិរញ្ញវត្ថុដែលមានលក្ខណៈលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលជាការទូទាត់នៃប្រាក់ដើមនិងការប្រាក់ និងបានធ្វើឡើងនៅក្នុងគំរូអាជីវកម្មដែលមានគោលដៅសម្រេចបាន ដោយការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា។
- ប្រភេទទ្រព្យសកម្មហិរញ្ញវត្ថុថ្មីមួយ ត្រូវបានវាស់វែងតាមតម្លៃទីផ្សារតាមរយៈប្រាក់ចំណូលផ្សេងៗទៀត ("FVTOCI") ត្រូវបានចាប់ផ្តើម។ នេះត្រូវបានអនុវត្តឧបករណ៍បំណុលជាមួយលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលជាការទូទាត់ប្រាក់ដើម និងការប្រាក់ និងបានធ្វើឡើងនៅក្នុងគំរូអាជីវកម្មដែលគោលដៅត្រូវបានសម្រេច ដោយការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ។
- ប្រភេទទ្រព្យសកម្មហិរញ្ញវត្ថុថ្មី សម្រាប់ការធ្វើវិនិយោគទុនដោយគ្មានការជួញដូរដែលបានវាស់វែងនៅ FVTOCI ត្រូវបានណែនាំ។

ស.រ.ហ.អ.ក ៩ ភាគច្រើនរក្សាទុក សម្រាប់តម្រូវការដែលមានស្រាប់នៅក្នុង ស.គ.អ.ក ៣៩ សម្រាប់ការចាត់ថ្នាក់បំណុលហិរញ្ញវត្ថុ។

ទោះបីជាយ៉ាងណា នៅក្រោម ស.គ.អ.ក ៣៩ រាល់ការផ្លាស់ប្តូរតម្លៃទីផ្សារនៃបំណុល ដែលបានកំណត់ជា FVTPL ត្រូវបានទទួលស្គាល់ក្នុងចំណេញឬ ខាត ចំណែកឯនៅក្រោម ស.រ.ហ.អ.ក ៩ ការផ្លាស់ប្តូរតម្លៃទីផ្សារ ត្រូវបានបង្ហាញជាទូទៅដូចខាងក្រោម៖

- ចំនួនទឹកប្រាក់នៃការផ្លាស់ប្តូរនៃតម្លៃទីផ្សារ ដែលបណ្តាលមកពីការផ្លាស់ប្តូរហានិភ័យឥណទាននៃការទទួលខុសត្រូវនេះត្រូវបានបង្ហាញនៅក្នុងចំណូលផ្សេងៗទៀត និង
- ចំនួនទឹកប្រាក់ដែលនៅសល់នៃការផ្លាស់ប្តូរនៅក្នុងតម្លៃទីផ្សារ ត្រូវបានបង្ហាញនៅក្នុងចំណេញ ឬខាត។

## ៣២. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣២.១ ការអនុវត្តនូវ ស.រ.ហ.អ.ក ថ្មី ក្នុងការិយបរិច្ឆេទ (ត)

(ក) *ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ (ត)*

(២) ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ

ការអនុម័ត ស.រ.ហ.អ.ក ៩ បានផ្លាស់ប្តូរគណនេយ្យមូលដ្ឋានសម្រាប់ការ ឱនភាពនៃការខាតបង់លើទ្រព្យសកម្មហិរញ្ញវត្ថុរបស់ ក.ស.ក ដោយជំនួសវិធីសាស្ត្របាត់បង់ដែលបានកើតឡើងរបស់ ស.គ.អ.ក ៣៩ ជាមួយនឹងវិធីបាត់បង់ឥណទានដែលរំពឹងទុក។ ស.រ.ហ.អ.ក ៩ ឱ្យតម្រូវក.ស.ក កត់ត្រាប្រាក់ឧបត្ថម្ភសម្រាប់ការខាតបង់ឥណទាន ដែលគេរំពឹងទុកសម្រាប់ទ្រព្យសម្បត្តិហិរញ្ញវត្ថុបំណុលទាំងអស់មិនត្រូវបានរក្សាដោយតម្លៃត្រឹមត្រូវតាមរយៈប្រាក់ចំណេញ ឬ ខាត។

ការខាតបង់ឥណទានរំពឹងទុក គឺផ្អែកលើភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ ដែល ក.ស.ក រំពឹងទុកថាបានទទួល។ ការប៉ាន់ស្មាននៃកង្វះខាតសាច់ប្រាក់ដែលរំពឹងទុក ត្រូវឆ្លុះបញ្ចាំងពីលំហូរសាច់ប្រាក់ដែលរំពឹងទុកពីការបញ្ចាំនិងឥណទានផ្សេងទៀតដែលជាលក្ខខណ្ឌនៃកិច្ចសន្យា។ កង្វះខាតនេះនឹងត្រូវបានបញ្ចុះតម្លៃនៅពេលសមស្របទៅនឹងអត្រាការប្រាក់ជាក់ស្តែងនៃទ្រព្យសកម្ម។

ឱនភាពសម្រាប់គណនីពាណិជ្ជត្រូវទទួល និងកិច្ចសន្យាទ្រព្យសកម្ម ដែលមិនបានរួមបញ្ចូលជាធាតុនៃហិរញ្ញវត្ថុសំខាន់ គឺត្រូវបានទទួលស្គាល់វិធីសាស្ត្រសាមញ្ញ ជាមួយ ស.រ.ហ.អ.ក ៩ ដោយប្រើការរំពឹងទុកលើអាយុកាលការខាតបង់ឥណទាន។

នៅក្នុងអំឡុងពេលនៃដំណើរការនេះ លទ្ធភាពនៃការមិនទូទាត់ ដោយគណនីពាណិជ្ជកម្មត្រូវទទួល បានកែតម្រូវដោយព័ត៌មាន ហើយគុណនឹងចំនួនទឹកប្រាក់នៃការខាតបង់ដែលរំពឹងទុកដែលកើតឡើងពីលំនាំដើមដើម្បីកំណត់ការបាត់បង់ឥណទានដែលរំពឹងលើអាយុកាល សម្រាប់គណនីពាណិជ្ជកម្មត្រូវទទួល។ សម្រាប់គណនីពាណិជ្ជកម្មត្រូវទទួល ដែលត្រូវបានរាយការណ៍នូវចំនួនសុទ្ធ ដូចជាឱនភាពដែលត្រូវបានកត់ត្រា ក្នុងគណនីដាច់ដោយឡែកជាមួយនឹងការខាតបង់ដែលត្រូវបានទទួលស្គាល់នៅក្នុងចំណាយរដ្ឋបាលនៅក្នុងរបាយការណ៍ប្រាក់ចំណេញឬខាត និង ចំណូលផ្សេងៗទៀត។ នៅលើការបញ្ជាក់ថាគណនីពាណិជ្ជត្រូវទទួល នឹងមិនអាចប្រមូលបានតាម តម្លៃសុទ្ធនៃទ្រព្យសកម្មសរុបដែលត្រូវបានលុបចោល ជាមួយឱនភាពដែលពាក់ព័ន្ធ។

ឱនភាពសម្រាប់គណនីពាណិជ្ជពីភាគីពាក់ព័ន្ធត្រូវបានទទួលស្គាល់ដោយផ្អែកលើវិធីសាស្ត្រទូទៅ នៅក្នុង ស.រ.ហ.អ.ក ៩ ដោយប្រើវិធីសាស្ត្រដែលបាត់បង់ឥណទារំពឹងទុកទៅមុខ។ វិធីសាស្ត្រដែលត្រូវបានប្រើដើម្បីកំណត់ចំនួនទឹកប្រាក់នៃឱនភាព ត្រូវបានផ្អែកលើថាតើមានការកើនឡើងគួរឱ្យកត់សម្គាល់នៃហានិភ័យឥណទាន ចាប់តាំងពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ។ ចំពោះហានិភ័យទាំងឡាយដែលហានិភ័យឥណទានមិនបានកើនឡើងយ៉ាងខ្លាំង ចាប់តាំងពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ការខាតបង់ឥណទានរំពឹងទុកក្នុងរយៈពេលដប់ពីរខែ រួមជាមួយនឹងចំណូលការប្រាក់សុទ្ធត្រូវបានទទួលស្គាល់។ ចំពោះកត្តាផ្សេងទៀតដែលត្រូវបានកំណត់ថាជាឱនភាពឥណទាន ដែលរំពឹងទុកថានឹងបាត់បង់ប្រាក់ឥណទានរួមជាមួយប្រាក់ចំណេញលើការប្រាក់ត្រូវបានទទួលស្គាល់។

## ៣២. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣២.១ ការអនុវត្តនូវ ស.រ.ហ.អ.ក ថ្មី ក្នុងការិយបរិច្ឆេទ (ត)

(ក) *ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ (ត)*

(៣) ចំណាត់ថ្នាក់ និងការវាស់វែង

តារាងខាងក្រោមសង្ខេបការធ្វើចំណាត់ថ្នាក់និងការវាស់វែងឡើងវិញនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ ក.ស.ភ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨៖

| | ចំណាត់ថ្នាក់ | | តំលៃពិតគណនេយ្យ | |
|---|---|---|---|---|
| | មាននៅក្នុង ស.គ.អ.ក ៣៩ | ថ្មីនៅក្នុង ស.រ.ហ.អ.ក ៩ | មាននៅក្នុង ស.គ.អ.ក ៣៩ | ថ្មីនៅក្នុង ស.រ.ហ.អ.ក ៩ |
| | | | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ | L&R | AC | ៣.០០៩.៣០៨ | ២.៥៥០.៤៩០ |
| សាច់ប្រាក់ និង សាច់ប្រាក់នៅធនាគារ | L&R | AC | ១១.៧១៧.៩៤៤ | ១១.៧១៧.៩៤៤ |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីបំណុលផ្សេងៗ | OFL | AC | ២.៥១០.៨៨៥ | ២.៥១០.៨៨៥ |
| ប្រាក់កម្ចី | OFL | AC | ២៨.៩៧៩.៦៣៧ | ២៨.៩៧៩.៦៣៧ |

តារាងខាងក្រោមនេះ គឺជាការផ្ទៀងផ្ទាត់នៃតួលេខជាក់ស្តែងនៃរបាយការណ៍ហិរញ្ញវត្ថុនៃ ក.ស.ភ ពី ស.គ.អ.ក ៣៩ ទៅ ស.រ.ហ.អ.ក ៩ គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៨៖

| | មាននៅក្នុង ស.គ.អ.ក ៣៩ តម្លៃពិតគណនេយ្យ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | ការធ្វើចំណាត់ថ្នាក់ឡើងវិញ | ការវាស់វែង | ថ្មីនៅក្នុង ស.រ.ហ.អ.ក ៩ តម្លៃពិតគណនេយ្យ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗ** | | | | |
| សមតុល្យដើមគ្រា | ៣.០០៩.៣០៨ | - | - | ៣.០០៩.៣០៨ |
| ការកើនឡើងនៃឱនភាព | - | - | (៤៥៨.៨១៨) | (៤៥៨.៨១៨) |
| **គណនីពាណិជ្ជ និងគណនីត្រូវទទួលផ្សេងៗសរុប** | ៣.០០៩.៣០៨ | - | (៤៥៨.៨១៨) | ២.៥៥០.៤៩០ |

## ៣២. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣២.១ ការអនុវត្តនូវ ស.រ.ហ.អ.ក ថ្មី ក្នុងការិយបរិច្ឆេទ (ត)

(ក) *ស.រ.ហ.អ.ក ៩ ឧបករណ៍ហិរញ្ញវត្ថុ (ត)*

(៣) ចំណាត់ថ្នាក់ និងការវាស់វែង (ត)

តារាងដូចខាងក្រោមនេះគឺជាការផ្ទៀងផ្ទាត់នៃតួលេខជាក់ស្តែងនៃរបាយការណ៍ហិរញ្ញវត្ថុនៃ ក.ស.ក ពី ស.គ.អ.ក ៣៩ ទៅ ស.រ.ហ.អ.ក ៩ គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៨៖

| | មាននៅក្នុង ស.គ.អ.ក ៣៩ តម្លៃពិត គណនេយ្យ នៅ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៧ ដុល្លារអាមេរិក | ការធ្វើចំណាត់ ថ្នាក់ឡើងវិញ ដុល្លារអាមេរិក | ការវាស់វែង ដុល្លារអាមេរិក | ថ្មីនៅក្នុង ស.រ.ហ.អ.ក ៩ តម្លៃពិត គណនេយ្យ នៅ ថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ ដុល្លារអាមេរិក |
|---|---|---|---|---|
| **មូលធន៖** | | | | |
| សមតុល្យដើមគ្រា | ៥.២៨២.០៦២ | - | - | ៥.២៨២.០៦២ |
| ការកើនឡើងនៃឱនភាព | - | - | (៤៥៨.៨១៨) | (៤៥៨.៨១៨) |
| **មូលធនសរុប** | ៥.២៨២.០៦២ | - | (៤៥៨.៨១៨) | ៤.៨២៣.២៤៤ |

(ខ) *ស.រ.ហ.អ.ក ១៥ ចំណូលពីការចុះកិច្ចសន្យាជាមួយអតិថិជន*

ខាងក្រោមនេះសង្ខេបពីផលប៉ះពាល់នៃការអនុម័ត ស.រ.ហ.អ.ក ១៥ នៅលើរបាយការណ៍ហិរញ្ញវត្ថុនៃ ក.ស.ក នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ សម្រាប់ធាតុនីមួយៗដែលរងផលប៉ះពាល់៖

| | ចំនួនទឹកប្រាក់ដែលមិនទាន់អនុវត្តន៍តាម ស.រ.ហ.អ.ក ១៥ ដុល្លារអាមេរិក | ការកែតម្រូវ ដុល្លារអាមេរិក | នៅក្នុងរបាយការណ៍ ដុល្លារអាមេរិក |
|---|---|---|---|
| **ចំណូល** | | | |
| ចំណូលពន្ធារ | ១៤.៨៥០.០០០ | (១៤.៨៥០.០០០) | - |
| កិច្ចសន្យាចំណូល | - | ១៤.៨៥០.០០០ | ១៤.៨៥០.០០០ |

លេខបញ្ជីពាណិជ្ជកម្ម៖
Co. ៧១៧៥ Et/២០០៤



## ៣២. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣២.២ ស.រ.ហ.អ.ក ថ្មីដែលបានចេញផ្សាយ ប៉ុន្តែនឹងចូលជាធរមានសម្រាប់ការិយបរិច្ឆេទចាប់ពី ឬបន្ទាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០១៩

ខាងក្រោមនេះគឺជាស្តង់ដារ វិសោធនកម្ម និងការបកស្រាយ ដែលបានចេញផ្សាយរួច ប៉ុន្តែ ក.ស.ក ពុំទាន់បានអនុវត្ត៖

| | ថ្ងៃចូលជាធរមាន |
|---|---|
| ស.រ.ហ.អ.ក ១៦ *ការជួល* | ១ មករា ២០១៩ |
| ការបកស្រាយ ២៣ *ភាពមិនច្បាស់លាស់លើការវិនិច្ឆ័យពន្ធលើប្រាក់ចំណូល* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.គ.អ.ក ២៨ *ការប្រាក់រយៈពេលវែងជាមួយញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុន* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ៩ *ការទូទាត់ជាមុន ជាមួយ សំណងដែលមានភាពអវិជ្ជមាន* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ៣ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក ខួប២០១៥ ដល់ ២០១៧* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១១ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក ខួប២០១៥ ដល់ ២០១៧* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.គ.អ.ក ១២ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក ខួប២០១៥ ដល់ ២០១៧* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.គ.អ.ក ២៣ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក ខួប២០១៥ ដល់ ២០១៧* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.គ.អ.ក ១៩ *វិសោធនកម្មផែនការ ការបន្ថយ ឬ ការទូទាត់* | ១ មករា ២០១៩ |
| វិសោធនកម្មលើ សេចក្តីព្រាងលើក្របខណ្ឌទស្សនទានក្នុងស្តង់ដា ស.រ.ហ.អ.ក | ១ មករា ២០១៩ |
| ស.រ.ហ.អ.ក ១៧ *កិច្ចសន្យាធានារ៉ាប់រង* | ១ មករា ២០១៩ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ និង ស.គ.អ.ក ២៨ *ការលក់ ឬការចែកចាយនៃទ្រព្យ រវាង ស.រ.ហ.អ.ក ៤ កិច្ចសន្យាធានារ៉ាប់រង* | ពន្យា |

ក.ស.ក កំពុងវិភាគលើផលប៉ះពាល់ក្នុងការអនុវត្តស្តង់ដារគណនេយ្យ វិសោធនកម្ម និងការបកស្រាយ ដោយហេតុថាក្រុមប្រឹក្សាភិបាលពុំទាន់មានជំហរ ដើម្បីសន្និដ្ឋានលើផលប៉ះពាល់ដែលអាចមានទៅលើលទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ក នៅឡើយទេ។

ឯកសារបញ្ជីពាណិជ្ជកម្ម៖
Co. ៧១៧៥ E/២០០៤



## ៣២. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣២.២ ស.រ.ហ.អ.ក ថ្មីដែលបានចេញផ្សាយ ប៉ុន្តែនឹងចូលជាធរមានសម្រាប់ការិយបរិច្ឆេទចាប់ពី ឬបន្ទាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ (ត)

ផលប៉ះពាល់ដែលអាចកើតមាន ពីការអនុវត្តស្តង់ដារគណនេយ្យវិសោធនកម្ម និង ការបកស្រាយខាងលើមានដូចខាងក្រោម៖

<u>ស.រ.ហ.អ.ក ១៦ *ការជួល*</u>

ស.រ.ហ.អ.ក ១៦ នៅកាលបរិច្ឆេទដែលមានប្រសិទ្ធភាពនឹងជំនួស ស.គ.អ.ក ១៧ *ការជួល* និងការបកស្រាយពាក់ព័ន្ធ ដែលបង្ហាញពីគំរូគណនេយ្យការជួលតែមួយ និងតម្រូវឱ្យអ្នកជួល ទទួលស្គាល់ទ្រព្យសកម្ម និងបំណុលសម្រាប់ការជួលទាំងអស់ ដែលមានរយៈពេលលើសពី ១២ខែ លើកលែងតែទ្រព្យសម្បត្តិមូលដ្ឋានមានតម្លៃទាប។ ជាពិសេសនៅក្រោម ស.រ.ហ.អ.ក ១៦ អ្នកជួលត្រូវបានតម្រូវឱ្យទទួលស្គាល់សិទ្ធិរបស់ខ្លួនក្នុងការប្រើប្រាស់ទ្រព្យសកម្ម តំណាងឱ្យសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម និងបំណុលមូលដ្ឋានដែលបានជួល ដែលតំណាងឱ្យកាតព្វកិច្ចរបស់ខ្លួនក្នុងការទូទាត់ថ្លៃជួល។ ដូច្នេះហើយ អ្នកជួលគួរតែទទួលខុសត្រូវលើការរំលស់ទ្រព្យសម្បត្តិដែលមានការប្រើប្រាស់ និងការប្រាក់ទៅលើការទទួលខុសត្រូវលើការជួល និងបែងចែកសាច់ប្រាក់ នៃបំណុលជួល ទៅជាចំណែកដើមទុន និងចំណែកការប្រាក់ និងបង្ហាញនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់។ ដូចគ្នានេះដែរ សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម និងបំណុលការជួល ត្រូវបានវាស់វែងដំបូងលើមូលដ្ឋានតម្លៃបច្ចុប្បន្ន។

ការវាស់វែងរួមបញ្ចូលទាំងការទូទាត់ជួលដែលមិនអាចលុបចោលបាន ហើយក៏រួមបញ្ចូលទាំងការបង់ប្រាក់ជាដំណាក់កាល ប្រសិនបើអ្នកជួលមានភាពសមហេតុផលជាក់លាក់ ក្នុងការប្រើប្រាស់ជម្រើសដើម្បីពន្យារការជួល ឬប្រើជម្រើស ដើម្បីបញ្ចប់ការជួល។ ការកត់ត្រាគណនេយ្យនេះ មានភាពខុសគ្នាយ៉ាងខ្លាំង ទៅលើគណនេយ្យរបស់អ្នកជួល ចំពោះការជួលដែលត្រូវបានចាត់ថ្នាក់ជាប្រតិបត្តិការជួលតាមស្តង់ដារមុន ស.គ.អ.ក ១៧។

ទាក់ទងទៅនឹងគណនេយ្យកររបស់ភតិសន្យាបតីនេះ ស.រ.ហ.អ.ក ១៦ អាចយោងទៅលើគណនេយ្យរបស់ភតិបតីនៅក្នុង ស.គ.អ.ក ១៧។ ដូច្នេះអ្នកជួល ត្រូវបន្តចាត់ថ្នាក់ភតិសន្យារបស់ខ្លួនជាភតិសន្យាប្រតិបត្តិការ ឬភតិសន្យាហិរញ្ញវត្ថុ និងបង្ហាញប្រភេទភតិសន្យាទាំងពីរនេះខុសគ្នា។

<u>ការបកស្រាយ ២៣ *ភាពមិនច្បាស់លាស់លើការវិនិច្ឆ័យពន្ធលើប្រាក់ចំណូល*</u>

ការបកស្រាយ គាំទ្រតម្រូវការនៃ*ពន្ធលើប្រាក់ចំណូល* ស.គ.អ.ក ១២ ដោយផ្តល់ការណែនាំអំពីវិធីក្នុងការឆ្លុះបញ្ចាំងពីឥទ្ធិពល នៃភាពមិនប្រាកដប្រជាក្នុងគណនេយ្យសម្រាប់ពន្ធលើប្រាក់ចំណូល។

នៅក្រោមការបកស្រាយ អង្គភាពគួរកំណត់ថាតើត្រូវពិចារណាការបង់ពន្ធមិនច្បាស់លាស់នីមួយៗដាច់ដោយឡែកពីគ្នា ឬរួមគ្នា ដោយផ្អែកលើវិធីសាស្ត្រណាមួយដែលអាចទស្សន៍ទាយបានពីភាពមិនច្បាស់លាស់។ អង្គភាពក៏ត្រូវសន្មតថាអាជ្ញាធរពន្ធដារ នឹងធ្វើការត្រួតពិនិត្យមើលលើបរិមាណ ដែលខ្លួនមានសិទ្ធិពិនិត្យ និងមានចំណេះដឹងពេញលេញអំពីព័ត៌មានពាក់ព័ន្ធទាំងអស់នៅពេលធ្វើការពិនិត្យ។ ប្រសិនបើអង្គភាពយល់ថាការកំណត់របស់ខ្លួន អាជ្ញាធរពន្ធនឹងទទួលយកការបង់ពន្ធមិនច្បាស់លាស់របស់ខ្លួន នោះបន្ទាប់មកអង្គភាពគួរតែវាស់វែងពន្ធបច្ចុប្បន្ន និងពន្ធពន្យារ ស្របតាមការកំណត់ពន្ធរបស់ខ្លួន។ ប្រសិនបើអង្គភាពបានកំណត់ថាវាមិនអាចទៅរួចនោះ ភាពមិនច្បាស់លាស់ក្នុងការកំណត់ពន្ធត្រូវបានឆ្លុះបញ្ចាំងដោយដោយការប្រើប្រាស់ វិធីសាស្ត្រសមស្របបំផុត ឬ តម្លៃដែលរំពឹងទុក ក្នុងការព្យាករណ៍ពីដំណោះស្រាយនៃភាពមិនច្បាស់លាស់។

## ៣២. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

**៣២.២ ស.រ.ហ.អ.ក ថ្មីដែលបានចេញផ្សាយ ប៉ុន្តែនឹងចូលជាធរមានសម្រាប់ការិយបរិច្ឆេទចាប់ពី ឬបន្ទាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ (ត)**

ផលប៉ះពាល់ដែលអាចកើតមាន ពីការអនុវត្តស្តង់ដារគណនេយ្យវិសោធនកម្ម និង ការបកស្រាយខាងលើមានដូចខាងក្រោម៖ (ត)

<u>វិសោធនកម្មលើ ស.គ.អ.ក ២៨ *ការប្រាក់រយៈពេលវែងជាមួយញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុន*</u>

វិសោធនកម្មនេះបានបញ្ជាក់ថាក្រុមហ៊ុនមានផលប្រយោជន៍រយៈពេលវែងនៅក្នុងការចូលរួម ឬការបណ្តាក់ទុនរួម ដែលវិធីសាស្ត្រមូលធនមិនត្រូវបានអនុវត្ត ប៉ុន្តែត្រូវប្រើប្រាស់ជំនួសដោយ ស.រ.ហ.អ ៩។

<u>វិសោធនកម្មលើ ស.រ.ហ.អ.ក ៩ *ការទូទាត់ជាមុនជាមួយសំណងដែលមានភាពអវិជ្ជមាន*</u>

វិសោធនកម្មបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុ ដែលអាចទូទាត់សងដោយសំណងអវិជ្ជមានអាចត្រូវបានវាស់វែងតាមតម្លៃរំលស់ ឬតម្លៃទីផ្សារតាមរយៈប្រាក់ចំណូលផ្សេងទៀត ប្រសិនបើលក្ខខណ្ឌជាក់លាក់ត្រូវបានបំពេញជំនួសឱ្យតម្លៃទីផ្សារតាមរយៈប្រាក់ចំណេញ ឬខាត។

<u>វិសោធនកម្មលើ ស.រ.ហ.អ.ក ៣ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក វដ្ត២០១៥ ដល់ ២០១៧*</u>

វិសោធនកម្មបានបោះផ្សាយក្រោមដំណើរការពង្រឹងប្រចាំឆ្នាំធ្វើឱ្យមានការផ្លាស់ប្តូរតិចតួច ឬមិនផ្លាស់ប្តូរស្តង់ដារដែលបច្ចុប្បន្នមិនទាន់ច្បាស់លាស់។ ពួកគេបញ្ចូល ស.រ.ហ.អ.ក ៣ ដែលបញ្ជាក់ថា ពេលដែលប្រតិបត្តិកររួមគ្នានៃអាជីវកម្មទទួលបានការគ្រប់គ្រងលើប្រតិបត្តិការរួមគ្នាមួយ នេះជាសមិទ្ធិផលនៃការរួមបញ្ចូលអាជីវកម្ម និងផលប្រយោជន៍នៃការកាន់កាប់មូលធនមុន គួរតែត្រូវបានវាស់វែងតម្លៃទីផ្សារម្តងទៀតនៅថ្ងៃទិញលក់ ស.រ.ហ.អ.ក ១៧ *កិច្ចសន្យាធានារ៉ាប់រង*។

<u>វិសោធនកម្មលើ ស.រ.ហ.អ.ក ១១ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក វដ្ត២០១៥ ដល់ ២០១៧*</u>

វិសោធនកម្មបានបោះផ្សាយក្រោមដំណើរការពង្រឹងប្រចាំឆ្នាំធ្វើឱ្យមានការផ្លាស់ប្តូរតិចតួច ឬមិនផ្លាស់ប្តូរស្តង់ដារដែលបច្ចុប្បន្នមិនទាន់ច្បាស់លាស់។ ពួកគេបញ្ចូល ស.រ.ហ.អ.ក ១១ ដែលបញ្ជាក់ថា ពេលដែលភាគីបានចូលរួម ប៉ុន្តែមិនមានការចូលរួមត្រួតពិនិត្យ ការចូលរួមប្រតិបត្តិការ ដែលជាអាជីវកម្មមួយ និងក្រោយមកបានទទួលការគ្រប់គ្រងរួមគ្នាផលប្រយោជន៍នៃការកាន់កាប់មូលធនមុន គួរតែត្រូវបានវាស់វែងតម្លៃទីផ្សារម្តងទៀតនៅថ្ងៃទិញលក់របស់ខ្លួនឡើយ។

<u>វិសោធនកម្មលើ ស.គ.អ.ក ១២ *ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក វដ្ត២០១៥ ដល់ ២០១៧*</u>

វិសោធនកម្មបានបោះផ្សាយក្រោមដំណើរការពង្រឹងប្រចាំឆ្នាំធ្វើឱ្យមានការផ្លាស់ប្តូរតិចតួច ឬមិនផ្លាស់ប្តូរស្តង់ដារដែលបច្ចុប្បន្នមិនទាន់ច្បាស់លាស់។ ពួកគេបញ្ចូល ស.គ.អ.ក ១២ ដែលបញ្ជាក់ថា ផលចំណេញពន្ធលើប្រាក់ចំណូលទាំងអស់នៃភាគលាភត្រូវបានទទួលស្គាល់ជាប្រចាំជាមួយប្រតិបត្តិការដែលបង្កើតប្រាក់ចំណេញ ដែលអាចចែកចាយបាន ទាំងនៅក្នុងប្រាក់ចំនេញ ឬ ខាត និងចំណូលផ្សេងៗសង្ខេប ឬដោយផ្ទាល់នៅក្នុងមូលធន។

## ៣២. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣២.២ ស.រ.ហ.អ.ក ថ្មីដែលបានចេញផ្សាយ ប៉ុន្តែនឹងចូលជាធរមានសម្រាប់ការិយបរិច្ឆេទចាប់ពី ឬបន្ទាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ (ត)

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តស្តង់ដារគណនេយ្យ វិសោធនកម្ម និងការបកស្រាយមានដូចខាងក្រោម៖ (ត)

*<u>វិសោធនកម្មលើ ស.គ.អ.ក ២៣ ការពង្រឹងប្រចាំឆ្នាំ លើស្តង់ដា ស.រ.ហ.អ.ក ខួប២០១៥ ដល់ ២០១៧</u>*

វិសោធនកម្មបានបោះផ្សាយក្រោមដំណើរការពង្រឹងប្រចាំឆ្នាំធ្វើឱ្យមានការផ្លាស់ប្តូរតិចតួច ឬមិនផ្លាស់ប្តូរស្តង់ដារដែលបច្ចុប្បន្នមិនទាន់ច្បាស់លាស់។ ពួកគេបញ្ចូល ស.គ.អ.ក ២៣ ដែលបញ្ជាក់ថាការខ្ចីមួយបានធ្វើជាពិសេសដើម្បីទទួលបានទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលនៅសល់ បន្ទាប់ពីទ្រព្យសកម្មមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលត្រូវបានត្រៀមរួចរាល់សម្រាប់ការប្រើប្រាស់ ឬ ការលក់ដែលមានបំណងនឹងក្លាយជាផ្នែកមួយនៃមូលនិធិដែលអង្គភាពខ្ចីជាទូទៅ ហើយដូច្នេះត្រូវបានរួមបញ្ចូលទាំងអស់។

*<u>វិសោធនកម្មលើ ស.គ.អ.ក ១៩ វិសោធនកម្មផែនការ ការបន្ថយ ឬ ការទូទាត់</u>*

វិសោធនកម្មបញ្ជាក់ថា៖

- វិសោធនកម្មលើការកាត់បន្ថយ ឬ ការទូទាត់នៃផែនការអត្ថប្រយោជន៍ដែលបានកំណត់ ក្រុមហ៊ុនគួរប្រើការសន្មត់តាមច្បាប់ដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីកំណត់តម្លៃសេវាបច្ចុប្បន្ននិងការប្រាក់សុទ្ធសម្រាប់រយៈពេលនេះ និង
- ផលប៉ះពាល់នៃការចំណាយទ្រព្យសកម្មមិនត្រូវបានយកចិត្តទុកដាក់ នៅពេលគណនាការចំណេញ ឬ ការខាតលើការទូទាត់ណាមួយនៃផែនការ ហើយត្រូវបានដោះស្រាយដាច់ដោយឡែកពីចំណូលផ្សេងៗសង្ខេប។

*<u>វិសោធនកម្មលើ សេចក្តីព្រាងលើក្របខណ្ឌទស្សនទានក្នុងស្តង់ដា ស.រ.ហ.អ.ក</u>*

ជាមួយនឹងកែសម្រួល*សេចក្តីព្រាងលើក្របខណ្ឌទស្សនទាន* IASB បានចេញផ្សាយវិសោធនកម្មលើ *សេចក្តីព្រាងលើក្របខណ្ឌទស្សនទានក្នុងស្តង់ដា ស.រ.ហ.អ.ក* ដែលរួមមានវិសោធនកម្មលើ ស.រ.ហ.អ.ក ២, ស.រ.ហ.អ.ក ៦, ស.រ.ហ.អ.ក ១៤, ស.គ.អ.ក ១, ស.គ.អ.ក ៨, ស.គ.អ.ក ៣៤ ស.គ.អ.ក ៣៧, ស.គ.អ.ក ៣៨, ការបកស្រាយ ១២, ១៩, ២០, និង ២២ ជាមួយនិងស្តង់ដាបកស្រាយ ៣២។

<u>ស.រ.ហ.អ.ក ១៧ *កិច្ចសន្យាធានារ៉ាប់រង*</u>

ស.រ.ហ.អ.ក ១៧ ត្រូវបានជំនួសឱ្យ ស.រ.ហ.អ.ក ៤ និងតម្រូវវាស់វែងតាមតម្លៃបច្ចុប្បន្ន ដែលការប៉ាន់ស្មានត្រូវបានវាស់វែងឡើងវិញនៃពេលរបាយការណ៍នីមួយៗ។

កិច្ចសន្យាត្រូវបានវាស់វែងដោយប្រើ៖

- អប្បហានៃប្រូបាប៊ីលីតេលំហូរសាច់ប្រាក់
- និយ័តកម្មហានិភ័យជាក់លាក់ និង
- ចំណេញនៃសេវាកិច្ចសន្យា ("CSM") ដែលតំណាងឱ្យកិច្ចសន្យានៃប្រាក់ចំណេញដែលមិនទាន់បានទទួលស្គាល់ ដែលត្រូវបានគេទទួលស្គាល់ថាជាប្រាក់ចំណូលក្នុងកំឡុងពេលនៃការធានារ៉ាប់រង។

## ៣២. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣២.២ ស.រ.ហ.អ.ក ថ្មីដែលបានចេញផ្សាយ ប៉ុន្តែនឹងចូលជាធរមានសម្រាប់ការិយបរិច្ឆេទចាប់ពី ឬបន្ទាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ (ត)

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តស្តង់ដារគណនេយ្យ វិសោធនកម្ម និងការបកស្រាយមានដូចខាងក្រោម៖ (ត)

*ស.រ.ហ.អ.ក ១៧ កិច្ចសន្យាធានារ៉ាប់រង (ត)*

ស្តង់ដារអនុញ្ញាតឱ្យមានជម្រើសរវាងការទទួលស្គាល់ ការផ្លាស់ប្តូរតាមអត្រាអប្បហារនៅក្នុងរបាយការណ៍ចំណូល ឬទទួលស្គាល់ដោយផ្ទាល់នៅក្នុងប្រាក់ចំណូលផ្សេងៗទៀត។ ជម្រើសនេះ គឺទំនងជាឆ្លុះបញ្ចាំងពីរបៀបដែលក្រុមហ៊ុនធានារ៉ាប់រង បកស្រាយពី ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួនក្រោម ស.រ.ហ.អ.ក ៩ ។

ជម្រើសម្យ៉ាងទៀត គឺវិធីសាស្ត្របែងចែកបុព្វលាភ ត្រូវបានអនុញ្ញាតសម្រាប់បំណុលសម្រាប់ការធានារ៉ាប់រងដែលនៅសល់សម្រាប់កិច្ចសន្យារយៈពេលខ្លីដែលត្រូវបានបង្ហាញលើការធានារ៉ាប់រងមិនមានជីវិត។

ការផ្លាស់ប្តូរគំរូនៃការវាស់ស្ទង់ទូទៅដែលគេហៅថា សម្រាប់កិច្ចសន្យាមួយចំនួន "វិធីសាស្ត្រតំលៃអថេរ" ដែលបានបង្ហាញលើការធានារ៉ាប់រងមានជីវិត ដែលឆ្លុះធ្វើគោលនយោបាយ ចែករំលែកជាការទទួលបានមកវិញនូវតម្លៃមូលដ្ឋាន។ នៅពេលអនុវត្តវិធីកំណត់តម្លៃអថេរ ការប្រែប្រួលតម្លៃទីផ្សារនៃភាគហ៊ុនក្រុមហ៊ុននៃតម្លៃមូលដ្ឋាន ត្រូវបានរួមបញ្ចូលនៅក្នុងចំណេញកម្រិតនៃកិច្ចសន្យាសេវា។ ជាលទ្ធផលក្រុមហ៊ុនធានារ៉ាប់រងដែលប្រើវិធីសាស្ត្រនេះទំនងជាមិនសូវប្រែប្រួលខ្លាំងជាងវិធីសាស្ត្រទូទៅទេ។

ច្បាប់ថ្មីនេះ នឹងប៉ះពាល់ដល់របាយការណ៍ហិរញ្ញវត្ថុ និងសូចនាករលទ្ធផលសំខាន់ៗរបស់ក្រុមហ៊ុនទាំងអស់ដែលបានចេញកិច្ចសន្យាធានារ៉ាប់រង ឬកិច្ចសន្យាវិនិយោគដែលមានលក្ខណៈពិសេសនៃការចូលរួម។

*វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ និង ស.គ.អ.ក ២៨ ការលក់ ឬការចែកចាយនៃទ្រព្យ រវាងអ្នកវិនិយោគនិងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន*

វិសោធនកម្មបញ្ជាក់ពីវិសាលភាពនៃប្រាក់ចំណេញឬខាត ដែលត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនលក់ ឬបរិចចាគទ្រព្យសកម្មទៅឱ្យក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុនរបស់ខ្លួន។ នៅពេលប្រតិបត្តិការពាក់ព័ន្ធនឹងអាជីវកម្មការចំណេញ ឬខាតត្រូវបានទទួលស្គាល់ពេញលេញ ផ្ទុយទៅវិញ នៅពេលដែលប្រតិបត្តិការទាក់ទងនឹងទ្រព្យសកម្ម ដែលមិនមែនជាអាជីវកម្មនោះការចំណេញឬខាតត្រូវបានទទួលស្គាល់តែទៅលើវិសាលភាពនៃផលប្រយោជន៍ វិនិយោគិនដែលមិនទាក់ទងគ្នានៅក្នុងក្រុមហ៊ុនរួមទុន ឬ ក្រុមហ៊ុនបុត្រសម្ព័ន្ធ។

# ផ្នែកទី ៨

# ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ

## ១. ប្រតិបត្តិការជាមួយភាគហ៊ុនិក

ក. ស. ភ. បានទទួលកម្ចីឥណទានចំនួន ២៨,៩ លានដុល្លារអាមេរិកក្នុងអត្រាការប្រាក់ ៤% ក្នុងមួយឆ្នាំពីធនាគារ **Export-Import Bank of China** នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កម្ចីនេះមានរយៈពេលអនុគ្រោះលើប្រាក់ដើមចំនួន ៧ឆ្នាំ ៣ខែ និង១៦ថ្ងៃ ដោយចាប់ផ្តើមពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១០ រហូតដល់ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨។ ចាប់ពីខែកុម្ភៈ ឆ្នាំ២០១៤ រហូតដល់ខែសីហា ឆ្នាំ២០១៧ ក. ស. ភ. ត្រូវធ្វើការបង់ការប្រាក់ពាក់កណ្តាលឆ្នាំក្នុងទឹកប្រាក់ ៥៧៩.៥៩២,៧៥ដុល្លារអាមេរិក។ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០៣១ ក. ស. ភ. ត្រូវធ្វើការបង់ប្រាក់ដើម រួមជាមួយនឹងការប្រាក់នៅពាក់កណ្តាលឆ្នាំនីមួយៗនៃ ឆ្នាំសារពើពន្ធ នៅថ្ងៃទី២០ ខែកុម្ភៈ និងខែសីហា។

ក. ស. ភ. ទទួលអំណោយជាដីពីរដ្ឋ និងទិញបន្ថែម ដែលមានបណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិអចលនវត្ថុដូចខាងក្រោម៖

- ចំណតផែTS៣ មានប្លង់កម្មសិទ្ធិលេខ ១២០២១០១២-០០១២ លេខ ១២០២១០១៥-០០៣៧ លេខ ១២០២១០១៤-០០៨៨ និងលេខ ១២០២១០១៣-០០៣៣
- ចំណតស្តុកកុងតឺន័រ ICD មានប្លង់កម្មសិទ្ធិលេខ ភព ០៦២៩០
- ក្អមសំណរ មានប្លង់កម្មសិទ្ធិលេខ ក.ណ ០១៩៨១០
- កោះរកា មានប្លង់កម្មសិទ្ធិលេខ ព.វ ០០៤០៣០ និង ព.វ ០០៤០៣១
- ចំណតផែកុងតឺន័រLM១៧ មានប្លង់កម្មសិទ្ធិលេខ ក.ណ០១៩៦៧១-៦៨១ លេខ ក.ណ ០១៩៦៨៣-៦៨៦ លេខ ក.ណ ០១៩៥៥២ លេខ ក.ណ ០០៩៣៩១-០០៩៣៩៣ និង លេខ ក.ណ ០១៨៣៦៥
- ចំណតផែអ្នកដំណើរ និងទេសចរ មានប្លង់កម្មសិទ្ធិលេខ ១២០២១១០៨-០០៤២ និងលេខ ១២០២១១០៩-០០៩៩។

## ២. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់មានផលប្រយោជន៍

សម្រាប់ ឆ្នាំ២០១៨ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ ក. ស. ភ. ទេ។

## ៣. ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

សម្រាប់ ឆ្នាំ២០១៨ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ ក. ស. ភ. ទេ។

## ៤. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គល ដែលមានទំនាក់ទំនងជាមួយអភិបាលរបស់កំពង់ផែស្វយ័តភ្នំពេញ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់កំពង់ផែស្វយ័តភ្នំពេញ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះ កើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលធ្វើឡើងដោយកំពង់ផែស្វយ័តភ្នំពេញ

សម្រាប់ ឆ្នាំ២០១៨ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ ក. ស. ភ. ទេ។

### ៥. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលក្នុងរយៈពេល ២ឆ្នាំចុងក្រោយ

សម្រាប់ ឆ្នាំ២០១៨ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ ក. ស. ភ. ទេ។

### ៦. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈ សម្រាប់សេវាដែលខ្លួនបានផ្តល់ តាមរយៈក្រុមហ៊ុនណាមួយ ដល់កំពង់ផែស្វយ័តភ្នំពេញ

សម្រាប់ ឆ្នាំ២០១៨ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ ក. ស. ភ. ទេ។

### ៧. ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធផ្សេងទៀត

សម្រាប់ ឆ្នាំ២០១៨ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ ក. ស. ភ. ទេ។

# ផ្នែកទី ៩
# ការវិភាគរបស់ថ្នាក់ដឹកនាំ

## ១.ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

ក.ស.ភ. គឺជាកំពង់ផែអន្តរជាតិមួយក្នុងចំណោមកំពង់ផែអន្តរជាតិទាំងពីរក្នុងប្រទេសកម្ពុជា។ ក.ស.ភ. មានមណ្ឌលអាជីវកម្មលាតសន្ធឹងពីភ្នំពេញ ដល់ទន្លេមេគង្គក្រោម (អ្នកលឿង) និងពីភ្នំពេញ ដល់ទន្លេមេគង្គលើ (ទន្លេបិទ) ដែលកំណត់ក្នុងអនុក្រឹត្យលេខ០១ ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩។ ក.ស.ភ. មានមុខងារជាអាជ្ញាធរផែ និងជាប្រតិបត្តិករផែ ដូចមានលម្អិតក្នុងផ្នែក១ ចំណុចទី២ នៃរបាយការណ៍ប្រចាំឆ្នាំ២០១៨នេះ។

បរិមាណកុងតឺន័រឆ្លងកាត់ ក.ស.ភ. ក្នុងឆ្នាំ២០១៨ មានការកើនឡើងចំនួន ២៨.៧៦៦ធីអ៊ីយូ ឬស្មើនឹង ១៥,៥៧% បើធៀបនឹងឆ្នាំ២០១៧។ ចំនួននាវាដឹកទំនិញសរុប ក្នុងឆ្នាំ២០១៨ មានការកើនឡើង ៣៥៧គ្រឿង ឬស្មើនឹង ២០,៧០% បើធៀបនឹងឆ្នាំ២០១៧។ ចំណែកនាវាដឹកអ្នកដំណើរកម្ពុជា និងអន្តរជាតិ ក្នុងឆ្នាំ ២០១៨ បានកើនឡើងចំនួន ១២២ជើងនាវា ឬស្មើនឹង ១៩,៥៨% បើធៀបនឹងឆ្នាំ២០១៧។ ទំនិញរាយឆ្លងកាត់ ក.ស.ភ. ក្នុងឆ្នាំ២០១៨ បានកើនឡើងចំនួន ២២៨.៣៥០តោន ឬស្មើនឹង ៥៥,៤៧% បើធៀបនឹងឆ្នាំ២០១៧។

ការពិភាក្សា និងការវិភាគរបស់ថ្នាក់ដឹកនាំលើស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ. និងលទ្ធផលប្រតិបត្តិការខាងក្រោមនេះ ធ្វើឡើងផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួចដោយសវនករឯករាជ្យ ក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៧ (គិតត្រឹមថ្ងៃទី៣១ ធ្នូ) ដូចបង្ហាញក្នុងផ្នែកទី៧ នៃរបាយការណ៍ប្រចាំឆ្នាំ ២០១៨នេះ។

*ក.ស.ភ. មានប្រភពចំណូលសំខាន់ៗចំនួន ៥ប្រភេទ៖*

***១.ចំណូលពីការលើកដាក់ក្រោមដងយោង (Stevedoring)*** ៖ សំដៅលើចំណូលដែលបានមកពីសេវាកម្មផ្ទេរ-ផ្ទុកទំនិញ/កុងតឺន័រពីនាវា និងដឹកជញ្ជូនពីស្ពានផែទៅទីលាននិងពីទីលានមកស្ពានផែ។

***២.ចំណូលពីការលើកដាក់លើទីលាន (LOLO)***៖សំដៅលើចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញ/កុងតឺន័រពីទីលានដាក់លើរថយន្ត និងពីរថយន្តដាក់លើទីលាន។

***៣.ចំណូលពីកិច្ចការផែ (PortDue & Charge)***៖សំដៅលើចំណូលដែលបានមកពីសេវាកម្មនាវាចរណ៍ និងការចូលចតនាវា រួមមាន ពន្ធលើចំណុះផ្ទុក ពន្ធសំចត ពន្ធប្រឡាយ ថ្លៃឈ្នួលកណ្ដាធារកិច្ច ថ្លៃឈ្នួលនាវាសណ្ដោង ថ្លៃឈ្នួលពាក់-ដោះពួរ ថ្លៃឈ្នួលបើក-បិទឃ្លប់នាវា និងថ្លៃឈ្នួលបោសសម្អាតឃ្លប់នាវា។

***៤.ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ (Storage Fee)***៖សំដៅលើចំណូលដែលបានមកពីការស្តុកទំនិញ/កុងតឺន័រនៅលើទីលាន ឬក្នុងឃ្លាំង។ ទំនិញរាយ មានការអនុគ្រោះថ្លៃស្តុក ៥ថ្ងៃ ទាំងនាំចេញ និងនាំចូល និងទំនិញជាកុងតឺន័រ មានការអនុគ្រោះថ្លៃស្តុក ៥ថ្ងៃសម្រាប់ការនាំចេញ និង៧ថ្ងៃសម្រាប់ការនាំចូល។

***៥. ចំណូលពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ (Sand dredging management fee)***៖សំដៅដល់ចំណូលដែលបានមកពីសេវាកម្មគ្រប់គ្រងអាជីវកម្មខ្សាច់(ប្រឡាយនាវាចរណ៍)។

## ក. ការវិភាគចំណូល

### ក.១.ការវិភាគចំណូល

ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| ចំណូលប្រតិបត្តិការផែ | ១៧.២៧៧.៧៨៥ | ៦៩.៨៨៨.៦៨០ | ១៥.៨៦១.០៥៦ | ៦២.៥៣៩.៩៧១ | ១.៨១៦.៧២៩ | ១១,៧៥% | ៧.៣៤៨.៦៦៩ | ១១,៧៥% |
| ចំណូលអាជ្ញាធរផែ | ៣.៩១៣.៧៩៧ | ១៣.៨០៨.៨០៩ | ៣.១៦៥.៦១៩ | ១២.៨០៤.៩២៩ | ២៤៨.១៧៨ | ៧,៨៤% | ១.០០៣.៨៨០ | ៧,៨៤% |
| សេវាផ្សេងៗ | ៣១.៣៤៦ | ១២៦.៧៩៥ | ២២៩.៦២១ | ៩២៨.៨១៧ | (១៩៨.២៧៥) | -៨៦,៣៥% | (៨០២.០២២) | -៨៦,៣៥% |
| **សរុប:** | **២០.៧២២.៩២៨** | **៨៣.៨២៤.២៨៤** | **១៨.៨៥៦.២៩៦** | **៧៦.២៧៣.៧១៧** | **១.៨៦៦.៦៣២** | **៩,៩០%** | **៧.៥៥០.៥២៧** | **៩,៩០%** |

ចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្ម បានកើនឡើងចំនួន ៧.៥៥០.៥២៧ ពាន់រៀល (១.៨៦៦.៦៣២ ដុល្លារអាមេរិក) ឬស្មើនឹង ៩,៩០% ពី ៧៦.២៧៣.៧១៧ ពាន់រៀល (១៨.៨៥៦.២៩៦ ដុល្លារអាមេរិក) សម្រាប់ឆ្នាំ២០១៧ ដល់ ៨៣.៨២៤.២៨៤ ពាន់រៀល (២០.៧២២.៩២៨ ដុល្លារអាមេរិក) សម្រាប់ឆ្នាំ២០១៨។ ការកើនឡើងនេះ បណ្តាលមកពីកំណើននៃចំណូលប្រតិបត្តិការផែ [ចំណូលលើកដាក់ក្រោមដងយោង (Stevedoring) ចំណូលលើកដាក់លើទីលាន (LOLO)] និងកំណើននៃចំណូលអាជ្ញាធរផែ (ចំណូលពីកិច្ចការផែ)។

## *ក.២. ការវិភាគចំណូលតាមផ្នែក*

**ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ប្រៀបធៀបនឹងដំណាច់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | |
|---|---|---|---|---|
| | ពាន់រៀល | ប្រៀបធៀបនឹងចំណូលសរុប | ពាន់រៀល | ប្រៀបធៀបនឹងចំណូលសរុប |
| ចំណូលលើកដាក់ក្រោមដងយោង(Stevedoring) | ៣៥.៣៧៧.៩៩១ | ៤២,២២% | ៣១.២៩៨.០៦២ | ៤១,០៥% |
| ចំណូលលើកដាក់លើទីលាន(LOLO) | ២៩.៧៣៤.៧៤២ | ៣៥,៤៧% | ២៦.៦៨៩.៣៥១ | ៣៤,៩៩% |
| ចំណូលពីកិច្ចការផែ | ១៣.៨០៨.៨០៩ | ១៦,៤៧% | ១២.៨០៤.៩២៩ | ១៦,៧៩% |
| ចំណូលពីច្រកទ្វារ | ៣.១៨៥.០២១ | ៣,៨០% | ២.៧១១.៤៨១ | ៣,៥៥% |
| ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ | ១.៤៩៦.២១៧ | ១,៧៨% | ១.៧២៣.៤៦៥ | ២,២៦% |
| ចំណូលពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ | ១២៦.៧៩៥ | ០,១៥% | ១៥៥.៦៣១ | ០,២០% |
| ចំណូលពីការវាស់ស្ទង់ | - | - | ៧៧៣.១៨៦ | ១,០១% |
| ចំណូលពីការដឹកជញ្ជូន | ៨.៦៦៨ | ០,០១% | ២.៩៨៥ | ០,០០% |
| ចំណូលពីថ្លៃឈ្នួលថ្លឹងកុងតឺន័រ | ២៧.២៤៣ | ០,០៣% | ១១៣.៧៨២ | ០,១៥% |
| ចំណូលពីសេវាកម្មជួសជុលនិងថែទាំកុងតឺន័រ | ៩១៤ | - | ៨៨៥ | - |
| ចំណូលពីការរើរៀបទំនិញ | ៥៧.៨៩៩ | ០,០៧% | - | - |
| **សរុប:** | **៨៣.៨២៤.២៩៩** | **១០០,០០%** | **៧៦.២៧៣.៧១៧** | **១០០,០០%** |

សម្រាប់ឆ្នាំ២០១៨ ក៏ដូចជាឆ្នាំ២០១៧ ក.ស.ភ. មានកំណើនលើចំណូល ៣ប្រភេទធំៗ ដែលមានចំនួនប្រមាណ **៩៤ %** នៃចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្ម ។ ចំណូលទាំងនោះរួមមាន៖ ចំណូលលើកដាក់ក្រោមដងយោង ចំណូលលើកដាក់លើទីលាន និងចំណូលពីកិច្ចការផែ។

**ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

សម្រាប់ឆ្នាំ២០១៨ ចំណូល ៣ប្រភេទធំៗ បានកើនឡើងចំនួន ៨ ពាន់រៀល ២០០.១២៩.(២ដុល្លារអាមេរិក ៦៩១.០០៩.) ឬស្មើនឹង ១១បើ ៨៨%,ធៀបនឹងឆ្នាំ២០១៧។

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| ចំណូលលើកដាក់ក្រោមដងយោង (Stevedoring) | ៨.៧៤៦.១០៤ | ៣៥.៣៧៧.៩៩១ | ៧.៧៣៧.៤៦៩ | ៣១.២៩៨.០៦២ | ១.០០៨.៦៣៥ | ១៣,០៤% | ៤.០៧៩.៩២៩ | ១៣,០៤% |
| ចំណូលលើកដាក់លើទីលាន(LOLO) | ៧.៣៥០.៩៨៧ | ២៩.៧៣៤.៧៩២ | ៦.៥៩៨.១០៩ | ២៦.៦៨៩.៣៥១ | ៧៥២.៨៧៨ | ១១,៤១% | ៣.០៤៥.៣៩១ | ១១,៤១% |
| ចំណូលពីកិច្ចការផែ | ៣.៤១៣.៧៩៧ | ១៣.៨០៨.៨០៩ | ៣.១៦៥.៦១៩ | ១២.៨០៤.៩២៩ | ២៤៨.១៧៨ | ៧,៨៤% | ១.០០៣.៨៨០ | ៧,៨៤% |

## ខ.ការវិភាគតំលាតប្រាក់ចំណេញដុល

ប្រាក់ចំណេញដុលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត របស់ ក.ស.ភ. ដែលបានមកពីចំណូលសរុបនៃផលអាជីវកម្ម និងសេវាកម្ម ដកនឹងចំណាយថ្លៃដើមនៃសេវាកម្ម(ចំណាយប្រតិបត្តិការ)។

**ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| **ចំណូល** | **២០.៧២២.៩២៨** | **៨៣.៨២៨.២៨៨** | **១៨.៨៥៦.២៩៦** | **៧៦.២៧៣.៧១៧** | **១.៨៦៦.៦៣២** | **៩,៩០%** | **៧.៥៥០.៥២៧** | **៩,៩០%** |
| **ថ្លៃដើមនៃសេវាកម្ម** | | | | | | | | |
| រំលស់ទ្រព្យពាងចក្រ បរិក្ខារ | ២.៦១៩.៦៧៧ | ១០.៥៩៦.៥៩៣ | ២.៥០៨.៨៥៨ | ១០.១៤៨.៣៣១ | ១១០.៨១៩ | ៤,៤២% | ៤៤៨.២៦២ | ៤,៤២% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ថ្លៃដងយោង | ១.៧៣៥.៨០០ | ៧.០២១.៣១១ | ១.៥១៥.៩៣៨ | ៦.១៣១.៩៦៩ | ២១៩.៨៦២ | ១៤,៥០% | ៨៨៩.៣៤២ | ១៤,៥០% |
| ប្រាក់បៀវត្ស និងប្រាក់ឈ្នួល | ១.៣៦១.០១០ | ៥.៥០៥.២៨៥ | ១.១៩៨.០០១ | ៤.៨៤៥.៩១៤ | ១៦៣.០០៩ | ១៣,៦១% | ៦៥៩.៣៧១ | ១៣,៦១% |
| ប្រេងឥន្ធនៈ(ប្រតិបត្តិការ និងបូមស្តារប្រឡាយនាវាចរណ៍) | ៨៣៨.៧៩០ | ៣.៣៩២.៩០៦ | ៦០៨.៤៧៨ | ២.៤៦១.២៩៤ | ២៣០.៣១២ | ៣៧,៨៥% | ៩៣១.៦១២ | ៣៧,៨៥% |
| ការជួសជុល និងថែទាំ | ៥១០.៥៥៦ | ២.០៦៥.១៩៧ | ៣៨៤.២៩៤ | ១.៥៥៤.៤៦៩ | ១២៦.២៦២ | ៣២,៨៦% | ៥១០.៧២៨ | ៣២,៨៦% |
| ចំណាយលើការគ្រប់គ្រងអាជីវកម្មខ្សាច់ | ៦.៦០៨ | ២៦.៧៣១ | ៣៨.៥០៧ | ១៥៥.៧៦១ | (៣១.៨៩៩) | -៨២,៨៤% | (១២៩.០៣០) | -៨២,៨៤% |
| ការវាស់ស្ទង់ | - | - | ៧.៤៧២ | ៣០.២២៤ | (៧.៤៧២) | -១០០,០០% | (៣០.២២៤) | -១០០,០០% |
| ចំណាយលើសេវាកម្មជួសជុលនិងថែទាំកុងតឺន័រ | ១៧៧ | ៧១៦ | ១៨៧ | ៧៥៦ | (១០) | -៥,៣៥% | (៤០) | -៥,២៩% |
| ផ្សេងៗ | ១៦២.១៦៤ | ៦៥៥.៩៥៤ | ១៩៩.០៥៩ | ៨០៥.១៩៤ | (៣៦.៨៩៥) | -១៨,៥៣% | (១៤៩.២៤០) | -១៨,៥៣% |
| **សរុបថ្លៃដើមនៃសេវាកម្ម** | **៧.២៣៤.៧៨២** | **២៩.២៦៤.៦៩៣** | **៦.៤៦០.៧៩៤** | **២៦.១៣៣.៩១២** | **៧៧៣.៩៨៨** | **១១,៩៨%** | **៣.១៣០.៧៨១** | **១១,៩៨%** |
| **ប្រាក់ចំណេញដុល** | **១៣.៨៤៨.១៩៦** | **៥៤.៥៥៩.៥៥១** | **១២.៣៩៥.៥០២** | **៥០.១៣៩.៨០៥** | **១.០៩២.៦៩៤** | **៨,៨១%** | **៤.៤១៩.៧៤៦** | **៨,៨១%** |
| **អត្រាគំលាតប្រាក់ចំណេញដុល** | **៦៥,០៩%** | **៦៥,០៩%** | **៦៥,៧៤%** | **៦៥,៧៤%** | | | | |

សម្រាប់ឆ្នាំ២០១៨ ចំណាយថ្លៃដើមនៃសេវាកម្ម បានកើនឡើងចំនួន ៣.១៣០.៧៨១ ពាន់រៀល (៧៧៣.៩៨៨ ដុល្លារអាមេរិក) ឬស្មើនឹង ១១,៩៨% បើធៀបនឹងឆ្នាំ២០១៧។

- អត្រាគំលាតប្រាក់ចំណេញដុល

អត្រាគំលាតប្រាក់ចំណេញដុលបានថយចុះចំនួន ០,៦៥% ពីអត្រា ៦៥,៧៤% ក្នុងឆ្នាំ២០១៧ ទៅ ៦៥,០៩ % ក្នុង ឆ្នាំ២០១៨។ ការថយចុះនៃអត្រាគំលាតប្រាក់ចំណេញដុលដោយសារតែចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មមានការកើនឡើងចំនួន ៧.៥៥០.៥២៧ ពាន់រៀល (១.៨៦៦.៦៣២ដុល្លារអា

មេរិក) ឬស្មើនឹង ៩,៩០%។ ចំណែកឯ ចំណាយថ្លៃដើមនៃសេវាកម្មមានការកើនឡើងចំនួន ៣.១៣០.៧៨១ពាន់រៀល (៧៧៣.៩៨៨ដុល្លារអាមេរិក) ឬស្មើនឹង ១១,៩៨% គឺដោយសារមានការកើនឡើងទៅលើចំណាយថ្លៃដើមនៃសេវាកម្មមួយចំនួនដូចជា ចំណាយទៅលើការប្រើប្រាស់ប្រេងឥន្ធនៈ ការជួសជុល និងថែទាំ និង ថ្លៃដងយោង ជាដើម។

## គ. ការវិភាគប្រាក់ចំណេញមុនបង់ពន្ធ

ប្រាក់ចំណេញមុនបង់ពន្ធ គឺបានមកពីប្រាក់ចំណេញដុល បូកចំណូលផ្សេងៗ ដកនឹងចំណាយរដ្ឋបាលទូទៅ និងចំណាយហិរញ្ញប្បទាន។

ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| **ប្រាក់ចំណេញដុល** | **១៣.៨៨៨.១៩៦** | **៥៤.៥៥៩.៥៥១** | **១២.៨៩៥.៥០២** | **៥០.១៣៩.៨០៥** | **១.០៩២.៦៩៤** | **៨,៨១%** | **៤.៤១៩.៧៤៦** | **៨,៨១%** |
| **ចំណូលផ្សេងៗ** | **១.៤៥៧.៦៥៨** | **៥.៨៩៦.២២៧** | **៦០៣.៩៦៨** | **២.៤៤៣.០៥១** | **៨៥៣.៦៩០** | **១៤១,៣៥%** | **៣.៤៥៣.១៧៦** | **១៤១,៣៥%** |
| ចំណាយរដ្ឋបាលទូទៅនិងការលក់ | | | | | | | | |
| ចំណាយប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗ | ៣.៥០៣.៨០២ | ១៤.១៧២.៨៧៩ | ៣.១៤៦.១៧១ | ១២.៧២៦.២៦២ | ៣៥៧.៦៣១ | ១១,៣៧% | ១.៤៤៦.៦១៧ | ១១,៣៧% |
| អំណោយសទ្ធារទាន | ៤៩២.១៦៨ | ១.៩៩០.៨២០ | ៣៨៦.៦១៣ | ១.៥៦៣.៨៥០ | ១០៥.៥៥៥ | ២៧,៣០% | ៤២៦.៩៧០ | ២៧,៣០% |
| ចំណាយទឹក-ភ្លើង និងប្រេងឥន្ធនៈ | ៤៤០.០៧៩ | ១.៧៨០.១២០ | ៤៤០.៥០០ | ១.៧៨១.៨២៣ | (៤២១) | -០,១០% | (១.៧០៣) | -០,១០% |
| ចំណាយរំលស់លើទ្រព្យវិនិយោគនិងទ្រព្យរោងចក្របរិក្ខារ | ៣៤៣.៥៧៨ | ១.៣៨៩.៧៧៣ | ៣៨៥.៣១៧ | ១.៥៥៨.៦០៧ | (៤១.៧៣៩) | -១០,៨៣% | (១៦៨.៨៣៤) | -១០,៨៣% |
| ចំណាយជួសជុលនិង ថែទាំ | ១៤៦.៧៨៤ | ៥៩៣.៩៧៩ | ១៣៧.១៨១ | ៥៥៤.៨៩៧ | ៩.៥៦៣ | ៦,៩៧% | ៣៨.៦៨២ | ៦,៩៧% |
| ចំណាយលើការកំសាន្ត | ២១៦.២៥៤ | ៨៧៤.៧៤៧ | ១៩២.០២៣ | ៧៧៦.៧៣៣ | ២៤.២៣១ | ១២,៦២% | ៩៨.០១៤ | ១២,៦២% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំណាយការធ្វើដំណើរ | ៥៦.៦០៤ | ២២៨.៩៦៣ | ១០៩.៧២៥ | ៤៤៣.៨៣៨ | (៥៣.១២១) | -៤៨,៤១% | (២១៤.៨៧៥) | -៤៨,៤១% |
| ចំណាយជំនាញវិជ្ជាជីវៈ | ៣៩.០៥៧ | ១៥៧.៩៨៦ | ៥១.២១៨ | ២០៧.១៧៧ | (១២.១៦១) | -២៣,៧៤% | (៤៩.១៩១) | -២៣,៧៤% |
| ចំណាយកម្រៃក្រុមប្រឹក្សាភិបាល | ២០៩.១៩៧ | ៨៤៦.២០២ | ២០៩.២២០ | ៨៤៦.២៩៥ | (២៣) | -០,០១% | (៩៣) | -០,០១% |
| ចំណាយសម្ភារផ្គត់ផ្គង់ការិយាល័យ | ៩១.៣៤៨ | ៣៦៩.៥០៣ | ១០២.៥៧១ | ៤១៤.៩០០ | (១១.២២៣) | -១០,៩៤% | (៤៥.៣៩៧) | -១០,៩៤% |
| ចំណាយទំនាក់ទំនងផ្សេងៗ | ៥៩.៥៧៨ | ២៤០.៩៩៣ | ៥៣.៨៤៦ | ២១៧.៨០៧ | ៥.៧៣២ | ១០,៦៥% | ២៣.១៨៦ | ១០,៦៥% |
| ចំណាយពន្ធផ្សេងៗ | ៦៧.៦៦៩ | ២៧៣.៧២១ | ៣០.៧១០ | ១២៤.២២២ | ៣៦.៩៥៩ | ១២០,៣៥% | ១៤៩.៤៩៩ | ១២០,៣៥% |
| ផ្សេងៗ | ៣៦៦.១៨០ | ១.៤៨១.១៩៧ | ៣១៦.១២៤ | ១.២៧៨.៧២០ | ៥០.០៥៦ | ១៥,៨៣% | ២០២.៤៧៧ | ១៥,៨៣% |
| **សរុបចំណាយរដ្ឋបាលទូទៅនិងការលក់** | **៦.០៩៣.២៧២** | **២៤.៦៤៧.២៨៥** | **៥.៥៦១.២១៩** | **២២.៤៩៥.១៣១** | **៥៣២.០៥៣** | **៩,៥៧%** | **២.១៥២.១៥៤** | **៩,៥៧%** |
| **ចំណាយហិរញ្ញប្បទាន** | **(១.១៧០.២២៧)** | **(៤.៧៣៣.៥៦៨)** | **(១.២៥៤.៧៦៧)** | **(៥.០៧៥.៥៣៣)** | **៨៤.៥៤០** | **-៦,៧៤%** | **៣៤១.៩៦៥** | **-៦,៧៤%** |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **៧.៦៨២.៣០៥** | **៣១.០៧៤.៩២៥** | **៦.១៨៣.៤៨៤** | **២៥.០១២.១៩២** | **១.៤៩៨.៨២១** | **២៤,២៤%** | **៦.០៦២.៧៣៣** | **២៤,២៤%** |

សម្រាប់ឆ្នាំ២០១៨ ចំណាយថ្លៃរដ្ឋបាលទូទៅ និងការលក់ បានកើនឡើងចំនួន ២.១៥២.១៥៤ ពាន់រៀល (៥៣២.០៥៣ ដុល្លារអាមេរិក) ឬស្មើនឹង ៩,៥៧% បើធៀបនឹងឆ្នាំ២០១៧។

### *ឃ.ការវិភាគប្រាក់ចំណេញក្រោយបង់ពន្ធ*

ក.ស.ភ. ស្ថិតនៅក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះ ក.ស.ភ. មានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំក្នុងអត្រា២០% ប៉ុន្តែក្រោយពី ក.ស.ភ. បានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈកាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ គឺ ក.ស.ភ. ទទួលបានការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ។

### ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| ប្រាក់ចំណេញមុនបង់ពន្ធ (ក) | ៧.៦៨២.៣០៥ | ៣១.០៧៤.៩២៥ | ៦.១៨៣.៤៨៤ | ២៥.០១២.១៩២ | ១.៤៩៨.៨២១ | ២៤,២៤% | ៦.០៦២.៧៣៣ | ២៤,២៤% |
| ចំណាយពន្ធលើប្រាក់ចំណេញ(ខ) | (៤១៨.៤៣៣) | (១.៦៩២.៥៦១) | ៨២១.៦៥១ | ៣.៣២៣.៥៧៨ | (១.២៤០.០៨៤) | -១៥០,៩៣% | (៥.០១៦.១៣៩) | -១៥០,៩៣% |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ៨.១០០.៧៣៨ | ៣២.៧៦៧.៤៨៦ | ៥.៣៦១.៨៣៣ | ២១.៦៨៨.៦១៤ | ២.៧៣៨.៩០៥ | ៥១,០៨% | ១១.០៧៨.៨៧២ | ៥១,០៨% |
| **អត្រាពន្ធមធ្យម(ខ)/(ក)** | **-៥,៤៥%** | **-៥,៤៥%** | **១៣,២៩%** | **១៣,២៩%** | | | | |

ក.ស.ភ.ទទួលបានប្រាក់ចំណេញសុទ្ធសម្រាប់ឆ្នាំ២០១៨ ចំនួន ៣២.៧៦៧.៤៨៦ ពាន់រៀល (៨.១០០.៧៣៨ ដុល្លារអាមេរិក) និងសម្រាប់ឆ្នាំ២០១៧ ចំនួន ២១.៦៨៨.៦១៤ ពាន់រៀល (៥.៣៦១.៨៣៣ ដុល្លារអាមេរិក) ដែលបង្ហាញឱ្យឃើញនូវការកើនឡើងនូវប្រាក់ចំណេញសុទ្ធចំនួន ១១.០៧៨.៨៧២ ពាន់រៀល (២.៧៣៨.៩០៥ ដុល្លារអាមេរិក) ឬស្មើនឹង ៥១,០៨%។ ការកើនឡើងនេះដោយសារចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មកើនឡើងស្មើនឹង៩,៩០% បើធៀបនឹងឆ្នាំ២០១៧។

ការថយចុះនៃអត្រាពន្ធមធ្យមចំនួន ១៨,៧៤% ពី ១៣,២៩% ក្នុងឆ្នាំ២០១៧ ទៅ -៥,៤៥% ក្នុងឆ្នាំ២០១៨ ដោយសារកើតមានពន្ធពន្យារលើទ្រព្យសកម្ម (Deferred tax asset) ទើបបណ្តាលឱ្យចំណាយពន្ធលើប្រាក់ចំណេញមានការថយចុះចំនួន ៥.០១៦.១៣៩ ពាន់រៀល(១.២៤០.០៨៤ដុល្លារអាមេរិក) ឬស្មើនឹង ១៥០,៩៣%។

## ង.ការវិភាគពីកត្តានិងនិន្នាការដែលប៉ះពាល់ដល់ស្ថានភាពនិងលទ្ធផលហិរញ្ញវត្ថុ

### ង.១. កំរិតនៃការជួញដូរក្នុងតំបន់និងជាសកលនិងសកលភាវូបនីយកម្ម

ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការរបស់ ក.ស.ភ. អាស្រ័យលើបរិមាណកុងតឺន័រឆ្លងកាត់ និង សកម្មភាពដឹកជញ្ជូនឆ្លងកាត់កំពង់ផែដែលពឹងផ្អែកលើទំហំពាណិជ្ជកម្មក្នុងស្រុក និងទូទាំងពិភពលោក ព្រមទាំងបរិមាណនៃការនាំចេញនិងការនាំចូលក្នុងតំបន់ដែលត្រូវបានធ្វើប្រតិបត្តិការ។ បរិមាណនៃការជួញដូរក្នុងស្រុក និងទូទាំងពិភពលោក និងបរិមាណនៃការនាំចេញ និងនាំចូលក្នុងស្រុកដែលបានធ្វើប្រតិបត្តិការនេះទទួលរងផលប៉ះពាល់ដោយសារការផ្លាស់ប្តូរលក្ខខណ្ឌសេដ្ឋកិច្ចហិរញ្ញវត្ថុ និងនយោបាយក្នុងតំបន់និងសកលដែលហួសពីការគ្រប់គ្រងរបស់ ក.ស.ភ.។

### ង.២. សមត្ថភាពទទួលកុងតឺន័រនៅចំណតផែកុងតឺន័រLM១៧

ការលើកដាក់ចំបងៗត្រូវបានធ្វើឡើងនៅចំណតផែកុងតឺន័រLM១៧។ ក.ស.ភ. មានសមត្ថភាពលើកដាក់ទំនិញជាកុងតឺន័រប្រមាណ ២១៣.៥៧១ ធីអ៊ីយូ ក្នុងមួយឆ្នាំគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ ក.ស.ភ. ដើម្បីឆ្លើយតបនឹងកំណើននាឆ្នាំបន្ទាប់ ក.ស.ភ. មានគម្រោងនឹងបញ្ចប់ការអភិវឌ្ឍហេដ្ឋារចនា-សម្ព័ន្ធផែដំណាក់កាលទី៣ ដែលនឹងបង្កើនសមត្ថភាពលើកដាក់កុងតឺន័រនៅចំណតផែកុងតឺន័រLM១៧ បន្ថែមចំនួន ២០០.០០០ ធីអ៊ីយូ។

| បរិយាយ | សមត្ថភាពលើកដាក់ | | | | |
|---|---|---|---|---|---|
| | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ផែនការ ឆ្នាំ២០១៩ |
| ចំណតផែកុងតឺន័រ LM១៧ (ធីអ៊ីយូ) | ១៥០.០០០ | ១៥១.៧៨១ | ១៨៥.៨០៥ | ២១៣.៥៧១ | ២៣៩.០០០ |

### ង.៣.ប្រសិទ្ធភាពនៃប្រតិបត្តិការ

ដើម្បីបង្កើនប្រសិទ្ធភាពខ្ពស់ក្នុងប្រតិបត្តិការ ក.ស.ភ. មានគោលការណ៍កាត់បន្ថយចំណាយថ្លៃដើមដោយប្រើធនធានដែលមានស្រាប់ និងការបំពាក់គ្រឿងចក្រលើកដាក់ទំនើបៗសម្រាប់បំរើឱ្យប្រតិបត្តិការ។ ជាក់ស្តែង ក.ស.ភ. បានអនុវត្តនូវវិធានការដូចខាងក្រោម ដើម្បីបង្កើនប្រសិទ្ធភាពប្រតិបត្តិការៈ

- បន្តបំពាក់គ្រឿងចក្រលើកដាក់ទំនើបៗដើម្បីបង្កើនល្បឿននៃការលើកដាក់ទំនិញនិងកាត់បន្ថយការរង់ចាំដោយសារការខូចខាតគ្រឿងចក្រ
- បន្តជម្រុញសមត្ថភាពផ្នែកប្រតិបត្តិការតាមរយៈការបណ្តុះបណ្តាល
- ពង្រីកចំណតផែដើម្បីធានាថានាវាដឹកកុងតឺន័រអាចដឹកជញ្ជូនចេញចូលបានលឿន និងប្រកបដោយប្រសិទ្ធភាព
- ការពង្រីកទីលានស្តុកកុងតឺន័រជំហានទី២ នៅចំណតផែកុងតឺន័រ LM១៧
- គ្រប់គ្រងទីលានស្តុកកុងតឺន័រឱ្យមានប្រសិទ្ធភាព ដោយកាត់បន្ថយការរក្សាទុកកុងតឺន័រនៅលើទីលានក្នុងរយៈពេលយូរ

- ប្រើប្រាស់ចំណតផែឲ្យមានប្រសិទ្ធភាព ដោយការរៀបចំទីតាំងចូលចតនាវាទៅតាមផែនការច្បាស់លាស់។

### ង.៤. *តម្លៃ*

ក្នុងគោលបំណងដើម្បីរក្សាអតិថិជន ដែលមានស្រាប់ និងទាក់ទាញអតិថិជនថ្មី បន្ថែមទៀត ក.ស.ភ. បានផ្តល់តម្លៃអនុគ្រោះ លើសេវាពន្ធនាវា ដល់នាវាទេសចរណ៍ នាវាដឹកជញ្ជូនទំនិញរាយ និងនាវាដឹកជញ្ជូនកុងតឺន័រ និងប្រភេទនាវាដឹកជញ្ជូនទំនិញផ្សេងៗទៀត។ ជាមួយគ្នានេះដែរ ក.ស.ភ. ក៏បានផ្តល់តម្លៃអនុគ្រោះដល់សេវាកម្មលើកដាក់ទំនិញរាយ ទាំងនៅចំណតផែកុងតឺន័ររបស់ ក.ស.ភ. និងនៅក្រៅចំណតផែរបស់ ក.ស.ភ.។ ក្រៅពីការអនុគ្រោះថ្លៃសេវាកម្មលើកដាក់ទំនិញរាយ ក.ស.ភ. ក៏បានផ្តល់តម្លៃអនុគ្រោះជាកញ្ចប់សម្រាប់សេវាកម្មលើកដាក់កុងតឺន័រ (Stevedore) ដល់ក្រុមហ៊ុនដឹកជញ្ជូនកុងតឺន័រទាំងអស់ដោយផ្អែកតាមបរិមាណកុងតឺន័រដែលដឹកជញ្ជូនបាន។ នេះមានន័យថា បើនាវាដឹកជញ្ជូនកុងតឺន័ររបស់ក្រុមហ៊ុនណាមួយ ដែលដឹកជញ្ជូនកុងតឺន័របានកាន់តែច្រើន នឹងទទួលបានការបញ្ចុះតម្លៃលើកទឹកចិត្តកាន់តែច្រើន។

### ង.៥. *ការតភ្ជាប់រវាងផែរណប*

ការតភ្ជាប់រវាងផែរណបដើរតួនាទីយ៉ាងសំខាន់ ដែលក្រុមហ៊ុនដឹកជញ្ជូនធ្វើការជ្រើសរើសកំពង់ផែសម្រាប់ការដឹកជញ្ជូនទំនិញ។ ការតភ្ជាប់រវាងផែរណបដែលមានប្រសិទ្ធភាពអាចជំរុញឱ្យអ្នកដឹកជញ្ជូនកាត់បន្ថយ ពេលវេលាដឹកជញ្ជូន។ ប្រសិទ្ធភាពចរាចរណ៍រវាងផែរណប អាស្រ័យទៅលើសេវាកម្មផែរណបផ្សេងទៀតដែលគ្រប់គ្រងលើចរាចរណ៍នៃការដឹកជញ្ជូនទំនិញ ព្រោះថាទីតាំងរបស់ ក.ស.ភ. មានអំណោយផលសម្រាប់ការប្រមូលទំនិញដើម្បីដឹកជញ្ជូនតាមផ្លូវទឹក។

### ង.៦. *ការរំលស់*

ការរំលស់កើតឡើងពីការរំលស់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារកំពង់ផែ រួមទាំង ចំណតនាវា អគារ ឃ្លាំង និងគ្រឿងចក្រលើកដាក់។ ការប៉ាន់ស្មានអាយុកាលប្រើប្រាស់ទ្រព្យសំខាន់ៗ មានដូចជាចំណតនាវា អគារ (១០-៥០ឆ្នាំ) គ្រឿងចក្រគ្រឿងម៉ាស៊ីន (១០-១៥ឆ្នាំ) គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ (៥ឆ្នាំ) កុំព្យូទ័រ (៥-១៥ឆ្នាំ) សម្ភារការិយាល័យ និងផ្សេងៗ (៥-១៥ឆ្នាំ) និងយានយន្ត (៨-១៥ឆ្នាំ)។ វិធីសាស្ត្ររំលស់អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ត្រូវបានពិនិត្យ នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវកែសម្រួលប្រសិនបើសមស្រប។

## ២.កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### *ក.កត្តាសេដ្ឋកិច្ចជាតិ តំបន់ និងសកល*

បរិមាណទំនិញឆ្លងកាត់ ក.ស.ភ. ទាក់ទងដោយផ្ទាល់ទៅនឹង កត្តាសេដ្ឋកិច្ចជាតិតំបន់ ឬ សកល។ ជាការចាំបាច់ដែល ក.ស.ភ. ត្រូវធ្វើការវិភាគសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដើម្បីបានដឹងនូវនិន្នាការ កំណើន ឬ

ការធ្លាក់ចុះនៃតម្រូវការដឹកជញ្ជូន។ នេះជាមូលដ្ឋាន ដើម្បីរៀបចំឆ្លើយតបបានទាន់ពេលវេលា ក៏ដូចជាធ្វើផែនការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ឬក៏បំពាក់គ្រឿងចក្របានសមស្រប។ នេះក៏អាចជួយឲ្យ ក.ស.ភ. ជៀសបានពីការវិនិយោគហួសតម្រូវការ ដែលធ្វើឲ្យខាតប្រយោជន៍ពីការប្រើប្រាស់ទុន ឬកប់ទុន ក្នុងករណីដែលតម្រូវការដឹកជញ្ជូនអាចធ្លាក់ចុះ។

## ខ.ការគ្រប់គ្រងថ្លៃដើមនៃសេវាកម្ម

ការរក្សាបាននូវភាពប្រកួតប្រជែងខ្ពស់ក្នុងទីផ្សារ ជាកត្តាសំខាន់សម្រាប់និរន្តភាពនៃការរីកលូតលាស់របស់ ក.ស.ភ. ក្នុងនោះ គឺគុណភាពសេវាកម្ម និងតម្លៃសេវាកម្មសមរម្យ។ ដើម្បីធានាបាននូវតម្លៃថ្លៃដើមនៃសេវាកម្មប្រកួតប្រជែង ក.ស.ភ. យកចិត្តទុកដាក់លើការគ្រប់គ្រងចំណាយប្រតិបត្តិការមួយចំនួនដូចខាងក្រោម៖

### ខ.១. ចំណាយបៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀតលើបុគ្គលិក

ផ្នែកមួយនៃការចំណាយច្រើន គឺទៅលើបៀវត្សបុគ្គលិក និងអត្ថប្រយោជន៍ផ្សេងៗដែលស្មើនឹងអត្រា **២៣,៤៨%** (អត្រា ៦,៥៧% ជាបៀវត្សបុគ្គលិកផ្នែកប្រតិបត្តិការ និងអត្រា ១៦,៩១% ជាបៀវត្សបុគ្គលិកផ្នែករដ្ឋបាល និងអត្ថប្រយោជន៍ផ្សេងៗ) ធៀបនឹងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មក្នុងឆ្នាំ២០១៨ ដែលបានកត់ត្រាជាចំណាយថ្លៃដើមនៃសេវាកម្ម និងចំណាយរដ្ឋបាលទូទៅ។ ទោះជាយ៉ាងណា ក.ស.ភ. បានរៀបចំផែនការធនធានមនុស្សត្រឹមត្រូវតាមទំហំការងារ និងការរៀបចំប្រាក់បៀវត្សយោងតាមបរិមាណកុងតឺន័រឆ្លងកាត់(ធីអ៊ីយូ)ដែលជួយឲ្យការចំណាយលើបុគ្គលិកមិនមានការប៉ះពាល់ខ្លាំងលើប្រាក់ចំណេញ ។

### ខ.២.ចំណាយថ្លៃដងយោង

ចំណាយថ្លៃដើមនៃសេវាកម្មដ៏ធំមួយផ្នែកទៀតគឺចំណាយថ្លៃដងយោងដែលស្មើនឹង **៨,៣៨%** បើធៀបទៅនឹងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្ម ក្នុងឆ្នាំ២០១៨។ ក.ស.ភ. បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនជាដៃគូអាជីវកម្មចំនួនបី ក្នុងការប្រើប្រាស់ដងយោង សម្រាប់សេវាកម្មលើកដាក់លើស្ពានផែ។ យោងតាមកិច្ចសន្យាភាគរយនៃការបែងចែកប្រាក់ចំណូលទៅកាន់ក្រុមហ៊ុនជាដៃគូនៅត្រឹម ៨០% បន្ទាប់ពីការធ្វើប្រតិបត្តិការបានរយៈពេល៣ ទៅ ៤ឆ្នាំ។ ក.ស.ភ. រំពឹងថាចំណាយថ្លៃដងយោងនឹងបន្តកើនឡើង ព្រោះកំណើនបរិមាណទំនិញឆ្លងកាត់ត្រូវបានព្យាករណ៍ថាបន្តឡើងខ្ពស់ក្នុងពេលខាងមុខ។ យ៉ាងណាមិញការចំណាយនេះ គឺប៉ះពាល់ដល់ផលចំណេញតិចតួចប៉ុណ្ណោះ ពីព្រោះការកើនឡើងនៃបរិមាណកុងតឺន័របានធ្វើឲ្យចំណូលរបស់ក.ស.ភ.មានការកើនឡើងដូចគ្នា។ តារាងខាងក្រោមនេះបង្ហាញពីភាគរយនៃការបែងចែកប្រាក់ចំណូល៖

| ម្ចាស់ ដងយោង | ឈ្មោះ ដងយោង | ចំនួន | សមត្ថភាព (តោន) | ចំណែកប្រាក់ ចំណូលរបស់ ម្ចាស់ដងយោង | ចំណែកប្រាក់ ចំណូលរបស់ ក.ស.ភ. | កាលបរិច្ឆេទ កិច្ចសន្យា |
|---|---|---|---|---|---|---|
| Sovereign | ដងយោង បណ្តែតទី១ | ១ | ៨០ | ៨០% | ២០% | ០១/០២/២០១៦-៣១/០១/២០១៩ |

| ម្ចាស់ដងយោង | ឈ្មោះដងយោង | ចំនួន | សមត្ថភាព (តោន) | ចំណែកប្រាក់ចំណូលរបស់ម្ចាស់ដងយោង | ចំណែកប្រាក់ចំណូលរបស់ ក.ស.ភ. | កាលបរិច្ឆេទកិច្ចសន្យា |
|---|---|---|---|---|---|---|
| | ដងយោងបណ្តែតទី២ | ១ | ៦០ | ៨០% | ២០% | |
| Kamsab | ដងយោងចល័ត៨០T | ១ | ៨០ | ៩០% | ១០% | ១១/០៣/២០០៨-១០/០៣/២០០៩ |
| | | | | ៨៥% | ១៥% | ១១/០៣/២០០៩-១០/០៣/២០១០ |
| | | | | ៨០% | ២០% | *១១/០៣/២០១១ ដល់បច្ចុប្បន្ន* |
| | ដងយោងចល័តទី២ | ១ | ៤១ | ៩០% | ១០% | ០១/០៧/២០១៣-៣១/០៦/២០១៥ |
| | | | | ៨៥% | ១៥% | ០១/០៧/២០១៥-៣១/០៦/២០១៦ |
| | | | | ៨០% | ២០% | *០១/០៧/២០១៦-៣១/០៦/២០៣៣* |
| | ដងយោងចល័តទី៣ | ១ | ៤១ | ៩០% | ១០% | ០១/០៧/២០១៣-៣១/០៦/២០១៥ |
| | | | | ៨៥% | ១៥% | ០១/០៧/២០១៥-៣១/០៦/២០១៦ |
| | | | | ៨០% | ២០% | *០១/០៧/២០១៦-៣១/០៦/២០៣៣* |
| Sungkwang | ដងយោងចល័តទី១ | ១ | ៤១ | ៩០% | ១០% | ០១/០១/២០១៣-៣១/១២/២០១៣ |
| | | | | ៨៥% | ១៥% | ០១/០១/២០១៤-៣១/១២/២០១៤ |
| | | | | ៨០% | ២០% | *០១/០១/២០១៥-៣១/១២/២០២៤* |

### *គ.កាតព្វកិច្ចពន្ធផ្សេងៗ*

ក.ស.ភ.ស្ថិតក្រោមច្បាប់សហគ្រាសពាណិជ្ជកម្មពាក់ព័ន្ធនឹងបញ្ហាពន្ធដារ។ ក.ស.ភ. ស្ថិតនៅក្រោមរបបស្វ័យប្រកាស និងចាត់ទុកជាអ្នកជាប់ពន្ធធំចំពោះការបង់ពន្ធ។ ដូចនេះ ក.ស.ភ. មានកាតព្វកិច្ចបង់ពន្ធ និងអាករតាមការកំណត់នៃច្បាប់និងបទប្បញ្ញត្តិជាធរមាន។

#### គ.១. *ពន្ធលើប្រាក់ចំណេញ*

ក.ស.ភ. មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញក្នុងអត្រា២០% ដោយបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ១% នៃផលរបរប្រចាំខែ។ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ១% ប្រចាំខែនឹងត្រូវទូទាត់កាត់កងជាមួយពន្ធលើប្រាក់ចំណេញ ២០% នៃចុងឆ្នាំសារពើពន្ធនីមួយៗ។ ក.ស.ភ. ធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥។ យោងតាមអនុក្រឹត្យលេខ០១អនក្រ.បកចុះថ្ងៃទី៨ខែមករា ឆ្នាំ២០១៥ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រសហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិទទួលបានការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០% នៃពន្ធលើប្រាក់ចំណេញត្រូវបង់សម្រាប់រយៈពេល៣ឆ្នាំគិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។ ដូច្នេះក្រោយពីការអនុគ្រោះនេះត្រូវបានបញ្ចប់នោះ ក.ស.ភ. នឹងអនុវត្តកាតព្វកិច្ចពន្ធលើប្រាក់ចំណេញដូចធម្មតាវិញ។

#### គ.២. *អាករលើតម្លៃបន្ថែម*

ក.ស.ភ. ជាក្រុមហ៊ុនដែលចុះបញ្ជីអាករលើតម្លៃបន្ថែម។ ក.ស.ភ. បានគិតអាករលើតម្លៃបន្ថែមតាមអត្រា១០% នៃចំនួនទឹកប្រាក់លើវិក្កយបត្រពេលដែលចេញវិក្កយបត្រទៅអតិថិជន។ ក.ស.ភ. ជាភ្នាក់ងារប្រមូលពន្ធនេះជូនរាជរដ្ឋាភិបាលព្រោះនេះជាអាករលើធាតុចេញរបស់ក.ស.ភ.។ អាករលើធាតុ

ចេញនេះនឹងត្រូវកាត់កងជាមួយអាករលើផាគុចូល១០%នៅពេលដែលក.ស.ភ.បង់ប្រាក់ទៅអ្នកផ្គត់ផ្គង់សម្រាប់ការទិញ។

### គ.៣. *ពន្ធកាត់ទុកលើចំណូលការប្រាក់*

ក.ស.ភ.មានកាតព្វកិច្ចបង់ពន្ធកាត់ទុកលើចំណូលការប្រាក់តាមអត្រា ៤% លើបញ្ញើទូទៅនិង ៦% លើបញ្ញើមានកាលកំណត់។ បច្ចុប្បន្ន ក.ស.ភ.មានបញ្ញើមានកាលកំណត់នៅធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) និងធនាគារអេប៊ីអេ (ABA)។

### គ.៤. *ពន្ធនាំចូល*

ក.ស.ភ.មានកាតព្វកិច្ចបង់ពន្ធនាំចូលលើសម្ភារ និងវត្ថុធាតុដើមតាមអត្រាចន្លោះពី ៧% ទៅ ៣៥% អាស្រ័យលើប្រភេទទំនិញនីមួយៗដែលកំណត់ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ។ យោងតាមគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី២ នៅចំណតផែកុងតឺន័រ LM១៧ នៅឆ្នាំ២០១៨ ក.ស.ភ. នឹងគ្រោងនាំចូលគ្រឿងចក្រលើកដាក់កុងតឺន័រ ដូចនេះ ចំណាយលើពន្ធនាំចូលនឹងមានការកើនឡើង។

## ៣. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ ក.ស.ភ. រួមមានប្រាក់ចំណូលពីការលើកដាក់ក្រោមដងយោង (Stevedoring) ការលើកដាក់នៅទីលាន (LOLO) និងចំណូលកិច្ចការផែដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនកុងតឺន័រ ដែលស្មើប្រមាណ **៩៤%** ធៀបនឹងចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្ម ក្នុងឆ្នាំ២០១៨។ កត្តាសំខាន់នៃការកើនឡើងប្រាក់ចំណូល គឺបានមកពីកំណើនចំនួនកុងតឺន័រ ទំនិញរាយ នាវាឆ្លងកាត់ និងចំណុះនាវាស្របតាមការលូតលាស់ វិស័យសំណង់ វិស័យកសិកម្មវិស័យពាណិជ្ជកម្ម និងវិស័យឧស្សាហកម្មវាយនភណ្ឌ(សំលៀកបំពាក់និងស្បែកជើង)។ ជាមួយគ្នានេះដែរ ការដាក់ឱ្យដំណើរការនូវកំពង់ផែមេ **កៃម៉េប** ប្រទេសវៀតណាម ក៏ជាប្រភពនៃកំណើនបរិមាណកុងតឺន័រឆ្លងកាត់ក.ស.ភ.។ ជាក់ស្តែង ការដឹកជញ្ជូនឆ្លងកាត់ ក.ស.ភ. ទៅកាន់កំពង់ផែមេ **កៃម៉េប** មានការចំណេញពេលវេលាដោយដឹកជញ្ជូនទៅផ្ទាល់ទៅកាន់ប្រទេសក្នុងតំបន់ប៉ាស៊ីហ្វិកប៉ែកខាងកើត និងសហរដ្ឋអាមេរិកប៉ែកខាងលិច។

## ៤.ផលប៉ះពាល់នៃការប្តូររូបិយបណ្ណអត្រាការប្រាក់និងថ្លៃទំនិញ

### ក. *ផលប៉ះពាល់ពីអត្រាប្តូរប្រាក់*

ក.ស.ភ.បានកត់ត្រាបញ្ជីគណនេយ្យ ដោយប្រើប្រាស់រូបិយបណ្ណដុល្លារអាមេរិក ដោយសារចំណូលពីប្រតិបត្តិការអាជីវកម្ម និងសេវាកម្មភាគច្រើនជាប្រាក់ដុល្លារអាមេរិក និងការទូទាត់លើការងារជួសជុលគ្រឿងចក្រធំៗ ប្រេងឥន្ធនៈ និងចំណាយផ្សេងៗមួយចំនួនទៀត ក៏ជាប្រាក់ដុល្លារអាមេរិកដែរ លើកលែងតែការចំណាយលើប្រាក់បៀវត្ស និងការបង់ពន្ធ។ហេតុដូចនេះផលប៉ះពាល់ពីអត្រាប្តូរប្រាក់សម្រាប់ ក.ស.ភ.គឺមានកម្រិតអប្បបរមា។

### ខ. ផលប៉ះពាល់ពីអត្រាការប្រាក់

ក.ស.ភ.មិនបានកត់ត្រាបំណុលហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ថេរតាមតម្លៃទីផ្សារដោយសារភាពលំអៀង ត្រូវបានបញ្ចូលក្នុងរបាយការណ៍លចំណេញ ឬខាតនោះទេហើយ ក.ស.ភ. ក៏ពុំមានឧបករណ៍ហិរញ្ញវត្ថុដេរីវេទីវនាចុងការិយបរិច្ឆេទនេះដែរ។ដូច្នេះការផ្លាស់ប្តូរអត្រាការប្រាក់នាចុងការិយ-បរិច្ឆេទពុំមានផលប៉ះពាល់ដល់ប្រាក់ចំណេញ ឬខាតនោះទេ របស់ ក.ស.ភ.។

### គ. ផលប៉ះពាល់ពីការប្រែប្រួលតម្លៃប្រេងឥន្ធនៈ

ប្រតិបត្តិការរបស់ ក.ស.ភ. ពឹងផ្អែកយ៉ាងខ្លាំងទៅលើគ្រឿងចក្រ ដែលមានតម្រូវការប្រើប្រាស់ប្រេងឥន្ធនៈខ្ពស់។ ការប្រែប្រួលតម្លៃប្រេងឥន្ធនៈ នឹងប៉ះពាល់ដល់ថ្លៃដើមសេវាកម្ម។ អាស្រ័យហេតុនេះ ក.ស.ភ. បានពង្រឹងការគ្រប់គ្រងលើចំណាយប្រតិបត្តិការតាមរយៈការបង្កើនប្រសិទ្ធភាពការងារលើកដាក់ ការរៀបចំទីលានស្តុកកុងតឺន័រ ដែលអាចកាត់បន្ថយការលើកដាក់ និងការចល័តគ្រឿងចក្រច្រើនដែលមិនចាំបាច់។ ជាមួយគ្នានេះដែរ ក.ស.ភ. បានបំពាក់គ្រឿងចក្រទំនើបៗក្នុងការលើកដាក់ដែលប្រើប្រាស់ថាមពលអគ្គិសនីជំនួសវិញ។

## ៥.ផលប៉ះពាល់ពីអតិផរណា

កំណើននៃត្រាអតិផរណាអាចមានផលប៉ះពាល់ដល់ការចំណាយ និងការវិនិយោគរបស់ក្រុមហ៊ុន ព្រោះតម្លៃទំនិញមានការកើនឡើង ហើយអំណាចទិញបានថយចុះ។ ប៉ុន្តែ យោងតាមរបាយការណ៍របស់ធនាគារពិភពលោកកម្ពុជាមានអត្រាអតិផរណាជាមធ្យម ៣,៨% ពីឆ្នាំ២០១១ ដល់ ឆ្នាំ២០១៥ ដែលកម្រិតអតិផរណានេះ ពុំប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការ ក.ស.ភ. នោះទេ។

## ៦.គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

ក.ស.ភ.បាន និងកំពុងទទួលផលពីគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះរួមមាន ដូចខាងក្រោម៖

- គោលនយោបាយស្តីពីការជម្រុញការនាំចេញអង្ករ បាននិងកំពុងផ្តល់ផលវិជ្ជមានដល់កំណើន នៃការនាំចេញផលិតផលនេះតាមក.ស.ភ.
- គោលនយោបាយក្នុងការអនុគ្រោះពន្ធលើការនាំចូលឧបករណ៍/គ្រឿងចក្រកសិកម្មនាំឱ្យមានការវិនិយោគខ្លាំងលើវិស័យកសិកម្ម
- កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការស្វែងរកការអនុគ្រោះពន្ធនិងកូតា ពីប្រទេសជាដៃគូ បាននិងកំពុងជម្រុញឱ្យមានការនាំចេញខ្ពស់
- ការរៀបចំឱ្យមានតំបន់សេដ្ឋកិច្ចពិសេសនិងភណ្ឌាគារគយមានដែនកំណត់ បាននិងកំពុងទាក់ទាញឱ្យមានការវិនិយោគដោយផ្ទាល់ពីបរទេស

- គោលនយោបាយឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ បាននិងកំពុងទាក់ទាញវិនិយោគិនឱ្យមកវិនិយោគនៅប្រទេសកម្ពុជានិងការបង្កើតរោងចក្រធុនធ្ងន់ព្រមទាំងសហគ្រាសធុនតូច និងមធ្យម
- គោលនយោបាយរបស់រាជរដ្ឋាភិបាលជម្រុញការដឹកជញ្ជូនតាមផ្លូវទឹក
- ធនាគារជាតិនៃកម្ពុជា បាននិងកំពង់បន្តអនុវត្តគោលនយោបាយរូបិយវត្ថុតឹងរឹងនិងអត្រាប្តូរប្រាក់សេរីដែលមានការគ្រប់គ្រង។គោលនយោបាយនេះបាននិងកំពុងរួមចំណែកក្នុងការបង្កើនទំនុកចិត្តសាធារណៈក្នុងបរិស្ថានម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសកម្ពុជានិងជម្រុញការធ្វើអាជីវកម្មពីវិស័យឯកជន
- ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រដល់សហគ្រាសបោះផ្សាយលក់មូលបត្រនៅកម្ពុជា បាននិងកំពុងជម្រុញឱ្យក្រុមហ៊ុនឯកជន និងសហគ្រាសរដ្ឋចូលទីផ្សារមូលបត្រកាន់តែច្រើនដែលចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

# ផ្នែកទី ១០

# ស្ថិតិប្រចាំឆ្នាំសង្ខេបពី លទ្ធផលអាជីវកម្មរបស់ គ.ស.ត.

## ស្ថិតិនាវាដឹកទំនិញឆ្លងកាត់ ក.ស.ភ.

ឯកតា (គ្រឿង)

| ឆ្នាំ | ឆ្នាំ២០១៨ | ឆ្នាំ២០១៧ | ឆ្នាំ២០១៦ |
|---|---|---|---|
| នាវា.សាឡង់អន្តរជាតិ | ១.៣៩៨ | ១.០៨៣ | ១.០៧៥ |
| នាវាប្រេង | ៥៦៨ | ៥២២ | ៥០២ |
| នាវាកម្ពុជា | ៥៧ | ៧១ | ១០២ |
| សាឡង់កម្ពុជា | ០ | ០ | ០ |
| សរុប | ២.០២៣ | ១.៦៧៦ | ១.៦៧៩ |

## ស្ថិតិកុងតឺន័រឆ្លងកាត់ ក.ស.ភ.

ឯកតា (ធីអ៊ីយូ)

| ឆ្នាំ | | ឆ្នាំ២០១៨ | ឆ្នាំ២០១៧ | ឆ្នាំ២០១៦ |
|---|---|---|---|---|
| នាំចូល | គ្មានទំនិញ | ៤១.៩៣៥ | ៣២.៦១៤ | ២៥.៨៥២ |
| | មានទំនិញ | ៦០.៤២៤ | ៥៦.៨៩៥ | ៤៩.១២៣ |
| សរុបនាំចូល | | ១០២.៣៥៩ | ៨៩.៥០៩ | ៧៤.៩៧៥ |
| នាំចេញ | គ្មានទំនិញ | ១៩.៨៥៧ | ១៥.២០៧ | ១០.៦៥០ |
| | មានទំនិញ | ៩១.៣៥៥ | ៨០.០៨៩ | ៦៦.១៥៦ |
| សរុបនាំចេញ | | ១១១.២១២ | ៩៥.២៩៦ | ៧៦.៨០៦ |
| សរុប | | ២១៣.៥៧១ | ១៨៤.៨០៥ | ១៥១.៧៨១ |

## ស្ថិតិនាវាទេសចរណ៍អន្តរជាតិឆ្លងកាត់ ក.ស.ភ.

| ឆ្នាំ | | ឆ្នាំ២០១៨ | ឆ្នាំ២០១៧ | ឆ្នាំ២០១៦ |
|---|---|---|---|---|
| នាវាទេសចរណ៍អន្តរជាតិ | អ្នកដំណើរ(នាក់) | ៣១.៨៩០ | ២៦.៧១៥ | ២៥.២៤២ |
| | នាវា(ជើង ) | ៧៤៥ | ៦២៣ | ៥៩៧ |

# ផ្នែកទី ១១

# ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន

**សម្រាប់ឆ្នាំ២០១៨ ក. ស. ភ. មានព័ត៌មានចាំបាច់សម្រាប់ការពារវិនិយោគិនដូចខាងក្រោម៖**

- បានពិនិត្យ និងទទួលស្គាល់នូវរបាយការណ៍ស្ដីពីលទ្ធផលបឋមផ្នែកអាជីវកម្ម និងហិរញ្ញវត្ថុឆ្នាំ២០១៧ របស់ ក. ស. ភ.
- បានពិនិត្យ និងសម្រេចឱ្យ ក.ស.ភ. ធ្វើកិច្ចសហការជាមួយក្រុមហ៊ុន KTC International Co., Ltd. ក្រោមទម្រង់ជាការជួលអចលនទ្រព្យ និងគ្រឿងចក្រវិញ ជំនួសឱ្យការចូលទុនធ្វើអាជីវកម្មរួមគ្នា
- បានពិនិត្យ និងសម្រេចឱ្យក្រសួងសាធារណការ និងដឹកជញ្ជូន ខ្ចីថវិការបស់ ក.ស.ភ. ដើម្បីទិញកាណូតដឹកអ្នកដំណើរតាមផ្លូវទឹក Taxi Boat ចំនួន ២ គ្រឿង ហើយក្រសួងនឹងប្រគល់កាណូតទាំង ២ គ្រឿងនេះ ឱ្យនាយកដ្ឋានណាមួយ ឬអង្គភាពណាមួយក្រោមចំណុះក្រសួងជាអ្នកធ្វើប្រតិបត្តិការសេវាដឹកអ្នកដំណើរតាមផ្លូវទឹកនេះ។ ក្រសួងនឹងសងត្រឡប់ មកឱ្យ ក.ស.ភ. នូវថវិកាកម្ចីខាងលើ ជាក្រោយវិញ។
- បានពិនិត្យ និងសម្រេចឱ្យ ក.ស.ភ. បន្តធ្វើការសហការជាមួយក្រុមហ៊ុន ហ្គ្រីន ត្រេដ (Green Trade) លើការបង្កើតរោងចក្រកែច្នៃស្រូវ-អង្ករ នៅចំណតផែកុងតឺន័រ LM១៧
- បានពិនិត្យ និងអនុញ្ញាតជាគោលការណ៍ឱ្យ ក.ស.ភ. ស្នើសុំអាជ្ញាបណ្ណពីក្រសួងរ៉ែ និង ថាមពល មុននឹងចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU) ជាមួយក្រុមហ៊ុន Infunde Development Pte. Ltd. លើគម្រោងផ្គត់ផ្គង់ថាមពលអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ (Solar Power) នៅចំណតផែកុងតឺន័រ LM១៧។
- បានសម្រេចអនុម័តរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទ២០១៧ ដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ KPMG
- បានពិភាក្សា និងសម្រេចលើការកំណត់ប្រាក់ថ្លៃងសរសើរជូនថ្នាក់ដឹកនាំ និងនិយោជិត ក. ស.ភ. ប្រចាំឆ្នាំ២០១៧ ចំនួន ៣ ខែ នៃប្រាក់បៀវត្សសរុបជាមធ្យមប្រចាំឆ្នាំ និងការបែងចែកប្រាក់ចំណេញចូលមូលនិធិនានាសម្រាប់ឆ្នាំ២០១៧
- បានពិភាក្សា និងសម្រេចលើការបែងចែកភាគលាភជូនភាគហ៊ុនិករបស់ ក.ស.ភ. ប្រចាំឆ្នាំ២០១៧ និងការផ្ទេរចូលមូលនិធិអភិវឌ្ឍន៍សហគ្រាស ដូចខាងក្រោម៖

  **ក).** បែងចែកភាគលាភជូនភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ"ក" ចំនួន ៦% នៃថ្លៃ IPO ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

  - ប្រភេទភាគលាភដែលត្រូវបែងចែក (Type of Dividend): ជាសាច់ប្រាក់
  - រយៈពេលភាគលាភ (Period of dividend): ប្រចាំឆ្នាំ២០១៧
  - អនុបាត នៃការបែងចែកភាគលាភ (Dividend Payout Ratio ): ៥,៨៦%
  - ភាគលាភសរុបដែលត្រូវបែងចែក (Total Dividend): ១.២៧០.៨៤៧.៣៨៦ រៀល
  - ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (Dividend per Shear): ៣០៧ រៀល
  - កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគលាភដែលត្រូវទទួលបានភាគលាភ (Record Date): ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨

- ➢ កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ (Payment Date)៖ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨។

  **ខ)**.បែងចែកភាគលាភជូនភាគហ៊ុនិកប្រភេទ "ខ" (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ទឹកប្រាក់ចំនួន ២.២៤២.៧០៨ ពាន់រៀល (ពីរប៊ីលាន ពីររយសែសិបពីរលាន ប្រាំពីររយប្រាំបីពាន់រៀលគត់)។

  **គ)**.ផ្ទេរចូលក្នុងមូលនិធិអភិវឌ្ឍន៍សហគ្រាសចំនួន ៨២% ដែលមានទឹកប្រាក់ចំនួន ១៦.០០៦.១៩៧ ពាន់រៀល (ស្មើនឹង ៣.៩៥៧.០៣២ ដុល្លារអាមេរិក)។

- ❖ បានពិភាក្សា និងសម្រេចលើការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៣ ឆ្នាំ២០១៨ របស់ ក. ស. ភ. ដូចខាងក្រោម៖
  - ➢ កាលបរិច្ឆេទប្រារព្ធមហាសន្និបាតភាគហ៊ុនិកលើកទី៣: ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៨
  - ➢ កាលបរិច្ឆេទកំណត់ទុក (Record Date): ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨
  - ➢ ទីកន្លែងនៃមហាសន្និបាតភាគហ៊ុនិកលើកទី៣: សាលប្រជុំជាន់ទី៣ នៃអគាររដ្ឋបាលទីស្នាក់ការកណ្តាល (ចំណតផែថ្មTS៣) ដែលមានអាសយដ្ឋាន ស្ថិតនៅអគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
  - ➢ របៀបវារៈ នៃមហាសន្និបាតភាគហ៊ុនិកលើកទី៣ គឺរបាយការណ៍ស្តីពីលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងទិសដៅការងារអនុវត្តបន្តឆ្នាំ២០១៨។
- ❖ បានសម្រេចអនុម័តកិច្ចសន្យារវាង ក.ស.ភ. និងក្រុមហ៊ុន SYC CO., LTD. ស្តីពីការផ្តល់សេវាកម្មដឹកជញ្ជូន
- ❖ បានសម្រេចយល់ព្រមផ្ទេរសិទ្ធិឱ្យទៅអគ្គនាយករួមនឹងប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុចុះហត្ថលេខាបញ្ជាក់លើរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆ្នាំ ដោយអនុវត្តចាប់ពីឆ្នាំ២០១៨ នេះតទៅ
- ❖ បានសម្រេចអនុញ្ញាតឱ្យ ក.ស.ភ. ធ្វើលិខិតស្នើសុំការលើកលែងការពិន័យ និងកាតព្វកិច្ចផ្សេងៗទៅក្រសួងរ៉ែ និងថាមពល
- ❖ បានយល់ព្រមឱ្យ ក.ស.ភ. លើកគម្រោងបន្ថែមសម្រាប់សាងសង់ទីលានផ្ទុកកុងតឺន័រត្រជាក់បន្ថែមលើគម្រោងសាងសង់ទីលានជំហានទី២ នៅចំណតផែកុងតឺន័រ LM១៧ ដែលនឹងកំពុងដំណើរការសាងសង់ ដោយត្រូវអនុវត្តការងារតាមនីតិវិធីច្បាប់ជាធរមាន។
- ❖ បានពិនិត្យ និងសម្រេចអនុម័តរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្មរយៈពេល ៥ ខែ ដើមឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុរយៈពេល ៤ខែ ដើមឆ្នាំ២០១៨ របស់ ក.ស.ភ.
- ❖ បានពិនិត្យ និងសម្រេចឱ្យ ក. ស. ភ. ធ្វើការកែសម្រួលខ្លឹមសារនៃសេចក្តីព្រាងកិច្ចសន្យាស្តីពីការជួលដីរបស់កំពង់ផែស្វយ័តភ្នំពេញ ពីគល់ស្ពានជ្រោយចង្វារ មកដល់ផ្សាររាត្រីឱ្យទៅក្រុមហ៊ុនចៀន ឈឹង ថៃ គ្រុប រួចស្នើសុំការពិនិត្យ និងសម្រេចពីក្រសួងអាណាព្យាបាលទាំងពីរ
- ❖ បានពិនិត្យ និងសម្រេចទទួលស្គាល់ខ្ទង់ចំណាយរបស់ ក. ស. ភ. លើការផ្គត់ផ្គង់ប្រេង និងការថែទាំកាណូតដឹកអ្នកដំណើរតាមផ្លូវទឹក (Taxi Boat) និងសម្រេចឱ្យ ក.ស.ភ. ធ្វើរបាយការណ៍បូកសរុបចំណាយជូនទៅក្រសួងសាធារណការ និងដឹកជញ្ជូន នៅពេលមានការប្រគល់ទទួល

ពីក្រសួងសាធារណការ និងដឹកជញ្ជូន ឱ្យទៅរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីមានមូលដ្ឋានក្នុងការស្នើសុំការទូទាត់ត្រឡប់មក ក.ស.ភ. វិញ

- បានពិនិត្យ និងសម្រេចឱ្យ ក.ស.ភ. ឧបត្ថម្ភថវិកាចំនួន ១០០ លានរៀល ដល់ "មូលនិធិគន្ធៈបុប្ផាកម្ពុជា" សម្រាប់ឆ្នាំ២០១៨ និងបានអនុញ្ញាតជាគោលការណ៍ឱ្យ ក.ស.ភ. បន្តផ្តល់ការឧបត្ថម្ភគាំទ្រដល់មូលនិធិគន្ធៈបុប្ផាកម្ពុជា និងកាកបាទក្រហមកម្ពុជា នៅឆ្នាំបន្តបន្ទាប់ខាងមុខទៀត
- បានពិនិត្យ និងសម្រេចតែងតាំងលោកស្រី ជួន សុខេម ជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ ជំនួសលោក តោ នី ដែលបានចូលនិវត្ត
- បានពិនិត្យ និងសម្រេចឯកភាពឱ្យ ក.ស.ភ. ទិញដីបន្ថែម ចំនួន ២ ហិកតា សម្រាប់ត្រៀមបម្រុងក្នុងការពង្រីកហេដ្ឋារចនាសម្ព័ន្ធ នៃចំណតផែកុងតឺន័រ LM១៧ នៅថ្ងៃខាងមុខ ដោយត្រូវអនុវត្តតាមនីតិវិធីនៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- បានពិនិត្យ និងសម្រេចអនុញ្ញាតជាគោលការណ៍ឱ្យ ក.ស.ភ. ធ្វើការសិក្សាពីផលសេដ្ឋកិច្ច និងតម្លៃជួលដីឃ្លាំងក្រុមហ៊ុន ហ្គ្រីន ត្រេដ ទំហំ ៧.៥៤៣,៦៨ ម៉ែត្រក្រឡា ជាមុនសិន រួចដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចលើលទ្ធផលនៃការសិក្សានាពេលក្រោយ។
- បានពិនិត្យ និងសម្រេចអនុម័តរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម សម្រាប់រយៈពេល ៨ខែ ដើមឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុប៉ាន់ស្មាន (មិនទាន់ធ្វើសវនកម្ម) សម្រាប់រយៈពេល ៧ខែ ដើមឆ្នាំ២០១៨ របស់ ក.ស.ភ.
- បានពិនិត្យ និងសម្រេចឱ្យ ក.ស.ភ. ស្នើសុំការអនុញ្ញាតពីក្រសួងអាណាព្យាបាលទាំងពីរ (ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ដើម្បីលុបបំណុលសេវាវាស់ស្ទង់ដែលក្រសួងរ៉ែ និងថាមពល នៅជំពាក់ ក.ស.ភ. ចំនួន USD ៥៣.៥៨៨,១០ (ហាសិបបីពាន់ ប្រាំរយប៉ែតសិបប្រាំបីដុល្លារអាមេរិក និងដប់សេន)
- បានពិនិត្យ និងទទួលជ្រាបអំពីការធ្វើវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឱ្យទៅក្រុមហ៊ុន យុនណាន សេងមៅ អ៊ិនវេសម៉ិន (ខេមបូឌា) ឯ.ក លើទីតាំងដីទីលានស្តុកសំបកកុងតឺន័រ (ICD) ដែលបានជួលឱ្យក្រុមហ៊ុន ដើម្បីអភិវឌ្ឍជា "មជ្ឈមណ្ឌលពាណិជ្ជកម្ម Triumph កម្ពុជា" សម្រាប់ឱ្យក្រុមហ៊ុនប្រើប្រាស់ក្នុងគោលបំណងស្របតាមផ្លូវច្បាប់
- បានពិនិត្យ និងសម្រេចឱ្យ ក.ស.ភ. ៖
  - សម្របសម្រួលជាមួយជាមួយភាគីក្រុមហ៊ុន ចៀន ឈឹងថៃ គ្រុប ដោះស្រាយបញ្ហានានាដែលនៅសេសសល់
  - លើកសំណើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលយកសំណូមពរលើការស្នើសុំពន្យារពេលក្នុងការបង់ប្រាក់ឈ្នួលរបស់ក្រុមហ៊ុន ចៀន ឈឹងថៃ គ្រុប
  - ធ្វើរបាយការណ៍មួយជូនទៅក្រសួងអាណាព្យាបាលទាំងពីរ អំពីការដោះស្រាយផលប៉ះពាល់ពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍ "មជ្ឈមណ្ឌលពាណិជ្ជកម្មចំរុះ THE CITY GATE"

- បានពិនិត្យ និងសម្រេចឱ្យ ក.ស.ភ. លើកសំណើសុំធ្វើការរុះរើ ឬផ្លាស់ប្តូរទៅទីតាំងថ្មីនូវអគារ ឬឃ្លាំង នៅលើទីតាំងទាំង ៣ កន្លែង របស់ ក.ស.ភ. ដូចជានៅទីតាំងដី ICD, ចំណតផែកុងតឺន័រ LM១៧, នៅទីតាំងដី ក.ស.ភ. ពីគល់ស្ពានជ្រោយចង្វារ ដល់ផ្សាររាត្រី ជាកញ្ចប់ទៅក្រសួងអាណាព្យាបាលទាំងពីរ ដើម្បីស្នើសុំបង្កើតគណៈកម្មការចុះពិនិត្យ និងវាយតម្លៃសំណង់អគារ ឬឃ្លាំង ដែលមានក្នុងបញ្ជីសារពើភ័ណ្ឌរបស់ ក.ស.ភ. មុននឹងធ្វើការរុះរើ ឬវាយកំទេចចោល
- បានពិនិត្យ និងសម្រេចឱ្យ ក.ស.ភ. ស្នើសុំការបំភ្លឺពីមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ លើការគិតពន្ធប្រភេទផ្សេងៗ នៃកញ្ចប់ថវិកាដែលទទួលបានពីការជួលដីឱ្យទៅក្រុមហ៊ុន ចៀន ឈឹងថៃ គ្រុប មុននឹងមានវិធានការជាក្រោយ
- បានពិនិត្យ និងសម្រេចទុកការស្នើនូវភាគលាភពិសេសពីសំណាក់ភាគហ៊ុនិកឯកជន ស្ថិតនៅក្នុងការពិចារណាជាក្រោយទៀត ដោយរង់ចាំពិនិត្យមើលលទ្ធផលអាជីវកម្មនាបំណាច់ឆ្នាំ២០១៨ របស់ ក. ស. ភ. ក្រោយពីការបិទបញ្ជី និងធ្វើសវនកម្មរួចដោយសវនករឯករាជ្យ
- បានពិនិត្យ និងអនុញ្ញាតឱ្យ ក.ស.ភ. ពិនិត្យ និងចរចាអំពីតម្លៃជួលដីជាមួយក្រុមហ៊ុន ហ្គ្រីន ត្រេដ ឱ្យបានសមស្របដោយគោរពទៅតាមនីតិវិធី នៃបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ជាធរមានរួចលើកសំណើសុំការអនុញ្ញាតជួលទីតាំងដីខាងលើនេះ ពីក្រសួងអាណាព្យាបាលបច្ចេកទេស (ក្រសួងសាធារណការ និងដឹកជញ្ជូន) និងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។
- បានពិនិត្យ និងអនុម័តលើរបាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម សម្រាប់រយៈពេល ១១ខែ ដើមឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុ សម្រាប់រយៈពេល ១០ខែ ដើមឆ្នាំ២០១៨ របស់ ក.ស.ភ.
- បានពិនិត្យ និងអនុម័តផែនការអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ឆ្នាំ២០១៩ របស់ ក.ស.ភ.
- បានពិភាក្សា និងសម្រេចស្នើឱ្យ ក.ស.ភ. សហការជាមួយភាគីកូរ៉េ ធ្វើការសិក្សាលម្អិតបន្ថែមអំពីផលសេដ្ឋកិច្ច, Return on Investment សម្រាប់ ក.ស.ភ. ផ្ទាល់ និងអំពីរយៈពេលដែល ក.ស.ភ. អាចមានលទ្ធភាពទទួលបានផលចំណេញពីគម្រោងនេះត្រលប់មកវិញជាមុន មុននឹងធ្វើការពិចារណាលើការស្នើសុំឥណទានសម្បទានពីសាធារណរដ្ឋកូរ៉េ ជាក្រោយ ហើយស្នើឱ្យ ក.ស.ភ. ធ្វើលិខិតផ្លូវការមួយទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនដំណឹងទៅភាគីកូរ៉េអំពីការសម្រេចនេះ
- បានពិនិត្យ ពិភាក្សា និងឯកភាពលើតម្លៃជួលដីជាមួយក្រុមហ៊ុនហ្គ្រីន ត្រេដ ដើម្បីបង្កើតជាចំណតផែស្ងួត និងសម្រាប់ផ្តល់សេវាកម្មពាក់ព័ន្ធនឹងឡូជីស្ទីក ពាណិជ្ជកម្ម ឧស្សាហកម្ម និងទេសចរណ៍ និងស្នើឱ្យ ក.ស.ភ. លើកសំណើទាំងអស់នេះ ជូនក្រសួងអាណាព្យាបាលទាំងពីរ ដើម្បីសុំការសម្រេចយល់ព្រម
- បានពិនិត្យ និងពិភាក្សា និងឯកភាពសម្រេចលើការបោះឆ្នោតជ្រើសតាំង និងជ្រើសរើសសមាសភាពនៃក្រុមប្រឹក្សាភិបាល អាណត្តិទី៧ ដូចខាងក្រោម÷

- សម្រាប់អភិបាលជាតំណាងនិយោជិត, អភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ក.ស.ភ. នឹងរៀបចំការបោះឆ្នោតជ្រើសតាំងផ្អែកតាមបែបបទ និងនីតិវិធី ដែលបានកំណត់
- សម្រាប់អភិបាលផ្សេងទៀត តំណាងមកពីក្រសួងពាក់ព័ន្ធដូចជា ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និងក្រសួងពាណិជ្ជកម្ម ក. ស. ភ. នឹងស្នើទៅក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីគោរពស្នើសុំការសម្រេចពីរាជរដ្ឋាភិបាលលើការរក្សាទុកសមាសភាពដដែល ក្នុងអាណត្តិទី៧ នៃក្រុមប្រឹក្សាភិបាលរបស់ ក. ស. ភ.។
- ចំពោះការចូលកាន់ដំណែងរបស់សមាជិកនៃក្រុមប្រឹក្សាភិបាលអាណត្តិទី៧,កំណត់យកកាលបរិច្ឆេទនៃការតែងតាំងក្រុមប្រឹក្សាភិបាលអាណត្តិទី៧ ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល គឺជាពេលវេលានៃការចូលកាន់តំណែងរបស់សមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី៧ ដើម្បីបង្កលក្ខណ:ងាយស្រួល ក្នុងដំណើការរៀបចំការបោះឆ្នោតជ្រើសតាំង និងការរៀបចំស្នើតែងតាំងក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិបន្តបន្ទាប់ទៀត។

- បានពិនិត្យ និងសម្រេចអនុញ្ញាតឱ្យក្រុមហ៊ុន យុនណាន សេងមៅ អ៊ិនវេសមិ៊ន (ខេមបូឌា) ឯ.ក ប្តូរឈ្មោះគម្រោងពី "មជ្ឈមណ្ឌលផ្គត់ផ្គង់គ្រឿងសំណង់ CMSC" ទៅជា "មជ្ឈមណ្ឌលពាណិជ្ជកម្ម Triumph កម្ពុជា" វិញ ដោយ ក.ស.ភ. ត្រូវស្នើសុំការសម្រេចពីក្រសួងអាណាព្យាបាលទាំងពីរជាបន្តទៀត។

## ហត្ថលេខារបស់អភិបាលកំពង់ផែស្វយ័តភ្នំពេញ

ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០១៩
បានអាន និងឯកភាព

ហត្ថលេខា
**ហ៊ី បាវី**
ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក

ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០១៩
បានអាន និងឯកភាព

ហត្ថលេខា
**សួន រចនា**
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន

ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០១៩
បានអាន និងឯកភាព

ហត្ថលេខា
**កែន សម្បត្តិ**
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០១៩
បានអាន និងឯកភាព

ហត្ថលេខា
**ប៉ែន សុវិជាតិ**
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងក្រសួងពាណិជ្ជកម្ម

ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០១៩
បានអាន និងឯកភាព

ហត្ថលេខា
**ហ៊្វី អានវ៉ានិថ**
សមាជិកក្រុមប្រឹក្សាភិបាល
អភិបាលឯករាជ្យ

ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០១៩
បានអាន និងឯកភាព

ហត្ថលេខា
**ឱក សុចល**
សមាជិកក្រុមប្រឹក្សាភិបាល
អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន

ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០១៩
បានអាន និងឯកភាព

ហត្ថលេខា
**ដួន សុខេម**
សមាជិកក្រុមប្រឹក្សាភិបាល
តំណាងនិយោជិត ក. ស. ភ.




## អាសយដ្ឋាន / Address

១-ចំណតផែកុងតឺន័រ LM១៧
ភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល
Container Terminal LM17 : Kandal Leu Village, Bantey Dek Commune, Kien Svay District, Kandal Province.

២-ចំណតផែកុងតឺន័រ TS៣
#៦៤៩ តិរវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Container Terminal TS3 : #649, Street 1 (Preah Sisowath), Sangkat Sras Chork, Khan Daun Penh, Phnom Penh.

៣-ចំណតផែ អ្នកដំណើរ និងទេសចរ TS១
តិរវិថីព្រះស៊ីសុវត្ថិ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Passenger and Tourist Terminal TS1 : Street 1 (Preah Sisowath), Sangkat Wat Phnom, Khan Daun Penh, Phnom Penh.

៤-ចំណតផែទន្លេបិទ UM២
ភូមិទន្លេបិទ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ
Tonle Bet Port UM2 : Tonle Bet Village, Tonle Bet Commune, Thbong Khmoum District, Thbong Khmoum Province.

៥-មជ្ឈមណ្ឌលពាណិជ្ជកម្ម ត្រាយអ៊ុម
ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
Triumph Commercial Center : Phum Boeung Salang, Sangkat Rousseykeo, Khan Reusseykeo, Phnom Penh.

ទំនាក់ទំនង / Contact
Email : ppapmpwt@online.com.kh
Tel/Fax : +855 23 427 802
Website : www.ppap.com.kh

PHNOM PENH AUTONOMOUS PORT